- ការវិវត្តន៍ទៅជំងឺអេដស៍ (ដំណាក់កាល WHO ទី៤ ចំនួនកោសិកា CD4 <២០០កោសិកា/មម$^{៣}$) ជាមធ្យមមានរយៈពេល ១០ឆ្នាំ ក្រោយពីការឆ្លងមេរោគអេដស៍។ កត្តាដែលអាចជម្រុញឱ្យមានការវិវត្តន៍លឿន ទៅជំងឺអេដស៍ រួមមាន អាយុ <៥ឆ្នាំ ឬ >៤០ឆ្នាំ និងការបង្ករោគរួមគ្នាជាមួយជំងឺផ្សេងៗ ជាពិសេសជំងឺរបេង។

រូបភាពទី១ -២ ប្រវត្តិធម្មជាតិនៃការបង្ករោគដោយមេរោគអេដស៍[៣]




| កម្រិតនៃការថយចុះភាពស៊ាំ | ចំនួនកោសិកា CD4 |
|---|---|
| • គ្មានការថយចុះភាពស៊ាំ | > ៥០០កោសិកា/មម$^{៣}$ |
| • ថយចុះភាពស៊ាំមធ្យម | ៣៥០-៥០០ កោសិកា/មម$^{៣}$ |
| • ថយចុះភាពស៊ាំខ្លាំងក្លា | ២០០-៣៤៩ កោសិកា/មម$^{៣}$ |
| • ថយចុះភាពស៊ាំធ្ងន់ធ្ងរ | < ២០០ កោសិកា/មម$^{៣}$ |

## ១.៤ ការបង្ហាញរោគសញ្ញាគ្លីនិកបង្កដោយមេរោគអេដស៍

### ១.៤.១ រោគសញ្ញាគ្លីនិកនៃ បុគ្គលផ្ទុកមេរោគអេដស៍

អ្នកផ្ទុកមេរោគអេដស៍ អាចមកជួបគ្រូពេទ្យនៅគ្រប់ដំណាក់កាល តាំងពីពេល ដែលទើបឆ្លងមេរោគអេដស៍ដំបូង (ដំណាក់កាល seroconversion) រហូតដល់ដំណាក់កាលជំងឺអេដស៍ធ្ងន់ធ្ងរ។

[៣] ចតចម្លងពីគោលការណ៍ណែនាំគ្លីនិកនៃការបង្ករោគរួមគ្នារវាងជំងឺរបេង/អេដស៍. អង្គការគ្រូពេទ្យគ្មានព្រំដែន ២០១៥

១. ដំណាក់ឆ្លងមេរោគអេដស៍ដំបូង = ដំណាក់កាល Seroconversion។
២. ស្ថានភាពជំងឺទាក់ទងនឹងការឆ្លងមេរោគអេដស៍ពុំរ៉ៃដោយ *មិនបានធ្វើតេស្តឈាមរកមេរោគអេដស៍*
- ស្វែងរកចំណុចគន្លឹះ: ស្ថានភាពប្រជាសាស្ត្រ ស្ថានភាពគ្លីនិក ស្ថានភាពនៃការធ្វើតេស្តអមវេជ្ជសាស្ត្រ → ការធ្វើតេស្តឈាមរកមេរោគអេដស៍ ។

៣. រោគសញ្ញាកើតឡើង *ក្រោយពីបានធ្វើរោគវិនិច្ឆ័យថា ផ្ទុកមេរោគអេដស៍ ។*
៤. រោគសញ្ញា *មិនទាក់ទង* នឹងភាពមិនបានដឹង ឬបានដឹង ពីស្ថានភាពមេរោគអេដស៍ ។

### ១.៤.២ មូលហេតុនៃការបង្ហាញរោគសញ្ញាគ្លិនិក

១. ការថយចុះប្រព័ន្ធភាពស៊ាំ
- ការបង្ករោគ
- ការបង្ករោគដោយជំងឺឱកាសនិយម
- ជំងឺមហារីក (Malignancy)

២. ការប្រែប្រួលប្រព័ន្ធភាពស៊ាំ (Immune dis-regulation)
ឧ. ការថយចុះផ្លាកែតក្នុងឈាម (thrombocytopaenia) ជំងឺ inflammatory arthropathies ជំងឺ sjogrens syndrome។

៣. ផលប៉ះពាល់ដោយផ្ទាល់នៅពេលបង្ករោគដោយមេរោគអេដស៍
ឧ. HIV associated cognitive decline(HAND) ជំងឺតម្រងនោម (nephropathy) ជំងឺក្រពះ (gastropathy)។

៤. ការបង្ករោគរួមគ្នា
- ជំងឺរលាកថ្លើមប្រភេទ B, C និង ជំងឺរបេង។

៥. ផលប៉ះពាល់នៃការប្រើប្រាស់ឱសថ-ផលប៉ះពាល់នៃឱសថ/អន្តរកម្មឱសថ។
៦. ចង្កោមរោគសញ្ញានៃការស្តារប្រព័ន្ធភាពស៊ាំឡើងវិញ (IRIS)
- ការលេចចេញ(Unmasking) ឬ ប្រតិកម្ម paradoxical នៅពេលបង្ករោគដោយមេរោគអេដស៍

៧. ការវិវត្តន៍តាមវ័យអ្នកជំងឺ និងកើតមានជំងឺពុំរ៉ៃផ្សេងៗបង្កឡើងដោយមេរោគអេដស៍ និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ ឧ. ជំងឺបេះដូង (cardiovascular) ឬ ជំងឺតម្រងនោម (renal disease) ។

### ១.៤.៣ ការឆ្លងមេរោគអេដស៍នៅដំណាក់កាលដំបូង៖ រោគសញ្ញាគ្លិនិក

- ដំណាក់កាល seroconversion គឺគ្មានរោគសញ្ញា > ៥០% នៃអ្នកជំងឺ។
- ដំណាក់កាលឆ្លងមេរោគអេដស៍ ១០ –១៤ ថ្ងៃ ។
- ចង្កោមរោគសញ្ញាអាចប្រែប្រួលពី កម្រិតស្រាលទៅកម្រិតធ្ងន់ធ្ងរ គឺដូចគ្នានឹងការបង្ករោគដោយវីរុសផ្សេងទៀត។

- ពិនិត្យមើលកត្តាប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ មាន/គ្មាន ជំងឺកាមរោគ និងការតេស្ត ឈាមរកមេរោគអេដស៍ភ្លាមៗ។

## សញ្ញាណគ្លីនិក

- លេចចេញរោគសញ្ញាភ្លាមៗ រួមមាន គ្រុនក្តៅ ឈឺចាប់សាច់ដុំ ឈឺសន្លាក់ ឡើងកូនកណ្តុរ (lymphadenopathy) រលាកបំពង់ក ជំងឺសាច់ដុំ ស្នាមកន្ទួលលើស្បែកមានពណ៌ និងពងទឹក (maculopapular) ដំបៅមាត់ ចង្កោមរោគសញ្ញាក្រពះ និងពោះវៀន ឈឺក្បាល និងមានជំងឺ aseptic meningitis។
- ករណីកំរ: ជំងឺសរសៃប្រសាទ (neuropathies) និងចង្កោមរោគសញ្ញា Guillain–Barré ។
- Transient immunosuppression opportunistic → បង្ករោគ ឧ. ជំងឺផ្សិតបង្កដោយកង់ឌីដា ឬជំងឺ PJP។

## សញ្ញាណនៃតេស្តអមវេជ្ជសាស្ត្រ

- ថយចុះផ្លាកែតក្នុងឈាម (Thrombocytopenia) មាន leukopenia កើនឡើងអង់ហ្ស៊ីមថ្លើម។
- ធ្វើតេស្តអង់ទីករមេរោគអេដស៍ អាចនឹងអវិជ្ជមាន រហូតដល់៣សប្តាហ៍ ក្រោយពីបានឆ្លងមេរោគអេដស៍។
- ប្រសិនបើអង់ទីករមេរោគអេដស៍ អវិជ្ជមាន នៅពេលមានការបង្ករោគដោយមេរោគអេដស៍ → ១ខែក្រោយ ត្រូវធ្វើតេស្តមេរោគអេដស៍ម្តងទៀត ។

## ១.៤.៤ ការបង្ករោគដោយមេរោគអេដស៍ក្នុងដំណាក់កាលរ៉ាំរ៉ៃ៖ ស្ថានភាពសុខភាពអាស្រ័យតាមចំនួនកោសិកា CD4

- តារាងខាងក្រោមនឹងរៀបរាប់ពីស្ថានភាពសុខភាពអាស្រ័យតាមចំនួនកោសិកា CD4។
- សូមអានប្រព័ន្ធបែងចែកតាមលក្ខខណ្ឌគ្លីនិក និង តេស្តអមវេជ្ជសាស្ត្រពីដំណាក់កាលទី ១–៤ របស់ WHO។

ឧបសម្ព័ន្ធ៖ តារាងទី៥៤- ១ ប្រព័ន្ធចំណាត់ថ្នាក់ដំណាក់កាលគ្លីនិក នៃជំងឺអេដស៍សម្រាប់មនុស្សពេញវ័យ និងក្មេងជំទង់ ស្របតាម WHO (≥ ១៥ឆ្នាំ)។

**តារាងទី១ -២ ស្ថានភាពសុខភាពនៅពេលបង្ករោគដោយមេរោគអេដស៍ ផ្អែកតាមចំនួនកោសិកា *CD4*[៤]**

| ចំនួនកោសិកាCD4 | ស្ថានភាពសុខភាព |
|---|---|
| ទោះបីមានចំនួនកោសិកា CD4 ប៉ុន្មានក៏ដោយ | ហើមប៉ោងកូនកណ្តុរពេញខ្លួន ជាប់ជាប្រចាំ(PGL)<br>រីកក្រពេញប៉ារ៉ូទីត (Parotid gland enlargement)<br>ជំងឺរើម Herpes zoster (shingles)<br>ជំងឺរបេង<br>ជំងឺរលាកសួតដោយបាក់តេរី<br>ជំងឺ Cervical intraepithelial neoplasia (CIN)<br>ជំងឺកង់ឌីដានៅទ្វារមាស (Vulvo-vaginal candidiasis)<br>ជំងឺស្លេកស្លាំងរ៉ាំរ៉ៃ (Chronic anaemia)<br>ថយចុះចំនួនផ្លាកែតពាក់ព័ន្ធនឹងមេរោគអេដស៍ (HIV-related thrombocytopenia)<br>ជំងឺ Lymphocytic interstitial pneumonitis (LIP) (children) |
| <២០០កោសិកា/μL ប្រឈមមុខនឹងការបង្ករោគដោយជំងឺឱកាសនិយមធ្ងន់ធ្ងរ | ដុះផ្សិតក្នុងមាត់ (Oral candidiasis (thrush))<br>ដុះផ្សិតក្នុងបំពង់ក (Oesophageal candidiasis)<br>ជំងឺ Oral hairy leukoplakia (OHL)<br>ជំងឺ Pneumocystis jiroveci pneumonia (PCP)<br>ជំងឺ Cryptosporidiosis<br>ជំងឺ Lymphoma (non-CNS)<br>ជំងឺ Kaposi's sarcoma (KS)<br>ជំងឺ HIV-associated dementia (HAD) |
| <១០០ កោសិកា/μL | ជំងឺ Toxoplasmosis<br>ជំងឺរលាកស្រោមខួរបង្កដោយគ្រីបតូកុក្វ (Cryptococcal meningitis (CM))<br>ជំងឺភ្នែកបង្កដោយ Cytomegalovirus<br>ស្រកទម្ងន់ដោយគ្មានមូលហេតុ (Wasting syndrome)។ |
| < ៥០ កោសិកា/μL | ជំងឺ Non-tuberculosis mycobacterial (NTM)<br>ជំងឺ Lymphoma (CNS)<br>ជំងឺ Progressive multifocal leukoencephalopathy (PML)<br>ជំងឺ Cytomegalovirus (brain or disseminated) |

[៤]កែសម្រួលពីគោលការណ៍ណែនាំគ្លីនិកនៃការបង្ករោគរួមគ្នារវាងជំងឺរបេង/អេដស៍. អង្គការគ្រូពេទ្យគ្មានព្រំដែន ២០១៥

## ១.៥ ការធ្វើតេស្តឈាមរកមេរោគអេដស៍

នៅប្រទេសកម្ពុជា ការធ្វើតេស្តឈាមរកមេរោគអេដស៍នៅមណ្ឌលធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ (VCCT) ផ្តួចផ្តើមដោយអ្នកផ្តល់សេវាជាមន្ត្រីសុខាភិបាល (HPITC) ឬដោយសហគមន៍/មិត្តអប់រំមិត្ត(C/PITC សម្រាប់ក្រុមប្រជាជនចំណុច) ដោយប្រើប្រាស់តេស្តរហ័សចំនួនបី ស្របតាមគំនូសបំព្រួញស្តង់ដា [៥] ។

**ករណីសង្ស័យថា ផ្ទុកមេរោគអេដស៍**:

- ផ្តល់ព័ត៌មានជូនអតិថិជន អំពីសារៈសំខាន់នៃការធ្វើតេស្តឈាមរកមេរោគអេដស៍ ។
- បញ្ជូនអតិថិជនទៅសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ ។
- ផ្តល់ព័ត៌មានជូនអតិថិជន អំពី ផ្លូវចម្លងមេរោគអេដស៍ និងការប្រព្រឹត្តការរួមភេទប្រកបដោយសុវត្ថិភាព នៅពេលដែលគាត់ រង់ចាំលទ្ធផលតេស្តឈាមរកមេរោគអេដស៍ ។
- ចំពោះអ្នកជំងឺដែលបានធ្វើរោគវិនិច្ឆ័យថា ផ្ទុកមេរោគអេដស៍ត្រូវបញ្ជូន ទៅសេវាថែទាំ និងព្យាបាលជំងឺអេដស៍ និងចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ភ្លាមៗ ។

## ១.៦ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

- ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ARV ឬ ART) គឺសំដៅលើការព្យាបាលជំងឺអេដស៍ ហើយបច្ចុប្បន្នត្រូវបានផ្តល់ជាអនុសាសន៍ ឱ្យចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឱ្យបានឆាប់ ជូនអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ទាំងអស់ ដោយមិនគិតពីចំនួនកោសិកា CD4។

- ឱសថប្រឆាំងមេរោគអេដស៍ បែងចែកជាច្រើនក្រុម ហើយមានសកម្មភាពប្រឆាំងនឹងវដ្តជីវិតនៃមេរោគអេដស៍ នៅតាមដំណាក់កាលខុសៗគ្នា តាំងពីដំណាក់កាលនៃការភ្ជាប់ខ្លួនជាមួយកោសិកា និងដំណាក់កាលនៃការបំបែកខ្លួន ។ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍រួមបញ្ចូលគ្នា(cART) នឹងទប់ស្កាត់ភ្លាមៗនូវការបំបែកខ្លួនរបស់វីរុសអេដស៍ នាំឱ្យថយចុះយ៉ាងឆាប់រហ័សនូវចំនួនមេរោគអេដស៍ក្នុងឈាម (viral load នៃមេរោគអេដស៍ ឬ VL) ឱ្យស្ថិតនៅក្នុងកម្រិតកំណត់មួយដែលមិនអាចរកឃើញដោយតេស្ត viral load ។ ជាលទ្ធផល នាំឱ្យកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ទៅលើប្រព័ន្ធភាពស៊ាំ និងស្តារមុខងារប្រព័ន្ធភាពឡើងវិញបន្តិចម្តងៗ ដែលបញ្ជាក់ដោយមានចំនួនកោសិកា CD4 lymphocyte កើនឡើង ។ នៅពេលដែលមុខងារប្រព័ន្ធភាពស៊ាំត្រូវបានស្តារឡើងវិញ និងរក្សាបានក្នុងកម្រិតមួយ នាំឱ្យការប្រឈមមុខនឹងជំងឺឱកាសនិយមទាក់ទងនឹងជំងឺអេដស៍ និងអត្រាមរណៈភាពថយចុះ។
- ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ មិនអាចជាដាច់បានទេតែវាមានសកម្មភាពទប់ស្កាត់ការបំបែកខ្លួនរបស់មេរោគអេដស៍ តែមិនអាចបោសសំអាតមេរោគអេដស៍ឱ្យអស់បានទេ។ ប្រសិនបើបញ្ឈប់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ មេរោគអេដស៍នឹងបន្តការ

[៥] និយាមបែបបទអំពីការប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍, NCHADS ២០១២

បំបែកខ្លួនឡើងវិញ ដូចដែលបានឃើញពេលធ្វើតេស្ត VL ហើយចំនួនមេរោគអេដស៍នឹងត្រឡប់មកក្នុងកម្រិតដូចមុនពេលព្យាបាលឡើងវិញយ៉ាងឆាប់រហ័ស និងបំផ្លាញប្រព័ន្ធភាពស៊ាំជាថ្មីម្តងទៀត។

- ជាងនេះទៅទៀត ឱសថប្រឆាំងមេរោគអេដស៍រួមបញ្ចូលគ្នា ត្រូវបានគេជ្រើសយកមកព្យាបាលអ្នកជំងឺអេដស៍ គឺជាឱសថដែលបានបង្ហាញថា មានប្រសិទ្ធភាពក្នុងការបង្ការមេរោគអេដស៍ចំពោះបុគ្គលដែលមិនផ្ទុកមេរោគអេដស៍ ហើយគេអាចយកមកប្រើប្រាស់សម្រាប់ព្យាបាលបង្ការការឆ្លងមេរោគអេដស៍ ក្រោយពីប្រឈមមុខនឹងការឆ្លងមេរោគអេដស៍(PEP) ឬ ប្រើប្រាស់សម្រាប់ព្យាបាលបង្ការការឆ្លងមេរោគអេដស៍ មុនពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (សូមអានផ្នែកខាងក្រោម)។

## ១.៦.១ គោលបំណងនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

១. ផលប្រយោជន៍សុខភាពជាបុគ្គលចំពោះអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ គឺមានភាពប្រសើរឡើងនូវគុណភាពជីវិត និងអាយុកាលមធ្យម (life expectancy) ដោយសារៈ

- ទប់ស្កាត់ការបំបែកខ្លួនរបស់មេរោគអេដស៍ វាស់វែងដោយការធ្វើតេស្ត viral load
- ស្តារឡើងវិញ និងរក្សាមុខងារប្រព័ន្ធភាពស៊ាំ បញ្ជាក់ដោយ ការធ្វើតេស្តរាប់ចំនួនកោសិកា CD4 ។
- កាត់បន្ថយអត្រាឈឺនិងអត្រាមរណៈភាព បង្កដោយជំងឺឱកាសនិយម និងជំងឺផ្សេងទៀតទាក់ទងនឹងជំងឺអេដស៍។

២. កាត់បន្ថយការចម្លងមេរោគអេដស៍ ដោយការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដើម្បីបង្ការ(TasP) និងការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ និងការព្យាបាលបង្ការមុនពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (PEP និង PrEP) ចំពោះផលប្រយោជន៍ផ្នែកសុខភាពជាលក្ខណៈបុគ្គល និង ជាប្រជាជនទាំងមូលៈ

- បង្ការការចម្លងតាមផ្លូវភេទ
- បង្ការការចម្លងពីម្តាយទៅកូន(PMTCT)
- បង្ការការចម្លងតាមរយៈការចាក់គ្រឿងញៀន
- បង្ការការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍នៅពេលបំពេញការងារ (Occupational exposure)។

## ១.៦.២ គោលការណ៍នៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍រួមបញ្ចូលគ្នា

ការព្យាបាលដោយឱសថប្រឆាំងមេរោគអដស៍រួមបញ្ចូលគ្នា ត្រូវចេញវេជ្ជបញ្ជាឱ្យបានត្រឹមត្រូវ និងត្រូវលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ដើម្បីបង្ការភាពស៊ាំនៃមេរោគអេដស៍ជាមួយនឹងឱសថដែលនាំឱ្យរូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអដស៍ ទទួលបរាជ័យ។

- ឱសថប្រឆាំងមេរោគអេដស៍រួមបញ្ចូលគ្នា មានយ៉ាងតិច ឱសថប្រឆាំងមេរោគអេដស៍៣មុខ ដែលត្រូវចេញវេជ្ជបញ្ជា យ៉ាងតិចមានឱសថប្រឆាំងមេរោគអេដស៍ពីរក្រុមផ្សេងគ្នា។
- ត្រូវលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់។

ជាធម្មតាការបំបែកខ្លួនរបស់មេរោគអេដស៍ បណ្តាលមកពីការផ្លាស់ប្តូរខ្លាំងក្លានៃសេនេទិកនៃមេរោគអេដស៍ដោយឯកឯង (high rate of spontaneous genetic mutations)។ ប្រសិទ្ធភាពនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នឹងបញ្ឈប់ការបំបែកខ្លួន និងកាត់បន្ថយអត្រាផ្លាស់ប្តូរសេនេទិកនៃមេរោគអេដស៍។ ករណីដែលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ មិនសូវមានប្រសិទ្ធភាព(suboptimal) (ឧ. ប្រើប្រាស់រូបមន្តព្យាបាលរួមគ្នាមិនសមស្រប ឬលេបថ្នាំមិនបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ នាំឱ្យមេរោគអេដស៍នៅតែបន្តបំបែកខ្លួនក្នុងពេលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអដស៍) បណ្តាយឱ្យកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនមេរោគអេដស៍ដែលមានសេនេទិកស៊ាំនឹងឱសថប្រឆាំងមេរោគអេដស៍។ នៅពេលដែលមេរោគអេដស៍ស៊ាំជាមួយឱសថ នឹងមានចំនួនច្រើនលើសលុប នោះរូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នឹងលែងមានប្រសិទ្ធភាព។

វាមានសារៈសំខាន់ណាស់ ក្នុងការឆាប់រកឃើញ នូវការបរាជ័យផ្នែកវីរុសសាស្ត្រ ពីព្រោះ បើសិនជាមិនបានព្យាបាល វីរុសដែលស៊ាំជាមួយឱសថនឹងប្រមូលផ្តុំនូវសេនេទិកច្រើនទៀត (genetic mutations) នាំឱ្យមានភាពស៊ាំជាមួយនឹងឱសថប្រឆាំងមេរោគអេដស៍ផ្សេងទៀត បណ្តាលឱ្យ៖ ១) បន្ថយប្រសិទ្ធភាពនៃរូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី២ និង ២) វីរុសដែលស៊ាំអាចឆ្លងរាលដាលទៅមនុស្សផ្សេងទៀត។ ករណីដែល ការបរាជ័យវីរុសសាស្ត្រត្រូវបានរកឃើញទាន់ពេល នាំឱ្យការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដោយមានឱសថថ្មីយ៉ាងហោចណាស់ពីរមុខក្នុងរូបមន្តព្យាបាលជួរទី២ ជាទូទៅ នឹងកាត់បន្ថយចំនួនវីរុសក្នុងឈាម (VL) សាជាថ្មី។

### ១.៦.៣ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដើម្បីបង្ការ (TasP)

- ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដើម្បីបង្ការ(TasP) គឺសំដៅទៅលើការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍រួមបញ្ចូលគ្នា ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងមេរោគអេដស៍ទៅអ្នកដទៃ។ ការសិក្សាបានបង្ហាញថា អ្នកជំងឺអេដស៍ដែលតេស្ត VL រកមេរោគអេដស៍មិនឃើញ(undetectbale VL)នៅក្នុងឈាម គឺមានកម្រិតចម្លងទាបបំផុតទៅអ្នកដទៃ ដូចជា ដៃគូរួមភេទរបស់គាត់ និងបុរសរួមភេទជាមួយបុរស។

- មគ្គុសទ្ទេសន៍នៃការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន(PMTCT protocols)គឺអាស្រ័យលើប្រសិទ្ធភាពនៃការអនុវត្តន៍ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដើម្បីបង្ការក្នុងគោលបំណងសម្រេចឱ្យបាននូវការលប់បំបាត់មេរោគអេដស៍ក្នុងឈាម តាមរយៈតេស្ត VL រកមិនឃើញមេរោគអេដស៍ (undetectable VL) ចំពោះស្ត្រីមានផ្ទៃពោះ។

- ពាក្យ TasP ត្រូវបានគេយកមកប្រើប្រាស់សម្រាប់ធ្វើការតស៊ូមតិ ក្នុងការផ្តល់ការព្យាបាលលើក្រុមប្រជាជនមួយចំនួន ដើម្បីបង្ការការឆ្លងរាលដាលនៃមេរោគអេដស៍ ក្នុងពេលដែលគេមិនទាន់ដឹងច្បាស់ថា ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បានផ្តល់ផលប្រយោជន៍លើសុខភាពផ្លូវកាយ ដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍។ ដោយហេតុផលថា ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បានផ្តល់ផលប្រយោជន៍លើសុខភាពផ្លូវកាយ ដល់អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ គេនឹងផ្តល់ការព្យាបាលនេះ លើអ្នកផ្ទុកមេរោគអេដស៍ និង អ្នកជំងឺអេដស៍ទាំងអស់ ដោយមិនគិតពីចំនួនកោសិកា CD4។

### ១.៦.៤ ការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (PEP)

- ការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍(PEP) គឺជាការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ក្នុងរយៈពេលកំណត់មួយ បន្ទាប់ពីមានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ តាមរយៈការប្រព្រឹត្តផ្លូវភេទប្រកបដោយគ្រោះថ្នាក់ និងការចម្លងពីម្តាយទៅកូន។ ត្រូវបន្តការព្យាបាលរយៈពេលមួយខែ ក្រោយពេលមានគ្រោះថ្នាក់ ហើយត្រូវធ្វើតេស្តឈាមរកអង់ទីករមេរោគអេដស៍នៅខែទី៣/ខែទី១២។

- នៅពេលមិនទាន់មានការសិក្សាតាមបែប randomized controlled trial ការសិក្សាតាមបែបអង្កេត(observational studies) បានគាំទ្រប្រសិទ្ធភាពនៃការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ដោយកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍ ទាំងក្នុងចំណោមក្រុមដែលបំពេញការងារប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ និងក្រុមដែលគ្មានការងារប្រឈមមុខនឹងការឆ្លងមេរោគអេដស៍(occupational and non-occupational exposures) ។

- វិធីសារ PMTCT ក៏បានយកគោលការណ៍នៃការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍មកប្រើប្រាស់ សម្រាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។
- ចំពោះការគ្រប់គ្រងការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ សូមអានជំពូក៨៣. ការព្យាបាលបង្ការក្រោយពេលមានគ្រោះថ្នាក់នៃការឆ្ល មេរោគអេដស៍ (PEP) ។

### ១.៦.៥ ការព្យាបាលបង្ការមុនពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (PrEP)

- ការព្យាបាលបង្ការមុនពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍(PrEP) គឺជាការព្យាបាលដោយ ឱសថប្រឆាំងមេរោគអេដស៍ ចំពោះបុគ្គលដែលមិនផ្ទុកមេរោគអេដស៍ មុនពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ដើម្បីទប់ស្កាត់ការឆ្លងមេរោគអេដស៍។

- បច្ចុប្បន្ននេះ ការព្យាបាលបង្ការមុនពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ត្រូវបានផ្តល់អនុសាសន៍ដោយអង្គការ WHO ជាជម្រើសមួយសម្រាប់បង្ការការឆ្លងមេរោគអេដស៍បន្ថែម ចំពោះក្រុមប្រជាជនប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ខ្ពស់ (> ៣% នៃអាំងស៊ីដង់)[៦] ។

- ការព្យាបាលបង្ការមុនពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ត្រូវអនុវត្តរួមគ្នាជាមួយនឹង កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ជ្រុងជ្រោយ ក្នុងការកាត់បន្ថយហានិភ័យ (harm reduction) រួមមាន ការធ្វើតេស្តឈាមរកមេរោគអេដស៍នៅពេលដើមគ្រានិងការធ្វើតេស្តឈាមរកមេរោគអេដស៍ ជាទៀងទាត់ ការតាមដានការពុលឱសថ និងការគ្រប់គ្រងការបង្ករោគរួមគ្នាជាមួយជំងឺរលាកថ្លើមប្រភេទB និងការធ្វើតេស្តនៃការមានផ្ទៃពោះ។ល។

- អង្គការ WHO នឹងបោះពុម្ពការគោលការណ៍ណែនាំសម្រាប់អនុវត្តគ្រប់ជ្រុងជ្រោយនៃការព្យាបាលបង្ការមុនពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ នៅឆ្នាំ២០១៦។

### ១.៦.៦ ឱសថប្រឆាំងមេរោគអេដស៍ដែលមាននៅប្រទេសកម្ពុជា[៧]

១. ក្រុម Nucleoside Reverse Transcriptase Inhibitors (NRTI)
- Tenofovir (TDF)
- Zidovudine (AZT or ZDV)
- Lamivudine (3TC)
- Abacavir (ABC)
- (Didanosine (ddI) និង Stavudine (d4T) ដែលកំពុងតែឈានទៅបញ្ឈប់ការប្រើប្រាស់ទាំងស្រុង)។

២. ក្រុម Non-Nucleoside Reverse Transcriptase Inhibitors (NNRTI)
- Efavirenz (EFV)
- Nevirapine (NVP)

៣. ក្រុម Protease Inhibitors (PI)
- Atazanavir combined with low dose Ritonavir (ATV/r)
- Lopinavir combined with low dose Ritonavir (LPV/r)

ឱសថប្រឆាំងមេរោគអេដស៍ភាគច្រើន គឺជាឱសថដែលមានកម្រិតដូសរួមបញ្ចូលគ្នា (fixed dose combinations) ពី២ ឬ៣មុខ (ឧ. TDF + 3TC+ EFV ឬ AZT + 3TC) ដើម្បីកាត់បន្ថយចំនួនគ្រាប់ថ្នាំ

[៦] គោលការណ៍ណែនាំ អំពីការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងការព្យាបាលបង្ការមុនពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍. WHO កញ្ញា ២០១៥

[៧] ឱសថដែលធ្វើលទ្ធកម្មសម្រាប់កម្មវិធីព្យាបាលជំងឺអេដស៍នៅកម្ពុជា ត្រូវបានផលិតដោយរោងចក្រទទួលស្គាល់តាមស្តង់ដារ របស់អង្គការសុខភាពពិភពលោក។

ដែលអ្នកជំងឺត្រូវលេបនិងបង្កើនជាអតិបរិមានូវការលេបឱសថឱ្យបានត្រឹមត្រូវទៀងទាត់ និងជាប់លាប់។

គេសង្ឃឹមថា នឹងមានឱសថប្រឆាំងមេរោគអេដស៍ថ្មីៗទៀតដូចជាPI(Darunavir, NNRTI Etravirine) និងឱសថក្នុងក្រុម Integrase inhibitor class agents ដូចជា Dolutegravir Raltegravir អាចនឹងដាក់ឱ្យប្រើប្រាស់នៅប្រទេសកម្ពុជា ក្នុងរូបមន្តព្យាបាលជួរទី១ និងជួរទី២។ ចំពោះអ្នកជំងឺដែលបរាជ័យវីរុសសាស្ត្រ(virological failure) ក្រោយពីទទួលការព្យាបាលដោយឱសថប្រឆាំង មេរោគអេដស៍រួមបញ្ចូលគ្នា អាចនឹងព្យាបាលដោយឱសថ salvage ឬ រូបមន្តព្យាបាលជួរទី៣។

# ការផ្តល់សេវាថែទាំ និងព្យាបាល
# អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

# ជំពូក ២. កម្មវិធីពិគ្រោះជំងឺជាប្រចាំ ជាមួយគ្រូពេទ្យព្យាបាល

## ២.១ កម្មវត្ថុនៃការមកពិគ្រោះជំងឺឱ្យបានឆាប់បំផុត

- ធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺឱកាសនិយម ឬ ជំងឺផ្សេងទៀតដែលកំពុងកើតមាន ។
- ពិនិត្យស្រាវជ្រាវរកជំងឺរបេង**រាល់ពេលមកពិនិត្យពិគ្រោះជំងឺ** និងបញ្ជូនទៅរករោគវិនិច្ឆ័យបន្ថែមទៀត ដោយថតសួតដោយកាំរស្មី x ឬចាប់ផ្តើមព្យាបាលបង្ការដោយ IPT ។
- ចាប់ផ្តើមព្យាបាលបង្ការជំងឺឱកាសនិយម ប្រសិនជាចាំបាច់ ។
- ផ្តល់ព័ត៌មានជូនអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ អំពីការបង្ការការឆ្លងរាលដាលនៃមេរោគអេដស៍ និងត្រៀមខ្លួនក្នុងការគ្រប់គ្រង និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍មួយជីវិត។
- ផ្តល់ព័ត៌មាន និងការគាំទ្រផ្នែកវេជ្ជសាស្ត្រ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខភាពទូទៅ។
- ឱ្យអ្នកជំងឺត្រៀមខ្លួន ដើម្បីចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។

## ២.២ កម្មវត្ថុនៃការពិគ្រោះជំងឺ ក្រោយពេលអ្នកជំងឺបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

- ធានាអ្នកជំងឺលេបថ្នាំ ឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ។
- ចៀសវាង និងគ្រប់គ្រងការពុលឱសថប្រឆាំងមេរោគអេដស៍ ។
- គ្រប់គ្រង និងព្យាបាលការបង្ការរោគរួមគ្នា ។
- បង្ការ និងគ្រប់គ្រងជំងឺមិនឆ្លងដែលមានអត្រាប្រេវ៉ាឡង់កើនឡើង ក្រោយពេលព្យាបាល ដោយឱសថប្រឆាំងមេរោគអេដស៍យូរអង្វែង លើអ្នកជំងឺមានវ័យច្រើន ។

រូបភាពទី ២-១ ការវិវត្តន៍គ្លីនិកនៃមេរោគអេដស៍




## ២.៣ ពេលវេលានៃការធ្វើតេស្តអមវេជ្ជសាស្ត្រ នៅពេលមកពិគ្រោះជំងឺ

- ការធ្វើតេស្តអមវេជ្ជសាស្ត្រ *ត្រូវធ្វើក្នុងថ្ងៃតែមួយ* ពេលដែលអ្នកជំងឺមកពិគ្រោះជំងឺ។
- គ្រូពេទ្យព្យាបាល ត្រូវដឹងពីកាលបរិច្ឆេទនៃការធ្វើតេស្ត VL ឬ CD4 លើកក្រោយ និងណាត់ជួបអ្នកជំងឺលើកក្រោយឱ្យត្រូវថ្ងៃដែលត្រូវធ្វើតេស្តអមវេជ្ជសាស្ត្រ ។
- ការធ្វើតេស្តអមវេជ្ជសាស្ត្រ អាចធ្វើបានក្នុងកំឡុងពេលមួយខែ នៃកាលបរិច្ឆេទដែលត្រូវធ្វើតេស្ត ។ បើសិនជា កាលបរិច្ឆេទនៃការធ្វើតេស្តអមវេជ្ជសាស្ត្រត្រូវធ្វើគឺ $_xY_z$ (ឧ. $_៥$៦$_៧$ គេកំណត់ថា ផែនការនៃធ្វើតេស្តអមវេជ្ជសាស្ត្រគឺរាល់៦ខែម្តង គេអាចធ្វើតេស្តអមវេជ្ជសាស្ត្រនៅពេលអ្នកជំងឺមកពិគ្រោះជំងឺនៅពេលណាក៏បាន ក្នុងចន្លោះពី ខែ ៥ និងខែ៧) ។
- បើសិន អ្នកជំងឺខកខានមិនបានធ្វើតេស្តរាប់ចំនួនកោសិកា CD4 ឬ VL តាមកាលវិភាគដែលបានកំណត់ គេត្រូវធ្វើតេស្តទាំងពីរនេះ ឱ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបាន ។

កាលវិភាគខាងក្រោម គឺកាលវិភាគដែលអ្នកជំងឺត្រូវមកពិគ្រោះជំងឺជាប្រចាំ ការធ្វើតេស្តអមវេជ្ជសាស្ត្រ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ការធ្វើតេស្តអមវេជ្ជសាស្ត្រ និងការព្យាបាលបង្ការជំងឺឱកាសនិយម ។ អាស្រ័យទៅតាមស្ថានភាពអ្នកជំងឺម្នាក់ៗ អាចនឹងត្រូវមានការមកពិគ្រោះជំងឺ ឬ ការធ្វើតេស្តអមវេជ្ជសាស្ត្រ ញឹកញាប់ជាងនេះ។

➢ **ការបំពេញទំរង់នៃការមកពិគ្រោះជំងឺ** ដែលអាចប្រើប្រាស់ជា បញ្ជីផ្ទៀងផ្ទាត់ (checklists) ជាជំហានៗសម្រាប់វាយតម្លៃការគ្រប់គ្រង និងព្យាបាលជំងឺ។ ត្រូវបំពេញជំហាននិមួយៗដោយយកចិត្តទុកដាក់ហើយត្រូវចងចាំថាព័ត៌មានដែលបានបញ្ចូលក្នុងឃ្លាំងផ្ទុកទិន្នន័យថ្នាក់ជាតិ (National database) គឺប្រើប្រាស់សម្រាប់តែកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍តែប៉ុណ្ណោះ ។

ទាក់ទងនឹងការវាយតម្លៃគ្លីនិក សូមអានផ្នែកឧបសម្ព័ន្ធ៤៥: ការណែនាំ អំពីការពិគ្រោះជំងឺ ។

**តារាងទី ២-១ កម្មវិធីមកពិគ្រោះជំងឺជាប្រចាំ**

| សប្តាហ៍ | សញ្ញាគ្លីនិក | ផ្តល់ប្រឹក្សាអំពី Adherence | ធ្វើតេស្តអមវេជ្ជសាស្ត្រ | ចាប់ផ្តើម/ការបញ្ឈប់ប្រើប្រាស់ឱសថ |
|---|---|---|---|---|
| សប្តាហ៍ទី 0 | ✔ | ✔ | ✔ | ចាប់ផ្តើមព្យាបាលដោយ Cotrimoxazole |
| សប្តាហ៍ទី ១ | | ✔ | | |
| សប្តាហ៍ទី ២ | ✔ | ✔ | | ចាប់ផ្តើមព្យាបាល ART បញ្ឈប់ការព្យាបាលដោយ Cotrimoxazole បើ CD4 > ៣៥០ និងគ្មានជំងឺរបេង |
| ក្រោយពេលចាប់ផ្តើមព្យាបាល ART | | | | |
| សប្តាហ៍ទី ២ | ✔ | ✔ | | ចាប់ផ្តើមព្យាបាល IPT |
| ខែទី១ | ✔ | ✔ | ✔ | |
| ជារៀងរាល់ខែនៅពេលព្យាបាល IPT | ✔ | ✔ | ✔VL រៀងរាល់ខែ ៥៦៧ | បញ្ឈប់ការព្យាបាល IPT ក្រោយរយៈពេល៦ខែ |
| ក្រោយពេលបញ្ឈប់ព្យាបាលដោយIPT បន្តការព្យាបាលដោយ Cotrimoxazole | | | | |
| រៀងរាល់១ – ៣ ខែម្តង (អាស្រ័យស្ថានភាពរោគសញ្ញាគ្លីនិក និងការលេបថ្នាំបានត្រឹមត្រូវ ទៀងទាត់និងជាប់លាប់)។ | ✔ | ✔ | ✔VL រៀងរាល់ខែ ៥៦៧ បន្ទាប់មកនៅ ខែ១១ ខែ១២១៣, ខែ ២៣២៤២៥ ខែ៣៥៣៦៣៧ ។ល។<br><br>✔CD4 រៀងរាល់ខែ ៥៦៧ | បញ្ឈប់ការព្យាបាលដោយឱសថ Cotrimoxazole ស្របតាមលក្ខណៈវិនិច្ឆ័យក្នុង តារាងទី ២.៤ ការព្យាបាលបង្ការជំងឺឱកាសនិយមជាបឋម<br><br>បញ្ឈប់ការតាមដានដោយធ្វើតេស្ត CD4 ស្របតាម លក្ខណៈវិនិច្ឆ័យនៅក្នុងជំពូក ១១. តាមដានការឆ្លើយតបទៅនឹង ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ |
| ក្រោយពេលបញ្ឈប់ការព្យាបាលដោយCotrimoxazole និងការតាមដោយធ្វើតេស្តរាប់ចំនួនកោសិកា CD4 | | | | |
| រៀងរាល់១ – ៣ ខែម្តង | ✔ | ✔ | ✔VL រៀងរាល់ខែ ១១១២១៣ | |

តារាងទី ២-២ លក្ខណៈវិនិច្ឆ័យនៃការស្រាវជ្រាវរោគសញ្ញាគ្លីនិកដែលសង្ស័យថា ជំងឺរបេង ចំពោះអ្នកផ្ទុកមេរោគអេដស៍និង អ្នកជំងឺមេរោគអេដស៍រៀងរាល់ពេលមកពិគ្រោះជំងឺ

| កាលពី៤សប្តាហ៍មុន សួរអ្នកជំងឺថា តើគាត់មានរោគសញ្ញាគ្លីនិកណាខ្លះដូចខាងក្រោម? |
|---|
| 1. ក្អក: គ្រប់ពេល ជួនយូរ ជួនឆាប់ (any time, any duration) |
| 2. គ្រុនក្តៅ: គ្រប់ពេល ជួនយូរ ជួនឆាប់ (any time, any duration) |
| 3. បែកញើសពេលយប់: រយៈពេល ≥ ២ សប្តាហ៍ |
| 4. ស្រកទម្ងន់ និង ត្រូវថ្លឹងទំងន់អ្នកជំងឺរៀងរាល់ពេលមកពិគ្រោះជំងឺ និងប្រៀបធៀបជាមួយនឹងទម្ងន់គាត់ដែលបានថ្លឹងកាលពីគាត់មកពិគ្រោះជំងឺលើកមុន។ |

តារាងទី ២-៣ ការធ្វើតេស្តអមវេជ្ជសាស្ត្រជាប្រចាំ

| ការធ្វើតេស្តអមវេជ្ជសាស្ត្រ | សេវា Pre ART | ការតាមដានចំពោះអ្នកជំងឺព្យាបាលដោយឱសថជួរទី១ | ការព្យាបាលបរាជ័យ | ការតាមដានចំពោះអ្នកជំងឺព្យាបាលដោយឱសថជួរទី២ |
|---|---|---|---|---|
| HIV Ab | ✔ | | | |
| រាប់ចំនួនកោសិកា CD4 | ✔ មិនចាំបាច់រង់ចាំលទ្ធផលតេស្តមុននឹងចាប់ផ្តើមព្យាបាល ART ទេ។ | ✔ ធ្វើតេស្តCD4 រៀងរាល់៦ខែម្តង បើកំពុងព្យាបាលបង្ការជំងឺឱកាសនិយម និង/ឬ ករណី តេស្ត VL មិនបានធ្វើជាប្រចាំ។<br><br>**បញ្ឈប់ការធ្វើតេស្ត CD4** ជាប្រចាំ ពេលឈប់ព្យាបាលបង្ការជំងឺឱកាសនិយម និងបានបំពេញលក្ខណៈវិនិច្ឆ័យក្នុង ជំពូកទី១១. តាមដានការឆ្លើយតបទៅនឹងការព្យាបាលដោយឱសថ | ✔ បើមានជំងឺឱកាសនិយមថ្មី រួមទាំង ជំងឺរបេង។<br><br>✔tនៅពេលប្តូរទៅរូបមន្តព្យាបាលជួរទី២ ។ | ✔ធ្វើតេស្តCD4 រៀងរាល់៦ខែម្តង បើកំពុងព្យាបាលបង្ការជំងឺឱកាសនិយម និង/ឬ ករណី តេស្ត VL មិនបានធ្វើជាប្រចាំ។<br><br>**បញ្ឈប់ការធ្វើតេស្ត CD4** ជាប្រចាំ ពេលឈប់ព្យាបាលបង្ការជំងឺឱកាសនិយម និងបានបំពេញលក្ខណៈវិនិច្ឆ័យក្នុង ជំពូក ១១. តាមដានការឆ្លើយតទៅនឹងការព្យាបាលដោយឱសថ |

| | | | | |
|---|---|---|---|---|
| | | ប្រឆាំងមេរោគអេដស៍ | | ប្រឆាំងមេរោគអេដស៍ |
| តេស្ត Viral Load | **មិនបាច់ធ្វើទេ** | ✔ខែទី៦, ខែទី១២, ខែទី២៤, ខែទី៣៦ ។ល។ | ✔ ធ្វើតេស្ត VL ដើម្បីបញ្ជាក់សម្រាប់ "targeted" តាមដាន។ | ✔ខែទី៦, ខែទី១២, ខែទី២៤, ខែទី៣៦ ។ល។ |
| AST/ALT | ✔ | ✔ខែទី១, ខែទី៣ | ✔ | ✔ខែទី១, ខែទី៣ |
| Hb | ✔ បើមានគំរោងប្រើ AZT | ✔ បើប្រើ AZT, ត្រូវធ្វើតេស្តនៅខែទី១, ខែទី៣ បន្ទាប់រៀងរាល់៦ខែម្តង | ✔បើមានគំរោងប្រើ AZT | ✔If on AZT, ត្រូវធ្វើតេស្តនៅខែទី១, ខែទី៣ បន្ទាប់រៀងរាល់៦ខែម្តង |
| Urine dipstick<br>Serum creatinine, (calculate eGFR) | ✔ | ✔<br>✔<br>បើប្រើ TDF ត្រូវធ្វើតេស្តនៅខែទី១, ខែទី៣ បន្ទាប់រៀងរាល់១២ខែម្តង | ✔ | ✔<br>✔<br>បើប្រើ TDF ត្រូវធ្វើតេស្តនៅខែទី១, ខែទី៣ បន្ទាប់រៀងរាល់១២ខែម្តង<br>បើមិនប្រើ TDF រៀងរាល់១២ខែម្តង |
| HBs Ag | ✔ បើ ↑ ALT<br>✔ បើត្រូវពិចារណារមិនទាន់ចាប់ផ្តើមប្រើ TDF។ | | ✔ បើមិនដឹងត្រូវពិចារណារបញ្ឈប់ប្រើ TDF | |
| Diabetes screen | | | ✔បើប្តូរទៅប្រើ PI | ✔បើប្រើ PI, ត្រូវធ្វើតេស្តរៀងរាល់១២ខែម្តង |
| Serum lipids | | | ✔បើប្តូរទៅប្រើ PI | ✔ បើប្រើ PI, ត្រូវធ្វើតេស្តរៀងរាល់១២ខែម្តង |

### តារាងទី ២-៤ ការព្យាបាលបង្ការជំងឺឱកាសនិយមជាបឋម

| | លក្ខណៈវិនិច្ឆ័យនៃការចាប់ផ្តើមព្យាបាល | កំរិតដូស | លក្ខណៈវិនិច្ឆ័យនៃការបញ្ឈប់ការព្យាបាល |
|---|---|---|---|
| Cotrimoxazole | *សូមអានៈ ជំពូកទី៥ ការព្យាបាលបង្ការជំងឺឱកាសនិយមជាបឋម* | | |
| | • CD4 < ៣៥០<br>• TB ទោះបីមាន CD4 ប៉ុន្មានក៏ដោយ<br>• WHO ដំណាក់កាលទី ៣ឬទី៤<br>• គ្រប់ក្មេងជំទង់ទាំងអស់ បើគ្មាន Contraindication ។ | ១ DS; (TMP-១៦០ម.ក្រ , SMX-៨០០ម.ក្រ) លេបរាល់ថ្ងៃ *ឬ*<br>២ SS; (TMP-៨០ម.ក្រ, SMX-៤០០ម.ក្រ) លេបរាល់ថ្ងៃ ។ | អាយុ ≥ ២០ឆ្នាំ *និង* គ្មានជំងឺរបេងសកម្ម *និង* តេស្ត VL រកមិនឃើញមេរោគ *និង* តេស្ត CD4 > ៣៥០ ពេលធ្វើពីរដងជាប់គ្នា > ៦ខែម្តង។ |
| ការព្យាបាលបង្ការដោយIsoniazid (IPT) | *សូមអាន ជំពូកទី៦ ការពិនិត្យសុខភាពស្រាវជ្រាវរកជំងឺរបេង និង ការវាយតម្លៃ ដើម្បីព្យាបាលបង្ការដោយ ឱសថ* Isoniazid (IPT) | | |
| | គ្រប់ PLHIV ទាំងអស់ (រួមទាំងស្ត្រីមានផ្ទៃពោះ) ដែលគ្មានជំងឺរបេងសកម្ម ត្រូវព្យាបាលបង្ការជំងឺរបេងដោយ IPT ឱ្យមានមួយវគ្គ (one course)<br>បើគ្មាន Contraindication ។ | ប្រើ Isoniazid ៣០០ ម.ក្រ /ថ្ងៃ<br>+ pyridoxine ៥០ម.ក្រ/ថ្ងៃ<br>(បើទំងន់ < ៤០គ.ក្រ Isoniazid ២០០ម.ក្រ/ថ្ងៃ) | ក្រោយពីព្យាបាលបាន ៦ខែ ។ |
| ការព្យាបាលដោយឱសថ | *សូមអានជំពូកទី៧ ការពិនិត្យស្រាវជ្រាវមេរោគ* Cryptococcus *និងការព្យាបាលបង្ការជំងឺ* | | |
| Fluconazole តែក្នុងករណីដែលគ្មានតេស្តស្រាវជ្រាវ CRAG | CD4 < ១០០<br><br>បើគ្មាន contraindication | ប្រើ Fluconazole ១០០ ម.ក្រ/ថ្ងៃ | តេស្ត VL រកមិនឃើញមេរោគ *និង* តេស្ត CD4 >១០០ ពេលធ្វើពីរដងជាប់គ្នា >៦ខែម្តង។ |

**តារាងទី ២-៥ អនុសាសន៍សម្រាប់បង្ការ និងការគ្រប់គ្រងព្យាបាលជំងឺមិនឆ្លង**

| |
|---|
| របបអាហារ និងការផ្លាស់ប្តូរជីវិតរស់នៅ គឺអាស្រ័យទៅតាមទម្ងន់អ្នកជំងឺម្នាក់ៗ ដែលមានទម្ងន់ស្រាល/លើសទម្ងន់/ទម្ងន់ធម្មតា និងកត្តាប្រឈមមុខផ្សេងទៀត ដូចជា មានជំងឺលើសសម្ពាធឈាម ទឹកនោមផ្អែម ។ល។ |
| **របបអាហារ:** ត្រូវផ្តោតលើការបរិភោគអាហារ ចំពោះមនុស្សភាគច្រើន<br>• បរិភោគប្រេតេអ៊ីនច្រើន (តៅហ៊ូ សណ្តែក សាច់មាន់ ត្រី)។<br>• បរិភោគបន្លែច្រើន (៥ x ៤០០– ៥០០ក្រ នៃបន្លែ និងផ្លែឈើក្នុងមួយថ្ងៃ)។<br>• បរិភោគខ្លាញ់តិច (ចៀសវាងអាហារចំអិនខ្លាំងពេក (ខ្លោច) ស្បែកជាប់ខ្លាញ់ ដូចជា ស្បែកជ្រូក/មាន់។<br>• បរិភោគជាតិស្ករតិច (ភេសជ្ជៈ (soft drinks) ជាតិផ្អែម ទឹកដោះគោ (condensed milk)។<br>• បរិភោគជាតិអំបិលតិច (ប្រហុក MSG ទឹកត្រី ទឹកជ្រលក់ (soy sauce) និង សាច់ឬ ត្រីប្រឡាក់) ដោយប្រើរស់ជាតិផ្សេងជំនួសវិញ ដូចជា ទឹកក្រូចឆ្មារ ម្រេច និង បន្លែជីផ្សេងៗ។<br>• បន្ថយការបរិភោគអាហារកែឆ្នៃ(processed foods) ជាទូទៅ មានជាតិអំបិល ជាតិខ្លាញ់ និងជាតិស្ករច្រើន។ |
| **ទំងន់:** ត្រូវរក្សាកម្រិត BMI ឱ្យនៅចន្លោះ ១៨,៥ – ២២,៩ (សូមមើល ៣៣.៣ ការពិនិត្យស្រាវជ្រាវជំងឺកង្វះអាហារូបត្ថម្ភ និងការគ្រប់គ្រងទម្ងន់) |
| **ជាតិស្រវឹង** (Alcohol): ត្រូវទទួលទានក្នុងកម្រិតជាអតិបរិមា២ស្តង់ដាក្នុងមួយថ្ងៃ ≥មិនសេពគ្រឿងស្រវឹង២ថ្ងៃ ក្នុងមួយសប្តាហ៍(2 alcohol free days)។ |
| **មិនជក់បារី** |
| **ការហាត់ប្រាណ:** ត្រូវហាត់ប្រាណរយៈពេល៣០នាទីរៀងរាល់ថ្ងៃ (ឧ. ការដើរលឿន) (ត្រូវហាត់ប្រាណខ្លាំងជាងនេះ បើចង់សម្រកទម្ងន់)។ |

# ការផ្តល់សេវាថែទាំ និងព្យាបាល ដោយឱសថប្រឆាំងមេរោគអេដស៍ ចំពោះ ក្រុមប្រជាជនពិសេស

# ជំពូក ៣. ស្ត្រីដែលស្ថិតក្នុងវ័យបន្តពូជ

តម្រូវការជាពិសេស ចំពោះស្ត្រីដែលរស់នៅជាមួយមេរោគអេដស៍គឺ សុខភាពបន្តពូជ ។

- នៅពេលមកពិគ្រោះជំងឺ ត្រូវពិនិត្យស្ត្រី សួរគាត់ថា តើអ្វីគាត់ចង់បានអ្វីទាក់ទងនឹងសុខភាពបន្តពូជ អាចជា:
  - រង់ចាំពេលវេលាសមស្រប ដែលគួរមានគភ៌ ?
  - ឬ មានបំណងចៀសវាងការមានគភ៌ ?
- បើសិនជា គាត់លេបថ្នាំប្រឆាំងមេរោគអេដស៍បានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ហើយ *តេស្ត VL មិនអាចរកមេរោគអេដស៍ឃើញ* ហើយគាត់មានបំណងចង់មានកូន គឺគាត់មានការប្រឈមមុខតិចបំផុតក្នុងការចម្លងមេរោគអេដស៍ទៅដៃគូជាបុរស និងឆ្លងទៅទារក ក្នុងកំឡុងពេលមានផ្ទៃពោះ ឬ ការបំបៅកូនដោយទឹកដោះ។

## ៣.១ ផែនការក្នុងការមានគភ៌

- ផ្តល់យោបល់ដល់ស្ត្រី អំពីពេលវេលាសមស្របដែលគាត់គួរមានគភ៌ ដោយមិនធ្វើឱ្យប៉ះពាល់ដល់សុខភាពគាត់គឺ ក្រោយពេលគាត់ចូលក្នុងកម្មវិធី PMTCT បានរយៈពេលពី ៦ ទៅ ១២ខែ ដោយបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ការធ្វើតេស្ត VL រកមេរោគអេដស៍មិនឃើញ មានចំនួនកោសិកា CD4 កើនឡើងវិញ និង បានបញ្ចប់ការព្យាបាលបង្ការជំងឺឱកាសនិយម ។

## ៣.២ ការពន្យាកំណើត

- ចំពោះស្ត្រីដែលចង់ពន្យាពេលឬមិនចង់មានគភ៌ ត្រូវពិភាក្សាជាមួយគាត់អំពី មធ្យោបាយការពារមិនឱ្យមានកូន៖
  - ជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់វិធីសាស្ត្រទ្វេភាគ (dual methods) នៃការការពារកុំឱ្យមានកូន ជាជាងការប្រើប្រាស់ស្រោមអនាម័យតែមួយមុខ ដែលមានអត្រាបរាជ័យខ្ពស់ក្នុងការបង្ការការមានផ្ទៃពោះ។
  - ឱសថការពារមិនឱ្យមានកូន: ថយចុះប្រសិទ្ធភាព បើប្រើកម្រិតដូសទាបនៃការលេបថ្នាំពន្យាកំណើត នៅពេលប្រើរួមគ្នាជាមួយឱសថប្រឆាំងមេរោគអេដស៍ក្នុងក្រុម NNRTI និងក្រុម PI ។ ការចាក់ថ្នាំ (Depo- Provera) ឬ LARC (long acting reversible contraception) ដូចជា វិធីសាស្ត្របង្កប់ក្រោមស្បែក (implants) និងដាក់កង IUD ដែលស្ត្រីភាគច្រើនចូលចិត្តប្រើ។

## ៣.៣ ការពន្យាកំណើតជាបន្ទាន់សម្រាប់ស្ត្រី កំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

  - បង្ការការមានផ្ទៃពោះក្នុងករណីបន្ទាន់ ត្រូវធ្វើឱ្យបានឆាប់បំផុត ≤ ៥ថ្ងៃ។

- បើព្យាបាលដោយឱសថ rifampicin NNRI ឬ PI: ត្រូវបង្កើនកម្រិតដូសថ្នាំពន្យាកំណើតទ្វេដង (កម្រិតដូសធម្មតា គឺ ១,៥ mg) = ៣ mg levonorgestral ត្រូវប្រើតែមួយកម្រិតដូស [៨]។

## ៣.៤ ផ្តល់ការគាំទ្រស្ត្រី ឱ្យលេបឱសថប្រឆាំងមេរោគអេដស៍បានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ និងធ្វើតេស្ត VL ដើម្បីតាមដានកំឡុងពេលមានផ្ទៃពោះ

- ស្ត្រីដែលមានលទ្ធផលតេស្តឈាមរកមេរោគអេដស៍ វិជ្ជមាន មុនពេល ឬនៅពេលមានផ្ទៃពោះ ឬនៅពេលបំបៅដោះកូន ត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឱ្យបានឆាប់ ដោយប្រើប្រាស់រូបមន្តព្យាបាលជួរទី១ (TDF+3TC+EVF) និង លេបថ្នាំ cotrimoxazole បើអាចប្រើបាន។
- ផ្តោតការយកចិត្តទុកដាក់ជាពិសេស លើការគាំទ្រគាត់ ឱ្យលេបឱសថប្រឆាំងមេរោគអេដស៍បានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ នៅពេលមានផ្ទៃពោះ ។
- គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់ ត្រូវធ្វើតេស្ត Viral load ក្នុងកំឡុងពេលមានផ្ទៃពោះ ។
- ត្រូវធ្វើតេស្ត Viral load តាមដានបន្ថែម លើសពីកាលវិភាគធ្វើតេស្ត Viral load ធម្មតា ចំពោះស្ត្រីមានផ្ទៃពោះ៖
  - បើស្ត្រីមានផ្ទៃពោះទើបតែចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ត្រូវធ្វើតេស្ត VL រយៈពេល៣ខែក្រោយ ។
  - បើស្ត្រីមានផ្ទៃពោះបានព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ហើយ ត្រូវធ្វើតេស្ត VL នៅពេលទើបមានគភ៌ (បន្ទាប់មក ធ្វើតេស្តស្របតាមគំនូសបំព្រួញនៃការធ្វើតេស្តVL) ។
- ការគ្រប់គ្រងកម្មវិធី PMTCT និងការព្យាបាលបង្ការមេរោគអេដស៍ និងការធ្វើតេស្តឈាមរកមេរោគអេដស៍ចំពោះកុមារ ត្រូវអនុវត្តស្របតាមគោលការណ៍ណែនាំជាតិអំពី PMTCT និង និយាមបែបបទជំរុញការអនុវត្តន៍ខ្លាំងក្លានៃវិធីសាស្រ្តឆ្លើយតបរួមគ្នារបស់ NCHADS និង MCH [៩] គោលការណ៍ណែនាំជាតិអំពី PMTCT ដែលទើបតែកែសម្រួលថ្មី និងគោលការណ៍ណែនាំអំពីការគ្រប់គ្រង និងព្យាបាលជំងឺអេដស៍លើកុមាររបស់ NCHADS។

  **ជំងឺមហារីកមាត់ស្បូន (Cervical carcinoma)** បណ្តាលមកពីវីរុស HPV កើតឡើងជាញឹកញាប់ចំពោះស្ត្រីផ្ទុកមេរោគអេដស៍ ។ ជំងឺមហារីកមាត់ស្បូនរាលដាល (invasive cervical cancer) ត្រូវបានចាត់ថ្នាក់ជា ជំងឺអេដស៍ដំណាក់កាលទី៤របស់ WHO ។ ស្ត្រីផ្ទុកមេរោគអេដស៍ត្រូវធ្វើការពិនិត្យស្រាវ ជ្រាវរកជំងឺមហារីកមាត់ស្បូន បើសិនជាមានសេវានេះ និងត្រូវទទួលការព្យាបាលជំបៅមុនពេលក្លាយមហារីក (precancerous lesions) (សូមអានជំពូកទី៣២៖ ទំនាក់ទំនងរវាងជំងឺអេដស៍ និងជា ជំងឺមហារីក)។

---

[៨] គោលការណ៍ណែនាំគ្លីនិក ជំងឺរបេង/អេដស៍ របស់អង្គការគ្រូពេទ្យគ្មានព្រំដែន ២០១៥ ទំព័រ ៨៥

[៩] និយាមបែបបទសំរាប់អនុវត្តវិធីសាស្រ្តឆ្លើយតបរួមគ្នារវាង អេដស៍និង សុខភាពបន្តពូជដើម្បីលុបបំបាត់ការឆ្លងអេដស៍ថ្មីលើកុមារនិងការឆ្លងស្វាយពីកំណើត ក្នុងប្រទេសកម្ពុជា

# ជំពូក ៤. ក្មេងជំទង់

- អង្គការ WHO ឱ្យនិយមន័យ ក្មេងជំទង់ គឺជាក្មេងដែលមានអាយុចន្លោះពី១០ ទៅ ១៩ ឆ្នាំ[១០] ។
- ប្រទេសកម្ពុជា បានផ្តល់សេវាថែទាំនិងព្យាបាលជំងឺអេដស៍កុមារអាយុត្រឹម ១៥ ឆ្នាំ និងត្រូវបញ្ជូនទៅទទួលសេវាថែទាំនិងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ ពេលកុមារឈានចូលវ័យជំទង់។

- **ក្មេងជំទង់រស់នៅជាមួយមេរោគអេដស៍** (ALHIV) **គឺជាក្មេងជំទង់ដែល៖**
- ឆ្លងមេរោគអេដស៍ជុំវិញពេលបង្កកំណើត (perinataly-acquired ) និងត្រូវបានបញ្ជូនពីសេវាថែទាំនិងព្យាបាលជំងឺអេដស៍កុមារ ទៅទទួលនៅសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ (ករណីភាគច្រើននៃក្មេងជំទង់នៅកម្ពុជា) ។
- បាន ឆ្លងមេរោគអេដស៍ថ្មី តាមរយៈការប្រព្រឹត្តិផ្លូវភេទ ការចាក់គ្រឿងញៀន ការចាក់ថ្នាំគ្មានសុវត្ថិភាព ឬការចាក់បញ្ចូលឈាម ហើយភាគច្រើននៃក្មេងជំទង់ទាំងនេះ មកទទួលសេវាថែទាំនិងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យផ្ទាល់តែម្តង ។
- ក្មេងស្រីជំទង់មួយចំនួនត្រូវបានធ្វើរោគវិនិច្ឆ័យថា ផ្ទុកមេរោគអេដស៍នៅសេវាសម្ភព ។

- **ការធ្វើតេស្តឈាមរកមេរោគអេដស៍** ក្មេងជំទង់ ត្រូវមកទទួលសេវាធ្វើតេស្តឈាមរក មេរោគអេដស៍ ដែលមានប្រព័ន្ធថែរក្សាការសំងាត់ និងទទួលបានការយល់ព្រម (informed consent) ពីក្មេងជំទង់ជាមុនសិន។

- **ប្រឈមនឹងបញ្ហាផ្លូវចិត្ត**

ក្មេងជំទង់ គឺជាក្រុមប្រជាជនដែលមានលក្ខណៈចម្រុះគ្នា (heterogeneous group) ហើយរីកលូតលាស់តាមលក្ខណៈធម្មជាតិ ផ្នែករាងកាយ ផ្នែកសតិបញ្ញា និងការទំនងទំនងសង្គមយ៉ាងលឿនតាមកម្រិតខុសៗគ្នានៃភាពពេញវ័យ ព្រមទាំងមានការទទួលខុសត្រូវខុសៗគ្នា ទាំងនៅក្នុងគ្រួសារ និងក្នុងសហគមន៍ ។

ភាគច្រើននៃកុមារដែលឆ្លងមេរោគអេដស៍នៅពេលសំរាលមានការប្រឈមមុខជាមួយនឹងការរើសអើង និងម៉ាក់ងាយនៅពេលឈានចូលវ័យជំទង់ រួមទាំង ការលូតលាស់មិនបានល្អ (stunted growth) ការសិក្សារៀនសូត្របានលទ្ធផលមិនសូវល្អ ដោយសារអវត្តមានញឹកញាប់ ។ ពួកគេអាចជាក្មេងកំព្រា ឬ រស់នៅជាមួយឪពុកម្តាយមានជំងឺរ៉ាំរ៉ៃ ឬ ជាមួយអ្នកថែទាំដែលមិនសូវផ្តល់នូវក្តីអាណិតមេត្តាចំពោះគេ ។ គេអាចវិវត្តន៍ទៅភាពពេញវ័យយឺតយ៉ាវ និង មិនសូវមានការទុកចិត្តលើខ្លួនឯង ។

---

[១០] អេដស៍និង ក្មេងជំទង់:គោលការណ៍ណែនាំ ផ្តល់ប្រឹក្សានិង តេស្តរក HIV និងការថែទាំក្មេងជំទង់ដែលរស់នៅជាមួយមេរោគអេដស៍: អនុសាសន៍សំរាប់យុទ្ធសាស្ត្រសាធារណៈនិងការពិចារណាសំរាប់អ្នកគ្រប់គ្រងនិងអ្នករៀបចំគោលនយោបាយ អង្គកាសុខភាពិភពលោក ២០១៣។

ក្មេងទំទង់ ដែលឆ្លងមេរោគអេដស៍តាមមធ្យោយបាយផ្សេងៗ មានតម្រូវការដោយឡែកៗពីគ្នា ។ ពួកគាត់អាចមកពីក្រុមប្រជាជនចំណុច ដូចជា ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំលែងភេទ ក្រុមអ្នកចាក់គ្រឿងញៀន និង/ឬ អាចជាក្រុមបម្រើសសេវាផ្លូវភេទ ។ ក្រុមនេះ ជាទូទៅ គឺជាក្រុមដែលមានការប្រព្រឹត្តិប្រឈមមុខខ្ពស់នឹងការឆ្លងរាលដាលមេរោគអេដស៍ ហើយអាចមានបញ្ហាប្រឈមជាមួយនឹងការលេបឱសថប្រឆាំងមេរោគអេដស៍ មិនសូវបានត្រឹមត្រូវ ទៀងទាត់ និង ជាប់លាប់ ។ ក្មេងជំទង់ក្រុមនេះ ក៏ត្រូវការសេវាផែនការគ្រួសារ និងសេវាថែទាំនិងព្យាបាលជំងឺកាមរោគផងដែរ។

- **ការផ្ទេរពីសេវាថែទាំ និងព្យាបាលជំងឺអេដស៍កុមារ ទៅសេវាមនុស្សពេញវ័យ**

ក្មេងជំទង់ភាគច្រើន មានកង្វល់និងព្រួយបារម្ភណ៍ អំពីការផ្ទេរពីសេវាថែទាំនិងព្យាបាលជំងឺអេដស៍កុមារ ទៅសេវាមនុស្សពេញវ័យ ដែលជាពេលវេលាដ៏ពិបាកក្នុងការសម្រួលសម្រួលដោយបង្កើននូវការទទួលខុសត្រូវ និង ក្តីរំពឹងទុកជាមុន នៅសេវាថែទាំនិងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ។

គោលបំណងនៃការផ្ទេរពីសេវាថែទាំនិងព្យាបាលជំងឺកុមារទៅសេវាមនុស្សពេញវ័យ ដោយជោគជ័យគឺ ការរក្សាក្មេងជំទង់ឱ្យបន្តមកទទួលសេវាថែទាំព្យាបាលជាប់ជានិច្ច រក្សានូវការលេបថ្នាំប្រឆាំងមេរោគអេដស៍បានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ បង្កើនសមត្ថភាពក្នុងការបន្ថយការប្រឈមមុខនឹងការឆ្លងរាលដាលមេរោគអេដស៍ និងបានទទួលការគាំទ្រទាំងផ្នែកគ្លីនិក និង ផ្លូវចិត្ត ដើម្បីក្លាយជាយុវជនដែលមានទាំង សុខភាពផ្លូវកាយ និងផ្លូវចិត្តល្អ។

ក្មេងជំទង់ផ្ទុកមេរោគអេដស៍ភាគច្រើន ដែលត្រូវផ្ទេរពីសេវាថែទាំ និងព្យាបាលជំងឺកុមារទៅសេវាមនុស្សពេញវ័យ មានអាយុចន្លោះពី **១៥និង២០ឆ្នាំ** ។ ក្មេងជំទង់ដែលបង្ហាញ ពីភាពម្ចាស់ការនៃការសំរេចចិត្ត និងការទទួលខុសត្រូវដោយខ្លួនឯងក្នុងការថែទាំ និងព្យាបាល អាចនឹងទៅទទួលសេវាថែទាំនិងព្យាបាលជំងឺមនុស្សពេញវ័យបានឆាប់ជាង ។

- **គាំទ្រក្នុងការផ្ទេរ និងការផ្តល់ការថែទាំ និងព្យាបាលជំងឺអេដស៍ដល់ក្មេងជំទង់ឱ្យបានសមស្រប**

ត្រូវទាមទារឱ្យសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ មានកិច្ចសហការល្អជាមួយអ្នកផ្តល់សេវាថែទាំ និងព្យាបាលជំងឺអេដស៍កុមារ ទាំងនៅកម្រិតនៃការផ្តល់សេវា និង នៅកម្រិតអ្នកជំងឺម្នាក់ៗ ដើម្បីគាំទ្រក្នុងការផ្ទេរក្មេងជំទង់ ដោយធានាឱ្យបានទទួលសេវា ដែលទាក់ទាញក្មេងជំទង់ឱ្យចូលចិត្តមកប្រើប្រាស់ "adolescent friendly" ។

## ៤.១ រៀបចំរចនាសម្ព័ន្ធសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ សម្រាប់ក្មេងជំទង់

| រៀបចំរចនាសម្ព័ន្ធគ្លីនិកនៅសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ សម្រាប់ក្មេងជំទង់ |
|---|
| ១. ចាត់តាំងអ្នកសម្របសម្រួល សម្រាប់ទំនាក់ទំនង រវាងសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ និងសេវាថែទាំ និងព្យាបាលជំងឺអេដស៍កុមារ ។ |

| |
|---|
| ២. បង្កើតនិយាមបែបបទជាក់លាក់ ក្នុងការទទួលក្មេងទំទង់ ដែលទើបតែបញ្ជូនមកទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ រួមមាន៖<br>• តម្រង់ទិសពីហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៃសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ ។<br>• ណែនាំពីបុគ្គលិកនៅសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ ។<br>• ពន្យល់ពីលំហូរនៃសេវាគ្លីនិក ។<br>• ពន្យល់ឱ្យច្បាស់ អំពីវិន័យពេលមកដល់គ្លីនិកយឺតយ៉ាវ និងពេលដើរចូលមកគ្លីនិក ។<br>• ចាត់តាំងបុគ្គលិកគ្លីនិកម្នាក់ ជាអ្នកទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នកជំងឺ ដោយផ្តល់ជូនព័ត៌មានទំនាក់ទំនង ដូចជា ពេលវេលាដែលអាចទាក់ទងបាន ។ |

| **រៀបចំរចនាសម្ព័ន្ធដើម្បីធ្វើឱ្យប្រសើរឡើង ដើម្បីទាក់ទាញក្មេងជំទង់ឱ្យចូលចិត្តមកប្រើប្រាស់សេវា " adolescent friendliness " ៖** |
|---|
| ១. រៀបចំកាលវិភាគប្រចាំសប្តាហ៍របស់គ្លីនិកជាក់លាក់ សម្រាប់ផ្តល់សេវាជូនក្មេងទំទង់ ។<br>២. កាត់បន្ថយពេលវេលារង់ចាំ និងផ្តល់ការពិគ្រោះជំងឺឱ្យបានយូរ ។<br>៣. អញ្ជើញអ្នកផ្តល់ប្រឹក្សា/ក្រុមមិត្តជួយមិត្ត (PSW) មកពីសេវាថែទាំ និងព្យាបាលជំងឺអេដស៍កុមារមកចូលរួម ។<br>៤. រៀបចំប្រជុំ MMM (មិត្តគាំទ្រមិត្ត)នៃក្រុមក្មេងជំទង់ ។<br>៥. ធានាថា មិនតម្រូវឱ្យបង់ថ្លៃសេវាថែទាំ និងព្យាបាលជំងឺអេដស៍ចំពោះក្មេងជំទង់ ។<br>៦. សហការក្នុងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រជាក់លាក់ដល់ក្មេងជំទង់ បន្ថែមពីសេវាដែលគ្លីនិក ។<br>៧. បណ្តុះវប្បធម៌របស់គ្លីនិកដោយគ្មានការរិះគន់ ការវាយតម្លៃ ប៉ុន្តែ មានការទទួលស្វាគមន៍រាក់ទាក់ពីសំណាក់បុគ្គលិករបស់គ្លីនិក នៅគ្រប់ពេលទាំងអស់ ។ |

គ្រូពេទ្យព្យាបាលនៅសេវាថែទាំ និងព្យាបាលជំងឺអេដស៍កុមារ ត្រូវរៀបចំក្មេងជំទង់ដែលត្រូវបញ្ជូនទៅទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ ដូចតទៅ ៖

១. រៀបចំផែនការអន្តរកាលជាមួយក្មេងជំទង់ គ្រួសារ និង អ្នកផ្តល់សេវា ។

២. ផ្តល់ការអប់រំ និងជំនាញតាមរយៈការបណ្តុះបណ្តាលក្មេងជំទង់ មុនពេលបញ្ជូន ដើម្បីឱ្យពួកគេមានសមត្ថភាព ក្នុងការ ៖

- យល់ដឹងអំពីការស្វែងរកសេវាថែទាំ និងព្យាបាល នៅពេលមានរោគសញ្ញាគ្លីនិកធ្ងន់ធ្ងរ ឬករណីសង្គ្រោះបន្ទាន់ ។
- កំណត់រោគសញ្ញាគ្លីនិក និងរៀបរាប់រោគសញ្ញាគ្លីនិកទាំងនោះ ។
- ការណាត់ជួប លុបចោលការណាត់ជួប និងរៀបចំការណាត់ជួបគ្រូពេទ្យ សារជាថ្មី ។
- មកតាមកាលកំណត់នៃការណាត់ជួប ។
- ទូរស័ព្ទមកមុន ករណីត្រូវការសង្គ្រោះបន្ទាន់ ។

- ធានាថាត្រូវមានថ្នាំលេបគ្រប់គ្រាន់ទុកនៅផ្ទះ មុនពេលត្រូវណាត់ជួបគ្រូពេទ្យលើកក្រោយ។
- យល់ដឹងពីសារៈសំខាន់នៃការតាមដាន ការថែទាំសុខភាព និងអាចទទួលការខុសត្រូវក្នុងការព្យាបាល និងការសំរេចចិត្តដោយខ្លួនឯង ។

៣. ក្រុមអ្នកផ្តល់សេវាថែទាំកុមារ/ក្មេងជំទង់ ត្រូវជួយក្មេងជំទង់ ស្វែងរកសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យដែលសមស្របចំពោះពួកគាត់ ។

៤. ធានាថា ការបញ្ជូនត្រូវធ្វើឡើង នៅពេលស្ថានភាពសុខភាពរបស់ក្មេងជំទង់មានលំនឹង ។

**ក្រោយពីបានបញ្ជូនក្មេងជំទង់ទៅទទួលថែទាំនិងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ**

អ្នកផ្តល់សេវាមនុស្សពេញវ័យ ត្រូវធ្វើការជាមួយក្រុមអ្នកផ្តល់សេវាកុមារ ក្នុងករណីដែលក្មេងជំទង់បានដកខ្លួនចេញពីការទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ ហើយត្រឡប់ទៅទទួលនៅសេវាថែទាំ និងព្យាបាលជំងឺអេដស៍កុមារវិញ ដើម្បីសម្របសម្រួល និងជំរុញលើកទឹកចិត្តឱ្យត្រឡប់ទៅទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យវិញ ។

## ៤.២ ការគាំទ្រផ្លូវចិត្ត និងសង្គម

សេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ ត្រូវបន្តផ្តល់ការគាំទ្រផ្លូវចិត្តដល់ក្មេងជំទង់រួមមាន៖

- ការស្វែងរក និងការដោះស្រាយវិបត្តិ ឧ. មានបំណងសម្លាប់ខ្លួន គ្មានផ្ទះសំបែងស្នាក់នៅ។ល។
- សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ជំរុញលើកទឹកចិត្តការអនុវត្តន៍ការប្រព្រឹត្តផ្លូវភេទដោយសុវត្ថិភាព។
- ផ្តល់ភាពទទួលបាននូវផលប្រយោជន៍ សិទ្ធិ និងសេវាផ្សេងៗ។
- គាំទ្រយុវជន ក្នុងការថែទាំសុខភាពខ្លួនឯង និងការអនុវត្តន៍ធ្វើឱ្យជីវិតបានប្រសើរឡើង ។
- ពិនិត្យស្រាវជ្រាវ និងការព្យាបាលបញ្ហាសុខភាពរុំរ៉ៃ ឧ. ការធ្លាក់ទឹកចិត្ត ការប្រើប្រាស់គ្រឿងញៀន។
- បង្កើនជំនាញក្នុងការរស់នៅដោយខ្លួនឯង និង ការផ្លាស់ប្តូរពីកុមារភាពទៅកាន់មនុស្សពេញវ័យ។

**ការផ្តល់ប្រឹក្សាចំពោះក្មេងជំទង់ រួមមាន៖** គាំទ្រការលេបថ្នាំប្រឆាំងមេរោគអេដស៍ឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ អប់រំអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ពន្យល់អំពីទំនាក់ទំនងស្នេហាដែលមានមនោសញ្ចេតនា ព្រមទាំងការទម្លាយពីស្ថានភាពមេរោគអេដស៍ប្រាប់ដៃគូ និងប្រាប់មនុស្សសំខាន់ផ្សេងទៀត ។

អ្នកផ្តល់សេវាត្រូវបង្ហាញពីការគោរព និងការស្តាប់ដោយយកចិត្តទុកដាក់ ដោយមិនវាយតម្លៃរាល់ជម្រើសផ្សេងៗ និង ក្តីបារម្ភណ៍របស់ក្មេងជំទង់។

អ្នកផ្តល់សេវា ត្រូវពិភាក្សាជាមួយក្មេងជំទង់ អំពីវិធីសាស្ត្រកាត់បន្ថយកត្តាប្រឈមមុខនឹងការឆ្លងរាលដាលមេរោគអេដស៍ ដោយមិនអាចនិយាយជាចំហនៅចំពោះមុខឪពុក ម្តាយ ឬអ្នកថែទាំ ។

ការផ្តល់ប្រឹក្សាជាក្រុម អាចជួយឱ្យក្មេងជំទង់បង្កើនទំនុកចិត្តលើខ្លួនឯង ដោយផ្តល់ទីកន្លែងសម្រាប់ជួបជុំគ្នានៅក្នុងគ្លីនិក អញ្ជើញអ្នកជំនាញ ហើយមន្ត្រីសុខាភិបាលជួយសម្របសម្រួលពីដំណើរការបង្កលក្ខណៈងាយស្រួលដល់ការជួបជុំគ្នារបស់ក្មេងជំទង់ អនុញ្ញាតឱ្យគេបង្កើតជាក្រុម និង ទទួលបាននូវជំនាញទាំងអស់នេះ ។

## ៤.៣. បញ្ហាដោយឡែក ដែលត្រូវដោះស្រាយចំពោះ ក្មេងជំទង់

### ៤.៣.១ ការបើកចំហពីស្ថានភាពមេរោគអេដស៍

- **ការបើកចំហពីស្ថានភាពមេរោគអេដស៍ចំពោះក្មេងជំទង់** ៖ អង្គការសុខភាពពិភពលោកផ្តល់យោបល់ថា កុមារដែលស្ថិតក្នុងវ័យសិក្សាគួរតែ បើកចំហពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ផ្ទុយទៅវិញ គេសង្កេតឃើញថា ក្មេងដែលមិនបានបើកចំហពីស្ថានភាពមេរោគអេដស៍ ភាគច្រើន មិនមកទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍បានជាប់លាប់ល្អទេ ។ ក្មេងជំទង់ដែលត្រូវបញ្ជូនទៅទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍មនុស្សពេញវ័យ ត្រូវតែប្រាប់គេពីស្ថានភាពផ្ទុកមេរោគអេដស៍ជាមុនៗពេលបញ្ជូន ។
    - ពេលវេលាដែលត្រូវបើកចំហពីស្ថានភាពមេរោគអេដស៍ចំពោះក្មេងជំទង់ទាំងអស់ ត្រូវធ្វើឡើងក្នុងចន្លោះអាយុ ៦ ទៅ ១២ឆ្នាំ ។
    - ករណីដែលការបើកចំហអំពីស្ថានភាពមេរោគអេដស៍ប្រព្រឹត្តទៅក្រោយពេលពេញវ័យជាទូទៅក្រោយអាយុ ១២ឆ្នាំ អាចនឹងមានផលប៉ះពាល់ជា អវិជ្ជមាន ដូចជាការព្យាបាលមិនបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ និង ការធ្លាក់ទឹកចិត្ត ។

- **កត្តាប្រឈម និងផលប្រយោជន៍នៃការបើកចំហពីស្ថានភាពមេរោគអេដស៍ប្រាប់អ្នកដទៃ៖** ត្រូវ ផ្តល់ប្រឹក្សាក្មេងជំទង់ អំពី៖
    - *សក្តានុពលនៃផលប្រយោជន៍នៃការបើកចំហពីស្ថានភាពមេរោគអេដស៍* ដូចជា ក)ការបើកចំហស្ថានភាពមេរោគអេដស៍ដល់អ្នកដទៃដើម្បីទទួលតម្រូវការគាំទ្រសេវាថែទាំ និង ព្យាបាលជំងឺអេដស៍ និង ខ)ការបើកចំហស្ថានភាពមេរោគអេដស៍ដល់ដៃគូរួមភេទដើម្បីចូលរួមអនុវត្តការរួមភេទប្រកបដោយសុវត្ថិភាព ក្នុងគោលបំណងបង្ការការឆ្លងរាលដាលនៃមេរោគអេដស៍។
    - *សក្តានុពលនៃកត្តាប្រឈមមុខនៅពេលបើកចំហពីស្ថានភាពមេរោគអេដស៍* ដូចជា ការម៉ាក់ងាយ ការរើសអើង ការបោះបង់ចោល និងអំពើហឹង្សា ។

- ក្មេងជំទង់ត្រូវការការផ្តល់អំណាច និងផ្តល់ការគាំទ្រក្នុងការសំរេចចិត្តក្នុងការបើកចំហពីស្ថានភាពមេរោគអេដស៍ ថា តើគួរបើកចំហនៅពេលណា? ដោយរបៀបណា? និងចំពោះអ្នកណា? ។

- ជាទូទៅ ការបើកចំហពីស្ថានភាពមេរោគអេដស៍ជាមួយដៃគូ គឺវាខុសគ្នា រវាងក្មេងជំទង់ និងមនុស្សពេញវ័យ៖
  - ក្មេងជំទង់មិនសូវរក្សាទំនាក់ទំនងជាមួយដៃគូបានយូរទេ ។
  - ក្មេងជំទង់អាចគ្មានចំណេះដឹង និងជំនាញក្នុងការគ្រប់គ្រងអារម្មណ៍ ដើម្បីដោះស្រាយបញ្ហាលំបាកដែលអាចកើតឡើង នៅពេលបើកចំហស្ថានភាពមេរោគអេដស៍ទៅដៃគូ រួមទាំង ការឈប់ទាក់ទងគ្នា ។
  - វិសមភាពអំណាចកើតមានឡើងជាញឹកញាប់ក្នុងចំណោមក្មេងជំទង់ (ឧ. រវាងក្មេងស្រីជំទង់ និងដៃបុរសដែលមានអាយុច្រើនជាង) អាចបណ្តាលឱ្យក្មេងជំទង់រងគ្រោះនឹងភាពឯកោ ឬរងនូវអំពើរំលោភបំពាន ក្រោយពីបានបើកចំហពីស្ថានភាពមេរោគអេដស៍ ។

- អ្នកថែទាំក្មេងជំទង់ ត្រូវផ្តល់ការគាំទ្រក្មេងជំទង់ក្នុងការបើកចំហពីស្ថានភាពមេរោគអេដស៍នៅក្នុងសហគមន៍ ដែលគេធ្លាប់មានបទពិសោធន៍ទទួលរងនូវការម៉ាក់ងាយ និងរើសអើង។

## ៤.៣.២ សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ

ក្មេងជំទង់ត្រូវមានការយល់ដឹងយ៉ាងច្បាស់អំពី៖

- ចំណេះដឹងជាមូលដ្ឋាន អំពីសុខភាពបន្តពូជ និងវិធីការពារកុំឱ្យមានកូន ដើម្បីចៀសវាងការមានផ្ទៃពោះ ។ ស្ត្រីស្ថិតនៅក្នុងវ័យសកម្មផ្លូវភេទ ត្រូវបានផ្តល់យោបល់ឱ្យប្រើប្រាស់វិធីសាស្ត្របង្ការកំណើតទ្វេ (dual contraceptive methods) ដោយប្រើអរម៉ូនបង្ការការមានគភ៌ ដែលមានសកម្មភាពយូរ គឺជាជម្រើសដ៏ល្អ ។
- ការបង្កជំងឺកាមរោគ៖ ផ្តល់ព័ត៌មានអំពីការបង្ការ ទីកន្លែងផ្តល់សេវាពិនិត្យ និងព្យាបាលជំងឺកាមរោគ។
- សិទ្ធិបុគ្គលក្នុងការបង្ការការឆ្លងរាលដាលមេរោគអេដស៍នៅពេលមានសកម្មភាពផ្លូវភេទ។

## ៤.៣.៣ ក្មេងជំទង់ និងការមកទទួលសេវាឱ្យបានជាប់លាប់រហូត

- បញ្ហាប្រឈមដ៏ចម្បងទាំងគ្រូពេទ្យព្យាបាលនិងក្មេងជំទង់គឺ ការលេបឱសថប្រឆាំងមេរោគអេដស៍ឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ និងការមកទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍ឱ្យបានជាប់លាប់រហូត ហើយបណ្តាលឱ្យមានផលវិបាក ទាំងចំពោះបុគ្គល និងសុខភាពសាធារណៈ។

- ផ្តល់សេវាថែទាំនិងព្យាបាលដែលមានលក្ខណៈទាក់ទាញឱ្យក្មេងជំទង់ចូលចិត្តមកប្រើប្រាស់ "adolescent friendly" និងឆ្លើយតបទៅនឹងតម្រូវការរបស់ក្មេងជំទង់រស់នៅជាមួយមេរោគអេដស៍ ។
- ស្វែងរករបាំងនៃការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ដោយស្តាប់រាល់ក្តីបារម្ភណ៍របស់ក្មេងជំទង់ម្នាក់ៗ និងពិភាក្សាជាមួយគាត់ដើម្បីស្វែងរកដំណោះស្រាយសមស្របនូវក្តីបារម្ភទាំងអស់នោះ និងដោយគ្មានការវាយតម្លៃ ។
- បើសិនជាអាច ត្រូវជ្រើសរើសក្រុមមិត្តគាំទ្រមិត្ត និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីគាំទ្រការងារនេះ។
- ត្រូវប្រើប្រាស់យន្តការនៃការស្រាវជ្រាវករណីសកម្មមេរោគអេដស៍ដើម្បីធានាឱ្យបានថាក្មេងជំទង់គ្រប់គ្នានៅបន្តប្រើប្រាស់សេវាថែទាំ និងព្យាបាលជំងឺអេដស៍ជាប់លាប់រហូត ។

## ៤.៤ បញ្ហារោគសញ្ញាគ្លីនិក នៃការថែទាំនិងព្យាបាលក្មេងជំទង់

| បញ្ហារោគសញ្ញាគ្លីនិកនៃការថែទាំនិងព្យាបាលក្មេងទំទង់ |
|---|
| • **ចំណាត់គ្លីនិករបស់ WHO** សម្រាប់ក្មេងជំទង់អាយុ ≥១៥ឆ្នាំ ដូចគ្នាជាមួយនឹងមនុស្សពេញវ័យដែរ រីឯកុមារអាយុ < ១៥ឆ្នាំ មានលក្ខណៈដូចគ្នាជាមួយនឹងកុមារ ។<br>• **ការចាប់ផ្តើម ART** លើក្មេងជំទង់ មានលក្ខណៈដូចគ្នាជាមួយមនុស្សពេញវ័យ ។<br>• ***រូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍*** លើក្មេងជំទង់ ≥ ៣៥ គ.ក្រ មានលក្ខណៈដូចគ្នាជាមួយមនុស្សពេញវ័យ បើទំងន់<៣៥ គ.ក្រ មានលក្ខណៈដូចគ្នាជាមួយនឹងកុមារ។<br>• **ជំងឺមិនឆ្លង**: គ្រប់ក្មេងជំទងដែលឆ្លងមេរោគអេដស៍នៅកំឡុងពេលសំរាលកូន នឹងប្រឈមមុខនឹងការពុលឱសថប្រឆាំងមេរោគអេដស៍រយៈពេលយូរ និងមានផលវិបាកមេតាបូលិកនៃមេរោគអេដស៍ ឧ. ការលើសជាតិខ្លាញ់ក្នុងឈាម(hyperlipidaemia) ។<br>• **ការព្យាបាលបង្ការជំងឺឱកាសនិយម**:<br>  ◦ ត្រូវប្រើ Cotrimoxazole ជាប្រចាំលើគ្រប់ក្មេងជំទង់ទាំងអស់ ហើយនៅពេលដែលគេក្លាយជាមនុស្សពេញវ័យ នៅអាយុ២០ឆ្នាំ ត្រូវអនុវត្តតាមគោលការណ៍នៃការបញ្ឈប់ការព្យាបាលបង្ការរបស់មនុស្សពេញវ័យ ។<br>  ◦ ការពិនិត្យស្រាវជ្រាវរកជំងឺរបេង និងលក្ខណៈវិនិច្ឆ័យក្នុងការព្យាបាលដោយ IPT ចំពោះក្មេងជំទង់ មានលក្ខណៈដូចគ្នាជាមួយមនុស្សពេញវ័យ ។<br>  ◦ ការពិនិត្យស្រាវជ្រាវរកមេរោគ Cryptococcus ចំពោះក្មេងជំទង់ គឺមានលក្ខណៈដូចគ្នាជាមួយមនុស្សពេញវ័យ ។ |

# ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងការព្យាបាលបង្ការជំងឺឱកាសនិយម

# ជំពូក៥. ការព្យាបាលបង្ការជំងឺឱកាសនិយមជាបឋម

## ៥.១ ការព្យាបាលបង្ការជាបឋមដោយឱសថ Cotrimoxazole

- គោលបំណងជាបឋមនៃការព្យាបាលបង្ការដោយឱសថ Cotrimoxazole គឺដើម្បីបង្ការជំងឺ PCP ឬ PJP(Pneumocystis Jirovecii Pneumonia) ជំងឺ toxoplasmosis និងជំងឺបង្កដោយពពួកបាក់តេរី។
- ការព្យាបាលបង្ការដោយឱសថ Cotrimoxazole អាចនឹងចាប់ផ្តើម*ព្យាបាលបង្ការជាបឋម (Primary Prophylaxis)* ចំពោះអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ដែលមិនធ្លាប់កើតជំងឺនេះពីមុន ឬជា*ការព្យាបាលបង្ការទី២ (Secondary Prophylaxis)* ក្នុងករណីដែលអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ធ្លាប់បានកើតជំងឺទាំងនេះពីមុន ព្រោះថា ទោះបីជាការព្យាបាលបង្ការកុំឱ្យកើតជំងឺទាំងនេះ តែជំងឺនេះអាចនឹងកើតសារជាថ្មី ។

- ឱសថ Cotrimoxazole គឺជាគ្រាប់ថ្នាំគ្រាប់សំប៉ែតរួមបញ្ចូលគ្នា រវាង trimethoprim TMP និង sulfamethoxazole SMP ។

**រូបមន្តនៃ** cotrimoxazole:

- Cotrimoxazole DS (double strength) = TMP ១៦០ម.ក្រ /SMX ៨០០ម.ក្រ (ឬ ៩៦០ម.ក្រ)
- Cotrimoxazole SS (single strength) = TMP ៨០ម.ក្រ/SMX ៤០០ម.ក្រ (ឬ ៤៨០ម.ក្រ)
- Cotrimoxazole oral suspension = TMP ៤០ម.ក្រ/SMX ២០០ម.ក្រ ក្នុង ៥ ម.ល។

### កម្រិតដូស និងវិធីប្រើ

- បើទំងន់ ≥ ៣៥ គ.ក្រ ប្រើ Cotrimoxazole DS លេប១ដង/ថ្ងៃ ឬលេប cotrimoxazole SS គ្រាប់ ២ដង/ថ្ងៃ ។
  បើទំងន់ < ៣៥គ.ក្រ ប្រើ cotrimoxazole SS លេប១ដង/ថ្ងៃ។
- បើការប្រើកម្រិតដូសស្តង់ដា cotrimoxazole ធ្វើឱ្យអ្នកជំងឺមិនអាចទ្រាំទ្របាន (ដោយមូលហេតុផ្សេងៗ) អាចកាត់បន្ថយកម្រិតដូស cotrimoxazole ឱ្យលេប SS ១ដង/ថ្ងៃ ឬ ប្រើ Dapsone ១០០mg លេប១ដង/ថ្ងៃ (ដើម្បីព្យាបាលបង្ការជំងឺ PJP តែមួយ – សូមអានផ្នែកខាងក្រោម)។
- លេប cotrimoxazoleពេលបរិភោគអាហារដើម្បីបង្ការផលវិបាកលើប្រដាប់រំលាយអាហារ(GIT)

## ៥.២ លក្ខណៈវិនិច្ឆ័យនៃការព្យាបាលបង្ការដោយឱសថ Cotrimoxazole

តារាងទី ៥-១ លក្ខណៈវិនិច្ឆ័យនៃការចាប់ផ្តើមព្យាបាល ការព្យាបាលបន្ត និងការបញ្ឈប់ការព្យាបាលបង្ការដោយឱសថ *Cotrimoxazole* លើមនុស្សពេញវ័យ និងក្មេងជំទង់ រួមទាំង ស្ត្រីមានផ្ទៃពោះ

| | ក្មេងជំទង់អាយុ (១១-១៩ឆ្នាំ) | មនុស្សពេញវ័យអាយុ (≥ ២០ឆ្នាំ) |
|---|---|---|
| ពេលណាដែលត្រូវចាប់ផ្តើមព្យាបាលបង្ការដោយឱសថ cotrimoxazole | គ្រប់អ្នកជំងឺទាំងអស់ដោយមិនគិតពីចំនួនកោសិកា CD4 | • កោសិកា CD4 < ៣៥០/មម៣ *<br>• គ្រប់អ្នកជំងឺទាំងអស់ដែលមានជំងឺរបេង<br>• ដំណាក់កាលទី៣ ឬទី៤នៃ WHO ដោយមិនគិតពីចំនួនកោសិកា CD4 |
| ពេលណាដែលត្រូវបន្តការព្យាបាលដោយឱសថ cotrimoxazole | គ្រប់អ្នកជំងឺទាំងអស់ | • កោសិកា CD4 <៣៥០/មម៣ និង/ឬ កំពុងព្យាបាលជំងឺរបេង<br>• បើមានប្រវត្តិកើតជំងឺ PCP និងកោសិកា CD4 > ២០០/មម៣ (ត្រូវព្យាបាលបង្ការដោយឱសថ Cotrimoxazole លើកទីពីរដោយគ្មានពេលកំណត់)។ |
| ពេលណាដែលត្រូវបញ្ឈប់ការព្យាបាលបង្ការដោយឱសថ cotrimoxazole | មិនត្រូវបញ្ឈប់ការព្យាបាលទេ(បន្តព្យាបាលរហូតដល់ពេញវ័យ) | • ចំនួនកោសិកាCD4 > ៣៥០/មម៣ ក្រោយពីបានធ្វើតេស្តរាប់ចំនួនកោសិកា២ដងឃ្លាតគ្នា៦ខែម្តង និងតេស្តVL រកមេរោគមិនឃើញនិងបានព្យាបាលជំងឺរបេងចប់។ |

* ត្រូវចាប់ផ្តើមព្យាបាលដោយឱសថcotrimoxazoleនៅពេលអ្នកជំងឺមកពិគ្រោះជំងឺលើកទី១ និងប្រសិនបើចំនួន កោសិកា CD4>៣៥០ នោះអាចបញ្ឈប់ការព្យាបាល នៅពេលអ្នកជំងឺមកពិគ្រោះជំងឺ នៅពេលបន្ទាប់នៅ២សប្តាហ៍ក្រោយ។

## ៥.៣ ការចាប់ផ្តើមព្យាបាលដោយឱសថ cotrimoxazole បើកោសិកា CD4 ថយចុះ ឬកើតជំងឺរបេងសកម្ម

- ត្រូវចាប់ផ្តើមព្យាបាលបង្ការដោយឱសថ cotrimoxazole បើកោសិកា CD4 ថយចុះ<៣៥០ កោសិកា/មម៣ ឬមានជំងឺរបេងសកម្ម និងលក្ខណៈវិនិច្ឆ័យក្នុងការបញ្ឈប់ការព្យាបាលបង្ការដោយឱសថ cotrimoxazole គឺដូចគ្នា ។

## ៥.៤ ការហាមប្រើប្រាស់ឱសថ cotrimoxazol

- ប្រតិកម្ម allergy ខ្លាំងក្លាជាមួយឱសថ cotrimoxazole ឬជាមួយឱសថក្នុងក្រុម sulfa
- ជំងឺថ្លើមធ្ងន់ធ្ងរ
- ជំងឺខ្វះឈាមក្រហមធ្ងន់ធ្ងរ ឬ neutropenia

- ជំងឺតម្រងនោមធ្ងន់ធ្ងរ: (eGFR <១៥មល/នាទី) ជំងឺតម្រងនោមកម្រិតមធ្យម (១៥ –៥០ម.ល/នាទី) → បន្ថយកម្រិតដូសដោយប្រើ ១SS លេប១ថ្ងៃ/ម្តង និងពិនិត្យមើល potassium។
- ថយចុះ Glucose-6-phosphate dehydrogenase(G6PD)។

## ៥.៥ ការព្យាបាលបង្ការដោយឱសថ Cotrimoxazole ចំពោះស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន

- អង្គការ WHO បានអនុម័តឱ្យប្រើប្រាស់ឱសថ cotrimoxazole ជាអាទិភាពចំពោះស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ ហើយគេមិនទាន់មានភស្តុតាងណាមួយបញ្ជាក់ថា ការប្រើប្រាស់ឱសថនេះ បណ្តាលឱ្យមានការប្រែប្រួលរូបរាងកូនពីកំណើត (teratogenicity) នោះទេ ។ ផ្ទុយទៅវិញ ផលប្រយោជន៍បានមកពីការព្យាបាលបង្ការដោយឱសថ cotrimoxazole មានច្រើនជាងផលប៉ះពាល់របស់វា។
- រូបមន្តព្យាបាលដោយប្រើប្រាស់ឱសថ Cotrimoxazole សម្រាប់អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ បានទទួលលទ្ធផលដូចគ្នាជាមួយនឹងការព្យាបាល intermittent preventive treatment (IPT) នៃជំងឺគ្រុនចាញ់ (ហាមប្រើប្រាស់ឱសថប្រឆាំងជំងឺគ្រុនចាញ់បន្ថែម)។

## ៥.៦ អន្តរកម្មឱសថ

- *ឱសថនេះបណ្តាលឱ្យរក្សាទុក potassium ក្នុងឈាម (retention) ឧ. ACE inhibitors*—បង្កើនហានិភ័យនៃ hyperkalaemia ដូច្នេះត្រូវតាមដានកំហាប់ potassium។
- ឱសថ Cotrimoxazole អាចមានឥទ្ធិពលលើការលេបឱសថបញ្ចុះជាតិស្ករ (hypoglycaemic agents) ត្រូវតាមដាន BSL។

## ៥.៧ ការតាមដាន

*ភាពញឹកញាប់នៃការតាមដាន:* ត្រូវតាមដាន១ខែ/ម្តងរហូតដល់ស្ថានភាពសុខភាពអ្នកជំងឺមានលំនឹង បន្ទាប់មករាល់៣ខែ/ម្តង ។

- ពិនិត្យមើលការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់និងជាប់លាប់ និងការយល់ដឹងរបស់អ្នកជំងឺ។
- តាមដានប្រតិកម្ម hypersensitivity មានគ្រុនក្តៅ និងស្នាមកន្ទួលលើស្បែក។
- តាមដានផលប៉ះពាល់ផ្សេងទៀត ដូចជា GIT hyperkalaemia (ជាពិសេស ករណីប្រើប្រាស់ ACE inhibitor) ថយចុះខួរឆ្អឹង នាំឱ្យកើតជំងឺស្លេកស្លាំង (anaemia) neutropenia, thrombocytopenia ការរលាកថ្លើម ករណីកំរអាចមានគ្រួសក្នុងតម្រងនោម/ស្ទះបង្ហូរនោម វិបត្តិសរសៃប្រសាទ។

## ៥.៨ ប្រតកម្ម hypersensitivity នៃឱសថ Cotrimoxazole

- ជាទូទៅ អាចកើតឡើងក្នុងកំឡុងពេលពី២ទៅ៣ថ្ងៃ–២ទៅ៣សប្តាហ៍ ក្រោយពីការព្យាបាល មានលេចចេញរោគសញ្ញាលើស្បែក និងមាន systemic symptoms៖ ស្នាមកន្ទួលលើស្បែក និង គ្រុនក្តៅ កើតឡើងជាញឹកញាប់។
- រោគសញ្ញាលើស្បែក៖ ស្ងួត → ស្នាមកន្ទួលមានទឹក(wetrash) មានStevens-Johnson syndrome និងការរលួយស្បែក (toxic epidermal necrolysis) ។
- រោគសញ្ញាជាប្រព័ន្ធ (Systemic)៖ គ្រុនក្តៅពិបាកដកដង្ហើម (dyspnoea) + ក្អកមានeosinophilia រលាកថ្លើម រលាកតម្រងនោម (interstitial nephritis) lupus-like syndrome multi-organ hypersensitivity syndrome, vasculitis និង pancytopenia ។

## ៥.៩ ការគ្រប់គ្រងព្យាបាលផលប៉ះពាល់

- ការលេចចេញស្នាមកន្ទួលលើស្បែកកម្រិតស្រាល(ស្បែកស្ងួត) កើតឡើងជាញឹកញាប់ ហើយ ជាទូទៅ ត្រូវគ្រប់គ្រងដោយតាមដានដោយយកចិត្តទុកដាក់ និងបន្តការព្យាបាលបង្ការដោយ ឱសថ cotrimoxazole ឬ ត្រូវបញ្ឈប់ការព្យាបាល ករណី ស្នាមកន្ទួលនៅជាប់រហូត ។
- បញ្ឈប់ការព្យាបាលដោយឱសថ cotrimoxazole ក្នុងករណីធ្ងន់ធ្ងរ (ជាទូទៅ មានចេញទឹករងៃ) មានស្នាមកន្ទួលស្បែកធ្ងន់ធ្ងរ រួមមាន Stevens Johnson syndrome លេចចេញរោគសញ្ញា រលាកថ្លើម ជំងឺស្លេកស្លាំងធ្ងន់ធ្ងរ ឬ pancytopaenia ក្នុងករណីធ្ងន់ធ្ងរ ត្រូវបញ្ជូនអ្នកជំងឺមកមន្ទីរ ពេទ្យ។
- ករណីមិនសូវធ្ងន់ធ្ងរ ដូចជា ការថយចុះ Hb ឬ គោលិកាឈាមស អាចគ្រប់គ្រងបានដោយកាត់ បន្ថយកំម្រិតដូសឱសថ cotrimoxazole។

**តារាងទី ៥-២ ការគ្រប់គ្រងព្យាបាលស្នាមកន្ទួលលើស្បែក បណ្តាលមកពីប្រតិកម្មឱសថ *Cotrimoxazole***

| កម្រិតនៃភាពធ្ងន់ធ្ងរ | បរិយាយ | គ្រប់គ្រងព្យាបាល |
|---|---|---|
| **កម្រិតទី១** | ឡើងស្នាមកន្ទួលក្រហម ហើយ រាលដាល (Patchy Erythema) អាចរមាស់ | បន្តព្យាបាលដោយឱសថ Cotrimoxazole តាមដានរយៈពេល៣-៤ថ្ងៃ ពិចារណាក្នុងប្រើ ឱសថ Antihistamines ដើម្បីបន្ធូរបន្ថយរោគ សញ្ញា។ |
| **កម្រិតទី២** | ឡើងស្នាមកន្ទួល Maculopapular ស្ងួត អាចលេចចេញជាទំរង់ Morbilliform Minimal Exfoliation | បន្តព្យាបាលដោយឱសថ Cotrimoxazole តាមដានរយៈពេល១-២ថ្ងៃ ពិចារណាក្នុងប្រើ ឱសថ Antihistamines ដើម្បីបន្ធូរបន្ថយរោគ សញ្ញា។ |

| | | |
|---|---|---|
| **កម្រិតទី៣** | Vesiculation, ដំបៅ Mucosal | ត្រូវឈប់ប្រើឱសថ Cotrimoxazole រហូតដល់ប្រតិកម្មបានជាសះស្បើយវិញ (ជាទូទៅ រយៈពេល២សប្តាហ៍) បន្ទាប់មកចាប់ផ្តើមប្រើឡើងវិញ ឬត្រូវពិចារណាកាត់បន្ថយភាព Desensitization ។ |
| **កម្រិតទី៤** | រលាកស្បែក Exfoliative, ចង្កោមរោគសញ្ញា Stevens-Johnson ឬ Erythema Multiforme, របកស្រកា (Moist Desquamation) | ត្រូវឈប់ប្រើឱសថ Cotrimoxazole ភ្លាម ត្រូវចូលសំរាកពេទ្យដើម្បីទទួលការថែទាំព្យាបាល។<br>**មិនត្រូវប្រើឱសថ Cotrimoxazole សារជាថ្មីទេ ។** |

- ឱសថ Dapsone មានប្រសិទ្ធភាពតិចជាងឱសថ Cotrimoxazole ក្នុងការព្យាបាលបង្ការជំងឺ PCP និងមិនមានសកម្មភាពប្រឆាំងនឹងមេរោគបានទូលំទូលាយដូចឱសថ Cotrimoxazole ទេ។ គប្បីសាកល្បងកាត់បន្ថយភាពប្រតិកម្មជាមួយឱសថ Cotrimoxazole (Desensitization to Cotrimoxazole) លើអ្នកជំងឺដែលមិនធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរជាមួយឱសថ Cotrimoxazole មុននឹងសំរេចចិត្តប្រើប្រាស់ឱសថ Dapsone ជំនួសវិញ។

## ៥.១០ ការកាត់បន្ថយប្រតិកម្មជាមួយឱសថ Cotrimoxazole សម្រាប់ការចាប់ផ្តើមព្យាបាលសារជាថ្មី

- កាត់បន្ថយប្រតិកម្មអាចធ្វើឡើងក្នុងរយៈពេល២សប្តាហ៍ក្រោយពីមានប្រតិកម្មមិនសូវធ្ងន់ធ្ងរជាមួយនឹងឱសថ Cotrimoxazole (កម្រិតទី៣ ឬ តិចជាងនេះ)។
- កាត់បន្ថយប្រតិកម្មជាមួយឱសថ Cotrimoxazole បានបង្ហាញថា មានអត្រាជោគជ័យ ពី៨០ ទៅ ៨០% នៃអ្នកជំងឺដែលធ្លាប់មានប្រតិកម្ម Hypersensitivity ហើយកំរមានប្រតិកម្មធ្ងន់ធ្ងរ។
- **ការកាត់បន្ថយប្រតិកម្មមិនត្រូវអនុវត្តចំពោះអ្នកជំងឺដែលធ្លាប់មានប្រវត្តិប្រតិកម្មជាមួយឱសថ cotrimoxazole កម្រិតទី៤ ឬ ជាមួយឱសថក្រុម Sulfa ពីមុនទេ។**
- ត្រូវចាប់ផ្តើមព្យាបាលដោយផ្តល់ Antihistamine មុននឹងផ្តល់ឱសថ Cotrimoxazole អាចបន្ថយហានិភ័យនៃប្រតិកម្ម hypersensitivity ហើយត្រូវបន្តផ្តល់ Antihistamine លេប១ថ្ងៃមុន ឬឱ្យលេបនៅថ្ងៃដែលចាប់ ផ្តើមព្យាបាលដោយឱសថ Cotrimoxazole និងបន្តលេបរាល់ថ្ងៃ រហូតដល់ការដំឡើងកម្រិតដូសឱសថ Cotrimoxazole បន្តិចម្តងៗត្រូវបានបញ្ចប់។

តារាងទី ៥-៣ វិធីសារនៃការកាត់បន្ថយប្រតិកម្មនៃឱសថ *Cotrimoxazole* ចំពោះមនុស្សពេញវ័យ និងក្មេងជំទង់

| កាលបរិច្ឆេទ | កម្រិតដូស cotrimoxazole * |
|---|---|
| ថ្ងៃទី១ | ១៦ម.ក្រ TMP/៨០ម.ក្រ SMX (២ ម.ល oral suspension) |
| ថ្ងៃទី២ | ៣២ម.ក្រ TMP/១៦០ម.ក្រ SMX (៤ម.ល oral suspension) |
| ថ្ងៃទី៣ | ៤៨ម.ក្រ TMP/២៤០ម.ក្រ SMX (៦ម.ល oral suspension) |
| ថ្ងៃទី៤ | ៦៤ម.ក្រ TMP/៣២០ម.ក្រ SMX (៨ម.ល oral suspension) |
| ថ្ងៃទី៥ | One single-strength (SS) TMP ៨០ម.ក្រ /SMX ៤០០ម.ក្រ គ្រាប់ |
| ថ្ងៃទី៦ និងថ្ងៃបន្តបន្ទាប់ | One double- strength (DS) TMP ១៦០ម.ក្រ/SM X ៨០០ម.ក្រ គ្រាប់ |
| * Cotrimoxazole oral suspension លេប ៨០ម.ក្រ TMP + ២០០ម.ក្រ SMX ក្នុង ៥ម.ល | |

- អ្នកជំងឺត្រូវមកព្យាបាលនៅគ្លីនិករាល់ថ្ងៃដើម្បីលេបថ្នាំតាមកម្រិតដូសម្តងៗ និងសំរាកមួយម៉ោងក្រោយពេលលេបថ្នាំ។
- មុននឹងផ្តល់ឱ្យលេបកម្រិតដូសបន្ទាប់ត្រូវពិនិត្យអ្នកជំងឺ រករោគសញ្ញាស្នាមកន្ទួលលើស្បែក និងគ្រុនក្តៅ។
- ប្រតិកម្មធ្ងន់ធ្ងរ(កម្រិតទី៣/៤)៖ បញ្ឈប់ការកាត់បន្ថយកម្រិតដូសឱសថក្នុងរូបមន្តព្យាបាលភ្លាមៗ និងត្រូវពិចារណាឱ្យអ្នកជំងឺសំរាកពេទ្យ ក្នុងករណីចាំបាច់។
- ប្រតិកម្មកម្រិតស្រាលទៅកម្រិតមធ្យម(កម្រិតទី១/២)៖ ផ្តល់កម្រិតដូសដូចគ្នាថែមមួយថ្ងៃទៀត។ ប្រសិនបើប្រតិកម្មបានធូរស្រាល បង្កើនកម្រិតដូសនៅថ្ងៃបន្ទាប់ និងពន្យឺតនៃការដំឡើងកម្រិតដូសតាមវិធីសារ ឧ. ប្រើប្រាស់កម្រិតដូសស្មើគ្នាសម្រាប់រយៈពេលពីរថ្ងៃ ។ ប្រសិន បើប្រតិកម្មធ្ងន់ធ្ងរ ត្រូវបញ្ឈប់រូបមន្តនៃការកាត់បន្ថយប្រតិកម្ម។
- នៅពេលបង្កើតបាននូវកម្រិតដូសសម្រាប់ព្យាបាលមួយ មិនត្រូវបញ្ឈប់ការព្យាបាលទេ ។
- ករណីការអនុវត្តន៍វិធីសារកាត់បន្ថយប្រតិកម្មទទួលបរាជ័យត្រូវពិចារណាប្រើប្រាស់ឱសថ Dapsone ១០០ម.ក្រ/ថ្ងៃ ជំនួសវិញ។

## ៥.១១ ការបង្កើនការកាត់បន្ថយប្រតិកម្ម Cotrimoxazole ចំពោះអ្នកជំងឺសំរាកពេទ្យ

- ក្នុងករណីបន្ទាន់និងមានធនធាន ត្រូវបង្កើនការកាត់បន្ថយប្រតិកម្មជាមួយឱសថ cotrimoxazole ចំពោះអ្នកជំងឺសំរាកព្យាបាល ក្នុងមន្ទីរពេទ្យលើសពី៦ម៉ោង។ វាមានសារៈសំខាន់ក្នុងការព្យាបាល ភ្លាមៗ ចំពោះជំងឺ PCP សកម្ម ឬជំងឺបង្កដោយ toxoplasmosis ។
- តម្រូវឱ្យឱសថការី លាយម្សៅថ្នាំលើកដំបូងក្នុងកម្រិត ១:២០០០ សម្រាប់កម្រិតដូសតាមម៉ោងនៃ TMP/SMX: ០,០០៤/០,០២ ០,០៤/០,២ ០,៤/២,០ ៤.០/២០ ៤០/២០០ ១៦០/៨០០ ម.ក្រ។

# ជំពូក ៦. ការពិនិត្យសុខភាពស្រាវជ្រាវរកជំងឺរបេង និង ការវាយតម្លៃ ដើម្បីព្យាបាលបង្ការដោយឱសថ Isoniazid (IPT)

- ជំងឺរបេង ជាមូលហេតុដែលកើតឡើងញឹកញាប់ជាងគេ នៃការឈឺ និងការស្លាប់ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ នៅទូទាំងពិភពលោក ច្រើនជាងមួយភាគបួននៃការស្លាប់ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ គឺបណ្តាលមកពីជំងឺរបេង[១១] ។
- ប្រទេសកម្ពុជា គឺមានអត្រាជំងឺរបេងខ្ពស់ក្នុងចំណោមប្រជាជនទូទៅ ។
- អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដែលមានការបង្ករោគរបេងរួមគ្នា មានហានិភ័យក្នុងអត្រាពី ៣០ ទៅ ៥០% ក្នុងការវិវត្តន៍ទៅជំងឺរបេងសកម្មនៅពេលណាមួយនៃជីវិត ។
- ការព្យាបាលបង្ការដោយឱសថ Isoniazid អាចកាត់បន្ថយហានិភ័យក្នុងការវិវត្តន៍ទៅជាជំងឺរបេងសកម្ម ។

សូមអានជំពូកទី១៣ ការវាយតម្លៃ និងការគ្រប់គ្រងព្យាបាលជំងឺរបេងសកម្ម។

## ៦.១ ការពិនិត្យសុខភាពស្រាវជ្រាវរករោគសញ្ញាជំងឺរបេងសកម្ម

មនុស្សពេញវ័យ និងក្មេងជំទង់ដែលផ្ទុកមេរោគអេដស៍ ត្រូវបានសេវាពិនិត្យសុខភាពស្រាវជ្រាវរករោគសញ្ញាគ្លីនិកនៃជំងឺរបេងសកម្ម រាល់ពេលមកពិគ្រោះជំងឺ ។

**តារាងទី ៦-១ ការពិនិត្យគ្លីនិកស្រាវជ្រាវរកជំងឺរបេង**

| សួរអ្នកជំងឺ តើគាត់មានរោគសញ្ញាណាមួយ ដូចខាងក្រោម កាលពី ៤សប្តាហ៍មុន? |
|---|
| ១. ក្អក: កើតឡើងគ្រប់ពេល និង មិនកំណត់រយៈពេល |
| ២. គ្រុនក្តៅ: កើតឡើងគ្រប់ពេល និងមិនកំណត់រយៈពេល |
| ៣. បែកញើសពេលយប់ ≥ ២សប្តាហ៍ |
| ៤. ស្រកទំងន់? និង ថ្លឹងទម្ងន់អ្នកជំងឺរាល់ពេលមកពិគ្រោះជំងឺ និងប្រៀបធៀបជាមួយនឹងទម្ងន់គាត់ដែលបានថ្លឹងកាលពីពេលមកពិគ្រោះជំងឺលើកមុន។ |

- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ដែល ក្អក គ្រុនក្តៅ ស្រកទម្ងន់ ឬបែកញើសពេលយប់ អាចកើតជំងឺរបេងសកម្ម និងត្រូវធ្វើការវាយតម្លៃពីជំងឺរបេង និងជំងឺផ្សេងទៀត។

- អ្នកជំងឺអេដស៍ដែលគ្មានរោគសញ្ញាណាមួយ ដូចជា ក្អក គ្រុនក្តៅ ស្រកទម្ងន់ ឬបែកញើសពេលយប់ មិនទំនងជាកើតជំងឺរបេងសកម្មទេ។ ដូច្នេះ អ្នកជំងឺនេះ អាចទទួលការព្យាបាលបង្ការ IPT។

---

[១១] គោលការណ៍ណែនាំសំរាប់ពង្រឹងការរុករកជំងឺរបេងនិងការព្យាបាលបង្ការដោយ INH សំរាប់អ្នករស់នៅជាមួយមេរោគអេដស៍នៅបរិបទដែលធនធានមានកំណត់ អង្គការសុខភាពពិភពលោក២០១១។

រូបភាពទី ៦-១ គំនូសបំព្រួញអំពីការពិនិត្យសុខភាពស្រាវជ្រាវរកជំងឺរបេងលើមនុស្សពេញវ័យ និងក្មេងជំទង់ដែលផ្ទុកមេរោគអេដស៍




## ៦.២ ពេលណាដែលត្រូវចាប់ផ្តើមព្យាបាល រូបមន្តព្យាបាល និងរយៈពេលព្យាបាល IPT

តារាងទី ៦-២ លក្ខណៈវិនិច្ឆ័យនៃការចាប់ផ្តើមការព្យាបាល ការព្យាបាលបន្ត និងការបញ្ឈប់ការព្យាបាលដោយឱសថ *Isoniazid (IPT)*

| IPT | **ការពិនិត្យសុខភាពស្រាវជ្រាវរកជំងឺរបេង ត្រូវធ្វើឡើងរាល់ពេលអ្នកជំងឺមកពិគ្រោះជំងឺ** |
|---|---|
| **ពេលណាចាប់ផ្តើមព្យាបាល IPT ចំពោះមនុស្សពេញវ័យ និងក្មេងជំទង់** | • គ្រប់ជំងឺទាំងអស់ដែលគ្មានរោគសញ្ញាជំងឺរបេង និងគ្មាន contraindications ជាមួយថ្នាំ។ Contraindications: អាចប៉ះពាល់ peripheral neuropathy ផឹកសុរាច្រើន ឡើង ALT/AST > ៣ x ULN។<br>• អ្នកជំងឺដែលរកឃើញរោគសញ្ញាជំងឺរបេង វិជ្ជមាន ចាប់ផ្តើមព្យាបាលដោយ IPT ក្រោយពីផាត់ចោលជំងឺរបេងសកម្មចេញ។<br>• ក្រោយពីព្យាបាលជំងឺរបេងបានបញ្ចប់(ការព្យាបាលបង្ការលើកទីពីរ)(*)<br>*ចាប់ផ្តើមព្យាបាល IPT នៅពេលដែលអ្នកជំងឺមកពិគ្រោះជំងឺលើកដំបូងក្រោយពីចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។*<br>*ផ្តល់ឱសថប្រឆាំងមេរោគអេដស៍ណាដែលអ្នកជំងឺអេដស៍ទ្រាំទ្រជាមួយផល* |

| | |
|---|---|
| | *លំបាកបាន និងរោគសញ្ញាគ្លីនិកមានលំនឹង។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវចាប់ផ្ដើមព្យាបាលបង្ការដោយឱសថ INH ឱ្យបានឆាប់ លើអ្នកជំងឺដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ហើយស្ថានភាពសុខភាពមានលំនឹង។* |
| ព្យាបាល IPT បន្ត | • បញ្ចប់ការព្យាបាលរយៈពេល៦ខែ (បើសិនមានការផ្អាកការព្យាបាល, សូមអានខាងក្រោម)។ |
| ពេលណាត្រូវបញ្ឈប់ការព្យាបាល IPT | • បើមានរោគសញ្ញារលាកថ្លើម (មិនឃ្លានអាហារ, ចង្អោរ, ក្អួត, ឈឺពោះ, រងារញាក់, រោគលឿង (icterus) និងទឹកនោមខ្មៅ) ត្រូវបញ្ឈប់ការព្យាបាលដោយឱសថ INH ភ្លាម និងបញ្ជូនអ្នកជំងឺទៅសេវាថែទាំនិងព្យាបាលជំងឺអេដស៍។<br>• បើតេស្ត ALT/AST កើនឡើង ត្រូវតាមដានអ្នកជំងឺ ដែលមានការរលាកថ្លើម ដូចខាងក្រោម៖<br>▪ គ្មានរោគសញ្ញា និង ALT/AST > ៥ដង x ULN ឬ<br>▪ មានរោគសញ្ញា និង ALT/AST > ៣ដង x ULN<br>• បើមានរោគសញ្ញាជំងឺសរសៃប្រសាទជាប់ជានិច្ច ក្រោយពីបង្កើនកម្រិតដូសឱសថ pyridoxine ដល់ ១០០ ម.ក្រ/ថ្ងៃ<br>• ក្រោយពីបញ្ចប់ការព្យាបាល IPT រយៈពេល ៦ខែ។ |

(*) ដើម្បីបញ្ឈប់ និងការពារបង្ករោគថ្មីៗ នៅពេលចាប់ផ្ដើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។

## ៦.៣ កម្រិតដូស និងរយៈពេលព្យាបាល IPT

| |
|---|
| រយៈពេល ៦ ខែ:<br>• បើ > ៤០គ.ក្រ: Isoniazid ៣០០ម.ក្រ/ថ្ងៃ + pyridoxine ៥០ម.ក្រ/ថ្ងៃ<br>• បើ ≤ ៤០គ.ក្រ: Isoniazid ២០០ម.ក្រ /ថ្ងៃ + pyridoxine ៥០ម.ក្រ/ថ្ងៃ |

## ៦.៤ ផលប៉ះពាល់នៃឱសថ

- ជាទូទៅ ផលប៉ះពាល់នៃ IPT អាចទ្រាំទ្របានល្អ។
- ផលប៉ះពាល់ចំបងគឺ
    - ប្រព័ន្ធរំលាយអាហារ(Gastrointestinal) – រួមមាន ចង្អោរ និង ក្អួតម្ដងម្កាល ។
    - ការរលាកថ្លើម – កម្រិតអត្រា ០,៣% ក្នុងចំណោមមនុស្សពេញវ័យ និងប្រហែល ២- ៣% ចំពោះមនុស្សពេញវ័យ។
    - Peripheral neuropathy–ភាគច្រើនអាចព្យាបាលបង្ការដោយឱសថ pyridoxine អាចបង្កើនកម្រិតដូសដល់ ១០០ម.ក្រ/ថ្ងៃ បើមានរោគសញ្ញាជំងឺ Peripheral neuropathy ជាប់ជានិច្ចត្រូវបញ្ឈប់ការព្យាបាលដោយឱសថ INH។
    - ប្រតិកម្ម Hypersensitivity។

## ៦.៥ ការផ្តល់ប្រឹក្សាអំពីការព្យាបាល IPT ដល់អ្នកជំងឺ

- ត្រូវផ្តល់ព័ត៌មានជូនអ្នកជំងឺឱ្យដឹងថា ការព្យាបាល IPT មានរយៈពេល ៦ខែ។
- អ្នកជំងឺមិនត្រូវសេពគ្រឿងស្រវឹងច្រើន និងជាទៀងទាត់បានទេ និងយល់ព្រមថា មិនសេពគ្រឿងស្រវឹងទេ។
- បើអ្នកជំងឺមានរោគសញ្ញារលាកថ្លើម៖ មិនឃ្លានអាហារ, ចង្អោរ, ក្អួត, ឈឺពោះ, រងារញាក់, រោគលឿង(ភ្នែកលឿង) និងទឹកនោមខ្មៅ *ត្រូវបញ្ឈប់ការព្យាបាលដោយឱសថ INH ភ្លាមៗ* និងបញ្ជូនអ្នកជំងឺទៅសេវាថែទាំនិងព្យាបាលជំងឺអេដស៍។

## ៦.៦ ការតាមដានរោគសញ្ញាគ្លីនិកនៅពេលកំពុងព្យាបាល IPT

អ្នកជំងឺត្រូវត្រឡប់មកសេវាថែទាំនិងព្យាបាលជំងឺអេដស៍រៀងរាល់ខែ–នៅពេល៖

- វាយតម្លៃរោគសញ្ញាគ្លីនិកបញ្ជាក់ពីការពុលនៃឱសថ INH។
- ពិនិត្យសុខភាពស្រាវជ្រាវរកជំងឺរបេងសកម្ម (រាល់ពេលអ្នកជំងឺមកពិគ្រោះជំងឺ ជាបន្តបន្ទាប់ និងក្រោយពេលបញ្ចប់ការព្យាបាល IPT)។
- ផ្តល់ឱសថ INH + pyridoxine ជូនអ្នកជំងឺរយៈពេល១ខែម្តង។

## ៦.៧ តាមដានមុខងារថ្លើម នៅពេលដើមគ្រា និង នៅពេលកំពុងព្យាបាល IPT

- ALT/AST ត្រូវធ្វើនៅពេលដើមគ្រា **តែម្តងទេ** ដោយមិនចាំបាច់ធ្វើតេស្តនេះតាមដានជាប្រចាំចំពោះអ្នកជំងឺដែលគ្មានការប្រឈមមុខនឹងជំងឺរលាកថ្លើម (សូមអានផ្នែកខាងក្រោម)៖
    - បើ ALT/AST > ៣ដង x ULN ធៀបនឹងតេស្តនៅពេលដើមគ្រា មិនត្រូវព្យាបាល IPT ទេ។
    - បើ ALT/AST លើសពីកម្រិតធម្មតា (ULN) ប៉ុន្តែ < ៣ដង x ULN ត្រូវធ្វើតេស្ត HBsAg និងធ្វើតេស្ត ALT/AST ម្តងទៀតនៅខែទី១ និងខែទី២ និងបន្តការធ្វើតេស្តតាមដានរាល់ខែ។
- បើមានការប្រឈមមុខខ្ពស់នឹងជំងឺរលាកថ្លើម (ឧ. មេរោគរលាកថ្លើមប្រភេទB ប្រភេទ C ប្រវត្តិជំងឺថ្លើម) បញ្ឈប់ការធ្វើតេស្ត ALT/AST តាមដានរាល់ខែ។
- ករណីលេចចេញរោគសញ្ញាគ្លីនិក និង/ឬ មានរោគសញ្ញារលាកថ្លើម (មិនឃ្លានអាហារ, ចង្អោរ, ក្អួត, ឈឺពោះ, រងារញាក់, រោគលឿង និងទឹកនោមខ្មៅ) *ត្រូវបញ្ឈប់ការព្យាបាលដោយឱសថ INH ភ្លាមៗ* និងត្រូវធ្វើតេស្ត ALT/AST ជាបន្ទាន់។

## ៦.៨ បញ្ឈប់ការព្យាបាល IPT

- ត្រូវផ្តល់យោបល់អ្នកជំងឺថា វាមានសារៈសំខាន់ណាស់ក្នុងការព្យាបាល IPT តាមវេជ្ជបញ្ជា ហើយបន្តការព្យាបាលរហូតដល់៦ខែ។
- ករណីផ្អាកការព្យាបាល IPT ត្រូវអនុវត្តដូចខាងក្រោម៖
  - បើផ្អាកការព្យាបាល <៨សប្តាហ៍ *ត្រូវពិនិត្យសុខភាពស្រាវជ្រាវជំងឺរបេងសកម្ម* បើគ្មានជំងឺរបេងសកម្មទេ ត្រូវបន្តការព្យាបាលដោយឱសថ INH និងបន្តរហូតគម្រប់រយៈពេលព្យាបាលសរុប ៦ខែ។
  - បើផ្អាកការព្យាបាល ≥ ៨សប្តាហ៍ *ត្រូវពិនិត្យសុខភាពស្រាវជ្រាវជំងឺរបេងសកម្ម* បើគ្មានជំងឺរបេងសកម្ម ត្រូវចាប់ផ្តើមការព្យាបាលដោយឱសថ INH ឡើងវិញ រយៈពេល ៦ខែ។
- ប្រើសិនបើអ្នកជំងឺផ្អាកការព្យាបាល IPTលើសពីរម្តង មិនចាំបាច់ព្យាយាមចាប់ផ្តើមការព្យាបាលគាត់សាជាថ្មីទៀតទេ។

# ជំពូក ៧. ការពិនិត្យសុខភាពស្រាវជ្រាវរកមេរោគ Cryptococcus និង ការព្យាបាលបង្ការ

## ៧.១ ការព្យាបាលបង្ការជំងឺ Cryptococcus បឋម និងការធ្វើតេស្តស្រាវជ្រាវ CRAG

ជំងឺរលាកស្រោមខួរដោយមេរោគ Cryptococcus(CM) គឺជាមូលហេតុដ៏ចំបងនៃការឈឺ និងការស្លាប់ ក្នុងចំណោមអ្នកជំងឺអេដស៍នៅប្រទេសកម្ពុជា។ ជំងឺនេះកើតឡើងជាញឹកញាប់ លើអ្នកជំងឺអេដស៍ក្នុងដំណាក់កាលធ្ងន់ធ្ងរដែលមានកោសិកា CD4 <១០០កោសិកា/មម³ ហើយកាន់តែមានការប្រឈមមុខខ្ពស់ក្នុងការកើតជំងឺនេះ លើអ្នកជំងឺដែលមានកោសិកា CD4 < ៥០កោសិកា/មម³។

**រកឃើញអង់ទីសែ្សន** Cryptococcus (CRAG)

- ប្រើប្រាស់វិធីសាស្រ្តសាមញ្ញមានតម្លៃទាប ក្នុងការធ្វើតេស្តរកអង់ទីហ្សែន Cryptococcus (CRAG) ដោយប្រើប្រាស់តេស្ត Lateral Flow Assay (LFA) សម្រាប់ធ្វើតេស្តស្រាវជ្រាវរកការបង្ករោគដោយក្រិបតូកុក ហើយតេស្តនេះ អាចនឹងដាក់ឱ្យប្រើប្រាស់នៅប្រទេសកម្ពុជាក្នុងពេលឆាប់ៗខាងមុខនេះ។
- តេស្ត CRAG អាចធ្វើការស្រាវជ្រាវរកការបង្ករោគដោយក្រិបតូកុក មុននឹងជំងឺនេះលេចចេញរោគសញ្ញាគ្លីនិក។
- ការបង្ករោគដោយក្រិបតូកុកដែលគ្មានរោគសញ្ញាគ្លីនិក នឹងមានការប្រឈមមុខក្នុងការវិវត្តន៍ជាជំងឺបង្កដោយក្រិបតូកុក ក្នុងពេលណាមួយហើយអាចប្រែប្រួលពីច្រើនសប្តាហ៍ ឬច្រើនខែ ។
- ការសិក្សាពីរនៅប្រទេសកម្ពុជាបានរកឃើញថា ប្រហែលជា ២០% (មានរោគសញ្ញាគ្លីនិកនិងគ្មានរោគសញ្ញាគ្លីនិក) និងប្រហែល ៨% (គ្មានរោគសញ្ញាគ្លីនិក) នៃអ្នកជំងឺដែលមានកោសិកា CD4 <១០០ មានលទ្ធផលតេស្ត CRAG វិជ្ជមាន នៅពេលអ្នកជំងឺមកទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍។

**សេណារីយ៉ូនៃរោគសញ្ញាគ្លីនិក និងលទ្ធផល** CRAG **វិជ្ជមាន រួមមាន៖**

១. ជំងឺរលាកស្រោមខួរដោយ cryptococcus(CM)/ជំងឺផ្សេងទៀតបង្កដោយ cryptococcs មានរោគសញ្ញាគ្លីនិក។

២. ជំងឺរលាកស្រោមខួរដោយ cryptococcus (CM) គ្មានរោគសញ្ញាគ្លីនិក។

៣. តេស្តអង់ទីសែ្សនក្រិបតូកុកនៅក្នុងឈាម វិជ្ជមាន (ICPA) តែឯកឯង។

- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ដែលបានធ្វើរោគវិនិច្ឆ័យថា មានជំងឺរលាកស្រោមខួរដោយក្រិបតូកុក ទាំងមានរោគសញ្ញាគ្លីនិក ឬគ្មានរោគសញ្ញាគ្លីនិក តម្រូវឱ្យសំរាកព្យាបាលក្នុងមន្ទីរពេទ្យ និងផ្តល់ការព្យាបាលស្តង់ដា (សូមអាន ជំពូក ១៧. ជំងឺរលាកស្រោមខួរបង្កដោយមេរោគ Cryptococcus (CM) ។

## ៧.២ ការព្យាបាលបង្ការបឋមដោយឱសថ Fluconazole

គួរបន្តការព្យាបាលដោយឱសថ Fluconazole រហូតដល់មានតេស្ត CRAG ៖

### តារាងទី ៧-១ ការព្យាបាលបង្ការដោយឱសថ *Fluconazole (ករណីគ្មានតេស្ត CRAG)*

| | |
|---|---|
| ពេលណាដែលត្រូវចាប់ផ្តើមព្យាបាលបង្ការដោយ ឱសថ Fluconazole | កោសិកា CD4 < ១០០កោសិកា/មម[៣]<br>*និង* ក្រៅពីស្ត្រីមានផ្ទៃពោះនៅត្រីមាសទី១<br>*និង* AST/ALT < ៣ដង x ULN* |
| ពេលណាដែលត្រូវបញ្ឈប់ព្យាបាលបង្ការដោយឱសថ Fluconazole | កោសិកា CD4 > ១០០ ក្រោយពីធ្វើតេស្តពីរដងជាប់គ្នា ឃ្លាតគ្នា > ៦ខែម្តង<br>*និង* តេស្ត VL រកមេរោគមិនឃើញ<br>ឬ បើមានជំងឺរលាកថ្លើម ត្រូវមើលៈ<br>• AST/ALT > ៣ដង x ULN និងមានរោគសញ្ញាគ្លីនិក<br>• ឬ AST/ALT > ៥ដង x ULN និងគ្មានរោគសញ្ញាគ្លីនិក |

* តាមដាន AST/ALT នៅពេលដើមគ្រា ខែទី១និងនៅខែទី២ក្រោយមក ប្រសិនជាមានរោគសញ្ញាគ្លីនិក។ ករណីមានការបង្ករោគរួមគ្នាជាមួយជំងឺរលាកថ្លើមប្រភេទ B/C ឬ តេស្ត AST/ALT នៅពេលដើមគ្រា មានលទ្ធផលមិនធម្មតា បន្តការតាមដានលទ្ធផលតេស្ត AST/ALT រៀងរាល់ខែ រហូតដល់ ៩ខែ។

## ៧.៣ ការធ្វើតេស្តស្រាវជ្រាវ Cryptococcal antigen (CRAG)

- ការធ្វើតេស្ត **CRAG** គឺសម្រាប់ស្រាវជ្រាវរកជំងឺបង្កដោយមេរោគ ក្រិបតូកុក តែប៉ុណ្ណោះ។ ករណីអ្នកជំងឺមានរោគសញ្ញាជំងឺរលាកស្រោមខួរ ត្រូវតែបូមទឹកខួរឆ្អឹងខ្នងភ្លាម ដោយមិនចាំបាច់រង់ចាំលទ្ធផលតេស្ត **CRAG** ទេ។ (សូមអានជំពូកទី១៦. ជំងឺរលាកស្រោមខួរ)។

- ចំពោះអ្នកជំងឺអេដស៍ទាំងមនុស្សពេញវ័យនិងក្មេងជំទង់ ទើបតែបានចុះបញ្ជីក្នុងសេវាថែទាំនិងព្យាបាលជំងឺអេដស៍ ហើយមានកោសិកាCD4 <១០០កោសិកា/មម[៣] ត្រូវធ្វើតេស្ត CRAG នៅថ្ងៃតែមួយនៅក្នុងមន្ទីរពិសោធន៍ដែលធ្វើតេស្តរាប់ចំនួនកោសិកា CD4។

### តើត្រូវធ្វើអ្វីខ្លះពេលទទួលបានលទ្ធផលតេស្ត CRAG?

- តេស្ត CRAG វិជ្ជមាន → ត្រូវហៅអ្នកជំងឺឱ្យត្រឡប់មកសេវាព្យាបាលជំងឺអេដស៍វិញ ដើម្បីវាយតម្លៃរោគសញ្ញាគ្លីនិកនៃជំងឺរលាកស្រោមខួរ ។
  - ➢ ប្រសិនជាមានរោគសញ្ញាគ្លីនិកនៃជំងឺរលាកស្រោមខួរ(ឈឺក្បាល រឹងក ខ្លាចពន្លឺ (photophobia) វង្វេងវង្វាន់ រោគសញ្ញាសរសៃប្រសាទ គ្រុនក្តៅ) → ត្រូវចាប់ផ្តើមព្យាបាល

ដោយឱសថ fluconazole ១២០០ម.ក្រ និងបញ្ជូនទៅបូមទឹកខួរឆ្អឹងខ្នងជាបន្ទាន់។ (សូមអាន ជំពូក ១៧. ជំងឺរលាកស្រោមខួរបង្កដោយមេរោគ Cryptococcus (CM)។

➢ ប្រសិនជាគ្មានរោគសញ្ញាគ្លីនិកនៃជំងឺរលាកស្រោមខួរ → ត្រូវចាប់ផ្តើមព្យាបាលដោយឱសថ fluconazole ៨០០ម.ក្រ/ថ្ងៃ x ២សប្តាហ៍ បន្ទាប់មកព្យាបាលបន្តក្នុងកម្រិតដូស ៤០០ម.ក្រ x ៨សប្តាហ៍។

- បើតេស្ត CRAG អវិជ្ជមាន → មិនត្រូវព្យាបាលដោយឱសថ fluconazole ទេ។
- គ្រប់អ្នកជំងឺដែលមានតេស្ត CRAG វិជ្ជមានទាំងអស់ ត្រូវលេបថ្នាំ fluconazole បន្តក្នុងកម្រិតដូស ២០០ម.ក្រ ក្នុងមួយថ្ងៃ រហូតលើសពី១ឆ្នាំ *និង* ធ្វើតេស្ត VL រកមើលមេរោគមិនឃើញ *និង* តេស្តកោសិកា CD4 > ១០០កោសិកា/មម៣ ក្រោយពីបានធ្វើតេស្តពីរលើក ឃ្លាតពីគ្នា > ៦ខែម្តង។

## ស្ត្រីមានផ្ទៃពោះ

ស្ត្រីស្ថិតក្នុងវ័យបង្កកំណើតដែលមានលទ្ធផលតេស្តស្រាវជ្រាវ CRAG វិជ្ជមាន ត្រូវធ្វើតេស្តបញ្ជាក់ពីការមានគភ៌ មុននឹងចាប់ផ្តើមព្យាបាលដោយឱសថ fluconazole (ពីព្រោះវាមានឥទ្ធិពល teratogenic)។ រីឯ ស្ត្រីដែលគ្មានគភ៌ ហើយត្រូវចាប់ផ្តើមព្យាបាលដោយឱសថ fluconazole ត្រូវផ្តល់យោបល់ឱ្យចៀសវាងការមានគភ៌ក្នុងកំឡុងពេលព្យាបាល។

- អ្នកជំងឺដែលមានតេស្ត CRAG វិជ្ជមាន ហើយមានផ្ទៃពោះ ត្រូវបូមទឹកខួរឆ្អឹងខ្នង (LP) និងត្រូវលើកករណីនេះ មកពិភាក្សាជាមួយគ្រូពេទ្យជំនាញ មុននឹងសំរេចចិត្តព្យាបាល ។

## រូបភាពទី ៧-១ ការពិនិត្យស្រាវជ្រាវ Cryptococcal Antigen

អ្នកជំងឺអេដស៍ថ្មីដែលទើបចុះ:

បើមានរោគសញ្ញាគ្លីនិកនៃ meningitis ដោយមិនរង់ចាំលទ្ធផលតេស្ត CRAG។ ត្រូវធ្វើ LP (សូមអានជំពូកទី១៦ ជំងឺរលាកស្រោមខួរ)

បើ CD4 < ១០០ត្រូវធ្វើតេស្តCRAG

CRAG អវិជ្ជមាន

ចាប់ផ្តើមព្យាបាលដោយ ART មិនត្រូវប្រើ fluconazole

CRAG វិជ្ជមាន

- ទាក់ទងអ្នកជំងឺ ដើម្បីតាមដាន
- ពិនិត្យស្រាវជ្រាវរកជំងឺ meningitis*
- ធ្វើតេស្ត AST/ALT < ៣ដង xULN
- តេស្តនៃការមានផ្ទៃពោះ អវិជ្ជមាន

មានរោគសញ្ញា*

ចាប់ផ្តើម Fluconazole ១២០០mg និង បញ្ជូនទៅធ្វើ LP ភ្លាម

LP: បន្ថយសម្ពាធ CCAG, glucose, Micro, India Ink.

LP វិជ្ជមាន

សំរាកពេទ្យ ឬម LP បរិមាណច្រើន CSF, ប្រើ Amphotericin B IVI និង fluconazole ៨០០mg /ថ្ងៃ x ២ សប្តាហ៍

គ្មានរោគសញ្ញា

LP អវិជ្ជមាន

អ្នកជំងឺក្រៅ ព្យាបាលដោយ fluconazole ៨០០mg /ថ្ងៃ x ២ សប្តាហ៍

ដំណាក់កាល Consolidation: ប្រើ Fluconazole ៤០០mg/ថ្ងៃ x ៨សប្តាហ៍
Maintenance: ២០០mg/ថ្ងៃ x ១ ឆ្នាំ + VL undetectable, CD4> ១០០ x ៦ខែ

ចាប់ផ្តើមព្យាបាលដោយ ART ៤ –៦ សប្តាហ៍ក្រោយពីការព្យាបាល antifungal ។

ចាប់ផ្តើមព្យាបាលដោយ ART ក្នុងកំឡុង ២ សប្តាហ៍នៃការព្យាបាល antifungal ។

***លក្ខណៈវិនិច្ឆ័យនៃការ ឬម LP ៖ មានរោគសញ្ញាជំងឺ meningitis:**
ឈឺក្បាល
រឹងក ខ្លាចពន្លឺ រោគសញ្ញាសរសៃប្រសាទ ឬ វង្វេងស្មារតី។

# ជំពូក ៨. ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

## ៨.១ លក្ខណៈវនិច្ឆ័យនៃការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង ពេលណាដែលត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍លើមនុស្សពេញវ័យ និងក្មេងជំទង់

តារាងទី ៨-១ លក្ខណៈវិនិច្ឆ័យនៃការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង ពេលណាដែលត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍លើមនុស្សពេញវ័យ និងក្មេងជំទង់

| | |
|---|---|
| អ្នកណាដែលត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | • **គ្រប់អ្នកជំងឺទាំងអស់ ដោយមិនគិតពីចំនួនកោសិកា CD4**<br>• ត្រូវផ្តល់អាទិភាពជូន:<br>    • អ្នកជំងឺអេដស៍ស្ថិតក្នុងដំណាក់កាលគ្លីនិក WHO ទី III/IV ឬ មានចំនួនកោសិកា CD4 ≤ ៣៥០<br>    • ស្ត្រីមានផ្ទៃនិងបំបៅដោះកូន ត្រូវអនុវត្តជម្រើស B+<br>    • អ្នកជំងឺអេដស៍ដែលបង្ករោគរួមគ្នាជាមួយជំងឺរលាកថ្លើមប្រភេទ B និង ជំងឺរបេង។ |
| ពេលណាដែលត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | • **កំឡុង២សប្តាហ៍ ក្រោយពីបានចុះក្នុងបញ្ជីត្រៀមព្យាបាលនិងបានផ្តល់ប្រឹក្សាអំពី ART រួច ។**<br>• បើមានជំងឺឱកាសនិយមមួយចំនួន ត្រូវពន្យាលពេលចាប់ផ្តើមព្យាបាល ART ក្រោយពីបានចាប់ផ្តើមព្យាបាលជំងឺឱកាសនិយម *<br>    • **ជំងឺរលាកស្រោមខួរដោយ គ្រិបតូកុក: ៤-៦សប្តាហ៍។**<br>    • **ជំងឺរបេងដែលមាន CD4 > ៥០: ២-៨ សប្តាហ៍។** |

* សូមមើលតារាងទី ៨-៣ ពេលវេលាដែលត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅពេលកំពុងមានជំងឺឱកាសនិយមសកម្ម ។

## ៨.២ រូបមន្តព្យាបាលជួរទី១ នៃឱសថប្រឆាំងមេរោគអេដស៍

តារាងទី ៨-២ រូបមន្តព្យាបាលស្តង់ដាជួរទី១ នៃឱសថប្រឆាំងមេរោគអេដស៍

| ឱសថប្រឆាំងមេរោគអេដស៍ជួរទី១ | ជម្រើសឱសថប្រឆាំងមេរោគ អេដស៍ជួរទី១ | ជម្រើសផ្សេងៗនៃ ឱសថប្រឆាំងមេរោគអេដស៍ជួរទី១* |
|---|---|---|
| មនុស្សពេញវ័យ រួមទាំង ស្ត្រីមានផ្ទៃពោះ/ម្តាយបំបៅ ដោះកូន និងបង្ករោគរួមគ្នា ជាមួយជំងឺរបេង និងក្មេងជំទង់ទម្ងន់>៣៥ គ.ក្រ | TDF + 3TC + EFV | AZT+ 3TC + EFV (or NVP)<br>TDF + 3TC + NVP |
| ក្មេងជំទង់ទម្ងន់ < ៣៥គ.ក្រ | TDF + 3TC + EFV | AZT+ 3TC + EFV (or NVP)<br>TDF + 3TC + NVP<br>ABC + 3TC + NVP |
| | *ABC ឬ PI ឬ នៅពេលមានឱសថ Dolutegravir អាចនឹងយកមកព្យាបាលក្នុងករណីពិសេស នៃជម្រើសក្នុងរូបមន្តព្យាបាលជួរទី១។ សូមពិភាក្សាជាមួយគ្រូពេទ្យជំនាញ។ | |

### ៨.២.១ ជម្រើសរូបមន្តព្យាបាលជួរទី១

**TDF + 3TC + EFV កម្រិតដូសរួមបញ្ចូលគ្នាលេបមួយថ្ងៃម្តង**

- ព្យាបាលដោយឱសថ TDF ៣០០ ម.ក្រ + 3TC ៣០០ ម.ក្រ + EFV ៦០០ ម.ក្រ គ្រាប់ថ្នាំសំប៉ែតដែលមានកម្រិតដូសរួមបញ្ចូលគ្នាគឺជាជម្រើសដ៏ល្អក្នុងរូបមន្តព្យាបាលជួរទី១បើគ្មាន contra-indications។
- រូបមន្តព្យាបាលនេះមានប្រសិទ្ធភាពខ្ពស់ និងមានភាពទ្រាំទ្រល្អ លេបមួយថ្ងៃម្តងមុនពេលហូបចំណីអាហារ (អាហារបង្កើនផលប៉ះពាល់នៃឱសថ EFV និងអាចបង្កើនផលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទកណ្តាល ផងដែរ)។
- រូបមន្តព្យាបាលនេះ សមស្របចំពោះមនុស្សពេញវ័យ និងក្មេងជំទង់ រួមទាំងស្ត្រីមានផ្ទៃពោះ និងម្តាយបំបៅដោះកូន និងអ្នកជំងឺដែលកំពុងព្យាបាលជំងឺរបេង។
- TDF និង 3TC ជាឱសថសម្រាប់ព្យាបាលជំងឺរលាកថ្លើមប្រភេទB ផងដែរ ដូច្នេះឱសថរួមបញ្ចូលគ្នាក្នុងក្រុម NRTI នេះ គឺជាជម្រើសមួយសម្រាប់ព្យាបាលការបង្ករោគរួមគ្នាជាមួយនឹងជំងឺរលាកថ្លើមប្រភេទB។
- TDF មានអានុភាពជាងឱសថ AZT ដោយសារតែ TDF ត្រូវបានគេយកមកបញ្ចូលក្នុងរូបមន្តព្យាបាលជួរទី២នៃឱសថប្រឆាំងមេរោគអេដស៍។ ការបរាជ័យនៃឱសថ AZT បណ្តាលមកពីការប្រមូលផ្តុំ thymidine នាំឱ្យបន្ថយប្រសិទ្ធភាពរបស់ថ្នាំ TDF(ឬABC) ប្រឆាំងមេរោគអេដស៍ ។

ប៉ុន្តែ ការប្រែប្រួលនៃ K65R នៅពេលដែលឱសថ TDF បរាជ័យ វាមិនបានកាត់បន្ថយ និងអាចបង្កើនប្រសិទ្ធភាពនៃឱសថ AZT ប្រឆាំងមេរោគអេដស៍សម្រាប់រូបមន្តព្យាបាលជួរទី២ ។

### ៨.២.២ ករណី Contraindications ជម្រើសរូបមន្តព្យាបាលជួរទី១: TDF + 3TC + EFV

- TDF មាន contraindicated ចំពោះអ្នកជំងឺខ្សោយតម្រងនោម មិនអាចព្យាបាលដោយ TDF បានទេ បើ eGFR < ៥០ម.ល/នាទី។
    - ប្រើជំនួសដោយឱសថ AZT ២៥០–៣០០ម.ក្រ លេប២ដង/ថ្ងៃ (ដូចប្រើ AZT + 3TC FDC) ។
- ចៀសវាងប្រើឱសថ EFV លើអ្នកជំងឺសរសៃប្រសាទ និងជំងឺវង្វេងវង្វាន់(dementia) ។
    - ប្រើជំនួសដោយឱសថ NVP ២០០ម.ក្រ លេប២ដង/ថ្ងៃ (ក្រោយពីប្រើកម្រិតដូសនាំមុខ)

### ៨.៣ កម្រិតដូសឱសថ Efavirenz

- EFV ៤០០ម.ក្រ បានបង្ហាញថា មានប្រសិទ្ធភាពដូចគ្នាជាមួយនឹង EFV ៦០០ម.ក្រ ដោយមានផលប៉ះពាល់តិចតួច[១២] ។
- ប៉ុន្តែ EFV ៤០០ម.ក្រ មិនត្រូវបានគេផ្តល់អនុសាសន៍ឱ្យប្រើចំពោះស្ត្រីមានផ្ទៃពោះ ឬអ្នកជំងឺដែលកំពុងព្យាបាលដោយឱសថ rifampicin ព្រោះវាអាចបន្ថយ concentration នៃឱសថ EFV។
- គេសង្ឃឹមថា EFV ៤០០ម.ក្រ គ្រាប់សំប៉ែត នឹងមានសម្រាប់ប្រើប្រាស់ក្នុងពេលឆាប់ៗខាងមុខ ហើយបន្ទាប់មក កម្រិតដូសរួមបញ្ចូលគ្នានឹងមានសម្រាប់ប្រើប្រាស់នៅពេលក្រោយ។
    - អ្នកជំងឺដែលមានផលវិបាកធ្ងន់ធ្ងរ បណ្តាលមកពីការព្យាបាលដោយឱសថ EFV ក្នុងរូបមន្តរួមគ្នាបញ្ចូលគ្នា: TDF+3TC+EFV ៦០០ម.ក្រ ត្រូវផ្តល់ជម្រើសក្នុងការប្តូរទៅព្យាបាលដោយឱសថ EFV ៤០០ម.ក្រ ជាមួយ NRTI វិញ អាចមានភាពទ្រាំទ្រល្អជាង (better tolerated)។ មិនត្រូវផ្តល់ការព្យាបាលដោយប្រើរូបមន្តនេះ ចំពោះស្ត្រីមានផ្ទៃពោះ និងអ្នកជំងឺអេដស៍ដែលកំពុងព្យាបាលជំងឺរបេងទេ។
    - អ្នកជំងឺដែលគ្មានប្រតិកម្ម នៅពេលកំពុងព្យាបាលដោយរូបមន្តព្យាបាលរួមបញ្ចូលគ្នានៃឱសថ TDF+3TC+EFV ៦០០ម.ក្រ អាចបន្តការព្យាបាលរហូតដល់មានរូបមន្តព្យាបាលថ្មីជំនួសដោយឱសថ EFV ៤០០ម.ក្រ ទើបផ្លាស់ប្តូរបាន។
    - អ្នកជំងឺដែលត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ត្រូវប្រើប្រាស់រូបមន្តព្យាបាលដោយឱសថរួមបញ្ចូលគ្នា គឺ TDF+3TC+EFV ៦០០ម.ក្រ ។

---

[១២] ការសិក្សា របស់ Encore 1 Study Group. ប្រសិទ្ធភាពនិងសុវត្ថិភាពការប្រើ efavirenz 400 mg ធៀបនឹង 600 mg រាល់ថ្ងៃ :ទិន្នន័យ ៩៦អាទិត្យពីការសិក្សា ENCORE1 randomised, double-blind, placebo-controlled, non-inferiority Lancet Infect Dis 2015;15:793–802

## ៨.៤ ជម្រើសផ្សេងទៀតក្នុងឱសថជួរទី១ AZT + 3TC FDC (+ NVP ឬ EFV)

- ឱសថ AZT ២៥០-៣០០ម.ក្រ + 3TC ១៥០ម.ក្រ លេប២ដង/ថ្ងៃ ត្រូវយកមកព្យាបាលជំនួសការព្យាបាលដោយឱសថ TDF នៅពេល Hb >៨,០ក្រ/ដ.ល។
- ឱសថ AZT + 3TC គ្រាប់រួមបញ្ចូលគ្នា លេប២ដង/ថ្ងៃ អាចព្យាបាលជាមួយឱសថ EFV លេប១ដង/ថ្ងៃ។
- ឱសថ AZT + 3TC + NVP មានជាគ្រាប់ថ្នាំរួមបញ្ចូលគ្នា លេប២ដង/ថ្ងៃ (ក្រោយពីបានព្យាបាលដោយកម្រិតឱសថ NVP នាំមុខ)។

**ឱសថ** Nevirapine (NVP)

- ឱសថ NVP អាចយកមកព្យាបាលជំនួសឱសថ EFV ក្នុងករណីមាន contraindication ជាមួយឱសថ EFV។
- ឱសថ NVP មិនអាចយកមកព្យាបាលបាន (contraindicated) នៅពេលអ្នកជំងឺកំពុងព្យាបាលដោយឱសថ rifampicin ដោយសារឱសថ rifampicin បន្ថយកម្រិតកំហាប់នៃឱសថ NVP ក្នុងឈាម។
- ឱសថ NVP មិនអាចយកមកព្យាបាលបាន (contraindicated) នៅពេលអ្នកជំងឺ រលាកថ្លើមធ្ងន់ធ្ងរ (ALT/ AST> ៥ដងនៃតម្លៃធម្មតា)។
- កត្តាប្រឈមមុខនឹងការពុលថ្លើម រួមមាន ស្ត្រីដែលមានកោសិកា CD4>២៥០ និងបុរសដែលមានកោសិកា CD4>៤០០ ព្យាបាលជំណាលគ្នាជាមួយនឹងឱសថពុលថ្លើមផ្សេងទៀត និងមានជំងឺរលាកថ្លើមដែលមិនបានដឹង។
- ត្រូវព្យាបាលដោយប្រើកម្រិតដូសឱសថ NVP ២០០ម.ក្រ លេប១ម្តង/ថ្ងៃ រយៈពេល ២សប្តាហ៍ មុននឹងដំឡើងទៅលេប NVP ២០០ម.ក្រ ២ដង/ថ្ងៃ។
- តាមដានតេស្ត ALT/AST នៅពេលដើមគ្រា បន្ទាប់មកនៅសប្តាហ៍ទី២ មុននឹងតំឡើងកម្រិតដូស ក្រោយមក ២សប្តាហ៍ទៀត រួចធ្វើតេស្ត១ខែ/ម្តង រយៈពេល៣ខែ។

**ឱសថ** Abacavir (ABC)

- ឱសថ ABC អាចយកមកព្យាបាលជំនួសឱសថ AZT ឬ TDF ករណីឱសថទាំងពីរ មាន contraindication។
- ប៉ុន្តែការព្យាបាលដោយឱសថ ABC/3TC រួមបញ្ចូលគ្នា ជាមួយនឹងឱសថ EFV ឬ ATV/r បានបង្ហាញថា មានបរាជ័យផ្នែកវីរុសសាស្ត្រ (VL failure) ខ្ពស់ ចំពោះអ្នកជំងឺដែលមាន VL > ១០០,០០០ មុនពេលព្យាបាល។ ករណីដែលរូបមន្តព្យាបាលដោយឱសថរួមបញ្ចូលគ្នានេះ ត្រូវបានជ្រើសរើសយកមកព្យាបាល ត្រូវធ្វើតេស្ត VL ជាមុនសិន។ ទោះបីជាយ៉ាងណាក៏ដោយ នៅប្រទេសកម្ពុជា ការធ្វើតេស្ត VL មិនត្រូវបានធ្វើជាប្រចាំទេ នាំឱ្យមានបាត់បង់ឱកាសនេះ។

- ប្រតិកម្ម hypersensitivity ជាមួយឱសថ ABC អាចកើតឡើងប្រហែល ៣% នៃអ្នកជំងឺ ហើយករណីនេះ គេមិនត្រូវព្យាបាលដោយឱសថ ABC សាឡើងវិញទេ (ការព្យាបាលដោយឱសថ ABC ឡើងវិញ អាចបណ្តាលឱ្យអ្នកជំងឺមានគ្រោះថ្នាក់ដល់ជីវិត) ។

## ៨.៥ ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នៅពេលមានជំងឺឱកាសនិយម

- ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឆាប់ពេកនៅពេលមានជំងឺឱកាសនិយម អាចបណ្តាលឱ្យអ្នកជំងឺប្រឈមមុខខ្ពស់នឹងការលេចឡើងនូវ ចង្កោមរោគសញ្ញានៃការស្តារប្រព័ន្ធភាពស៊ាំឡើងវិញ (IRIS)។ ទោះបីជាយ៉ាងណាក៏ដោយ ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានឆាប់ អាចនឹងកាត់បន្ថយអត្រាឈឺ និងអត្រាស្លាប់។
- ត្រូវពន្យាពេលចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ចំពោះអ្នកជំងឺអេដស៍ដែលមានជំងឺរបេង និងមានកោសិកា CD4 >៥០ រហូតដល់ពី២–៨សប្តាហ៍ ដើម្បីកាត់បន្ថយការប្រឈមមុខខ្ពស់នឹងការលេចឡើងនូវចង្កោមរោគសញ្ញានៃការស្តារប្រព័ន្ធភាពស៊ាំឡើងវិញ (IRIS) ។
- ម្យ៉ាងទៀត IRIS អាចបណ្តាលឱ្យស្លាប់បានដោយសារមានការបង្ករោគនៅប្រព័ន្ធសរសៃប្រសាទកណ្តាល ដូច្នេះត្រូវពន្យាពេលចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចាប់ពី ២ ទៅ ៨សប្តាហ៍ ចំពោះអ្នកជំងឺរលាកស្រោមខួរបង្កដោយជំងឺរបេង និងចាប់ពី៤ទៅ៦សប្តាហ៍ ចំពោះអ្នកជំងឺរលាកស្រោមខួរបង្កដោយក្រិបតូកុក (Cryptococcus meningitis)។
- ក្រៅពីនេះ ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ គឺត្រូវចាប់ផ្តើម**ក្នុងកំឡុង ២ សប្តាហ៍ ក្រោយពីការព្យាបាលជំងឺឱកាសនិយម**។

តារាងទី ៨-៣ ពេលវេលាដែលត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នៅពេលកំពុងមានជំងឺឱកាសនិយមសកម្ម

| ជំងឺឱកាសនិយម | ពេលវេលា ដោយគិតចាប់ពីពេលដែលចាប់ផ្តើមព្យាបាលជំងឺឱកាសនិយម និង ចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ |
|---|---|
| ជំងឺរបេង [១៣]<br>CD4 < ៥០កោសិកា/មម$^3$<br>CD4 > ៥០កោសិកា/មម$^3$ | <br>កំឡុង ២សប្តាហ៍<br>២–៨ សប្តាហ៍ |
| ជំងឺ Cryptococcal meningitis (CM) | ៤–៦សប្តាហ៍ |
| ជំងឺរលាកស្រោមខួរដែលមិនមែន គ្រិបតូកុក រួមទាំង Cryptococcal Ag + CSF neg | កំឡុង២សប្តាហ៍ |
| គ្រប់ជំងឺឱកាសនិយមទាំងអស់ | កំឡុង២សប្តាហ៍។ |

## ៨.៦ បញ្ហាដែលជួបប្រទះពេលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងការព្យាបាលជំងឺ ឱកាសនិយម

- គ្រាប់ថ្នាំច្រើនពេល និងផលប៉ះពាល់
- អ្នកជំងឺមានចិត្តរំភើបខ្លាំងពីការរកឃើញនូវរូបមន្តព្យាបាលថ្មី
- អន្តរកម្មឱសថ
- ការពុលឱសថ– ថ្លើម តម្រងនោម និងខួរឆ្អឹង
- ចង្កោមរោគសញ្ញានៃការស្តារប្រព័ន្ធភាពស៊ាំឡើងវិញ។

[១៣] គោលការណ៍ណែនាំអំពី របេង របស់ អង្គការសុខភាពិភពលោក:អនុសាសន៍ ព្យាបាលដោយ cART ឆាប់បំផុតក្នុងកំឡុងពេល ៨ អាទិត្យ នៃការព្យាបាល របេង។ កាលវិភាគនេះដូចគ្នានឹង TB CARE Iស្តង់ដារអន្តរជាតិសំរាប់ថែទាំរបេង, បោះពុម្ពលើកទី៣ ។. TB CARE I, The Hague, 2014, និងMSF HIV/TB Clinical guide 2015។ សូមមើល Uthman O.A et al អំពី ពេលវេលាដ៏ល្អ សំរាប់ចាប់ផ្តើមព្យាបាល ARV ដល់មនុស្សពេញវ័យឆ្លងមេរោគអេដស៍ដែលទើបតែរកឃើញមានរបេងសួត។ Systematic Review and Meta-analysisកំណត់ត្រារបស់ Internal Medicine .Vol. 163 No. 1 : ៧កក្កដា ២០១៥។

# ឧបសម្ព័ន្ធ ៩. ចង្កោមរោគសញ្ញានៃការស្តារប្រព័ន្ធភាពស៊ាំឡើងវិញ (IRIS)

ក្រោយពីចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នាំឱ្យកាត់បន្ថយចំនួនវីរុសអេដស៍ក្នុងឈាម អនុញ្ញាតឱ្យមានការស្តាឡើងវិញនូវភាពស៊ាំ ហើយបង្កើនសមត្ថភាពឆ្លើយតបរបស់ភាពស៊ាំប្រឆាំងនឹងការបង្ករោគ ជូនកាល អាចបណ្តាលឱ្យលេចចេញនូវរោគសញ្ញាគ្លីនិកថ្មីដែលមានសភាពធ្ងន់ធ្ងរ។

## ៩.១ បរិបទចំបងដែល IRIS អាចកើតឡើង

១. ប្រែក្លាយពីការបង្ករោគជំងឺឱកាសនិយម ដែលពីមុនគ្មានរោគសញ្ញា ទៅជាមានរោគសញ្ញាគ្លីនិក (លេចចេញនូវ IRIS)។

២. លេចចេញនូវរោគសញ្ញាគ្លីនិកធ្ងន់ធ្ងរនៃការបង្ករោគ ទោះបីជា ការព្យាបាលបានជោគជ័យ ក៏ដោយ (paradoxical IRIS)។

៣. ប្រតិកម្ម Remnants ឬ អង់ទីហ្សែននៃជំងឺឱកាសនិយមដែលធ្លាប់កើតពីមុន ក្រោយពីបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។

- **ការប្រឈមមុខនៃ IRIS មានកម្រិតខ្ពស់ក្នុងករណីដែល**
  - ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ចំពោះអ្នកជំងឺអេដស៍ក្នុងដំណាក់កាលធ្ងន់ធ្ងរ មានកោសិកា CD4 ទាប និងមានកម្រិត viral loads ខ្ពស់។
  - ការបង្ករោគធ្ងន់ធ្ងរ (high pathogen burden) ដូចជា ការបង្ករោគរាលដាល (disseminated infection)។
  - គម្លាតនៃពេលវេលាខ្លី រវាងការចាប់ផ្តើមព្យាបាលជំងឺឱកាសនិយម និងការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។

- IRIS កើតឡើងជាញឹកញាប់ក្នុងកំឡុង **២ទៅ៨សប្តាហ៍ ក្រោយចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។** ទោះបីជាយ៉ាងណា IRIS អាចកើតឡើងគ្រប់ពេលក្នុងកំឡុងពេល៦ខែដំបូង ក្រោយពេលចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ក្នុងករណីកំរ វាក៏អាចកើតឡើងនៅពេលក្រោយទៀតដែរ ។
- **ចង្កោមរោគ** អាចច្រឡំគ្នាជាមួយរោគសញ្ញាជំងឺឱកាសនិយមដែលកើតឡើងជាមួយគ្នា ។
- IRIS អាចនាំឱ្យកើនឡើងនូវអត្រាឈឺ និងបង្កើនភាពស្មុគស្មាញនៃការគ្រប់គ្រងព្យាបាល រួមទាំង ការផ្លាស់ប្តូររូបមន្តព្យាបាលនៃឱសថប្រឆាំងមេរោគអេដស៍ ប្រសិនបើ ចង្កោមរោគសញ្ញាទាំងនោះមានភាពមិនច្បាស់លាស់ អាចបណ្តាលមកពីចង្កោមរោគសញ្ញានៃការពុលឱសថទៅវិញ។ ទោះបីជា ករណីភាគច្រើននៃ IRIS មិនបណ្តាលឱ្យស្លាប់ តែវាបណ្តាលឱ្យកើនឡើងនូវអត្រាមរណភាព ជាពិសេស ករណីមានជំងឺរលាកស្រោមខួរបង្កដោយគ្រិបតូកុក ។

- **ជំងឺរបេង** គឺជាជំងឺមួយកើតឡើងជាញឹកញាប់ជាមួយនឹង IRIS។ វាដូចគ្នានឹងប្រតិកម្មប៉ារ៉ាដុក 'paradoxical reactions" ដែលកើតមានឡើងលើអ្នកមិនផ្ទុកមេរោគអេដស៍ និង កំពុងព្យាបាលជំងឺរបេង។ ជាទូទៅ រោគសញ្ញា តែងតែជួបប្រទះ រួមមាន គ្រុនក្ដៅ ការកើនឡើង (ទាំងទំហំនិងចំនួន) ដំបៅបណ្ដាលមកពីជំងឺរបេង ជាពិសេស ការឡើងកូនកណ្ដុរ និង/ឬ ជំងឺរលាកសួត (Pulmonary infiltrates) ជំងឺរលាកទងសួត ជំងឺស្ទះបង្ហួរនោម ឬ ជំងឺប្រព័ន្ធសរសៃប្រសាទកណ្ដាល។
  ការធ្វើរោគវិនិច្ឆ័យលើភាពខុសគ្នារវាង IRIS បណ្ដាលមកពីជំងឺរបង គឺ ភាពបរាជ័យនៃការព្យាបាលបណ្ដាលមកពីភាពស៊ាំជាមួយឱសថប្រឆាំងជំងឺរបេង(DR-TB) ឬ ការលេបឱសថមិនបានត្រឹមត្រូវ មិនទៀងទាត់ និងមិនជាប់លាប់ ។

- IRIS អាចកើតឡើង រួមជាមួយ ការបង្ករោគច្រើន និងគ្មានការបង្ករោគ ចំពោះអ្នកជំងឺអេដស៍៖
  - បង្ករោគដោយវីរុសរលាកថ្លើមប្រភេទB និងC→ ជំងឺរលាកថ្លើម
  - បង្ករោគដោយ CMV → ជំងឺ vitritis
  - លក្ខខណ្ឌជំងឺសើស្បែក– ជំងឺ VZV ជំងឺ folliculitis
  - លក្ខខណ្ឌប្រព័ន្ធសរសៃប្រសាទកណ្ដាល–បង្កដោយមេរោគCryptococcus មេរោគ toxoplasmosis មេរោគរបេង មេរោគ JCV មេរោគ PML។
  - រោគសញ្ញាប៉ះពាល់សរីរាងច្រើន – ជំងឺ MAC ជំងឺរបេង ជំងឺផ្សិត។
  - ជំងឺ PCP ជំងឺ peniciliium ជំងឺ histoplasmosis ។ល។
  - ជំងឺ Kaposis sarcoma (ជាករណីកំរនៅកម្ពុជា)។

## ៩.២ ការគ្រប់គ្រង និងព្យាបាល IRIS

- *បន្តការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍* (លើកលែងតែក្នុងករណីកំរ មានជំងឺរលាកស្រោមខួរដោយក្រិបតូកុកធ្ងន់ធ្ងរ) ។
- ត្រូវធ្វើការពិនិត្យស្រាវជ្រាវជំងឺឱកាសនិយមថ្មី ឬជំងឺឱកាសនិយមសកម្ម បណ្ដាលមកពីការព្យាបាលបរាជ័យ។
  - ការធ្វើតេស្ដ: កំហាក m/c/s, បណ្ដុះឈាម ថតសួតដោយកាំរស្មីអ៊ិច បូមទឹកឆ្អឹងខ្នង បើមានរោគសញ្ញាប្រព័ន្ធសរសៃប្រសាទកណ្ដាល ការច្រិបសាច់(biopsy) បើមានការហើមប៉ោងកូនកណ្ដុរថ្មី និងធ្ងន់ធ្ងរ (lymphadenopathy) ឬ ដំបៅស្បែក។
- អ្នកជំងឺមានជំងឺរបេងធ្ងន់ធ្ងរ ត្រូវធ្វើការបណ្ដុះកំហាកសារជាថ្មី (sputum cultures) និងធ្វើតេស្ដលើប្រសិទ្ធភាពនៃថ្នាំប្រឆាំងជំងឺរបេង(sensitivity testing) ដើម្បីវាយតម្លៃនៃភាពបរាជ័យនៃការព្យាបាល អាចមកពីភាពស៊ាំជាមួយនឹងឱសថប្រឆាំងជំងឺរបេង ឬ ការព្យាបាលជំងឺ MAC ។
- ការចាប់ផ្ដើម/បន្តការព្យាបាលស្ដង់ដាជំងឺឱកាសនិយម។
- អនុសាសន៍នៃការព្យាបាលជំងឺឱកាសនិយម ពេលមាន IRIS ដោយសារតែមានរោគសញ្ញាទាក់ទងនឹងការព្យាបាលជំងឺឱកាសនិយមពីមុន ទោះបីជាទើបកើតឡើងនូវជំងឺឱកាសនិយម

សកម្ម ក្នុងករណីសង្ស័យ ត្រូវចាប់ផ្ដើមព្យាបាលជំងឺឱកាសនិយមនោះឡើងវិញ។

- ឱសថក្នុងក្រុម Non-steroidal anti-inflammatory agents (NSAID) អាចយកមកព្យាបាលដើម្បីបន្ធូរបន្ថយរោគសញ្ញាទាក់ទងនឹងការរលាក ឧ. ការលាកកូនកណ្ដុរ (lymphadenitis) និងគ្រុនក្ដៅ។
- ការព្យាបាលដោយឱសថ corticosteroids មួយវគ្គ ត្រូវបានអនុវត្ត បើរោគសញ្ញាក្លាយជាធ្ងន់ធ្ងរ ឧ. ពិបាកដកដង្ហើម រោគសញ្ញាសរសៃប្រសាទកណ្ដាល ស្ទះតម្រងនោម។

- **គំណាត់ចំណាំ អំពីការព្យាបាលដោយឱសថ** corticosteroid

១. បើអ្នកជំងឺកំពុងព្យាបាលដោយឱសថ rifampicin នាំឱ្យមានអន្តរកម្មជាមួយឱសថក្រុម steroids បណ្ដាលឱ្យកាត់បន្ថយយ៉ាងខ្លាំងនូវកំហាប់ឱសថក្រុម steroid ក្នុងឈាម។ ដូច្នេះ តម្រូវឱ្យផ្ដល់កម្រិតដូសឱសថ prednisolone ខ្ពស់ជាងកម្រិតដូសធម្មតា ឧ .ចាប់ផ្ដើម ព្យាបាលដោយឱសថ prednisolone មានកម្រិតដូស ១,៥ ម.ក្រ/គ.ក្រ។

២. ការព្យាបាលដោយឱសថក្រុម steroids មានកម្រិតដូសខ្ពស់/រយៈពេលយូរលើអ្នកជំងឺអេដស៍ដែលមានភាពស៊ាំចុះខ្សោយ បណ្ដាយឱ្យកើនឡើងនូវការប្រឈមមុខនឹងការកើតជំងឺព្រូន strongyloidiasis រាលដាល និង septic shock។

- ការព្យាបាលដោយឱសថ prednisolone កម្រិតដូសខ្ពស់ (>២០ ម.ក្រ) រយៈពេលលើសពី ២ សប្ដាហ៍ គឺត្រូវព្យាបាលតាមបទពិសោធន៍ ដោយប្រើប្រាស់ឱសថ albendazole រួមគ្នា ក្នុងកម្រិតដូស ៤០០ម.ក្រ លេបពេលបរិភោគអាហារមានសារជាតិខ្លាញ់ លេប១២ម៉ោងម្ដង x ៧ថ្ងៃ[១៤] ។

---

[១៤] គោលការណ៍ណែនាំរបស់ Sanford ស្ដីអំពីការព្យាបាលដោយ Antimicrobial therapy. បោះពុម្ពលើកទី៤៥ឆ្នាំ២០១៥

# ជំពូក ១០. ការតាមដាននៃការពុលឱសថ និងការប្តូរឱសថប្រឆាំងមេរោគអេដស៍

- ត្រូវផ្តល់ព័ត៌មានអំពីផលប៉ះពាល់សំខាន់ៗនៃឱសថនិមួយៗ នៅក្នុងវេជ្ជបញ្ជា។
- តាមដានផលប៉ះពាល់នៃឱសថ ដោយផ្តោតលើរោគសញ្ញា និងធ្វើតេស្តអមវេជ្ជសាស្ត្រមួយចំនួន ដើម្បីគាំទ្រការព្យាបាល។
- នៅពេលអ្នកជំងឺមកពិគ្រោះជំងឺ គ្រូពេទ្យព្យាបាលត្រូវសួរអ្នកជំងឺថា បានលេបថ្នាំអ្វី? និងពិនិត្យមើលពីផលប៉ះពាល់នៃឱសថទាំងនោះ។
- ការពុលឱសថធ្ងន់ធ្ងរដែលមានការគំរាមកំហែងដល់ជីវិត បានរៀបរាប់ដូចខាងក្រោម និងក្នុងតារាងខាងក្រោម[១៥] ។

## ១០.១ ផលប៉ះពាល់នៃឱសថប្រឆាំងមេរោគអេដស៍ដែលកេតមានជាញឹកញាប់

### ចង្អោរ និងក្អួត

- អាចកើតឡើងមានឡើងចំពោះអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ និងកាត់តែធ្ងន់ធ្ងរឡើងនៅពេលចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍–ជាពិសេស នៅពេលព្យាបាលដោយឱសថ AZT និង ឱសថក្រុម PI។
- ជាញឹកញាប់ រោគសញ្ញានេះអាចធូរស្រាលឡើងវិញ ក្រោយពី២ទៅ៣សប្តាហ៍ ត្រូវឲ្យអ្នកជំងឺលេបឱសថនេះនៅពេលខុសគ្នា បើករណីធ្ងន់ធ្ងរ ត្រូវលេបបន្ថែមឱសថ metoclopramide ១០ mg ៣ដង/ថ្ងៃ។
- បើក្អួតថ្នាំចេញមកវិញក្រោយពេលលេប ត្រូវឱ្យលេបថ្នាំម្តងទៀតនៅ ២ម៉ោងក្រោយ។
- បើក្អួតមិនអាចព្យាបាលបាន៖ ត្រូវវាយតម្លៃពីចង្កោមរោគសញ្ញា hypersensitivity(ABC) ជំងឺរលាកថ្លើម ជំងឺរលាកលំពែង។ល។
- បើក្អួតលើសពី ៦ម៉ោង ក្រោយពេលព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ត្រូវគិតពីអាស៊ីតឡាក់ទិក (lactic acidosis)។

## ១០.២ ការពុលឱសថប្រឆាំងមេរោគអេដស៍ ដែលមានការគំរាមកំហែងដល់ជីវិត

### ១០.២.១ អាស៊ីតឡាក់ទិក

- អាស៊ីតឡាក់ទិក កើតឡើងជាញឹកញាប់នៅពេលព្យាបាលដោយឱសថ d4T អាស៊ីតឡាក់ទិកអាចកើតមានឡើងនៅពេលព្យាបាលដោយឱសថណាមួយក្នុងក្រុម NRTI ជាពិសេស ឱសថ AZT ហើយវាកើតមានដោយកំរ នៅពេលព្យាបាលដោយឱសថ TDF ABC 3TC។

[១៥] គោលការណ៍ណែនាំគ្លីនិក អំពី របេង អេដស៍របស់ អង្គការគ្រូពេទ្យគ្មានព្រំដែន និង គោលការណ៍ណែនាំរួម របស់អង្គការសុខភាពពិភពលោក

- អាស៊ីតឡាក់ទិក អាចកើតឡើងក្រោយពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍លើស ពី៦ខែ។
- កត្តាប្រឈមមុខ រួមមាន ភេទស្រី ធាត់ និងស្ត្រីមានផ្ទៃពោះ។
- **តាមដានការវិវត្តន៍នៃអាស៊ីតឡាក់ទិក៖** តាមដានរោគសញ្ញា ការកើនឡើងនៃជាតិឡាក់តាតដោយគ្មានរោគសញ្ញា កើតឡើងជាញឹកញាប់ តែវាគ្មានសារៈសំខាន់ទេ។
- **រោគសញ្ញាគ្លីនិកនៃអាស៊ីតឡាក់ទិក៖** រួមមាន ចង្អោរនិងក្អួត ឈឺពោះ ពិបាកដកដង្ហើម អស់កម្លាំង និងស្រកទម្ងន់។ អាស៊ីតឡាក់ទិក (Lactic acidosis) អាចមានទំនាក់ទំនងជាមួយការព្យាបាលដោយឱសថក្នុងក្រុម NRTI-ជំរុញឱ្យមានជំងឺ peripheral neuropathy ឬជំងឺខ្លាញ់ក្នុងថ្លើម (hepatic steatosis)។
- **រោគវិនិច្ឆ័យញែកចេញពីជំងឺផ្សេង**:ការឡើងខ្ពស់នៃ lactate និង acidosis អាចកើតមានឡើងនៅពេលមាន sepsis ឬជំងឺខ្សោយប្រព័ន្ធឈាមរត់ តម្រូវឱ្យធ្វើការវាយតម្លៃរោគសញ្ញាគ្លីនិក។
- **រោគវិនិច្ឆ័យ**
- ការកើនឡើងជាតិ lactate > ៥mmol/ល + acidosis អាចវាស់វែងបានដោយប្រើប្រាស់សេរ៉ូម bicarbonate កម្រិតទាប (< ២០mmol/ល) ។
- ករណីមិនមានតេស្ត lactate ត្រូវប្រើសេរ៉ូម bicarbonate កម្រិតទាប (< ២០mmol/ល) គឺសមស្របជាមួយនឹងរោគវិនិច្ឆ័យ។
- រួមផ្សំជាមួយភាពមិនធម្មតា (Associated abnormalities) មាន ↑ALT/AST និង ↑ creatinine kinase ។
- **ការគ្រប់គ្រងព្យាបាល**
- បើរោគសញ្ញាស្រាល + bicarbonate <២០mmol/ml → ប្តូរឱសថក្នុងក្រុម NRTI ពីឱសថ AZT ទៅឱសថ TDF ឬ ABC វិញ។
- បើរោគសញ្ញាធ្ងន់ធ្ងរ +/ឬ bicarbonate <១៥mmol/ml→ ចូលសំរាកព្យាបាលក្នុងមន្ទីរពេទ្យ ឈប់ព្យាបាលដោយឱសថក្នុងក្រុម NRTI ទាំងអស់។
  - ពិនិត្យរករោគសញ្ញា sepsis និងជំងឺគ្រុនចាញ់ និងត្រូវព្យាបាលសាកល្បងដោយចាក់ antibiotics តាមសរសៃ ករណីសង្ស័យ។
  - ព្យាបាលដោយបន្ថែមឱសថ ATV/r ជាបណ្ដោះអាសន្ន លើការប្រើឱសថក្រុម NNRTI រហូតអ្នកជំងឺមានស្ថានភាពសុខភាពប្រសើរឡើង និងជាតិ bicarbonate ត្រឡប់មកតម្លៃធម្មតា។ បន្ទាប់មកបញ្ឈប់ការព្យាបាលដោយឱសថ ATV/r និងប្តូរទៅប្រើប្រាស់ឱសថ TDF ឬ ABC
  - បើអ្នកជំងឺបានទទួលការព្យាបាលដោយឱសថ LPV/r ឬ ATZ/r ត្រូវបន្តការព្យាបាលដោយប្រើ ឱសថតែមួយមុខ រហូតលុះត្រាតែ អ្នកជំងឺមានស្ថានភាពសុខភាពប្រសើរឡើង និងបន្ទាប់មកបន្ថែមឱសថTDF ឬ ABC ។

### ១០.២.២ ប្រតិកម្ម hypersensitivity នៃឱសថ Abacavir

- អ្នកជំងឺមួយចំនួនដែលព្យាបាលដោយឱសថ ABC មានប្រតិកម្ម hypersensitivity នេះ នឹងកើតឡើងជាញឹកញាប់ក្នុងកំឡុង១០ថ្ងៃដំបូងនៃការព្យាបាលដោយឱសថ ABC និងជាទូទៅ ក្នុងកំឡុង ៦សប្តាហ៍ដំបូង។

- **ការលេចចេញរោគសញ្ញាគ្លីនិក** នៃប្រតិកម្ម hypersensitivity បណ្តាលមកពីការព្យាបាលដោយ ឱសថ abacavir៖ គ្រុនក្តៅ (៨០% នៃករណី) ស្នាមកន្ទួលលើស្បែក (៧០% នៃករណី ជាទូទៅមានកម្រិតស្រាល) ចង្កោមរោគសញ្ញាប្រដាប់រំលាយអាហារ និងប្រដាប់ដកដង្ហើម រួមមានក្អកនិងពិបាកដកដង្ហើម និងចង្កោមរោគសញ្ញាទល់លាមកមិនជាក់លាក់ និងអស់កម្លាំងល្ហិតល្ហៃ និងឈឺចាប់សាច់ដុំ ។ ចង្កោមរោគសញ្ញាទាំងអស់នោះវិវត្តន៍កាន់តែធ្ងន់ធ្ងរឡើងៗ ក្រោយពេលលេបឱសថ abacavir ម្តងៗ ។
- **ការតាមដានប្រតិកម្ម** hypersensitivity **បណ្តាលមកពីការព្យាបាលដោយឱសថ** abacavir៖ តាមដានការវិវត្តន៍នៃរោគសញ្ញា ។
- **ការធ្វើរោគវិនិច្ឆ័យវែកញែក៖** ប្រតិកម្មឱសថ ឧ. ប្រតិកម្មឱសថ cotrimoxazole ឬ ឱសថក្រុម NNRTI ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រតិកម្ម hypersensitivity បណ្តាលមកពីការព្យាបាលដោយឱសថ ABC ច្រើនបង្ហាញរោគសញ្ញាគ្លីនិកពេញរាងកាយ ប៉ុន្តែ មានសភាពមិនធ្ងន់ធ្ងរ/ស្នាមកន្ទួលលើស្បែកបន្តិចបន្តួច បើប្រៀបធៀបជាមួយនឹងប្រតិកម្មជាមួយឱសថផ្សេងទៀត។
- **ការគ្រប់គ្រងព្យាបាល**
- ឈប់ព្យាបាលដោយឱសថ ABC និងមិនត្រូវប្រើឱសថនេះសាឡើងវិញទេ ពីព្រោះ វាអាចបណ្តាលឱ្យគ្រោះថ្នាក់ដល់ជីវិត ។
- រោគសញ្ញាលេចឡើងក្នុងកំឡុងពេល៤៨ម៉ោង និងត្រូវចាប់ផ្តើមប្តូរទៅព្យាបាលដោយឱសថក្រុម NRTI (TDF ឬ AZT) ។

### ១០.២.៣ រលាកលំពែង

- ការរលាកលំពែង កើតឡើងជាញឹកញាប់ នៅពេលព្យាបាលដោយឱសថ ddi និង d4T (ហាមប្រើឱសថទាំងពីរនេះជាមួយគ្នាជាដាច់ខាត)។ ប៉ុន្តែ វាអាចកើតមានដោយកំរ នៅពេលព្យាបាលដោយឱសថ 3TC។
- គ្រួសក្នុងថង់ទឹកប្រម៉ាត់ (Gallstones) ការញៀនស្រា (alcoholism) និង hypertriglyceridemia (ពាក់ព័ន្ធជាមួយការព្យាបាលដោយឱសថ PI និង EFV) ក៏អាចបណ្តាលឱ្យរលាកលំពែង ដែរ។
- **តាមដានការរលាកលំពែង**: តាមដានការវិវត្តន៍នៃរោគសញ្ញា។
- **ការលេចចេញរោគសញ្ញាគ្លីនិក**: ឈឺពោះ។

- **ការធ្វើរោគវិនិច្ឆ័យ**: កើនឡើង amylase ឬ lipase ត្រូវឆ្លុះពោះដោយអេកូ (abdominal ultrasound)។
- ការគ្រប់គ្រងព្យាបាល: បើ amylase <១,៥ x ULN និងរោគសញ្ញាមិនធ្ងន់ធ្ងរ និងរោគវិនិច្ឆ័យមិនច្បាស់ → ត្រូវពិនិត្យឡើងវិញ១សប្តាហ៍ក្រោយ និងធ្វើតេស្ត amylase ម្តងទៀត។ បើអ្នកជំងឺមិនស្រួលខ្លួន (unwell) ឬ amylase > ១,៥ x ULN និង/ឬ ការឆ្លុះអេកូពោះ បានបង្ហាញថា រលាកលំពែង ត្រូវបញ្ឈប់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។ ផ្តល់ការព្យាបាលបែបគាំទ្រ ត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឡើងវិញ ក្រោយពេលដែលអ្នកជំងឺបានធូរស្បើយ ប៉ុន្តែ ត្រូវដកឱសថ ddi ឬ d4T ចេញពីរូបមន្តព្យាបាល ដោយត្រូវប្រើឱសថ TDF AZT ឬ ABC ជំនួស។

## ១០.៣ ផលប៉ះពាល់ធ្ងន់ធ្ងរនៃឱសថប្រឆាំងមេរោគអេដស៍

### ១០.៣.១ ការពុលតម្រងនោមបណ្តាលមកពីការព្យាបាលដោយឱសថ Tenofovir

- ការពុលតម្រងនោមបណ្តាលមកពីការព្យាបាលដោយឱសថ TDF គឺបណ្តាលមកពីការខូចមុខងារកោសិកា proximal tubular។
- កើតឡើង < ១% នៃអ្នកជំងឺដែលព្យាបាលដោយឱសថ TDF។
- ការពុលឱសថ TDF ជាទូទៅអាចកើតឡើងក្នុងកំឡុងពេលប្រែប្រួលពីច្រើនសប្តាហ៍ ទៅច្រើនខែ ក្រោយពីការចាប់ផ្តើមព្យាបាលដោយឱសថ TDF។
- សម្រាប់គោលការណ៍ណែនាំអំពីជំងឺខ្សោយតម្រងនោម ជាទូទៅសូមអានជំពូក៩០ជំងឺតម្រងនោម ។
- **កត្តាប្រឈមមុខ** រួមមាន វ័យចាស់ ភេទប្រុស ទម្ងន់ស្រាល ជំងឺអេដស៍ដំណាក់កាលធ្ងន់ធ្ងរ ជំងឺខ្សោយមុខងារតម្រងនោម និងជំងឺផ្សេងទៀតរួមផ្សំ (ជំងឺទឹកនោមផ្អែម ជំងឺលើសសម្ពាធឈាម ជំងឺរលាកថ្លើមប្រភេទC) រួមផ្សំនឹងការព្យាបាលដោយឱសថពុលតម្រងនោម (nephrotoxic) និងឱសថបញ្ចេញចោលតាមទឹកនោម និង ការព្យាបាលដោយរូបមន្តឱសថ ritonavir boosted protease។

### ការធ្វើតេស្តនៅពេលដើមគ្រា និងតេស្តតាមដានការពុលឱសថ TDF[១៦]

- មុននឹងព្យាបាលដោយឱសថ TDF ត្រូវធ្វើតេស្ត creatinine និងតេស្ត eGFR នៅពេលដើមគ្រាលើគ្រប់អ្នកជំងឺទាំងអស់ ជាពិសេស គ្រប់អ្នកជំងឺដែលមានកត្តាប្រឈមមុខខ្ពស់ ដូចជា វ័យចាស់ ជំងឺខ្សោយមុខងារតម្រងនោម ជំងឺទឹកនោមផ្អែម ឬជំងឺលើសសម្ពាធឈាមរយៈយូរ ហើយកំពុងព្យាបាលដោយឱសថក្រុម PI រួមផ្សំនឹងការព្យាបាលដោយឱសថពុលតម្រងនោម (nephrotoxic) និងឱសថបញ្ចេញចោលតាមទឹកនោម[១៦] ។

---

[១៦] គោលការណ៍ណែនាំរួម របស់អង្គការសុខភាពពិភពលោក២០១៣

- មិនត្រូវចាប់ផ្ដើមព្យាបាលដោយឱសថ TDF បើ eGFR < ៥០ម.ល/នាទី ឬ ជំងឺទឹកនោមផ្អែមរយៈពេលយូរ ជំងឺលើសសម្ពាធឈាមមិនអាចគ្រួតពិនិត្យបាន ឬ ជំងឺខ្សោយតម្រងនោម។

- បន្តការតាមដានជាប្រចាំក្នុងការធ្វើតេស្ត serum creatinine និងតេស្ត urine dipstick នៅខែទី១, ខែទី៣ និងរៀងរាល់១២ខែម្តង ក្រោយពេលចាប់ផ្តើមព្យាបាលដោយឱសថ TDF[១៧] ។
- បើគ្មានធនធានគ្រប់គ្រាន់សម្រាប់ធ្វើតេស្តតាមដានជាប្រចាំនូវ serum creatinine តេស្ត urine dipstick សម្រាប់វាស់ជាតិស្ករក្នុងទឹកនោមទេ (សម្រាប់អ្នកជំងឺដែលគ្មានជំងឺទឹកនោមផ្អែម) ការធ្វើតេស្ត proteinuria តែឯកឯងត្រូវតែអនុវត្ត សម្រាប់តាមដានភាពពុលធ្ងន់ធ្ងរឱសថ TDF → ត្រូវតែធ្វើតេស្ត proteinuria បើតេស្ត serum creatinine មានលទ្ធផល វិជ្ជមាន។

## ការគ្រប់គ្រងព្យាបាលជំងឺខ្សោយតម្រងនោមបណ្ដាលមកពីពុលឱសថ TDF

(Cr<៥០ម.ល/នាទី):

- វាយតម្លៃ និងព្យាបាលរាល់មូលហេតុជំងឺតម្រងនោម (ការខ្សោះជាតិទឹក ជំងឺលើសសម្ពាធឈាម។ល។)
- បញ្ឈប់ការព្យាបាលដោយឱសថពុលតម្រងនោម –ជាពិសេសឱសថ NSAIDS។
- ធ្វើតេស្តរកអង់ទីហ្សែនមេរោគរលាកថ្លើមប្រភេទ B (HbsAg) ករណីមិនទាន់ដឹង។
- ប្តូរឱសថ TDF ចេញ (បើរោគសញ្ញាខ្សោយតម្រងនោមនៅតែមាន ហើយរកមូលហេតុផ្សេងទៀតដែលអាចព្យាបាលជា មិនឃើញ)៖
    - បើ TDF កំពុងតែយកមកព្យាបាលក្នុងរូបមន្តព្យាបាលជួរទី១→ ត្រូវប្តូរទៅ AZT ឬ ABC
    - បើធ្លាប់ប្រើ AZT ពីមុន → ត្រូវប្តូរទៅប្រើ ABC ឬ ddi វិញ។

- បើតេស្ត HBsAg វិជ្ជមាន៖ គឺប្រឈមមុខនឹងមានលេចចេញស្នាមក្រហមលើស្បែក "flare" នៃជំងឺរលាកថ្លើម ក្រោយពីបញ្ឈប់ការព្យាបាលដោយឱសថ TDF និង ការវិវត្តន៍ជំងឺរលាកថ្លើមប្រភេទ B។
    - បើមិនច្បាស់ថា វាបណ្ដាលមកពីការពុលឱសថ TDF បន្តការព្យាបាលដោយឱសថ TDF និងបន្តការតាមដាននៅខែទី១ និងខែទី៣។
    - បើតម្រូវឱ្យប្តូរឱសថ TDF ចេញ ត្រូវតាមដានការវិវត្តនៃ hepatitis flare (ទាំងរោគសញ្ញាគ្លីនិក និង ALT) អាចនឹងកើតឡើង ក្រោយពីបញ្ឈប់ការព្យាបាលដោយឱសថ TDF និងបន្តការវិវត្តន៍ជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ។

- ប្រែប្រួលកម្រិតដូសឱសថទាំងឡាយណា ដែលបញ្ចេញចោលតាមតម្រងនោម៖ តារាងទី ៤៧-១ កែតម្រូវកម្រិតដូសឱសថលើអ្នកជំងឺខ្សោយតម្រងនោម ។

---

[១៧] គោលការណ៍ណែនាំគ្លីនិក អំពី របេង អេដស៍របស់ អង្គការគ្រូពេទ្យគ្មានព្រំដែន ២០១៥

- តាមដានមុខងារតម្រងនោម លើការប្រែប្រួលកម្រិត eGFR អាចតម្រូវឱ្យមានការលៃសម្រួលកម្រិតដូសឱសថបន្ថែមទៀត ។

### ១០.៣.២ ការពុលឈាម (Hematological toxicity)

- អ្នកជំងឺ ជាញឹកញាប់មានការស្លេកស្លាំង បណ្តាលមកពីការបង្ករោគដោយមេរោគអេដស៍ពុំរ៉ៃ និងជំងឺឱកាសនិយម ជាពិសេស ជំងឺរបេង និងជំងឺអេដស៍ក្នុងដំណាក់កាលធ្ងន់ធ្ងរ ជំងឺបណ្តាលមកពីពពួកផ្សិត និងជំងឺ MAC ទៅក្នុងខួរឆ្អឹង។
- ជាងនេះទៅទៀត ឱសថ AZT និងឱសថ cotrimoxazole អាចបណ្តាលឱ្យមានជំងឺស្លេកស្លាំង និង neutropenia ផងដែរ។

## ការធ្វើតេស្តនៅពេលដើមគ្រា និង ការធ្វើតេស្តតាមដាន ជំងឺស្លេកស្លាំង ៖

- ធ្វើតេស្ត Hb នៅពេលដើមគ្រា រាល់ពេលចាប់ផ្តើមព្យាបាលដោយឱសថ AZT (ចៀសវាងព្យាបាលដោយឱសថ AZT បើ Hb <៨ក្រ/ដ.ល និងធ្វើតេស្ត Hb ឡើងវិញ នៅខែទី១ ខែទី៣ និងរៀងរាល់ ៦ខែម្តង។

## ការគ្រប់គ្រងព្យាបាល៖

- បើ ↓Hb <២៥% និងមានជំងឺស្លេកស្លាំងកម្រិតស្រាល (Hb≥ ៨០ ក្រ/ដ.ល) និងគ្មានរោគសញ្ញាធ្ងន់ធ្ងរ ត្រូវឈប់ព្យាបាលដោយឱសថ cotrimoxazole និង ធ្វើការពិនិត្យនិងព្យាបាលមូលហេតុផ្សេងៗ ដូចជា ជំងឺរបេង ជំងឺប្រដាប់រំលាយអាហារ ការបាត់បង់ឈាម។ល។ ព្យាបាលដោយ folic acid។ បើកម្រិត Hb បានល្អប្រសើរឡើងវិញ ត្រូវបន្តការព្យាបាលដោយឱសថ AZT និង បន្តការតាម ដាន។

- បើ ↓Hb >២៥% ឬ Hb <៨ ក្រ/ល ឬ មានរោគសញ្ញានៃជំងឺស្លេកស្លាំង ត្រូវឈប់ព្យាបាលដោយឱសថ cotrimoxazole និង AZT (ប្តូរទៅព្យាបាលដោយឱសថ ABC ឬ TDF) និង ធ្វើការពិនិត្យនិងព្យាបាលមូលហេតុផ្សេងៗ និងផ្តល់ folate។ បើ ជំងឺស្លេកស្លាំងមិនមែនបណ្តាលមកពី AZT ទេ អាចបន្តការព្យាបាលដោយឱសថ AZT នៅពេលក្រោយ ។

### ១០.៣.៣ ការពុលថ្លើម

- ប្រតិកម្មបណ្តាលឱ្យរលាកថ្លើម អាចកើតឡើងបណ្តាលមកពីឱសថជាច្រើន ដូចជា ឱសថព្យាបាលជំងឺរបេង ឱសថ ARV និងឱសថ antimicrobials ផ្សេងទៀត ដូចជា ឱសថ cotrimoxazole និងឱសថ fluconazole ឱសថបញ្ចុះជាតិខ្លាញ់ និងឱសថ NSAIDS។ល។
- ឱសថបុរាណមួយចំនួន ក៏បណ្តាលឱ្យពុលថ្លើមដែរ។
- ជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ជំងឺរលាកថ្លើមប្រភេទ C និងការផឹកសុរាច្រើនពេក ជំរុញឱ្យពុលថ្លើមពេលលេបថ្នាំ។

- IRIS បណ្តាលមកពីជំងឺរលាកថ្លើមប្រភេទ B ឬC ឬការបង្ករោគផ្សេងទៀតបណ្តាលឱ្យរលាកថ្លើម លើអ្នកជំងឺដែលទើបតែចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។
- **ឱសថ ATV/r មិនសូវបណ្តាលឱ្យកើតរោគលឿងទេ (jaundice)** ដូច្នេះការព្យាបាលដោយឱសថនេះ វាមិនបណ្តាលឱ្យរលាកថ្លើមទេ។ កម្រិត AST/ALT នៅធម្មតា និងគ្មានរោគសញ្ញា និងមិនមានមូលហេតុអ្វីគួរឱ្យបារម្ភណ៍ទេ។

**រោគសញ្ញាគ្លីនិកជំងឺរលាកថ្លើម** រួមមាន៖ ចង្អោរ ក្អួត ឈឺពោះ សាច់ថ្លើមមានសភាពស្រទន់ (liver tenderness) រោគលឿង និងគ្រុនក្តៅ។

## ការធ្វើតេស្តនៅពេលដើមគ្រា និង ការធ្វើតេស្តតាមដាន

- ធ្វើតេស្ត ALT/AST នៅពេលដើមគ្រា និងនៅខែទី១ និងខែទី៣ រាល់ក្រោយពេលប្តូររូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។
- តាមដានរោគសញ្ញា គឺមានសារសំខាន់ណាស់ ហើយបើមានរោគសញ្ញារលាកថ្លើមលេចឡើងត្រូវធ្វើតេស្ត ALT/AST ភ្លាម។

## ការគ្រប់គ្រងព្យាបាល

- បើ ALT/AST > ៥ដង x ULN, +/ឬ រោគលឿង (jaundice), +/ឬ រោគសញ្ញា
  - ត្រូវបញ្ឈប់ការព្យាបាលដោយឱសថក្រុម NNRTI ក្រុម PI ឱសថ cotrimoxazole ឱសថព្យាបាលជំងឺរបេង ឱសថ fluconazole និងឱសថផ្សេងទៀតដែលមិនសំខាន់ តែវាអាចបណ្តាលឱ្យពុលថ្លើម។
  - ធ្វើតេស្ត INR ALP bilirubin ពិនិត្យគ្រាប់ឈាមទាំងអស់(CBC) creatinine និង electrolytes
  - ត្រូវឱ្យអ្នកជំងឺសំរាកព្យាបាលក្នុងមន្ទីរពេទ្យ ដោយព្យួរសេរ៉ូមតាមសរសៃ(IVI fluids) និងតាមដានឱ្យបានដិតដល់។
  - អាចបន្តការព្យាបាលដោយឱសថក្រុម NRTI រយៈពេល៧ថ្ងៃទៀត បើអ្នកជំងឺព្យាបាលដោយឱសថ NNRTI ដើម្បីការពារប្រឆាំងនឹងប្រសិទ្ធភាពនៃការព្យាបាលតែមួយមុខ (effective monotherapy)។ ប៉ុន្តែ ករណីដែលស្ថានភាពអ្នកជំងឺមានសភាពធ្ងន់ធ្ងរ ត្រូវបញ្ឈប់ការព្យាបាលដោយឱសថក្រុម NRTI ។
  - ការស្រាវជ្រាវបន្ថែម ផ្អែកតាមលទ្ធផលរោគសញ្ញាគ្លីនិក និងតេស្តអមវេជ្ជសាស្ត្រ រួមមាន៖ ការឆ្លុះអេកូពោះ ការស្រាវជ្រាវរករោគសញ្ញាជំងឺរបេង និងការបង្ករោគផ្សេងទៀត។
  - បើអ្នកជំងឺមានជំងឺរបេងធ្ងន់ធ្ងរ ត្រូវពិចារណាក្នុងការប្តូរឱសថព្យាបាលជំងឺរបេងដែលបានដឹងថា មិនសូវពុលថ្លើម ឧ. ឱសថ streptomycin ឱសថ moxifloxacin ដោយពិភាក្សាជាមួយនឹងមជ្ឈមណ្ឌលជាតិកំចាត់ជំងឺរបេង(CENAT)។
- បើ AST/ALT < ៥ដង x ULN និងគ្មានរោគសញ្ញាគ្លីនិក និងគ្មានរោគលឿង (jaundice)
  - បន្តការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងការព្យាបាលជំងឺរបេង ប៉ុន្តែត្រូវឈប់ប្រើប្រាស់ឱសថ fluconazole ឱសថ cotrimoxazole និងឱសថផ្សេងទៀត។
  - តាមដាន AST/ALT រៀងរាល់ ៥–១៤ ថ្ងៃ។

- អាស្រ័យតាមភាពធ្ងន់ធ្ងរនៃការរលាកថ្លើម និងត្រូវផ្អាកការព្យាបាលដោយភ្នាក់ងារដែលអាចបង្កឱ្យរលាកថ្លើម ហើយអាចចាប់ផ្តើមព្យាបាលឡើងវិញតាមវិធីសាស្ត្រ stepwise (ដោយបង្កើនកម្រិតដូសបន្តិចម្តងៗ) ធ្វើការតាមដានមុខងារថ្លើមឱ្យជិតដល់។ បើការពុលថ្លើម បណ្តាលមកពីឱសថព្យាបាលជំងឺរបេង ត្រូវពិភាក្សាជាមួយនឹង CENAT។
- នៅពេល AST/ALT ត្រឡប់មកតម្លៃធម្មតាវិញ
  - បើបណ្តាលមកពីផលវិបាកនៃឱសថ NVP → ចាប់ផ្តើមព្យាបាលដោយឱសថ EFV និងតាមដានការព្យាបាលរៀងរាល់សប្តាហ៍ (មិនត្រូវព្យាបាលដោយឱសថ NVP ម្តងទៀតទេ)។
  - បើបណ្តាលមកពីផលវិបាកនៃឱសថ EFV → ចាប់ផ្តើមព្យាបាលដោយឱសថក្រុម PI (មិនត្រូវព្យាបាលដោយឱសថក្រុម NNRTI ម្តងទៀតទេ)។
  - បើបណ្តាលមកពីផលវិបាកនៃឱសថ PI និង មិនមែនបណ្តាលមកពីឱសថក្រុម NNRTI → ចាប់ផ្តើមព្យាបាលដោយឱសថ EFV ។
  - បើបណ្តាលមកពីផលវិបាកនៃឱសថ PI → និងបណ្តាលមកពីឱសថក្រុម NNRTI ត្រូវពិភាក្សាជាមួយគ្រូពេទ្យជំនាញ ។
- ពេលណាតម្រូវឱ្យមានការព្យាបាលដោយឱសថផ្សេង ក្រៅពីឱសថប្រឆាំងជំងឺរបេង ឬ ឱសថប្រឆាំងមេរោគអេដស៍ ត្រូវចាប់ផ្តើមព្យាបាលដោយឃ្លាតគ្នាយ៉ាងតិច ២សប្តាហ៍ និងតាមដានតេស្ត AST/ALT រៀងរាល់សប្តាហ៍។

## ១០.៣.៤ ស្នាមកន្ទួលលើស្បែកបណ្តាលមកពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

- ស្នាមកន្ទួលលើស្បែកច្រើនកើតឡើងពេលព្យាបាល ដោយ ឱសថក្រុម NNRTI (ពេលព្យាបាលដោយឱសថ NVP ជួបញឹកញាប់ជាងពេលព្យាបាលដោយ ឱសថEFV) និងឱសថ cotrimoxazole។
- ការគ្រប់គ្រងព្យាបាល ស្នាមកន្ទួលលើស្បែក បណ្តាលមកពីការព្យាបាលដោយឱសថ cotrimoxazole សូមអានតារាងទី ៥ ២ ការគ្រប់គ្រងព្យាបាលស្នាមកន្ទួលលើស្បែក បណ្តាលមកពីប្រតិកម្មឱសថ Cotrimoxazole ។
- ស្នាមកន្ទួលលើស្បែក ក៏ជារោគសញ្ញាមួយនៃប្រតិកម្ម hypersensitivity ក្រោយពីការព្យាបាលដោយឱសថ abacavir ដែរ ប៉ុន្តែប្រតិកម្មនេះ ទំនងគ្របដណ្តប់ដោយមានរោគសញ្ញានៅរាងកាយ (systemic symptoms) វិញ។

### ការវាយតម្លៃ និងការគ្រប់គ្រងព្យាបាល

- នៅពេលមានស្នាមកន្ទួលលើស្បែក ត្រូវធ្វើតេស្ត AST/ALT នៅពេលប្រើប្រាស់ឱសថបណ្តាលឱ្យរលាកថ្លើម។

- **ស្នាមកន្ទួលលើស្បែក កម្រិតស្រាល (ចំណាត់ថ្នាក់ទី១ ឬទី២)៖** សាយភាព ឬ ដុំបន្ទះពណ៌ក្រហម ឬ macules និង papules និង/គ្មានរមាស់ខ្លាំង (pruritus) គ្មាន mucosal ឬ គ្រុនក្តៅ និងតេស្ត AST/ALT មានកម្រិតធម្មតា។
  - បន្តការព្យាបាលដោយឱសថក្រុម NNRTI បន្ថែមឱសថ antihistamine និងតាមដាន។
  - បើមានទំនាក់ទំនងជាមួយវិធីសាស្ត្រ ដំឡើងកម្រិតដូសរបស់ NVP បន្តិចម្តងៗ ការដំឡើងកម្រិតដូសនាំមុខនេះ អាចបន្តលើសពី ១សប្តាហ៍ទៀត។

- **ស្នាមកន្ទួលលើស្បែក កម្រិតមធ្យម (ចំណាត់ថ្នាក់ទី៣)**: ពងទឹក និងប៉ះពាល់ដល់ mucosal ខ្លះ មាន/គ្មានឡើង ALT/AST មាន/គ្មានគ្រុនក្តៅ។
  - បញ្ឈប់ការព្យាបាលដោយឱសថក្រុម NNRTI និងឱសថ cotrimoxazole បន្តការព្យាបាលដោយឱសថក្រុម NRTI លើសពី ៧ថ្ងៃទៀត។
    - នៅពេលមានស្នាមកន្ទួលលើស្បែក (មាន/គ្មាន) ជំងឺរលាកថ្លើម និង systemic symptoms ធូរស្រាល។
    - បើអ្នកជំងឺព្យាបាលដោយឱសថ NVP ត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឡើងវិញ ជាមួយនឹងឱសថ EFV។
    - បើអ្នកជំងឺព្យាបាលដោយឱសថ EFV ត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឡើងវិញ ជាមួយនឹងឱសថ ATV/r ។
  - នៅពេលដែលបានចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឡើងវិញ ត្រូវផ្តល់ការព្យាបាលដោយឱសថcotrimoxazoleឡើងវិញដោយអនុវត្តន៍តាមវិធីសារ desensitization តារាងទី ៥-៣ វិធីសារនៃការកាត់បន្ថយប្រតិកម្មនៃឱសថ Cotrimoxazole ចំពោះមនុស្សពេញវ័យ និងក្មេងជំទង់។

- **ស្នាមកន្ទួលលើស្បែកធ្ងន់ធ្ងរ(កម្រិតទី៤ និងមានគ្រោះថ្នាក់ដល់ជីវិត)**:រោគសញ្ញាដូចខាងក្រោម៖
  - **ចង្កោមរោគសញ្ញា** Drug hypersensitivity syndrome (DRESS): ស្នាមកន្ទួលលើស្បែក (morbilliform) > ៥០%នៃស្បែក + គ្រុនក្តៅ +/- ហើមប៉ោងកូនកណ្តុរ +/- eosinophilia, +/- nephritis (ពិនិត្យសម្អាធឈាម urine dipstick) +/- ជំងឺរលាកសួត (pneumonitis) ដោយថតសួតដោយកាំរស្មី X។
  - **ចង្កោមរោគសញ្ញា** Stevens–Johnson syndrome **និង ការពុលរលួយស្បែក** (Toxic Epidermal Necrolysis): ប្រតិកម្មពងស្បែករលួយ និងរាលដាលដល់ភ្នាសទីពីរនៃ mucus ឧ. មាត់ ភ្នែក ប្រដាប់បន្តពូជខាងក្រៅ (genitalia)។ ជាទូទៅ វាកើតឡើងភ្លាមៗ ឡើងដុំទឹកពណ៌ស្វាយជម្ពូរ ហើយឈឺ (dusky purple macules) នៅជំបន់ជុំវិញកន្លែងសង្កត់។

- **បញ្ឈប់ការព្យាបាលដោយឱសថទាំងអស់** និងបញ្ជូនអ្នកជំងឺទៅសំរាកព្យាបាលក្នុងមន្ទីរពេទ្យ មិនត្រូវចាប់ផ្តើមព្យាបាលដោយឱសថណាមួយក្នុងក្រុម NNRTI និង cotrimoxazole ឡើងវិញឡើយ តែត្រូវព្យាបាលដោយឱសថ ATV/r ជំនួសវិញ។

## ១០.៤ ផលលំបាករយៈពេលយូរនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

### ការប៉ះពាល់នៃមេតាបូលិក

- Protease inhibitors បណ្តាលឱ្យមានការប្រឈមមុខនឹងផលប៉ះពាល់មេតាបូលិក រួមមាន ឡើងជាតិស្ករក្នុងឈាម (hyperglycemia/ស៊ាំជាមួយ insulin និងកើតជំងឺទឹកនោមផ្អែម លើសជាតិខ្លាញ់ (hyperlipidemia) និងការប្រមូលផ្តុំជាតិខ្លាញ់នៅផ្នែកកណ្តាល(central adiposity)។
- គ្រប់ជំងឺទាំងអស់នេះ បង្កើនការប្រឈមមុខជាមួយនឹងជំងឺបេះដូង (cardiovascular disease)។ ដោយសារតែ អ្នកជំងឺអេដស៍ មានការប្រឈមមុខជាមួយនឹងជំងឺបេះដូង ដូច្នេះ ការឆាប់ចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ អាចមានផលប្រយោជន៍ក្នុងការកាត់បន្ថយនូវការប្រឈមមុខនេះ។
- ឱសថ Atazanavir/r បណ្តាលឱ្យមានផលប៉ះពាល់មេតាបូលិកតិចជាងឱសថ lopinovir/r។
- ឱសថ Efavirenz ចូលរួមលើការបង្កឱ្យមានវិបត្តិជាតិខ្លាញ់ (dyslipidemia)។
- ឱសថ Tenofovir និង PI's បណ្តាលឱ្យមានការវិវត្តន៍ទៅជំងឺពុកឆ្អឹង (osteoporosis)។

### ការបង្ការ និងការគ្រប់គ្រងព្យាបាល៖

- ត្រូវផ្តោតការយកចិត្តទុកដាក់ លើការកែសម្រួលកត្តាប្រឈមមុខ និងផ្តល់ការព្យាបាលសមស្របនៃជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម។ល។

## តារាងទី ១០-១ ការពុលឱសថប្រឆាំងមេរោគអេដស៍

| ឱសថប្រឆាំងមេរោគអេដស៍ | ការពុល | កត្តាប្រឈមមុខ | ការតាមដាន និងការគ្រប់គ្រងព្យាបាល | ជម្រើសនៃប្តូរឱសថ (Switch options) |
|---|---|---|---|---|
| ឱសថ AZT | ស្លេកស្លាំង neutropenia | ជំងឺស្លេកស្លាំងនៅពេលដើមគ្រា ឬ neutropenia | ចៀសវាងប្រើឱសថ AZT បើ Hb <៨ g/dl<br>ធ្វើតេស្ត Hb នៅថ្ងៃ០ ខែទី១ ខែទី៣ និងរៀងរាល់៦ខែម្តង។ | ប្តូរទៅប្រើ TDF ឬ ABC |
| | ជំងឺ Myopathy | | តាមដានរោគសញ្ញា បើឈឺសាច់ដុំ ឬ សាច់ដុំខ្សោយ ត្រូវធ្វើតេស្ត CK។ | |
| | Lipoatrophy | ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍រយៈពេលយូរ | ថយចុះជាតិខ្លាញ់នៅផ្ទៃមុខនៅអវៈយវៈ (limbs) នៅគូថ | |
| ឱសថ<br>AZT, TDF, ddi | Lactic acidosis ឬថ្លើមរីកធំខ្លាំង និង ខ្លាញ់ក្នុងថ្លើម | ព្យាបាល > ៦ខែ នៃឱសថក្រុម NRTI<br>BMI ខ្ពស់ ភេទស្រី | តាមដានរោគសញ្ញា:បើ N + V ឈឺពោះ ពិបាកដកដង្ហើម អស់កម្លាំង ពិនិត្យមើល: bicarbonate, AST/ALT, CK, lactate។ | បើកំពុងព្យាបាលដោយឱសថ AZT ត្រូវប្តូរទៅឱសថ TDF ឬ ABC<br>បើកំពុងព្យាបាលដោយឱសថ TDF ឬ ABC ត្រូវពិភាក្សាជាមួយគ្រូពេទ្យជំនាញ។ |

| | | | | |
|---|---|---|---|---|
| ឱសថ TDF | វិបត្តិមុខងារតម្រងនោម (Renal tubular dysfunction) | វ័យចាស់ ភេទប្រុស BMI ទាប ជំងឺអេដស៍ដំណាក់កាលធ្ងន់ធ្ងរ មានជំងឺមួយចំនួនដែលបន្ថយមុខងារតម្រងនោម (ជំងឺទឹកនោមផ្អែម លើសសម្ពាធឈាម រលាកថ្លើមប្រភេទC) ព្យាបាលដោយឱសថពុលតម្រងនោម និងបញ្ចេញតាមទឹកនោម ឬក្រុម PI។ | ចៀសវាងប្រើ TDF បើ eGFR < ៥០ ml/min ឬ កើតជំងឺទឹកនោមផ្អែមរយៈពេលយូរ ឬ ជំងឺលើសសម្ពាធឈាមមិនអាចត្រួតពិនិត្យបាន។ ការវាយតម្លៃ និងព្យាបាលមូលហេតុនៃជំងឺតម្រងនោម (ការខ្វះជាតិទឹក ជំងឺលើសសម្ពាធឈាម។ល។) *ឈប់ប្រើឱសថដែលពុលតម្រងនោម – ឌ NSAIDS* ធ្វើតេស្ត Cr + dipstick នៅថ្ងៃ០ ខែទី១ ខែទី៣ និងរៀងរាល់១២ខែម្តង។ | ប្តូរឱសថ TDF ទៅប្រើឱសថ AZT ឬ ABC វិញ<br><br>**ពិនិត្យតេស្ត HbsAg មុននឹងប្តូរឱសថ ** |
| | ថយចុះកំហាប់សារធាតុរ៉ែក្នុងឆ្អឹង | អាយុ > ៥០ឆ្នាំ ភេទស្រី BMI ទាប អសកម្មផ្លូវកាយ ជក់បារី ចាក់គ្រឿងញៀន ជំងឺទឹកនោមផ្អែម CLD ប្រើឱសថ Corticosteroid | រោគសញ្ញា<br>បាក់ឆ្អឹង ថយចុះកម្ពស់ (loss of height)<br>ឧបករណ៍វាយតម្លៃកត្តាប្រឈមមុខនឹងការបាក់ឆ្អឹង(FRAX)។ | |
| ឱសថ ABC | ប្រតិកម្ម Hypersensitivity | វត្តមាន HLA-B 5701 gene | មិនត្រូវព្យាបាលព្យាបាលដោយឱសថ ABC ឡើងវិញទេ។ | ប្តូរទៅប្រើឱសថ TDF ឬ AZT វិញ |
| ឱសថ 3TC / FTC | ករណីកំរនៃផលប៉ះពាល់របស់ក្នុងក្រុម NRTI | | | |
| ឱសថ EFV | ប្រព័ន្ធសរសៃប្រសាទកណ្តាល– ឈឺក្បាលតិចតួច សំរា | ប្រវត្តិជំងឺធ្លាក់ទឹកចិត្ត ឬជំងឺប្រកាច់ (seizures) | ជាធម្មតាជំងឺទឹកនោមផ្អែមអាចមានធូរស្រាលឡើងវិញ ក្រោយការព្យាបាល | ប្តូរទៅប្រើឱសថ NVP វិញ |

| | | | | |
|---|---|---|---|---|
| | នូមិនលក់ សុបិន្តអាក្រក់ វិបត្តិផ្លូវចិត្ត ធ្លាក់ទឹកចិត្ត វង្វេងស្មារតី | | ដោយឱសថ EFV ពីរសប្តាហ៍ តែវាក៏នៅជាប់រហូតដែរ។ | |
| | ប្រុសឡើងដោះ (Male gynaecomastia) | | | |
| ឱសថក្រុម NNRTI: EFV និង NVP | ពុលថ្លើម | រលាកថ្លើម ប្រើឱសថដែលពុលថ្លើម។ ព្យាបាលដោយឱសថ NVP ស្រីមាន CD4 > ២៥០ ប្រុស CD4 > ៤០០ | តាមដានរោគសញ្ញា និងធ្វើតេស្ត AST/ALT នៅថ្ងៃ០ ខែទី១ ខែទី៣។ | ប្តូរទៅប្រើឱសថផ្សេងក្នុងក្រុម NNRTI, ទោះបីជា អ្នកជំងឺមិនអាចទ្រាំបាន (tolerate) អាចជា NNRTI ប្តូរទៅប្រើឱសថ PI (ឬ DTG បើអាចធ្វើបាន) |
| | ស្នាមកន្ទួលស្បែក និង hypersensitivity syndrome (Stevens Johnson) | | | សូមអានផ្នែកអំពីស្នាមកន្ទួលលើស្បែកបណ្តាលមកពីការព្យាបាលដោយឱសថ ARV ក្នុងជំពូកទី១០ ការតាមដាននៃការពុលឱសថ និងការប្តូរឱសថប្រឆាំងមេរោគអេដស៍។ |

| | | | | |
|---|---|---|---|---|
| ឱសថ ATV/r | Indirect hyperbilirubinaemia (សញ្ញាគ្លីនិក ចេញលឿង) | | បើគ្មានរោគសញ្ញា និង ALT/AST ធម្មតា មិនត្រូវប្តូរឱសថទេ។ | |
| | Electrocardiographic មិនធម្មតា (PR interval prolongation) | ធ្លាប់មានជំងឺនាំមុខមួយចំនួន ដូចជា ថយចុះជាតិប៉ូតាស្យ៉ូម (Hypokalemia) | ចៀសវាងការប្រើរួមគ្នាជាមួយឱសថផ្សេងទៀតដែលនាំឱ្យ QT យូរ ឬ PR interval ។ | |
| | Nephrolithiasis និងប្រឈមមុខនឹងកើតកូនមិនគ្រប់ខែ (prematurity) | | | ប្រើឱសថ LPV/r (ឬ ឱសថ DRV/r ប្រើ សិនជាមាន)។ |
| ឱសថក្រុម Protease inhibitors | ពុលថ្លើម | ជំងឺរលាកថ្លើម ប្រើឱសថដែលពុលថ្លើម | តាមដានរោគសញ្ញា និងធ្វើតេស្ត AST/ALT នៅថ្ងៃ0 ខែទី១ ខែទី៣។ | ប្តូរទៅប្រើឱសថ LPV/r ឬប្តូរឱសថ DRV/r ទៅប្រើឱសថ ATV/r វិញ។ |
| | រាគរូស និងជំងឺប្រដាប់រំលាយអាហារ (ធ្ងន់ឡើងពេលប្រើឱសថ LPV/r) | | | ប្តូរទៅប្រើឱសថ LPV ទៅប្រើឱសថ ATV/r វិញ។ |
| | ចង្កោមរោគសញ្ញាមេតាបូលិក (ប្រើឱសថ LPV/r កាន់តែធ្ងន់) ជំងឺទឹកនោមផ្អែម dyslipidaemia ជំងឺរលាកលំពែង។ | ជំងឺសួរពូជ និង ការកែប្រែកត្តាប្រឈមមុខ។ | វាស់សម្ពាធឈាមរាល់ពេលមកពិគ្រោះជំងឺ។ ផ្តល់យោបល់ពីរបៀបរស់នៅ (Lifestyle advice) ជំងឺទឹកនោមផ្អែម និង ធ្វើតេស្ត lipids រៀងរាល់១២ខែម្តង។ | ប្តូរទៅប្រើឱសថ LPV/r ទៅប្រើឱសថ ATV/r វិញ។ |

| | | | | |
|---|---|---|---|---|
| ឱសថ Darunavir /r (DRV/r) | ស្បែកនិងប្រតិកម្ម hypersensitivity | Sulfonamide allergy | | |
| | ពុលប្រព័ន្ធសរសៃប្រសាទកណ្តាល: សំរាន្តមិនលក់ សុបិន្តអាក្រក់ ធ្លាក់ទឹកចិត្ត វង្វេងស្មារតី។ | ធ្លាប់មានបញ្ហាសុខភាពផ្លូវចិត្ត | កម្រិតដូសលេបពេលថ្ងៃ។ | |
| ឱសថ LPV/r | Electrocardiographic មិនធម្មតា (PR និង QT interval prolongation, torsade de points)។ | ធ្លាប់មានជំងឺនាំមុខមួយចំនួនដូចជា ថយចុះជាតិប៉ូតាស្យ៉ូម (Hypokalaemia)។ | ចៀសវាងការប្រើរួមគ្នាជាមួយឱសថផ្សេងទៀតដែលនាំឱ្យ QT យូរ ឬ PR interval ។ | |
| | ស្បែក និង ប្រតិកម្ម hypersensitivity | | | ប្រើឱសថ ATV/r វិញ |
| ឱសថ Dolutegravir (DTG) | សំរាន្តមិនលក់ និង ឈឺក្បាល។ | | | |
| | ការពុលថ្លើម | ជំងឺរលាកថ្លើម ប្រើឱសថដែលពុលថ្លើម | ធ្វើតេស្ត AST/ALT នៅថ្ងៃ០ ខែទី១ ខែទី៣ និងរៀងរាល់៦ខែម្តង។ | |
| | ប្រតិកម្ម Hypersensitivity | | | |

# ជំពូក ១១. តាមដានការឆ្លើយតបទៅនឹង ការព្យាបាលដោយ ឱសថប្រឆាំងមេរោគអេដស៍

ការតាមដានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ចែកជា បីកម្រិត។ សូមមើលតារាងទី១១-២ និយមន័យនៃការបរាជ័យផ្នែកគ្លីនិក ផ្នែកភាពស៊ាំ និងផ្នែកវីរុសសាស្ត្រ ស្របតាម WHO។

## ១១.១ ការតាមដានវីរុសសាស្ត្រ

- លទ្ធផលតេស្ត HIV Viral load គឺរំពឹងថា នឹងមិនអាចរកមេរោគអេដស៍ឃើញ(undetectable) នៅពេលធ្វើតេស្តតាមដានជាប្រចាំនៅ៦ខែដំបូង និងរក្សាភាព undetectable VL ក្នុងកំឡុងពេលព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។ បើមានការកើនឡើងវិញនូវ viral load ចំពោះអ្នកជំងឺដែលបានលេបថ្នាំត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ត្រូវចាត់ទុកថា បរាជ័យផ្នែកវីរុសសាស្ត្រ និងជាទូទៅ វាជាលទ្ធផលនៃការវិវត្តន៍នៃមេរោគអេដស៍ទៅរកភាពស៊ាំជាមួយឱសថប្រឆាំងមេរោគអេដស៍(HIV drug resistant mutations) ដែលអនុញ្ញាតឱ្យវីរុសអាចគេចផុតពីឥទ្ធិពលរបស់ថ្នាំបាន(virological escape)។

- **ការធ្វើតេស្ត** viral load **ជាប្រចាំ** រកឃើញថា មានការកើនឡើងនៃ viral load ដែលអាចជាគន្លឹះមួយដែលត្រូវធ្វើការពិនិត្យវាយតម្លៃឡើងវិញនូវរោគសញ្ញាគ្លីនិក និងផ្តល់ការគាំទ្រអ្នកជំងឺឱ្យលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់។

- **គោលដៅនៃការធ្វើតេស្ត** viral load **ជាប្រចាំ** អាចនឹធ្វើឡើង ដើម្បីបញ្ជាក់ពីការបរាជ័យផ្នែកវីរុសសាស្ត្រ នៅក្នុងបរិបទដែលមានការបរាជ័យផ្នែកគ្លីនិក ឬផ្នែកភាពស៊ាំ។

- ការធ្វើតេស្ត VL ជាប្រចាំ គឺជាជម្រើសដ៏ល្អជាងគេ ក៏ប៉ុន្តែ ការធ្វើតេស្ត VL គោលដៅអាចយកមកអនុវត្តន៍ ប្រសិនបើមិនមានធនធានគ្រប់គ្រាន់ក្នុងការធ្វើតេស្ត VL ជាប្រចាំនោះទេ។
- សូមមើលគំនូសបំព្រួញនៃការធ្វើតេស្ត Viral load ខាងក្រោម។

## ១១.២ ការតាមដានភាពស៊ាំ

- ត្រូវធ្វើតេស្តកោសិកាCD4 អាចត្រូវបានអនុវត្តន៍មុននឹងចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ប៉ុន្តែ មិនតម្រូវឱ្យរង់ចាំលទ្ធផលតេស្តកោសិកាCD4 នោះទេ មុននឹងចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទេ។

- ការធ្វើតេស្តកោសិកាCD4 នៅពេលដើមគ្រា គឺមានសារៈសំខាន់ក្នុងការកំណត់ពីតម្រូវការនៃការព្យាបាលបង្ការជំងឺឱកាសនិយម និងដឹងពីកម្រិតនៃការថយចុះនៃភាពស៊ាំ និងការប្រឈមមុខនឹងជំងឺឱកាសនិយម មាន/ឬគ្មាន IRIS នៅពេលព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។
- គេអាចបញ្ឈប់ការធ្វើតេស្តតាមដានCD4 ចំពោះអ្នកជំងឺដែលមានលំនឹងផ្នែកសុខភាពៈ
  - បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ យ៉ាងតិចមួយឆ្នាំ មានចំនួនកោសិកា CD4> ៣៥០ និងគ្មានប្រតិកម្មឱសថដែលតម្រូវឱ្យតាមដានជាទៀងទាត់ គ្មានជំងឺឱកាសនិយម ឬ គ្មានផ្ទៃពោះ ហើយដឹងច្បាស់ពីការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់និងជាប់លាប់អស់មួយជីវិត និងមានភស្តុតាងបញ្ជាក់ពី ភាពជោគជ័យនៃការព្យាបាល (ការធ្វើតេស្ត VL ២ដងមានលទ្ធផល undetectale VL)។
- ករណីមានការបរាជ័យផ្នែកវីរុសសាស្ត្រ ត្រូវធ្វើតេស្តកោសិកាCD4។
- ប្រសិនបើ មិនអាចធ្វើតេស្តVL ជាប្រចាំ ត្រូវបន្តធ្វើតេស្តរាប់ចំនួនកោសិកាCD4 រៀងរាល់ ៦ខែម្តង និងការធ្វើតេស្ត VL គោលដៅ ករណីមានការធ្លាក់ចុះចំនួនកោសិកាCD4។
- សូមមើលគំនូសបំព្រួញនៃការធ្វើតេស្តរាប់ចំនួនកោសិកាCD4 ខាងក្រោម។

## ១១.៣ ការតាមដានរោគសញ្ញាគ្លីនិក

- ត្រូវតាមដានអ្នកជំងឺអេដស៍ក្នុងការវិវត្តន៍សារចុះសារឡើងទៅដំណាក់កាលគ្លីនិកទី៤នៃ WHO ដែលកំណត់ពី ភាពបរាជ័យនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។ តារាងទី ៩៤-១ ប្រព័ន្ធចំណាត់ថ្នាក់ដំណាក់កាលគ្លីនិក នៃជំងឺអេដស៍សម្រាប់មនុស្សពេញវ័យ និងក្មេងជំទង់ស្របតាម WHO (≥ ១៥ឆ្នាំ)។

រូបភាពទី ១១-១ គំនូសបំព្រួញនៃការធ្វើតេស្តរាប់ចំនួនកោសិកា CD4



### តារាងទី ១១-១ ពេលណាដែលត្រូវចាប់ផ្តើម/បន្ត និងបញ្ឈប់ការធ្វើតេស្តកោសិកា *CD4* សម្រាប់តាមដាន

| | |
|---|---|
| **ការចាប់ផ្តើម /បន្ត** | ធ្វើតេស្តកោសិកា CD4 នៅពេលដើមគ្រា បន្ទាប់រាល់៦ខែម្តង រហូតដល់បំពេញបាននូវលក្ខណៈវិនិច្ឆ័យដើម្បីឈប់ធ្វើតេស្តកោសិកាCD4។ |
| **លក្ខណៈវិនិច្ឆ័យនៃការឈប់ធ្វើតេស្តកោសិកា CD4 តាមដាន * នៅពេលដែលមានតេស្ត VL ។** | ព្យាបាលដោយ ART យ៉ាងតិច១ឆ្នាំ និងបានបំពេញលក្ខណៈវិនិច្ឆ័យខាងក្រោម: <br>• គ្មានប្រតិកម្មឱសថដែលតម្រូវឱ្យធ្វើការតាមដានជាទៀងទាត់។ <br>• គ្មានជំងឺឱកាសនិយម និងគ្មានការព្យាបាលជំងឺរបេង <br>• មិនមានផ្ទៃពោះ <br>• យល់ដឹងយ៉ាងច្បាស់ពីការលេបថ្នាំបានត្រឹមត្រូវ ទៀងទាត់និងជាប់លាប់អស់មួយជីវិត។ <br>• ធ្វើតេស្ត ២ដង x CD4 > ៣៥០ កោសិកា/មម៣ <br>• ធ្វើតេស្ត ២ដង x undetectable VL <br>• ធ្វើតេស្ត VL តាមដានជាប្រចាំ បើសិនជាមានលទ្ធភាព។ |
| **ធ្វើតេស្តកោសិកា CD4 ឡើងវិញ** | បរាជ័យផ្នែកវីរុសសាស្រ្ត → អនុវត្តន៍តាមរូបភាពនៃការធ្វើតេស្តកោសិកា CD4 <br>ផ្ទៃពោះ → អនុវត្តន៍តាមអនុសាសន៍ បើ < ៣៥០ +/ឬ VL detectable។ |

រូបភាពទី១១ -២ ការធ្វើតេស្ត Viral load សម្រាប់តាមដាន



**តារាងទី១១-២ និយមន័យនៃការបរាជ័យផ្នែកគ្លីនិក ផ្នែកភាពស៊ាំ និងផ្នែកវីរុសសាស្រ្ត ស្របតាម *WHO*[១៨]**

| បរាជ័យ | និយមន័យ | អត្ថាធិប្បាយ |
|---|---|---|
| ផ្នែកគ្លីនិក | **មនុស្សពេញវ័យនិងក្មេងជំទង់**<br>កំពុងលេចចេញរោគសញ្ញាគ្លីនិក ឬមានរោគសញ្ញាគ្លីនិកថ្មីៗដែលបញ្ជាក់ពី ការចុះថយភាពស៊ាំធ្ងន់ធ្ងរ (ដំណាក់កាលគ្លិនិកទី៤ នៃWHO )* ក្រោយពីព្យាបាលដោយ ART បាន៦ខែ។<br>**កុមារ**<br>កំពុងលេចចេញរោគសញ្ញាគ្លីនិក ឬមានរោគសញ្ញាគ្លីនិកថ្មីៗដែលបញ្ជាក់ពីការចុះថយភាពស៊ាំធ្ងន់ធ្ងរ (ដំណាក់កាលគ្លីនិកទី៣និងទី៤នៃ **WHO**, លើកលែងតែជំងឺរបេង) ក្រោយពីព្យាបាលដោយ ART បាន៦ខែ។ | លក្ខខណ្ឌខុសគ្នាពី ចង្កោមរោគសញ្ញានៃការស្តារឡើងវិញនៃភាពស៊ាំ ដែលកើតឡើងក្រោយពី ការចាប់ផ្តើមព្យាបាលដោយ ART ។<br><br>ចំពោះមនុស្សពេញវ័យ ដំណាក់កាលគ្លីនិកទី៣ នៃ WHO (ជំងឺរបេងសួត និងជំងឺបង្ករោគដោយបាក់តេរីធ្ងន់ធ្ងរ) អាចបញ្ជាក់ផងដែរ ពីភាពបរាជ័យនៃការព្យាបាល។ |
| ផ្នែកភាពស៊ាំ | **មនុស្សពេញវ័យនិងក្មេងជំទង់**<br>ចំនួនកោសិកា CD4 ថយចុះ ទៅដល់កម្រិតដើមគ្រា (ឬទាបជាង)<br>ឬ<br><br>ចំនួនកោសិកា CD4 ថយចុះ ជានិច្ច នៅកម្រិត < ១០០កោសិកា/មម³។<br>———<br>**កុមារ**<br>**កុមារអាយុតិចជាង ៥ឆ្នាំ**<br>ចំនួនកោសិកា **CD4** ថយចុះជានិច្ចនៅកម្រិត < ២០០កោសិកា/មម³ ឬ < ១០% ។<br>**អាយុលើសពី៥ឆ្នាំ**<br>ចំនួនកោសិកា **CD4** ថយចុះជានិច្ចនៅកម្រិត < ១០០កោសិកា/មម³ ។ | ករណីគ្មានការបង្ករោគរួមគ្នា ឬការបង្ករោគថ្មីៗ ដែលនាំឱ្យថយចុះចំនួនកោសិកាCD4 រយៈពេលខ្លី។<br>ការសិក្សាតាមវិធីសាស្រ្តពិនិត្យឡើងវិញជាប្រព័ន្ធ (systematic review) បង្ហាញថា លក្ខណៈវិនិច្ឆ័យគ្លីនិកនិងភាពស៊ាំបច្ចុប្បន្នរបស់ WHO មាន sensitivity និង positive predictive value កម្រិតទាបក្នុងការកំណត់បុគ្គលណា ដែលមានភាពស៊ាំផ្នែកវីរុស សាស្រ្ត ។ positive predictive value ត្រូវបានរំពឹងថា មានកម្រិតទាប នៅពេលចាប់ផ្តើមព្យាបាល ដោយ ART បានឆាប់ និងបរាជ័យនៃការព្យាបាលនៅពេលមានចំនួនកោសិកា CD4 នៅតែខ្ពស់។ បច្ចុប្បន្ននេះ មិនទាន់មាននិយមន័យណាផ្សេងទៀត អំពី ការបរាជ័យនៃការព្យាបាលទេ និង គ្មាន និយមន័យផ្សេងនៃការបរាជ័យផ្នែកភាពស៊ាំទេ។ |
| ផ្នែកវីរុសសាស្រ្ត | ផ្លាស់ស្នា VL ច្រើនជាង ១០០០ copies/ម.ល ដោយផ្អែកលើការធ្វើតេស្ត VL ពីរដងបន្តបន្ទាប់គ្នាចន្លោះគ្នា៣ខែម្តង ក្រោយពីផ្តល់ការគាំទ្រលើការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់និងជាប់លាប់ល្អ។ | តម្លៃទាបបំផុត(optimal threshold)នៃVL ដែលបញ្ជាក់ពីការបរាជ័យផ្នែកវីរុសសាស្រ្ត និងតម្រូវឱ្យផ្លូរូបមន្តព្យាបាលដោយ ART នៅមិនទាន់បានកំណត់នៅឡើយទេ។<br>ត្រូវព្យាបាលអ្នកជំងឺយ៉ាងតិច៦ខែ មុននឹងកំណត់ថារូបមន្តព្យាបាលនោះបរាជ័យ។<br>វាយតម្លៃ VL ដោយប្រើ DBS និងបច្ចេកវិទ្យា Point-of-care ដោយកំណត់យកកម្រិត VL ខ្ពស់ជាង។ |

[១៨] គោលការណ៍ណែនាំ អង្គការសុខភាពពិភពលោក ២០១៣

# ជំពូក ១២. ការគ្រប់គ្រងភាពបរាជ័យ នៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

## ១២.១ តើត្រូវធ្វើដូចម្តេចនៅពេលដែលលទ្ធផលតេស្ត viral load មានមេរោគអេដស៍ច្រើន អាចរកឃើញ (detectable )

ការគ្រប់គ្រងព្យាបាលអ្នកជំងឺដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគ ហើយមានតេស្ត VL មានចំនួនមេរោគច្រើន ត្រូវបានរកឃើញ (detectable) គឺមានសារៈសំខាន់ណាស់ ទាំងចំពោះសុខភាពអ្នកជំងឺ និង ដើម្បីកាត់បន្ថយការប្រឈមមុខនឹងការចម្លងមេរោគអេដស៍ រួមទាំង ភាពស៊ាំនៃមេរោគអេដស៍ជាមួយឱសថ។

Viral load **អាច** detectable **ដោយសារ**

១. ភាពស៊ាំនៃមេរោគអេដស៍ជាមួយឱសថប្រឆាំងមេរោគអេដស៍និងការគេចខ្លួននៃមេរោគអេដស៍។

២. ការបន្តបំបែកខ្លួននៃមេរោគអេដស៍ បណ្តាលមកពី ការលេបថ្នាំមិនបានត្រឹមត្រូវ ទៀងទាត់និងជាប់លាប់ (poor adherence) ។

៣. A "blip": ជួនកាល VL detectable នៅកម្រិតទាប < ១០០០copies/ម.ល (ជាពិសេស < ៥០០ copies/ម.ល) និងក្រោយមក VL ត្រឡប់មកមានចំនួនតិច មិនអាចរកឃើញវិញ (undetectable) ដោយមិនចាំបាច់ប្តូររូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។

### ការព្យាបាលបង្ការជាវិជ្ជមាន (Positive prevention)

- ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍គឺ ជាការព្យាបាលដ៏មានប្រសិទ្ធភាពក្នុងការបង្ការការចម្លងមេរោគអេដស៍តាមផ្លូវភេទពីអ្នកផ្ទុកមេរោគអេដស៍ ទៅដៃគូដែលមិនផ្ទុកមេរោគអេដស៍ ដែលបញ្ជាក់ដោយលទ្ធផលតេស្ត*viral load គឺ* undetectable។
- បើលទ្ធផលតេស្ត VL ក្លាយជា detectable នៅពេលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នឹងមានការប្រឈមមុខនឹងការឆ្លងរាលដោយមេរោគអេដស៍ និងមានភាពស៊ាំជាមួយឱសថប្រឆាំងមេរោគអេដស៍។
  - ត្រូវអប់រំអ្នកជំងឺ ឱ្យពាក់ស្រោមអនាម័យ ដើម្បីបង្ការការចម្លងមេរោគអេដស៍ទៅដៃគូជាពិសេស រហូតដល់លទ្ធផលតេស្ត VL undetectable

### ការស្រង់ប្រវត្តជំងឺ

- ពិនិត្យសាកសួរអ្នកជំងឺឱ្យច្បាស់ថា អ្នកជំងឺមិនធ្លាប់បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីមុនទេ មុននឹងចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ? –តើអ្នក

ជំងឺធ្លាប់បានទទួលការព្យាបាលជំងឺអ្វីពីមុនមក? រួមទាំង កម្មវិធី PMTCT? ឬការព្យាបាលដោយដោយឱសថប្រឆាំងមេរោគអេដស៍ដោយប្រើឱសថតែមួយមុខ/ពីរមុខ នៅសេវាគ្លីនិកឯកជន?

## ការវាយតម្លៃរោគសញ្ញាគ្លីនិក

- ការវាយតម្លៃ និងការគ្រប់គ្រងព្យាបាលរោគសញ្ញាគ្លីនិក ដែលកើតឡើងដោយសារតែភាពបរាជ័យផ្នែកវីរុសសាស្ត្រ។ ពិនិត្យមើលរោគសញ្ញា ដូចជា ក្អួត ឬរាករូសបណ្ដាលមកពីវិបត្តិនៃការជ្រៀបចូល (malabsorption) ក្នុងរយៈពេលខ្លី ព្រមទាំង វាយតម្លៃរោគសញ្ញាគ្លីនិកជំងឺរបេង និង ជំងឺឱកាសនិយមផ្សេងៗ។

## ដោះស្រាយបញ្ហាលេបថ្នាំឱសថបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់

- ករណីភាគច្រើននៃភាពបរាជ័យនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បណ្ដាលមកពីបញ្ហាលេបថ្នាំមិនសូវបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ។ ក្នុងករណី តេស្ត VL detectable វាមានសារៈសំខាន់ណាស់ក្នុងការចំណាយពេលជាមួយអ្នកជំងឺ ពិភាក្សាគ្នាពីបញ្ហាពាក់ព័ន្ធជាមួយនឹងការលេបថ្នាំមិនសូវបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ហើយថា តើអ្នកជំងឺនឹងត្រូវរកដំណោះស្រាយបញ្ហានេះដោយរបៀបណា ?
- ពិនិត្យមើលការយល់ដឹងរបស់អ្នកជំងឺ អំពីរូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ពិនិត្យមើលថា តើគាត់យល់ដឹងច្បាស់ទេអំពី កម្រិតដូសត្រឹមត្រូវ និងពេលវេលាដែលត្រូវលេបថ្នាំ និងយល់ដឹងអំពី ភាពចាំបាច់ដែលត្រូវលេបថ្នាំ ឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់។
- ពិនិត្យមើលពីតម្រូវការនៃការហូបអាហារពេលលេបថ្នាំ និងពិនិត្យមើលថា តើអ្នកជំងឺបានលេបថ្នាំត្រឹមត្រូវ ដែរឬទេ?
- ពិនិត្យមើលឱសថ–អន្តរកម្មឱសថ
- ស្វែងយល់ពី កម្រិតនៃការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ របស់អ្នកជំងឺ។
    - បើអ្នកជំងឺលេបថ្នាំមិនបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់(adherence is very poor)ទេ ហើយលទ្ធផលតេស្ត VL មានកម្រិតមេរោគអេដស៍ខ្ពស់ ដូច្នេះវាអាចមិនមែនមកពី ភាពស៊ាំនៃមេរោគអេដស៍ជាមួយនឹងឱសថប្រឆាំងមេរោគអេដស៍ដែលមានក្នុងរូបមន្តព្យាបាលទេ។
    - បើលទ្ធផលតេស្ត viral load អាច detectable តែមានកម្រិតទាប ក្រោយពីមានបញ្ហាទាក់ទងនឹងការលេបថ្នាំមិនសូវបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់នៅពេលកន្លងទៅថ្មីៗ ក្រោយពេលដែលមានការលេបថ្នាំត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ឡើងវិញ នាំឱ្យលទ្ធផលតេស្ត VL សំរេចបាននូវការលប់បំបាត់មេរោគអេដស៍ ។
- វាយតម្លៃពីរបាំងនៃការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ រួមមាន៖
    - របាំងនៃការជំរុញទឹកចិត្តឱ្យលេបថ្នាំ (Motivational barriers) ដូចជា ការបាក់ទឹកចិត្ត (depressed mood) (សូមអាន ជំពូកទី៤២. សុខភាពផ្លូវចិត្ត។

- របាំងនៃការចងចាំ (Cognitive barriers) រួមមាន ថយចុះការចងចាំ ឬជំងឺវិកលចរិត (dementia) (សូមអានជំពូក ២០. ជំងឺខួរក្បាលបង្កដោយមេរោគអេដស៍/ជំងឺវិកលចរិក (dementia)។
- ការផឹកសុរា ឬ ប្រើប្រាស់គ្រឿងញៀន ។
- ភាពទ្រាំទ្រជាមួយឱសថ (Drug tolerability) ផលប៉ះពាល់នៃឱសថប្រឆាំងមេរោគអេដស៍ក្នុងរូបមន្តព្យាបាល ។
- របាំងនៃការចាត់ចែង (Organizational barriers) ដូចជា កម្មវិធីមមាញឹក ការធ្វើដំណើរ ស្ថានភាពសង្គមច្របូកច្របល់ (chaotic social situation)។ល។

- ធ្វើការជាមួយអ្នកជំងឺ និងក្រុមគ្រួសារដើម្បីដោះស្រាយបញ្ហាលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់៖
  - ផ្តល់ព័ត៌មានតាមធ្យោបាយដែលអ្នកជំងឺអាចទទួលយកបាន ធ្វើតាមការណែនាំ និងយល់ដឹងច្បាស់លាស់ ។
  - ជ្រើសរើស និងស្វែងរកការគាំទ្រពីក្រុមគ្រួសារ ឬមិត្តភ័ក្រ ។
  - បើសង្ស័យថា អ្នកជំងឺមានជំងឺបាក់ទឹកចិត្ត ឬជំងឺវិកលចរិក(dementia) ត្រូវបញ្ជូលអ្នកជំងឺទៅទទួលសេវាសុខភាពផ្លូវចិត្តសមស្រប ។
  - ផ្តល់យោបល់ឱ្យអ្នកជំងឺប្រើប្រាស់ឧបករណ៍រម្លឹក(reminders) – ឧ. ទូរស័ព្ទដៃ ឬផ្សារភ្ជាប់ពេលវេលានៃការលេបថ្នាំទៅនឹងការងារប្រចាំថ្ងៃរបស់គាត់ (ឧ. ការដុសធ្មេញ ការលុបលាងមុខ)។
  - ធ្វើបញ្ជីឈ្មោះនិងលេខទូរស័ព្ទទំនាក់ទំនង រវាងក្រុមមិត្តជួយមិត្ត ឬ អ្នកផ្តល់ប្រឹក្សា អ្នកជំងឺអេដស៍ស្ម័គ្រចិត្ត ក្រុម MMM ឬ គិលានុបដ្ឋាកដែលជាអ្នកផ្តល់ប្រឹក្សា ។

**ត្រូវធ្វើតេស្ត VL ឡើងវិញ នៅខែទី៣**

- បើ VL undetectable: ធានាថា អ្នកជំងឺ ត្រូវបានត្រឡប់មកតាមដានជាប្រចាំវិញ ។
- បើ Detectable VL < ១០០០ copies/ម.ល : បន្តការងារពង្រឹងការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ និងធ្វើតេស្ត VL ឡើងវិញនៅខែទី៣ ។
- បើ VL > ១០០០copies/ម.ល: មានន័យថា *បរាជ័យផ្នែកវីរុសសាស្ត្រ* ។

## ១២.២ ការបរាជ័យផ្នែកវីរុសសាស្ត្រ ក្រោយពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ក្នុងរូបមន្តព្យាបាលជួរទី១

- ករណីដែលបញ្ជាក់ថា បរាជ័យផ្នែកវីរុសសាស្ត្រ ត្រូវប្តូរទៅព្យាបាលដោយប្រឆាំងមេរោគអេដស៍ជួរទី២ ជាបន្ទាន់ ដើម្បីចៀសវាងការវិវត្តន៍ទៅរកភាពស៊ាំ (resistance mutations)។

- ម្យ៉ាងទៀត គឺការប្តូរទៅព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី២បាន លុះត្រាតែបានដោះស្រាយបញ្ហានៃការលេបថ្នាំមិនបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់រួចហើយ។ ករណីនៅតែបន្តលេបថ្នាំមិនបានត្រឹមត្រូវ ទៀងទាត់និងជាប់លាប់ អាចបណ្តាលឱ្យបរាជ័យជាមួយឱសថប្រឆាំងមេរោគអេដស៍ជួរទី២ទៀត ហើយយើងនឹងមិនមានជម្រើសផ្សេងទៀតទេ ។
- ធ្វើតេស្តរាប់ចំនួនកោសិកា CD4 ដើម្បីបញ្ជាក់ពីការបរាជ័យផ្នែកវីរុសសាស្ត្រ និងវាយតម្លៃពីតម្រូវការព្យាបាលបង្ការជំងឺឱកាសនិយម ។
- បើអ្នកជំងឺកំពុងតែព្យាបាលជំងឺរបេងសកម្ម គួរពិចារណាក្នុងការពន្យាពេលប្តូរទៅព្យាបាលឱសថប្រឆាំងមេរោគអេដស៍ជួរទី២ រហូតដល់បញ្ចប់ការព្យាបាលជំងឺរបេង ដើម្បីចៀសវាងអន្តរកម្មឱសថ ដែលតម្រូវឱ្យប្រើប្រាស់កម្រិតដូសទ្វេនៃឱសថLPV/r។
- ការប្តូរទៅព្យាបាលឱសថជួរទី២ ក្រោយពីធ្វើតេស្ត VL ២ដង មានលទ្ធផល detectable > ១០០០ copies/ml ដោយឃ្លាតគ្នា ≥ ៣ខែម្តង និង ក្រោយពីបានដោះស្រាយបញ្ហាលេបថ្នាំមិនបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ។
- ត្រូវជ្រើសរើសឱសថជួរទី២ ដូចខាងក្រោមៈ

## ១២.៣ រូបមន្តព្យាបាលជួរទី២ នៃឱសថប្រឆាំងមេរោគអេដស៍

ប្រទេសកម្ពុជា បានអនុវត្តវិធីសាស្ត្រសុខភាពសារធារណៈក្នុងការព្យាបាលជំងឺអេដស៍ ដែលមានរូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ស្តង់ដា អាចនឹងវិវត្តន៍ទៅរកភាពស៊ាំជាមួយឱសថ ក្រោយពីការបរាជ័យជាមួយឱសថប្រឆាំងមេរោគអេដស៍ជួរទី១ ។

- សូមមើលតារាទី ១២-១ រូបមន្តស្តង់ដា នៃព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី២ ដែលមានឱសថឆ្លាស់គ្នាក្នុងរូបមន្តជួរទី២ អាស្រ័យទៅតាមឱសថក្នុងក្រុម NRTI ដែលបានប្រើប្រាស់ក្នុងរូបមន្តព្យាបាលជួរទី១។ ឱសថជម្រើសទី៣ គឺឱសថ protease inhibitor Atazanavir រួមផ្សំជាមួយឱសថ ritonavir ក្នុងកម្រិតដូសទាប ដូចជា ATV/r ៣០០/១០០ ម.ក្រ លេប១ថ្ងៃម្តង។

### ត្រូវធ្វើតេស្តអមវេជ្ជសាស្ត្រ មុននឹងប្តូរទៅប្រើប្រាស់ឱសថជួរទី២ៈ

- ស្ថានភាពជំងឺរលាកថ្លើមប្រភេទ B បើតេស្ត HBsAg វិជ្ជមាន ត្រូវរក្សាទុកឱសថ TDF ក្នុងរូបមន្តព្យាបាលជួរទី២ ។
- ធ្វើតេស្តរាប់ចំនួនកោសិកា CD4 ធ្វើតេស្ត CBC ធ្វើតេស្តមុខងារតម្រងនោម ធ្វើតេស្តរកជាតិខ្លាញ់ក្នុងឈាម (serum lipids)។

**តារាទី ១២-១ រូបមន្តស្តង់ដា នៃព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី២**

| បរាជ័យជាមួយឱសថជួរទី១ | ជម្រើសឱសថជួរទី២ |
|---|---|
| TDF + 3TC + NNRTI | AZT + 3TC + ATV/r (បើ HBsAg អវិជ្ជមាន) |
| | TDF + 3TC + AZT + ATV/r (បើ HBsAg វិជ្ជមាន) |
| AZT (or d4T) + 3TC + NNRTI | TDF + 3TC + ATV/r |
| បើព្យាបាលដោយ Rifampicin (ព្យាបាលជំងឺរបេង)<br>➢ ប្តូរត្រឡប់ទៅប្រើប្រាស់ឱសថ ATV/r វិញ ក្រោយពេលបញ្ចប់ការព្យាបាលជំងឺរបេង | ឱសថ NRTI ក្នុងរូបមន្តព្យាបាលជួរទី២ដូចខាងលើ + រួមជាមួយ អាចជា៖<br>• កម្រិតដូសទ្វេនៃឱសថ LPV/r លេប១២ម៉ោងម្តង ឬ<br>• LPV/r + ៣ x ១០០ម.ក្រ ritonavir លេប១២ម៉ោងម្តង តាមដានការពុលឱសថឱ្យដឹតដល់ ។ |
| បើបរាជ័យជាមួយឱសថជួរទី១ ដែលមានឱសថក្រុម PI | ពិភាក្សាជាមួយគ្រូពេទ្យជំនាញ។ |

**រូបមន្តព្យាបាលជួរទី២ រួមមាន៖**

- ATV/r ៣០០ម.ក្រ/១០០ម.ក្រ លេប១ថ្ងៃ/ម្តង+(AZT ៣០០ម.ក្រ + 3TC ១៥០ម.ក្រ) លេប១២ម៉ោង/ម្តង។
- ATV/r ៣០០ម.ក្រ/១០០ម.ក្រ លេប១ថ្ងៃ/ម្តង + (TDF ៣០០ម.ក្រ + 3TC ១៥០ម.ក្រ) លេប១ថ្ងៃ/ម្តង ។
- ATV/r ៣០០ម.ក្រ/១០០ម.ក្រ លេប១ថ្ងៃ/ម្តង + TDF ៣០០ម.ក្រ លេប១ថ្ងៃ/ម្តង + (AZT ៣០០ម.ក្រ + 3TC ១៥០ម.ក្រ) លេប១២ម៉ោង/ម្តង។
- ឬ បើកំពុងព្យាបាលដោយឱសថ rifampicin
  - ២ x LPV/r ៤០០ម.ក្រ/១០០ម.ក្រ លេប១២ម៉ោង/ម្តង + NRTI backbone ឬ
  - LPV/r ៤០០ម.ក្រ/១០០ម.ក្រ + ritonavir ៣x១០០ម.ក្រ លេប១២ម៉ោង/ម្តង + NRTI backbone។

**តាមដានការព្យាបាលដោយឱសថជួរទី២**

- ធ្វើតេស្ត VL ឡើងវិញក្រោយ ៦ខែ និងបន្ទាប់មក រៀងរាល់១២ខែ/ម្តង ។
- បើតេស្ត viral load មានលទ្ធផល detectable ពិនិត្យមើលរោគសញ្ញាគ្លីនិក និងបញ្ហាលេបថ្នាំត្រឹមត្រូវ ទៀងទាត់និងជាប់លាប់ និងធ្វើតេស្តVL ឡើងវិញនៅខែទី៣។

- ផ្តល់យោបល់ជូនអ្នកជំងឺថា គាត់មានការប្រឈមមុខខ្ពស់ក្នុងការចម្លងមេរោគអេដស៍តាមផ្លូវភេទ និងត្រូវប្រើប្រាស់ស្រោមអនាម័យជាប់ជានិច្ចរាល់ពេលរួមភេទ ។

**ឱសថ** Protease inhibitor **ក្នុងរូបមន្តព្យាបាលជួរទី២**: ATV/r

- ឱសថ ATV/r គឺជាជម្រើសមួយនៃឱសថក្នុងក្រុម protease inhibitor សម្រាប់ប្រើប្រាស់ក្នុងរូបមន្តព្យាបាលជួរទី២ ។ វាមានប្រសិទ្ធភាពដូចគ្នាជាមួយឱសថ LPV/r ដែរ និងមានផលប៉ះពាល់លើមេតាបូលិកតិចជាង ។
- ឱសថ ATV/r ៣០០ម.ក្រ /១០០ម.ក្រ លេប១ថ្ងៃ/ម្តងពេលបរិភោគអាហារ ដោយរួមជាមួយឱសថក្រុម NRTI ២មុខទៀត ។
- ឱសថ ATV/r មិនត្រូវប្រើទេ បើអ្នកជំងឺកំពុងព្យាបាលដោយឱសថ rifampicin។
- Proton pump inhibitors និងការបញ្ចេញទឹកអាស៊ីតក្រពះបណ្តាលឱ្យកម្រិតដូសឱសថប្រឆាំងមេរោគអេដស៍ថយចុះ ដោយបន្ថយការជ្រាបចូលរបស់ឱសថ ATV/r។
- ឱសថ ATV អាចបង្កើន PR និង QT intervals នឹងប្រឈមមុខនឹងជំងឺបេះដូងលោតខុសចង្វាក់ (arrhythmia)។
- ផលប៉ះពាល់ រួមមាន៖
  - ស្នាមកន្ទួលលើស្បែក ជាទូទៅអាចបាត់ទៅវិញដោយឯកឯងក្នុងកំឡុងពីរសប្តាហ៍ ក៏ប៉ុន្តែត្រូវបញ្ឈប់ការព្យាបាលដោយឱសថ ATV/r បើស្នាមកន្ទួលលើស្បែក មានសភាពធ្ងន់ធ្ងរ ។
  - ចេញលឿង (jaundice) បើគ្មានរោគសញ្ញា និង ALT/AST មានលទ្ធផលធម្មតា ករណីនេះមិនចាំបាច់បារម្ភណ៍ទេ ។
  - ឈឺក្បាល ចង្អោរ អង់ហ្ស៊ីមថ្លើមកើនឡើង ។
  - ផលលំបាកមេតាបូលិករយៈពេលយូរ: lipodystrophy ជំងឺទឹកនោមផ្អែម និងជាតិខ្លាញ់កើនឡើង។
- សូមអានជំពូក ១០. ការតាមដាននៃការពុលឱសថ និងការប្តូរឱសថប្រឆាំងមេរោគអេដស៍
- សូមអានផ្នែកខាងលើ អំពីរូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី១ ខាងលើ ដើម្បីទទួលបានព័ត៌មានអំពីឱសថក្នុងក្រុម NRTI ។

**ឱសថ Protease inhibitor ក្នុងរូបមន្តព្យាបាលជួរទី២: Lopinavir/ritonavir**

- ឱសថ LPV/r ត្រូវបានប្រើជំនួសឱសថក្រុម PI ក្នុងរូបមន្តព្យាបាលជួរទី២ តែត្រូវប្រើតែក្នុងបរិបទនៃការប្រើឱសថនេះរួមគ្នាជាមួយឱសថ rifampicin ដែលតម្រូវឱ្យប្រើកម្រិតដូសឱសថ LPV/r ខ្ពស់។ ការតាមដានឱ្យជិតដល់នូវផលប៉ះពាល់ រួមទាំង វិបត្តិប្រដាប់រំលាយអាហារ និងការពុលថ្លើម។
- កម្រិតដូសធម្មតាឱសថ LPV/r = ៤០០ម.ក្រ /១០០ម.ក្រ លេប២ដង/ថ្ងៃ នៅពេលបរិភោគអាហារ។

## ១២.៤ បរាជ័យជាមួយឱសថជួរទី ២

- ករណីមានការបញ្ជាក់ថា មានការបរាជ័យផ្នែកវីរុសសាស្ត្រក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី២ ត្រូវពិភាក្សាជាមួយផ្នែកថែទាំជំងឺអេដស៍នៃមជ្ឈមណ្ឌលជាតិ ដើម្បីពិភាក្សាអំពី ការវិភាគ genotype និងជម្រើសឱសថប្រឆាំងមេរោគអេដស៍ជួរទី ៣ (បើមានឱសថជួរទី៣នេះ)។
- គ្រប់ព័ត៌មានទាំងអស់អំពី អ្នកជំងឺដែលបរាជ័យជាមួយឱសថជួរទី២ នឹងត្រូវប្រមូល ដោយប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យរបស់មជ្ឈមណ្ឌលជាតិ និងត្រូវបានពិនិត្យដោយផ្នែកថែទាំជំងឺអេដស៍ រួមទាំង ការធ្វើតេស្ត Viral Load ។

## ចំណុចត្រូវពិចារណាក្នុងការគ្រប់គ្រងព្យាបាលអ្នកជំងឺ ដែលបរាជ័យក្រោយពេលព្យាបាលដោយ ឱសថប្រឆាំងមេរោគអេដស៍ជួរទី២[១៩]

**ការវិភាគ** Genotype

- ការវិភាគ genotype គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកំណត់ ថាតើមានភាពស៊ាំជាមួយឱសថប្រឆាំងមេរោគអេដស៍ដែរឬទេ? ។ ប្រសិនបើ គ្មានភាពស៊ាំជាមួយឱសថប្រឆាំងមេរោគអេដស៍ទេ ការបរាជ័យផ្នែកវីរុសសាស្ត្រ គឺស្ទើរតែប្រាកដថា ទាក់ទងទៅនឹងបញ្ហានៃការលេបថ្នាំមិនបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ (adherence) ដូច្នេះត្រូវផ្តោតលើការលើការជំរុញលើកទឹកចិត្តឱ្យអ្នកជំងឺលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ និងភាពទ្រាំទ្រជាមួយឱសថជួរទី២ (មិនត្រូវប្តូរទៅព្យាបាលឱសថជួរទី៣ ទេ) ។

- ការវិភាគ genotype គួរតែត្រូវបានអនុវត្ត ខណៈពេលដែលអ្នកជំងឺទទួលការព្យាបាលដោយរូបមន្តព្យាបាលនៃឱសថប្រឆាំងមេរោគអេដស៍បរាជ័យ ក្នុងគោលបំណងដើម្បីរកឱ្យឃើញឱសថប្រឆាំងមេរោគអេដស៍ដែលស៊ាំ ។

- បើ genotype បានបញ្ជាក់ពីភាពស៊ាំជាមួយឱសថ (វាមានលក្ខណៈស៊ីគ្នាជាមួយប្រវត្តិនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍របស់អ្នកជំងឺ) នឹងនាំឱ្យរៀបចំរូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ថ្មីមួយដែលគួរតែមានឱសថយ៉ាងហោចណាស់ពីរមុខ និងជាជម្រើសដ៏ល្អគឺ មានបីមុខដែលសកម្មពេញលេញ ។

---

[១៩] គោលការណ៍ណែនាំ អង្គការសុខភាពពិភពលោក ២០១៣ និង Panelសំរាប់ គោលការណ៍ណែនាំការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍សំរាប់មនុស្សពេញវ័យនិង ក្មេងជំទង់. គោលការណ៍ណែនាំការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ប្រឆាំងនឹង HIV-1 សំរាប់មនុស្សពេញវ័យនិង វ័យជំទង់។អាចរកបានពីប្រភព
: http://aidsinfo.nih.gov/contentfiles/lvguidelines/AdultandAdolescentGL.pdf

## ១២.៥ រូបមន្តព្យាបាលជួរទី ៣ (salvage regiment)

- ការប្រើឱសថប្រឆាំងមេរោគអេដស៍ "ថ្មី" ដែលអ្នកជំងឺមិនធ្លាប់បានលេបពីមុនមក មិនធានាថា ឱសថថ្មីនេះនឹងមានភាពសកម្មពេញលេញនោះទេ ដោយសារតែ វាមានភាពស៊ាំឆ្លងក្រុមនៃឱសថប្រឆាំងមេរោគអេដស៍។

- ទោះយ៉ាងណាក៏ដោយ ភ្នាក់ងារ "ឱសថប្រឆាំងមេរោគអេដស៍ជំនាន់ទីពីរ" ថ្មី នៃក្រុមឱសថប្រឆាំងមេរោគអេដស៍បច្ចុប្បន្ន សកម្មយ៉ាងខ្លាំងក្នុងការប្រឆាំងមេរោគអេដស៍ដែលមានភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគអេដស៍ដែលបានប្រើយូរហើយនៅក្នុងក្រុមដូចគ្នា ឧ. ឱសថ Etravirine (NNRTI) និងអាស្រ័យលើភាពស៊ាំជាក់លាក់នៃឱសថប្រឆាំងមេរោគអេដស៍ ឱសថក្រុម PI មួយចំនួន នឹងសកម្មក្នុងការប្រឆាំងមេរោគអេដស៍នៅក្នុងបរិបទដែលមានភាពស៊ាំជាមួយឱសថ PI ផ្សេងទៀត។

- នៅពេលមានភាពស៊ាំជាមួយឱសថប្រឆាំងមេរោគអេដស៍មួយចំនួន អនុសាសន៍ឱ្យកែសម្រួលកម្រិតដូសនៃឱសថប្រឆាំងមេរោគអេដស៍មួយចំនួន ដូចជា ឱសថ DRV/r (បើមានភាពស៊ាំជាមួយក្រុម PI) និងឱសថ DTG (បើមានភាពស៊ាំជាមួយក្រុម integrase inhibitor) ត្រូវឱ្យអ្នកជំងឺលេបឱសថនេះ២ដង/ថ្ងៃ ជំនួសឱ្យការលេប១ដង/ថ្ងៃ ដើម្បីសម្រេចបាននូវកម្រិតឱសថក្នុងឈាមខ្ពស់ជាង ។

- ឱសថប្រឆាំងមេរោគអេដស៍មួយចំនួន រក្សាភាពសកម្មមិនពេញលេញ (ឧ. ឱសថក្នុង NRTIs និង PIs) ក្នុងរូមមន្តព្យាបាល ប៉ុន្តែឱសថខ្លះ (ឧ. ឱសថក្រុម NNRTI) មិនមាននៅរូបមន្តព្យាបាលទេ ។

- ភាពស៊ាំជាមួយឱសថ 3TC/FTC អាចបណ្តាលមកពីគុណវិបត្តិនៃ "សម្បទា" របស់មេរោគអេដស៍ ជាលទ្ធផលនាំឱ្យកម្រិតមេរោគអេដស៍ក្នុងឈាមទាប ដូច្នេះ ជាទូទៅ គេផ្តល់យោបល់ឱ្យបន្តការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី៣។

- ពិនិត្យមើលស្ថានភាពជំងឺរលាកថ្លើមប្រភេទ B ។ ប្រសិនបើតេស្ត HBsAg វិជ្ជមាន ត្រូវរក្សាទុកឱសថ TDF នៅក្នុងរូបមន្តព្យាបាល ឬប្រសិនបើមិនអាចប្រើឱសថនេះបានទេ បណ្តាលមកពីការពុលនៃឱសថនេះ ត្រូវបន្តការព្យាបាលដោយឱសថ 3TC និងតាមដានយ៉ាងដិតដល់អំពីការផ្ទុះឡើងជំងឺរលាកថ្លើម (ឱសថ Etravirine គឺជាឱសថមួយទៀតដែលមានសកម្មភាពប្រឆាំងជំងឺរលាកថ្លើមប្រភេទ B ប៉ុន្តែវាគ្មានសកម្មភាពប្រឆាំងមេរោគអេដស៍ទេ) ដែលអាចយកប្រើជំនួសបាន ប៉ុន្តែ ឱសថនេះ មិនទាន់អាចរកបាននៅប្រទេសកម្ពុជាទេ) ។

- ឱសថប្រឆាំងមេរោគអេដស៍ផ្សេងទៀត ដែលត្រូវបានប្រើក្នុងរូបមន្តព្យាបាលជួរទី៣ នៅកម្ពុជារួមមាន-ឱសថ Darunavir/ritonavir(DRV/r) ឱសថ Etravirine (ETV) ឱសថ Raltegravir(RAL) និង ឱសថ Dolutegravir (DTG) ។

- ចំពោះអ្នកជំងឺមួយចំនួនដែលមានបទពិសោធន៍ក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដ៏មានប្រសិទ្ធភាពខ្ពស់ នៅមានជម្រើសឱសថប្រឆាំងមេរោគអេដស៍ជាច្រើនមុខទៀត។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មិនអាចឈានទៅសំរេចបាននូវការលប់បំបាត់ចំនួនមេរោគអេដស៍ក្នុងឈាមជាអតិបរមាបានដែរ ដោយសារតែ មានភាពស៊ាំ និងការពុលឱសថ ។ ក្នុងករណីនេះ ត្រូវបន្តការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ជាមួយរូបមន្តព្យាបាលដោយកាត់បន្ថយការពុលឱសថ និងបន្តធ្វើតេស្តរាប់ចំនួនកោសិកា CD4 និងពន្យាពេលលេចចេញនូវរោគសញ្ញាគ្លីនិក ។

# ជំងឺរបេង

# ជំពូក ១៣. ជំងឺរបេង

## ១៣.១ ចំណុចគន្លឹះ

- ប្រទេសកម្ពុជាមានបន្ទុកខ្ពស់នៃការបង្ករោគរបេងក្នុងចំណោមប្រជាជនទូទៅ។
- ជំងឺរបេង គឺជាមូលហេតុដ៏ចំបងនៃអត្រាឈឺនិងអត្រាស្លាប់ក្នុងចំណោមអ្នកជំងឺមេរោគអេដស៍។
- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ដែលមានការបង្ករោគដោយមេរោគរបេងផង នឹងមានការប្រឈមមុខនឹងការវិវត្តន៍ទៅជា ជំងឺរបេងសកម្មពី ៣០ ទៅ ៥០% ពេញមួយជីវិត ។
- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ទាំងអស់ ត្រូវតែទទួលបានការពិនិត្យស្រាវជ្រាវរករោគសញ្ញាជំងឺរបេង *រាល់ពេលមកពិគ្រោះជំងឺ* ។
- ត្រូវពិចារណានឹកគិតពីជំងឺរបេង នៅគ្រប់អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ទាំងអស់ ដែលមានរោគសញ្ញាផ្លូវដង្ហើម។
- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ដែលមានជំងឺរបេងរួមគ្នាទំនងជាមានជំងឺគ្រុនក្តៅអូសបន្លាយ ក្អកតិចតួច ពិនិត្យ AFB កំហាកអវិជ្ជមាន និងការថតសួត(CXR) មានរូបភាពមិនធម្មតា (atypical) ជាងអ្នកជំងឺដែលមិនផ្ទុកមេរោគអេដស៍ ។
- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ដែលគ្មានជំងឺរបេងសកម្មទាំងអស់ ត្រូវទទួលបានការព្យាបាលបង្ការជំងឺរបេងដោយឱសថ Isoniazid (IPT) ។
- សូមអានគោលការណ៍ណែនាំជាតិ អំពីសារតារលម្អិត និងការគ្រប់គ្រងព្យាបាលជំងឺរបេង/អេដស៍ និង DR-TB ។[២០,២១]

## ១៣.២ សេចក្តីផ្តើម

- ជំងឺរបេង(TB) បង្កដោយបាក់តេរីឈ្មោះ *Mycobacterium tuberculosis (MTB)* ។
- ជំងឺរបេង **ឆ្លងតាម** ផ្លូវដង្ហើមដែលមានមេរោគរបេងក្នុងដំណក់ទឹកមាត់តូចៗក្អកចេញពី អ្នកជំងឺរបេងសួតសកម្ម (PTB) ។
- វាជាការសំខាន់ក្នុងការបែងចែក រវាង **ការបង្ករោគរបេង** តែឯកឯង (គ្មានរោគសញ្ញាគ្លីនិក មិនចម្លងមេរោគរបេងទៅអ្នកដទៃទេ និងការធ្វើរោគវិនិច្ឆ័យនៅពេលធ្វើតេស្ត TST ឬ តេស្ត Interferon តែប៉ុណ្ណោះ) និង **ជំងឺរបេងសកម្ម** ។
  - ការព្យាបាលបង្ការដោយឱសថ Isoniazid (IPT) អាចបង្ការការវិវត្តន៍ពី ការបង្ករោគរបេងទៅជា ជំងឺរបេងសកម្ម។

---

[២០] ព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាល។ គោលការណ៍ ណែនាំគ្លីនិក ថ្នាក់ជាតិសំរាប់គ្រប់គ្រងការឆ្លងរួមគ្នាជំងឺរបេង/អេដស៍ (ភាសាអង់គ្លេសឆ្នាំ ២០០៨ មិនផ្លូវការ)និង ភាសាខ្មែរឆ្នាំ២០១៣។

[២១] គោលការណ៍ ណែនាំបច្ចេកទេស និងប្រតិបត្តិ សំរាប់គ្រប់គ្រងកម្មវិធី របេងស៊ាំថ្នាំនៅប្រទេសកម្ពុជា។

- **ជំងឺរបេង សកម្មភាពបញ្ជាក់ដូចខាងក្រោម៖**
    - **ជំងឺរបេងសួត (PTB)** អាចមាន លទ្ធផលពិនិត្យ *កំហាកវិជ្ជមាន* តាមរយៈការពិនិត្យដោយអតិសុខុមទស្សន៍ (ពេលមានការចម្លងរោគខ្លាំង) ឬ *កំហាកអវិជ្ជមាន* (លំបាកក្នុងការធ្វើរោគវិនិច្ឆ័យ) *ឬ*
    - **ជំងឺរបេងក្រៅសួត (EPTB)** កើតឡើងស្ទើរគ្រប់សរីរៈនៃរាងកាយ ។

## ១៣.៣ ភាពស៊ាំជាមួយឱសថប្រឆាំងជំងឺរបេង

- ជំងឺរបេង អាចបង្កឡើងដោយមេរោគរបេងដែលឆ្លើយតបនឹងឱសថប្រឆាំងជំងឺរបេង ឬមេរោគរបេងដែលស៊ាំជាមួយឱសថប្រឆាំងជំងឺរបេង (DR-TB) ។
- ការចម្លងមេរោគរបេងដែលស៊ាំជាមួយថ្នាំ (DR-TB) គឺប្រព្រឹត្តទៅតាមខ្យល់ដង្ហើម ដូចគ្នានឹងការចម្លងមេរោគរបេងដែលឆ្លើយតបទៅនឹងថ្នាំដែរ ដូច្នេះ អ្នកណាក៏អាចឆ្លងមេរោគរបេងដែលស៊ាំជាមួយថ្នាំជាបឋមដែរ (ជាពិសេស អ្នកដែលបានប៉ះពាល់នៅក្នុងបរិស្ថានថែទាំសុខភាព/មន្ទីរពិសោធន៍) ។
- ភាពស៊ាំជាមួយឱសថប្រឆាំងមេរោគរបេង (DR-TB) អាចកើតឡើងចំពោះអ្នកជំងឺដែលធ្លាប់ទទួលការព្យាបាលជំងឺពីមុន ដោយសារការប្រើរូបមន្តព្យាបាលមិនបានត្រឹមត្រូវ ឬ ការលេបថ្នាំមិនបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ល្អ។
- ភាពស៊ាំជាមួយឱសថប្រឆាំងមេរោគរបេង (DR-TB) កើតឡើងជាញឹកញាប់ ក្រោយពីការព្យាបាលបរាជ័យ ការលាប់ឡើងវិញ (relapse) និង ការលេបថ្នាំមិនបានត្រឹមត្រូវ ទៀងទាត់និងជាប់លាប់ល្អ ឬ ការជ្រាបចូលឱសថប្រឆាំងជំងឺរបេងមិនបានល្អ។

### ១៣.៣.១ ចំណាត់ថ្នាក់ភាពស៊ាំជាមួយឱសថប្រឆាំងជំងឺរបេង (DR- TB)[២២]

- ភាពស៊ាំជាមួយឱសថមួយមុខ: ភាពស៊ាំជាមួយឱសថប្រឆាំងមេរោគរបេងក្នុងរូបមន្តព្យាបាលជួរទី១ តែមួយមុខគត់ ។
- ភាពស៊ាំជាមួយឱសថច្រើនមុខ: ឱសថប្រឆាំងមេរោគរបេងក្នុងរូបមន្តព្យាបាលជួរទី១ លើសពីពីរមុខដែលស៊ាំជាមួយមេរោគរបេង ប៉ុន្តែមិនមែនឱសថ Isoniazid(H) និង Rifampicin (R) ដែលមានភាពស៊ាំជាមួយគ្នានោះទេ ។
- ភាពស៊ាំជាមួយពហុឱសថ (MDR-របេង): ភាពស៊ាំជាមួយឱសថ H និង R ដោយមាន ឬគ្មានភាពស៊ាំជាមួយឱសថផ្សេងទៀត ក្នុងរូបមន្តព្យាបាលជួរទី១ (FLD)ទេ។
- ភាពស៊ាំជាមួយឱសថទូលំទូលាយ (XDR-របេង): ភាពស៊ាំជាមួយឱសថ H និង R និងស៊ាំជាមួយឱសថ fluoroquinolone ព្រមទាំងស៊ាំជាមួយឱសថប្រឆាំងជំងឺរបេងណាមួយសម្រាប់ចាក់ (ដូចជា amikacin capreomycin និង kanamycin)។

---
[២២] គោលការណ៍ណែនាំ អំពីការព្យាបាលរបេង បោះពុម្ពផ្សាយលើកទី៤ របស់អង្គការសុខភាពពិភពលោក ២០១០

### ១៣.៣.២ ការធ្វើរោគវិនិច្ឆ័យភាពស៊ាំជាមួយឱសថប្រឆាំងជំងឺរបេង

- ការធ្វើតេស្ត DST រហ័ស: ឥឡូវតេស្ត GeneXpert MTB/RIF ត្រូវបានប្រើសម្រាប់ធ្វើរោគវិនិច្ឆ័យជំងឺរបេង និងអាចរកឃើញភាពស៊ាំជាមួយឱសថ Rifampicin។ តេស្ត GeneXpert MTB/RIF អាចធ្វើបាននៅតាមបណ្ដាខេត្តជាច្រើនក្នុងប្រទេសកម្ពុជា។
- ការធ្វើតេស្តរកឱសថណាដែលមានប្រសិទ្ធភាពប្រឆាំងមេរោគរបេង (Drug Susceptibility Testing =DST) ដោយការបណ្ដុះមេរោគរបេង ដើម្បីបញ្ជាក់អំពី ភាពស៊ាំជាមួយឱសថ Rifampicin និងការរកឃើញនូវភាពស៊ាំជាមួយឱសថផ្សេងទៀត ។

### ១៣.៣.៣ ការគ្រប់គ្រងព្យាបាលភាពស៊ាំឱសថប្រឆាំងជំងឺរបេង

- បើមានភាពស៊ាំជាមួយឱសថប្រឆាំងមេរោគរបេង: ការព្យាបាលតាមស្តង់ដារទំនងជាធ្វើឱ្យភាពស៊ាំជាមួយឱសថកាន់តែអាក្រក់ឡើង។
- ភាពស៊ាំជាមួយឱសថប្រឆាំងមេរោគរបេង តម្រូវឱ្យអូសបន្លាយការព្យាបាលជំងឺដោយប្រើឱសថច្រើនមុខ (multidrug) និងត្រូវមានវិធានការពិសេស សម្រាប់ទំនាក់ទំនងជាមួយអ្នកជំងឺ និង វិធានការត្រួតពិនិត្យការចម្លងរោគ ។[២៣]

## ១៣.៤ ជំងឺរបេងនៅកម្ពុជា

- បើយោងតាមអង្គការសុខភាពពិភពលោក សេចក្ដីសង្ខេបអំពីជំងឺរបេងនៅប្រទេសកម្ពុជាឆ្នាំ ២០១៣[២៤] មានដូចខាងក្រោម៖
  - ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានបន្ទុកជំងឺរបេងខ្ពស់ គឺមាន ៦៤%នៃចំនួនប្រជាជនសរុបបានបង្ករោគរបេង (ប្រមាណជា ៨ លាននាក់) ប៉ាន់ប្រមាណថា មាន ៦១.០០០ ករណីជំងឺរបេងសកម្ម។
  - ការប៉ាន់ប្រមាណអត្រាប្រេវ៉ាឡង់ជំងឺរបេងនៅប្រទេសកម្ពុជា: ៧១៥ នាក់ក្នុងចំណោមប្រជាជន ១០០.០០០ នាក់។
  - អត្រាភាពស៊ាំជាមួយឱសថប្រឆាំងជំងឺរបេងច្រើនមុខ ត្រូវបានគេប៉ាន់ប្រមាណថាមាន ១,៤%នៃករណីជំងឺរបេងថ្មី ហើយ ១១% នៃករណីដែលទទួលការព្យាបាលសារឡើងវិញ ។
  - លើសពី ១.២៤១ នៃអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថា មានជំងឺរបេងសកម្ម។
  - ការសិក្សានៅប្រទេសកម្ពុជា ២០០៧-២០០៩ លើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ដែលមានអ្នកជំងឺរបេងចំនួន ២៣៦នាក់ បានរកឃើញថា មានភាពស៊ាំជាមួយឱសថប្រឆាំងមេរោគរបេងណាមួយនៃរូបមន្តព្យាបាលជួរទី១ មាន ៣៩,៧% និង ៨,១% មានភាពស៊ាំជាមួយ

[២៣] គោលការណ៍ ណែនាំបច្ចេកទេស និងប្រតិបត្តិ សំរាប់គ្រប់គ្រងកម្មវិធី របេងស៊ាំថ្នាំនៅប្រទេសកម្ពុជា២០១៣

[២៤] ស្ថានភាពជំងឺរបេងនៅកម្ពុជារបាយការណ៍របស់អង្គការពិភពលោក ២០១០។ប្រភព: https://extranet.who.int/sree/Reports?op=Replet&name=/WHO_HQ_Reports/G2/PROD/EXT/TBCountryProfile&ISO2=KH&outtype=html

ឱសថច្រើនមុខ (MDR-TB) នៃអ្នកជំងឺ។ សមាមាត្រនៃភាពស៊ាំជាមួយឱសថច្រើនមុខ (MDR-TB) នៃជំងឺរបេងក្នុងចំណោមអ្នកជំងឺថ្មី គឺមាន ៣,៧% និង ក្នុងចំណោមអ្នកជំងឺដែលធ្លាប់បាន ព្យាបាលជំងឺរបេងពីមុន គឺមាន ២៨,៩%[២៥] ។

## ១៣.៥ ការបង្ករោគរួមគ្នា រវាងជំងឺរបេង និងអេដស៍

- នៅទូទាំងពិភពលោក ជំងឺរបេងគឺជាមូលហេតុនាំមុខគេនៃការស្លាប់ ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ។
- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ងាយស្រួលក្នុងការវិវត្តន៍ទៅជា ជំងឺរបេងសកម្ម ការបរាជ័យនៃការព្យាបាល ការលាប់ឡើងវិញ និងការស្លាប់បណ្តាលមកពីជំងឺរបេង។
- បុគ្គលដែលគ្មានផ្ទុកមេរោគអេដស៍និងបានបង្ករោគរបេង មានហានិភ័យវិវត្តន៍ទៅជាជំងឺរបេងសកម្មពេញមួយជីវិតក្នុងអត្រាត្រឹមតែ៥-១០% ចំណែកឯ អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍មានការវិវត្តន៍ក្នុងអត្រាចាប់ពី៣០-៥០% ឬប្រហែល ៥-៨% ជារៀងរាល់ឆ្នាំ។
- ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឆាប់រហ័ស នៅពេលដែលមានចំនួនកោសិកា CD4 ខ្ពស់ អាចបន្ថយហានិភ័យនៃការវិវត្តន៍ទៅ ជំងឺរបេងសកម្ម ។
- សូមអាន **គោលការណ៍ណែនាំនៃការគ្រប់គ្រងព្យាបាលជាតិនៃការបង្ករោគរួមគ្នារវាង ជំងឺរបេង/អេដស៍**[២៦] សម្រាប់ការយល់ដឹងពីទិដ្ឋភាពទូទៅ ។

## ១៣.៦ យុទ្ធសាស្ត្រ 3Is នៅកម្ពុជា

យុទ្ធសាស្ត្រ3I's នៅកម្ពុជា[២៧] មានគោលបំណងកាត់បន្ថយផលប៉ះពាល់នៃការបង្ករោគរួមគ្នារវាងជំងឺរបេង/អេដស៍ តាមរយៈ៖

១. ការបង្កើនការស្រាវជ្រាវរកករណីជំងឺរបេង (ICF) ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ និងធ្វើការទំនាក់ទំនងគ្រួសាររបស់អ្នកជំងឺ ។

២. ការព្យាបាលបង្ការដោយឱសថ Isoniazid (IPT) សម្រាប់អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ដែលគ្មាន ជំងឺរបេងសកម្ម។

---

[២៥] របេងស៊ាំថ្នាំ នៃ អ្នកជំងឺអេដស៍នៅមន្ទីរពេទ្យបង្អែកជាតិ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។ Genevieve Walls et al Glob Health Action 2015, 8: 25964http://dx.doi.org/10.3402/gha.v8.25964

[២៦] ព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាល។ គោលការណ៍ ណែនាំគ្លីនិក ថ្នាក់ជាតិសំរាប់គ្រប់គ្រងការបង្ករោគរួមគ្នាជំងឺរបេង/អេដស៍។ ភាសាអង់គ្លេសឆ្នាំ ២០០៨ និង ភាសាខ្មែរឆ្នាំ២០១៣: http://www.cenat.gov.kh/km/documents/guidelines-and-sops

[២៧] ព្រះរាជាណាចក្រកម្ពុជាក្រសួងសុខាភិបាល។ និយាមប្រតិបត្តិសំរាប់អនុវត្ត 3Is ក្នុងបរិបទ ការថែទាំបន្ត ឆ្នាំ២០១០។

៣. ការពង្រឹងវិធានការត្រួតពិនិត្យការឆ្លងមេរោគរបេង (IC) ត្រូវអនុវត្តវិធានការនេះនៅគ្រឹះស្ថានថែទាំ និងព្យាបាលបន្ត (CoC) ។

**វិធីសាស្រ្តបន្ថែមក្នុងយុទ្ធសាស្រ្ត3I's នៅកម្ពុជាមាន៖**

១. អ្នកជំងឺរបេងទាំងអស់ត្រូវធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយមិនគិតពីកត្តាប្រឈមមុខនៃការឆ្លងមេរោគអេដស៍ ។

- អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ទាំងអស់ ត្រូវទទួលការពិនិត្យរោគសញ្ញាគ្លីនិកស្រាវជ្រាវរកជំងឺរបេងសកម្ម នៅរៀងរាល់ពេលមកពិនិត្យពិគ្រោះជំងឺ ដូចខាងក្រោម៖
    - គ្រុនក្តៅ នៅពេលណាក៏ដោយ រយៈពេលយូរប៉ុន្មានក៏ដោយ។
    - ក្អក នៅពេលណាក៏ដោយ រយៈពេលយូរប៉ុន្មានក៏ដោយ។
    - បែកញើសពេលយប់ រយៈពេល ២សប្តាហ៍ ឬ លើសពីនេះ។
    - ស្រកទម្ងន់។
  - ➢ អ្នកជំងឺទាំងអស់ ដែលសង្ស័យថាមានជំងឺរបេងសួត ឬ ជំងឺរបេងក្រៅសួត ក្រោយពេលពិនិត្យរោគសញ្ញាគ្លីនិក ត្រូវបានវាយតម្លៃជំងឺរបេងយ៉ាងឆាប់រហ័ស (សូមអានផ្នែកខាងក្រោម) ។

២. គ្រប់អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ទាំងអស់ ដែលគ្មានរោគសញ្ញាគ្លីនិក ក្រោយពេលពិនិត្យ (អវិជ្ជមាន) ត្រូវទទួលការព្យាបាលបង្ការជំងឺរបេង (IPT) ។ (សូមអានជំពូក ៦ ការពិនិត្យសុខភាពស្រាវជ្រាវរកជំងឺរបេង និង ការវាយតម្លៃ ដើម្បីព្យាបាលបង្ការដោយ ឱសថ Isoniazid (IPT)។

៣. ការត្រួតពិនិត្យការចម្លងរោគរបេង រួមមាន:

- ការធ្វើរោគវិនិច្ឆ័យ និងព្យាបាលនៃជំងឺរបេងសកម្មឱ្យបានឆាប់ ។
- ដាក់អ្នកជំងឺដែលបានធ្វើរោគវិនិច្ឆ័យ ឬសង្ស័យថាមានជំងឺរបេងឱ្យនៅដាច់តែឯង ។
- ឱ្យអ្នកជំងឺពាក់ម៉ាស់ នៅពេលក្អក ។
- បង្កើនខ្យល់ចេញចូលជាអតិបរមា និងឱ្យមានពន្លឺថ្ងៃក្នុងបន្ទប់ ។

## ១៣.៧ ការបង្ហាញរោគសញ្ញាគ្លិនិកនៃជំងឺរបេង លើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍

- ការបង្ហាញរោគសញ្ញាគ្លីនិកនៃជំងឺរបេងលើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍គឺ អាស្រ័យតាមដំណាក់កាលនៃជំងឺអេដស៍ ។
- ការទំនាក់ទំនងជាមួយអ្នកជំងឺរបេងសួត គឺជាករណីដែលគេដឹងថា នឹងមានការឆ្លងជំងឺរបេង ។

ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ដែលមានចំនួនកោសិកា CD4 ខ្ពស់ ការបង្ហាញរោគសញ្ញាគ្លីនិកនៃជំងឺរបេង គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងបុគ្គលដែលមិនផ្ទុកមេរោគអេដស៍៖

- ក្អករ៉ាំរ៉ៃមិនឆ្លើយតបទៅនឹងថ្នាំ antibiotics ក្រោយពីព្យាបាល ២- ៣ សប្តាហ៍
- ស្រកទម្ងន់ (ដោយអចេតនា)
- បែកញើសពេលយប់ (drenching)
- គ្រុនក្តៅ
- មិនឃ្លានអាហារ ចុះខ្សោយ អស់កម្លាំងល្ហិតល្ហៃ
- ឈឺទ្រូង និងក្អកធ្លាក់ឈាម (haemoptysis)។

ចំនួនកោសិកា CD4 ថយចុះនាំឱ្យ៖

១. ការបង្ហាញរោគសញ្ញាគ្លីនិកនៃជំងឺរបេងសួត មានភាពមិនជាក់លាក់៖

- ភាពអស់កម្លាំងជាទូទៅ និងភាពទន់ខ្សោយល្ហិតល្ហៃ
- ស្រកទម្ងន់ខ្លាំង (ឧ. > ១០% នៃទម្ងន់ខ្លួន ធៀបនឹងទម្ងន់ដែលថ្លឹង នៅពេលដើមគ្រា)
- ក្អកតិចតួច អាចមានក្អកស្ងួត និង ពិបាកដកដង្ហើម
- ភាពស្លេកស្លាំង (Anaemia)
- ពិនិត្យដោយអតិសុខុមទស្សន៍ មិនសូវច្បាស់ ។

២. អត្រាជំងឺរបេងក្រៅសួត កើនឡើងកាន់តែខ្ពស់ ទោះបីជា ជំងឺរបេងសួតត្រូវបានជួបប្រទះជាញឹកញាប់ក៏ដោយ ។ សូមមើល តារាងទី១៣ -១ លក្ខណៈរោគសញ្ញាគ្លីនិក និងការធ្វើវិនិច្ឆ័យជំងឺរបេងក្រៅសួតដែលជួបប្រទះញឹកញាប់។

## ១៣.៨ ការធ្វើរោគវិនិច្ឆ័យ និងការគ្រប់គ្រងព្យាបាលជំងឺរបេងសួត និងជំងឺរបេងក្រៅសួត លើអ្នកផ្ទុកមេរោគមេរោគអេដស៍និងអ្នកជំងឺអេដស៍

សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត សូមអានគោលការណ៍ណែនាំជាតិអំពី ការគ្រប់គ្រងព្យាបាលនៃការបង្ករោគរួមគ្នារវាងជំងឺរបេង/អេដស៍ និងមើលគំនូសបំព្រួញក្នុងគោលការណ៍ណែនាំជាតិនេះក្នុងឧបសម្ព័ន្ធ៩៦ជំងឺរបេងៈ គំនូសបំព្រួញអំពីជំងឺរបេង/អេដស៍ ។

### ១៣.៨.១ ជំងឺរបេងសួត

**ការធ្វើរោគវិនិច្ឆ័យ**:

អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ដែលសង្ស័យថា មានជំងឺរបេង ក្រោយពីបានធ្វើការពិនិត្យស្រាវជ្រាវរកជំងឺរបេងជាប្រចាំ តម្រូវឱ្យធ្វើ៖

- ការពិនិត្យកំហាក និង
- ការថតសួតដោយកាំរស្មី X ។

**ការពិនិត្យកំហាក**

១. វត្ថុវិភាគកំហាក ត្រូវបានពិនិត្យដោយតេស្ត GeneXpert MTB/RIF ។ តេស្ត GeneXpert MTB/RIF គឺជាការវិភាគរហ័សក្នុងការធ្វើរោគវិនិច្ឆ័យជំងឺរបេងសួត និងវាយតម្លៃកំហាក សម្រាប់រក

ភាពស៊ាំជាមួយឱសថ Rifampicin ។ តេស្ត GeneXpert MTB/RIF មានភាពប្រែប្រួល (Sensitivity) ខ្ពស់ជាងការពិនិត្យដោយអតិសុខុមទស្សន៍ និងជាទូទៅប្រហែល ៩០% Sensitivity បើប្រៀបធៀបទៅនឹងការបណ្តុះមេរោគ ។

តេស្ត GeneXpert MTB/RIF អាចធ្វើបាននៅតាមមន្ទីរពេទ្យបង្អែកខេត្ត/ក្រុងភាគច្រើននៅកម្ពុជា និងត្រូវបានពង្រីកទៅកាន់តំបន់ផ្សេងទៀត ។ នៅថ្នាក់ស្រុក សំណាកត្រូវបានប្រមូល និងដឹកជញ្ជូនភ្លាមទៅកន្លែងដែលអាចធ្វើតេស្តបានក្នុងកំឡុងពេល១២-២៤ម៉ោង ក្រោយពីការប្រមូលសំណាកទាំងនោះ ។ សំណុំបែបបទស្នើរសុំធ្វើតេស្ត ត្រូវសរសេរលេខទូរស័ព្ទមន្ទីរពិសោធន៍ ដើម្បីងាយស្រួលសាកសួរពីលទ្ធផលតេស្ត ។

- បើតេស្ត GeneXpert MTB/RIF វិជ្ជមាន ត្រូវហៅអ្នកជំងឺឱ្យត្រឡប់មកពេទ្យវិញ និងត្រូវចាប់ផ្តើមព្យាបាលជំងឺរបេងភ្លាម ដោយប្រើរូបមន្តព្យាបាលជួរទី១ ។
- បើតេស្ត GeneXpert MTB/RIF វិជ្ជមាន បានបញ្ជាក់ថា មានភាពស៊ាំជាមួយឱសថ Rifampicin ត្រូវហៅអ្នកជំងឺឱ្យត្រឡប់មកពេទ្យវិញ ដោយស្រង់យកសំណាកកំហាកចំនួន ៣ (សំណាកកំហាក១ សម្រាប់ពិនិត្យដោយអតិសុខុមទស្សន៍ និង សំណាកកំហាក២ទៀត សម្រាប់យកទៅបណ្តុះមេរោគ) និងចាប់ផ្តើមព្យាបាលជំងឺរបេងដោយប្រើរូបមន្តព្យាបាលជួរទី២ភ្លាម។ នៅពេលដែលមេរោគរបេងដុះក្រោយពីការបណ្តុះ ត្រូវបញ្ជូនបន្តទៅ CENAT សម្រាប់ធ្វើតេស្ត DST បញ្ជាក់នៃភាពស៊ាំជាមួយឱសថ Rifampicin និង ដើម្បីពិនិត្យមើលភាពស៊ាំជាមួយឱសថផ្សេងទៀត។

២. បើគ្មានតេស្ត GeneXpert MTB/RIF ទេ ត្រូវពិនិត្យដោយអតិសុខុមទស្សន៍លើសំណាកកំហាកទាំង៣នេះ ។

**ការបណ្តុះមេរោគ Mycobacterial** អាចធ្វើបាននៅ CENAT ភ្នំពេញនិងនៅមន្ទីរពិសោធន៍នៅខេត្តបាត់ដំបង និងខេត្តកំពង់ចាម ។ លទ្ធផលនៃការបណ្តុះ MTB ត្រូវការរយៈពេលពី៦ ទៅ៨សប្តាហ៍។

- ការបណ្តុះមេរោគរបេង ត្រូវតែអនុវត្តនៅពេលមានភាពស៊ាំជាមួយឱសថ Rifampicin ដែលបានបញ្ជាក់ដោយតេស្ត GeneXpert MTB/RIF ។
- ការបណ្តុះមេរោគរបេង គឺមានប្រយោជន៍លើករណីលទ្ធផលតេស្ត GeneXpert MTB/RIF ឬពិនិត្យកំហាក អវិជ្ជមាន (ជំងឺរបេងសួត និងជំងឺរបេងក្រៅសួត) ជាពិសេសក្នុងករណីមាន ជំងឺរលាកស្រោមខួរបង្កដោយជំងឺរបេង ដែលជាញឹកញាក់មានការលំបាកក្នុងការធ្វើរោគវិនិច្ឆ័យឱ្យបានច្បាស់លាស់ ។

- **ការបណ្តុះមេរោគរបេង វិជ្ជមាន ត្រូវបញ្ជូនបន្តទៅ CENAT សម្រាប់ធ្វើតេស្ត (DST)** ក្នុងករណីលាប់ជំងឺរបេង ឬ ការព្យាបាលបរាជ័យ ឬករណីសង្ស័យផ្សេងទៀតនៃភាពស៊ាំជាមួយឱសថ រួមទាំង គ្រប់ករណីតេស្ត GeneXpert MTB/RIF វិជ្ជមានទាំងអស់ដែលមានភាពស៊ាំជាមួយឱសថ Rifampicin។

**ការថតសួតបានបង្ហាញ៖** ជំងឺរបេងសួត អាស្រ័យទៅតាមកម្រិតនៃការថយចុះនៃភាពស៊ាំ៖

- បើចំនួនកោសិកា CD4 >៥០០កោសិកា/មម³: របេង cavitary ធម្មតា ឬនៅ upper lobe consolidation ។
- ចំនួនកោសិកា CD4 <២០០កោសិកា/មម³: កាថតសួតដោយកាំរស្មី X បានបង្ហាញ រូបភាពមិនធម្មតា (atypical) ត្រូវបានជួបប្រទះជាញឹកញាប់ រួមមាន រូបភាពស្ទើរធម្មតា ការជ្រៀតចូលសងខាង ឬនៅ lower lobar infiltrates នៃសួត មាន lymphadenopathy mediastinal, ឡើងខ្ទុះនៅសួត មានInterstitial nodules ។ល។

### ការធ្វើរោគវនិច្ឆ័យបែងចែក

- សូមមើល តារាងទី១៥-១ រោគវិនិច្ឆ័យបែងចែកនៃរោគសញ្ញាគ្លីនិកតាមផ្លូវដង្ហើម ។

### បើការពិនិត្យកំហាក អវិជ្ជមាន

- ប្រសិនបើ ការបង្ហាញរោគសញ្ញាគ្លីនិក និងការថតសួតដោយកាំរស្មី X គឺមានភាពស្របគ្នាថាមានជំងឺរបេង ត្រូវបញ្ជូលអ្នកជំងឺទៅទទួលការព្យាបាលជំងឺរបេងសាកល្បង និងត្រូវតាមដានយ៉ាងដឹតដល់ (តាមដានរោគសញ្ញា ពិន្ទុ Karnofsky ទម្ងន់ Hb) ។
- ឬ បើសង្ស័យថា មានការបង្ករោគដោយពពួកបាក់តេរី ត្រូវផ្តល់ការព្យាបាលសាកល្បងដោយឱសថ antibiotics (amoxycillin ១ក្រ ៣ដង/ថ្ងៃ ឬ ប្រសិនបើមាន allergy ត្រូវប្រើ Erythromycin ៥០០ម.ក្រ លេប៤ដង/ថ្ងៃ លេបរាល់ថ្ងៃ ត្រូវវាយតម្លៃរោគសញ្ញាគ្លីនិក និង/ឬ ថតសួតដោយកាំរស្មី X និង/ឬ ធ្វើតេស្ត AFBs ក្រោយពេលបញ្ចប់ការព្យាបាលដោយឱសថ antibiotics ។

## ១៣.៤.២ ជំងឺរបេងក្រៅសួត

ជំងឺរបេងក្រៅសួត (EPTB) កើតមានជាញឹកញាប់ចំពោះអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ច្រើនជាងអ្នកដែលមិនផ្ទុកមេរោគអេដស៍ ដោយមិនគិតពីចំនួនកោសិកា CD4 ។ ប្រហែលជា ៥០% នៃករណីជំងឺរបេងក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ គឺជាជំងឺរបេងក្រៅសួតដែលមានកោសិកា CD4 < ២០០កោសិកា/មម³ បើប្រៀបធៀបនឹង អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ដែលមានកោសិកា CD4 > ២០០កោសិកា/មម³ គឺមានត្រឹមតែ ២០%។

### រោគសញ្ញាគ្លីនិក និងការធ្វើរោគវនិច្ឆ័យ

ភាគច្រើននៃជំងឺរបេងក្រៅសួត បានបង្ហាញពី ការហើមប៉ោងកូនកណ្តុរតែម្ខាង (unilateral lymphadenopathy) ។ ទោះបីជាយ៉ាងណា ជំងឺរបេងក្រៅសួត អាចត្រូវបានរកឃើញនៅក្នុងសរីរាង្គជាច្រើន និងបង្ហាញនូវរោគសញ្ញាគ្លីនិកជាច្រើនសណ្ឋាន ដូចជា៖

- បូសនៅប្រព័ន្ធសរសៃប្រសាទកណ្តាល ឬជំងឺរលាកស្រោមខួរ
- ជំងឺរបេងឆ្អឹងខ្នង (ជំងឺ Potts) ហើមសន្លាក់ ឬឆ្អឹងផ្សេងទៀត ឬឆ្អឹងខូចទ្រង់ទ្រាយ
- ទឹក Serositis (ទឹកស្រោមសួត ទឹកស្រោមបេះដូង និង/ឬទឹកស្រោមពោះ)

- ដុំពោះ ឬ ទាចទឹក(ascites)
- រលាកថ្លើម ឬរលាកពោះវៀន (enteritis)
- របេងតម្រងនោម ការស្ទះបង្ហូរនោម ឬតម្រងនោមរីកធំ
- ដំបៅនៅលើស្បែក
- របេងសាយភាយ (ជំងឺរបេង miliary) ។

សូមមើល តារាងទី១៣-១ លក្ខណៈរោគសញ្ញាគ្លីនិក និងការធ្វើវិនិច្ឆ័យជំងឺរបេងក្រៅសួតដែលជួបប្រទះញឹកញាប់។

ការធ្វើរោគវិនិច្ឆ័យឱ្យបានច្បាស់លាស់នៃជំងឺរបេងក្រៅសួត (EPTB) ជាមួយនឹងការពិនិត្យកំហាកវិជ្ជមាន ឬ ការបណ្តុះមេរោគរបេងសម្រាប់រក MTB ជាញឹកញាប់គឺ មានការពិបាក។ ការធ្វើតេស្តដោយ ប្រឡាក់ទឹកអាស៊ីតលឿន (Acid-fast stains) លើសំណាកបានមកពី ទឹកស្រោមសួត ទឹកខួរឆ្អឹងខ្នង និងទឹកសន្លាក់ ជាធម្មតាមាន លទ្ធផលអវិជ្ជមាន និងទាមទារឱ្យមានការបណ្តុះមេរោគ ។ ការធ្វើតេស្ត GeneXpert MTB/RIF អាចត្រូវបានអនុវត្តលើគ្រប់សំណាកទាំងអស់ លើកលែងតែសំណាកឈាម ទឹកនោម និងលាមក ។

### តារាងទី១៣-១ លក្ខណៈរោគសញ្ញាគ្លីនិក និងការធ្វើវិនិច្ឆ័យជំងឺរបេងក្រៅសួតដែលជួបប្រទះញឹកញាប់

*(Adapted from the National Clinical Guideline for the management of HIV/TB Co-infection)*

| ជំងឺរបេងក្រៅសួត | ជំងឺរលាកស្រោមខួរបង្កដោយជំងឺរបេង | ជំងឺរបេងកណ្តុរ Lymph Node (LN) (peripheral និងនៅពោះ) | ជំងឺរបេង Miliary (disseminated) | ជំងឺរបេងឆ្អឹង និងសន្លាក់ និងខួរឆ្អឹងខ្នង | ជំងឺរបេងនៅ seous effuions |
|---|---|---|---|---|---|
| **រោគសញ្ញាគ្លីនិក** | • គ្រុនក្តៅ បែកញើស malaise ++<br>• ឈឺក្បាលខ្លាំងបន្តិចម្តងៗ<br>• វង្វេងស្មារតី<br>• ថយចុះ consciousness, ប្រកាច់<br>• +/- រឹងក<br>• Focal neurological deficits ឧ. Cranial nerve palsy។ | • ឡើងកូនកណ្តុរ≥ ១ នៅក ក្លៀក ឬក្រលៀន (> ២ cm) មិនឈឺ discrete firm ឬ fluctuant nodes matted together<br>• +/- រលាត់ស្បែក បូសហូរចេញទឹករងៃរាំរ៉ៃ<br>• +/- គ្រុនក្តៅ បែកញើស malise | • គ្រុនក្តៅ បែកញើស malaise +++<br>• ថ្លើម អណ្តើករីកធំ<br>• ឡើងកណ្តុរច្រើនកន្លែង<br>• Choroidal tubercles ពេលពិនិត្យដោយ funduscopic ។ | • ឆ្អឹងខ្នង: ឈឺនៅកន្លែង ប្រែប្រួលរូបរាង +/- neurological deficits<br>• សន្លាក់: ហើមសន្លាក់ចង្កេះ/ក្បាលជង្គង់/ស្មា មិនសូវឈឺចាប់ខ្លាំងទេ<br>• +/- គ្រុនក្តៅ បែកញើស malaise | • គ្រុនក្តៅ បែកញើស malaise<br>• *Local features:*<br>• សួត (ឈឺទ្រូង ហត់ ដកដង្ហើមខ្លី)<br>• ពោះ (ឈឺពោះ ហើមពោះ)<br>• Pericardial (ឈឺទ្រូង និងផ្នែកខាងឆ្វេង (ហត់) និងថតបេះដូង ខាងស្តាំចុះខ្សោយ( right ventricular failure) ហើយនៅជើងនិងដៃ (peripheral oedema)។ |
| **ការធ្វើរោគវិនិច្ឆ័យ** | • បូមទឹកឆ្អឹងខ្នង<br>• បើសញ្ញាគ្លីនិក ↑ នៃសម្ពាធខួរក្បាល (papilledema, ↓ consciousness)ការបូម LP មានគ្រោះថ្នាក់ ត្រូវចាប់ផ្តើមព្យាបាល និងបូម LP ក្រោយពេលរោគសញ្ញាបានប្រសើរឡើង។ | • បូមទឹកឆ្អឹងខ្នងដោយម្ជុល បើ node មានសភាពទន់ខ្វោកៗ។<br>• ការពិនិត្យអេកូ (itra-abdominal lmph nodes) | • ថតសួត X-ray<br>• បណ្តុះមេរោគ Mycobacterial ក្នុងឈាម (បើអាចធ្វើបាន) | • ថតសួត X-ray<br>• ច្រិបយកជាលិកាទៅពិនិត្យ (Tissue biopsy) | • Physical examination<br>• ថតសួត X-ray<br>• ពិនិត្យអេកូ<br>• Echocardiogram<br>• បូមទឹក (Aspirate effusion) |

| | | | | | |
|---|---|---|---|---|---|
| **លទ្ធផល** | • បើសម្ពាធ CSF ↑<br>• CSF mild ↑ គោលិកាស, សំបូរណ៍ដោយពួក lymphocytes<br>• កម្រិត Protein ↑<br>• Glucose ↓<br>• ការពិនិត្យកំហាកដោយ AFB កំរិជ្ជមាន ធ្វើតេស្ត<br>• GeneXpert។ | • ជាលិកាមានសភាពដូចដុំឈីស(Caseation)<br>• ការធ្វើតេស្ត AFB អាចមើលឃើញ<br>• ធ្វើតេស្តGeneXpet | • ថតសួត X-ray<br>• diffuse, small milliary shadows<br>• CBC +/- pancytopenia<br>• តេស្តមុខងារថ្លើម +/- មិនធម្មតា<br>• ពិនិត្យកំហាក BK+, CSF ឬ bone marrow aspirate may be +ve (តេស្ត GeneXpert មិនអាចពិនិត្យសំណាកឈាមទេ)។ | • តេស្ត AFB អាចមើលឃើញ<br>• ប្រតិកម្ម Granulomatous អាចឃើញពេលវិភាគជាលិកាសាស្ត្រ។ | • ថតសួត X-ray- pleural effusion, ឬ large globular heart shadow<br>• អេកូ: ascites និង intra-abdominal LN<br>• ច្រឹបសាច់សួត: BK+ និង /ឬ granulomas<br>• បូមទឹក: ជាទូទៅ BK -<br>• បណ្ដុះមេរោគរបេង (៤-៦ សប្តាហ៍)<br>• Exudate: Protein > ៣០g/l (if aspirate clots exudate likely) |

## ១៣.៩ ការគ្រប់គ្រងព្យាបាលជំងឺរបេងសួត និងជំងឺរបេងក្រៅសួត

### ឱសថព្យាបាលជំងឺរបេង

- គ្រប់អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ដែលមានជំងឺរបេង ត្រូវបានព្យាបាលស្របតាមគោលការណ៍ណែនាំស្តង់ដាក្នុងប្រទេសកម្ពុជា[២៨] ។
- ពិនិត្យមើល**សក្តានុភាពនៃអន្តរកម្មឱសថ** ជាមួយឱសថព្យាបាលជំងឺរបេង (ជាពិសេសឱសថ Rifampicin ឧ. Warfarin (តម្រូវឱ្យ ↑កម្រិតដូសថ្នាំ) ឱសថពន្យារកំណើត (↓ ប្រសិទ្ធភាព), ឱសថ fluconazole (↓កម្រិត) និងឱសថប្រឆាំងមេរោគអេដស៍មួយចំនួន[២៩] ។
- បន្ថែមឱសថ **Pyridoxine** (វីតាមីន $B_6$) ៥០ ម.ក្រ ជារៀងរាល់ថ្ងៃ ដើម្បីបន្ថយហានិភ័យជំងឺសរសៃប្រសាទខាងចុង។
- ជំងឺរលាកស្រោមខួរបង្កដោយជំងឺរបេង: បន្ថែមឱសថ prednisolone ៦០ម.ក្រ/ថ្ងៃ រយៈពេល ៤ សប្តាហ៍ បន្ទាប់មកបន្ថយកម្រិតដូសបន្តិចម្តងៗ រយៈពេលជាង ២សប្តាហ៍ ។
- កម្រិតដូសខ្ពស់/អូសបន្លាយរយៈពេលព្យាបាលនៃឱសថ steroid រួមផ្សំជាមួយភាពស៊ាំចុះខ្សោយបង្កដោយមេរោគអេដស៍ បណ្តាលឱ្យបង្កើនហានិភ័យនៃការបង្ករោគដោយ strongyloidiasis សាយភាព និង septic shock ដូច្នេះ ត្រូវការព្យាបាលរួមជាមួយឱសថ albendazole ៤០០ម.ក្រ លេបនៅពេលបរិភោគអាហារដែលមានជាតិខ្លាញ់ រាល់១២ម៉ោង/ម្តង x ៧ថ្ងៃ ។
- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ទាំងអស់ដែលមានជំងឺរបេង ត្រូវចាប់ផ្តើម**ព្យាបាលបង្ការដោយឱសថ cotrimoxazole** ដោយមិនគិតពីចំនួនកោសិកា CD4 ។

### ការពិនិត្យរោគសញ្ញាជំងឺអេដស៍: ធ្វើតេស្ត VL និងតេស្តរាប់ចំនួនកោសិកា CD4

- អ្នកផ្ទុកមេរោគអេដស៍ដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដែលទើបតែបានធ្វើរោគវិនិច្ឆ័យថា មានជំងឺរបេង ត្រូវធ្វើតេស្ត VL និងតេស្តរាប់ចំនួនកោសិកា CD4 ដើម្បីធ្វើការស្រាវជ្រាវពី ភាពបរាជ័យផ្នែកភាពស៊ាំ និង ផ្នែកវីរុសសាស្ត្រ ។
- កែតម្រូវដំណាក់កាលគ្លីនិកនៃ WHO (ជំងឺរបេងសួតលើមនុស្សពេញវ័យ គឺស្ថិតក្នុងដំណាក់កាលគ្លីនិកទី៣ រីឯ ជំងឺរបេងក្រៅសួតគឺស្ថិតក្នុងដំណាក់កាលគ្លីនិកទី៤) ។

### ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ទាំងអស់ដែលមានជំងឺរបេង ត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដោយមិនគិតពីចំនួនកោសិកា CD4 ស្របតាមកម្មវិធីដែលបានរៀបរាប់

---

[២៨] ព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាល និយាមបែបបទសំរាប់របបថ្នាំព្យាបាល ជំងឺរបេង ។ CENAT ឆ្នាំ២០១១ និងគោលការណ៍ណែនាំបច្ចេកទេស និងប្រតិបត្តិ សំរាប់គ្រប់គ្រងកម្មវិធី របេងស៊ាំថ្នាំនៅប្រទេសកម្ពុជា២០១៣។

[២៩] www.hivdruginteractions.org

នៅក្នុងតារាងទី៨-៣ពេលវេលានៃការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគ អេដស៍នៅពេលកំពុងមានជំងឺឱកាសនិយមសកម្ម ។

- ពិនិត្យមើលអន្តរកម្មឱសថ រវាងឱសថប្រឆាំងមេរោគអេដស៍ និងឱសថប្រឆាំងមេរោគរបេង ស្របតាមតារាងទី ១៣ -៣ អន្តរកម្ម រវាងឱសថប្រឆាំងមេរោគអេដស៍ និងឱសថប្រឆាំងមេរោគរបេង។

**ការតាមដាន**

- រោគសញ្ញាគ្លីនិក- ក្អក បែកញើស ចង់ហូបអាហារ កម្រិតថាមពល ទម្ងន់ ។
- កំហាក (ពិនិត្យដោយអតិសុខុមទស្សន៍) នៅខែទី២ និងខែទី៥ និងនៅពេលបញ្ចប់ការព្យាបាលបង្ការជំងឺរបេង (PTP) ។
- តាមដានផលប៉ះពាល់នៃរូបមន្តព្យាបាលជំងឺរបេង និងរូបមន្តព្យាបាលដោយឱសថប្រឆាំងជំងឺ អេដស៍ ។

**ប្រសិនបើ មិនមានភាពប្រសើរឡើងក្រោយការព្យាបាលជំងឺរបេង៖**

- ការពិនិត្យអតិសុខុមទស្សន៍ម្តងទៀត (មិនចាំបាច់ធ្វើតេស្ត GeneXpert MTB/RIF ទេ) បណ្តុះមេរោគរបេង ធ្វើតេស្ត DST និងពិចារណាអំពី:
  - ការលេបថ្នាំមិនបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ល្អ ការជ្រៀបចូលនៃថ្នាំមិនបានល្អ (malabsorption) ។
  - ភាពស៊ាំជាមួយឱសថប្រឆាំងជំងឺរបេង ។
  - មាន Paradoxical IRIS (សូមអាន ជំពូក ៩. ចង្កោមរោគសញ្ញានៃការស្តាប្រព័ន្ធភាពស៊ាំឡើងវិញ (IRIS)។
  - ការបង្ករោគផ្សេងទៀត ជំងឺមហារីក និងជំងឺខ្សោយបេះដូង (cardiac failure) (សូមមើលតារាងទី ១៤- ១ រោគវិនិច្ឆ័យបែងចែកនៃរោគសញ្ញាគ្លីនិកតាមផ្លូវដង្ហើម ។
  - ឱសថបង្កឱ្យមានផលលំបាក ។
- ជំងឺរបេងក្រៅសួតនៅគ្រប់ទម្រង់ជំងឺរបេងទាំងអស់ លើកលែងតែជំងឺរលាកស្រោមខួរបង្កដោយជំងឺរបេង ត្រូវព្យាបាលដោយប្រើឱសថក្នុងកាតេកូរីទី១ ដូចគ្នានឹងការព្យាបាលជំងឺរបេងសួតដែរ (២RHZE/៤RH) ។ ជំងឺរលាកស្រោមខួរបង្កដោយជំងឺរបេង តម្រូវឱ្យព្យាបាលដោយរូបមន្តនៃឱសថប្រឆាំងជំងឺរបេងខុសគ្នាបន្តិច ។ សូមអានគោលការណ៍ណែនាំជាតិនៃជំងឺរបេង ។

## ១៣.៩.១ ផលប៉ះពាល់នៃឱសថព្យាបាលជំងឺរបេង រួមជាមួយឱសថប្រឆាំងមេរោគអេដស៍

តារាងទី១៣ -២ ផលប៉ះពាល់នៃការព្យាបាលរបេងរួមជាមួយការព្យាបាលប្រឆាំងមេរោគអេដស៍

| ផលប៉ះពាល់ | ឱសថ ARV | ឱសថព្យាបាលជំងឺរបេង |
|---|---|---|
| ចង្អោរ | AZT; PIs | Pyrazinamide |
| ជំងឺរលាកថ្លើម | NVP; EFV; PIs | Pyrazinamide, Rifampicin, INH |
| ជំងឺ Peripheral neuropathy | d4T; ddI | INH |
| ស្នាមកន្ទួលលើស្បែក | NVP; EFV | Rifampicin; INH; Pyrazinamide |

## ១៣.៩.២ ជំងឺរបេង– អន្តរកម្មជាមួយឱសថប្រឆាំងមេរោគអេដស៍

### តារាងទី១៣ -៣ អន្តរកម្ម រវាងឱសថប្រឆាំងមេរោគអេដស៍ និងឱសថប្រឆាំងមេរោគរបេង[៣០]

| ឱសថ | អន្តរកម្មជាមួយឱសថប្រឆាំងមេរោគអេដស៍ និងឱសថ fluconazole |
|---|---|
| ការព្យាបាលដោយឱសថប្រឆាំងជំងឺរបេង: រូបមន្តព្យាបាលជួរទី១ និងទី២ | |
| Ethambutol | គ្មានអន្តរកម្ម |
| Isoniazid | គ្មានអន្តរកម្ម |
| Pyrazinamide | DDI អាចបង្កើនកម្រិត ↑PYR មិនចាំបាច់កែតម្រូវកម្រិតដូស និងតាមដានផលប៉ះពាល់នៃឱសថ (SE) |
| Rifampicin | AZT: ↓ កំហាប់ឱសថក្នុងឈាម ចៀសវាងប្រើបើមានជម្រើស<br>Dolutegravir: ចៀសវាង ↓↓ កំហាប់ឱសថក្នុងឈាម<br>Abacavir: slight ↓ កំហាប់ឱសថក្នុងឈាម<br>Nevirapine : contraindicated នាំឱ្យ↓↓ កំហាប់ឱសថក្នុងឈាម<br>Efavirenz :↓កំហាប់ឱសថក្នុងឈាម មិនត្រូវបន្ថយកម្រិតដូសឱសថ EFV ទៅ៤០០មក្រទេ<br>Atazanavir /r: contraindicated នាំឱ្យ ↓↓កំហាប់ឱសថក្នុងឈាម<br>Lopinavir/r : ↓↓ កំហាប់ឱសថក្នុងឈាម ប្រើឱសថកម្រិតដូសខ្ពស់ LPV/r ៨០០ម.ក្រ/៤០០ម.ក្រ លេប២ដង/ថ្ងៃ ឬ LPV/r ៨០០ម.ក្រ/២០០ម.ក្រ លេប២ដង/ថ្ងៃ ប៉ុន្តែវាមានហានិភ័យនៃភាពពុលខ្ពស់<br>Fluconazole: ↓ កំហាប់ឱសថក្នុងឈាម ។ |
| Streptomycin | TDF: តាមដានមុខងារតម្រងនោមឱ្យជិតដល់ |
| Capreomycin, | TDF: តាមដានមុខងារតម្រងនោម។ ឱសថ DTV អាច ↑ Capreomycin កំហាប់ក្នុងឈាម ddi និង 3TC: Capreomycin និង 3TC និង DDI កំហាប់ឱសថក្នុងឈាមអាច ↑<br>PI និង NNRTI គ្មានបញ្ហា ។ |
| Ethionamide, | គ្មានអន្តរកម្ម |
| Levofloxacin | ប្រយ័ត្នពេលប្រើ ATZ + LPV ដោយឱសថទាំងពីរនេះអាច ↑ QT interval,<br>3TC កំហាប់ឱសថក្នុងឈាមអាច ↑ ។ |
| Moxifloxacin | ATZ, LPV និង Moxi all can ↑ QT interval levels |
| Cycloserine | គ្មានអន្តរកម្មឱសថ |
| Kanamycin | ឱសថ Kanamycin និង TDF នាំឱ្យពុលតម្រងនោម (nephrotoxic) ។ តាមដានមុខងារតម្រងនោម អាចតម្រូវឱ្យកែសម្រួលកម្រិតដូស ឱសថ 3TC ។ |
| Clarithromycin | AZT កំហាប់ក្នុងឈាម ↓ ប្រើប្រាស់ឃ្លាតគ្នា២ ម៉ោង<br>NNRTI: កម្រិត Clarithromycin ↓<br>PI: ការកែសម្រួលកម្រិតដូសអាស្រ័យតាមកម្រិតដូសឱសថ និងមុខងារតម្រងនោម ។ |

[៣០] http://www.hiv-druginteractions.org/

# ជំងឺតាមផ្លូវដង្ហើម

# ជំពូក ១៤. ការបង្ករោគតាមផ្លូវដង្ហើម

- ទាំងការបង្ករោគតាមផ្លូវដង្ហើមផ្នែកខាងលើ(ឧ.រលាកច្រមុះ=sinusitis) និងផ្លូវដង្ហើមផ្នែកខាងក្រោម កើតមានញឹកញាប់ លើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ។
- ជាទូទៅ មានការបង្ករោគជាច្រើន អាចកើតឡើងក្នុងពេលតែមួយ ។

**ការវាយតម្លៃរោគសញ្ញាគ្លីនិក:**

ការវាយតម្លៃរោគសញ្ញាគ្លីនិក តម្រូវឱ្យស្រង់ប្រវត្តិជំងឺពេញលេញ រួមទាំង កត្តាប្រឈមមុខនឹងការឆ្លងមេរោគរបេង រយៈពេលនៃការចាប់ផ្តើម ពេលវេលាវិវត្តន៍ទៅលេចចេញរោគសញ្ញាគ្លីនិក និងការពិនិត្យរាងកាយពេញលេញ ។

សូមអានឯកសារខាងក្រោម:

- តារាងទី១៤-១ រោគវិនិច្ឆ័យបែងចែកនៃរោគសញ្ញាគ្លីនិកតាមផ្លូវដង្ហើម ដើម្បីយល់ដឹងពីគោលការណ៍ណែនាំ អំពីរោគសញ្ញាគ្លីនិក និងការគ្រប់គ្រងព្យាបាលនៃការបង្ករោគតាមផ្លូវដង្ហើមដែលកើតឡើងជាញឹកញាប់។
- រូបភាពទី១៥ -១ គំនូសបំព្រួញ: រោគសញ្ញាគ្លីនិកនៃជំងឺតាមផ្លូវដង្ហើម
- ជំពូកទី១៥ ជំងឺ Pneumocystis Pneumonia (PCP)
- ជំពូកទី១៣. ជំងឺរបេងសួត

## ១. រោគសញ្ញាគ្លីនិកនៃជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ

វាជាការសំខាន់ក្នុងការដឹងពីអ្នកជំងឺដែលមានជំងឺរលាកសួតធ្ងន់ធ្ងរនិងត្រូវបញ្ជូនគាត់ទៅកាន់មន្ទីរពេទ្យ:

- អត្រាសង្វាក់ដង្ហើម > ៣០ដង/នាទី
- មិនដកដង្ហើមនៅពេលសំរាក ឬ ពេលនិយាយ
- ប្រើប្រាស់សាច់ដុំផ្លូវដង្ហើមខ្លាំង
- ឡើងស្វាយ (Cyanosis)
- ឡេះឡះ ឬ វង្វេងស្មារតី ។

## ២. ការពិនិត្យរោគសញ្ញាគ្លីនិករកជំងឺរបេង

- ប្រសិនបើមាន គ្រុនក្តៅ ក្អក បែកញើសពេលយប់ ឬស្រកទម្ងន់ → យកកំហាកទៅធ្វើតេស្ត Gene/Xpert (ឬពិនិត្យដោយអតិសុខុមទស្សន៍ ប្រសិនបើគ្មានតេស្ត Gene/Xpert) និងថតសួតដោយកាំរស្មី X ។

- ពិចារណា អំពីការព្យាបាលជំងឺរបេងសាកល្បង ប្រសិនបើមានការសង្ស័យខ្ពស់ថា ជំងឺរបេង ទោះ បីជាលទ្ធផលនៃការពិនិត្យកំហាក អវិជ្ជមាន ក៏ដោយ (តេស្ត GeneXpert មិនអាចធ្វើរោគវិនិច្ឆ័យជំងឺរបេងសួតបាន ក្នុងកម្រិត១០%) ។

៣. ពិចារណាពីជំងឺ Pneumocystis Pneumonia (សូមអានផ្នែកបន្ទាប់) ។

៤. ទំនងជាមានការបង្ករោគដោយពពួកបាក់តេរី ឬការធ្វើរោគវិនិច្ឆ័យមិនច្បាស់លាស់ គួរព្យាបាលសាកល្បងការបង្ករោគដោយបាក់តេរីដោយប្រើឱសថ antibiotics និងតាមដានការឆ្លើយតបនៃការព្យាបាល៖

- ឱសថ Amoxacillin ១ក្រ លេប៣ដង/ថ្ងៃ ឬ ឱសថ doxycycline ១០០ម.ក្រ លេប២ដង/ថ្ងៃ រៀងរាល់ថ្ងៃ ឬឱសថ erythromycin ៥០០ម.ក្រ ៤ដង/ថ្ងៃ រៀងរាល់ថ្ងៃ ឬ ឱសថ cefixime ៤០០ម.ក្រ លេប១ដង/ថ្ងៃ រៀងរាល់ថ្ងៃ រយៈពេល១សប្តាហ៍ ។

**តារាងទី១៤-១ រោគវិនិច្ឆ័យបែងចែកនៃរោគសញ្ញាគ្លីនិកតាមផ្លូវដង្ហើម**

| **រោគវិនិច្ឆ័យ** | **សញ្ញាគ្លីនិក** | **ការថតសួតដោយកាំរស្មី X** | **ការគ្រប់គ្រងព្យាបាល** |
|---|---|---|---|
| **ការបង្ករោគ** | | | |
| ១. ជំងឺរបេងសួត (ទោះបីជាចំនួនកោសិកា CD4 ប៉ុន្មានក៏ដោយ) | ចាប់ផ្តើមបន្តិចម្តងៗ, ក្អក +/- មានកំហាក បែកញើសយប់ +/- ឈឺចាប់ | Lobar consolidation, Cavitation (តំបន់ខាងលើ) ទឹកស្រោមសួត (Pleural effusion) lymphadenopathy | សូមអានជំពូកទី.១៣ |
| ២. Bacterial pneumonia (ជំងឺរលាកសួតបង្កដោយបាក់តេរី) (ទោះបីជាចំនួនកោសិកា CD4 ប៉ុន្មានក៏ដោយ) | ជាទូទៅរោគសញ្ញាធ្ងន់ធ្ងរ គ្រុនក្តៅ ក្អក +/- មានកំហាក +/- ឈឺចាប់ ឆ្លើយតបនឹងការព្យាបាលដោយឱសថ antibiotic។ | Lobar consolidation with air/bronchogram ឬ patchy interstitial change | **Danger signs → បញ្ជូនទៅសំរាកពេទ្យ** ការពិគ្រោះជំងឺក្រៅ: Amoxyl ១g លេបរាល់៨ម៉ោងម្តងឬ erythromycin ៥០០mg លេបរាល់៦ ម៉ោង/ម្តង សំរាកពេទ្យ: IVI penicillin/ampicillin ឬ IVI ceftriaxone |
| ៣. ជំងឺ PCP (*Pneumocystis jiroveci* pneumonia) (CD4 < ២០០) | ជាទូទៅរោគសញ្ញាមិនសូវធ្ងន់ធ្ងរ ភាគច្រើនពិបាកដកដង្ហើម ក្អក គ្មានកំហាក | Bilateral diffuse interstitial "ground glass" shadowing Pneumothorax No air bronchograms | សូមអានជំពូកទី.១៥ |

| | | | |
|---|---|---|---|
| ៤. ការបង្ករោគដែលមិនសូវជួបប្រទះ | រោគផ្សិត (ឧ. Cryptococcus, penicilliosis), MAC, Nocardia | ប្រែប្រួល | ការប្រើប្រាស់ឱសថផ្អែកលើការសិក្សាអតិសុខុមជីវសាស្ត្រ (Guided by microbiology) |
| ៥. បូសសួត (ទោះបីជាចំនួនកោសិកា CD4 ប៉ុន្មានក៏ដោយ) | ក្អកមានកំហាកដែលមានខ្ទុះច្រើន ដង្ហើមស្អុយខ្លាំង consolidation with cavitation with fluid level on CXR | Focal change with air fluid level visible | ការប្រើប្រាស់ឱសថផ្អែកលើការសិក្សាអតិសុខុម ជីវសាស្ត្រ ឬ Amoxacillin /clavulanate ១ x ២ដង/ថ្ងៃ ឬ clindamycin ៤៥០ម.ក្រ ៣ដង /ថ្ងៃ រយៈពេល ៣ – ៤សប្តាហ៍។ |
| ៦. ជំងឺស្វះទងសួត (Bronchiectasis) | កំហាកមានខ្ទុះច្រើន | Thickened bronchial tree នៅដំបន់ផ្អែកខាងក្រោម។ | ការព្យាបាលខ្លាំងក្លា និងការប្រើប្រាស់ឱសថផ្អែកលើការសិក្សាអតិសុខុមជីវសាស្ត្រ។ |

| **ការធ្វើរោគវិនិច្ឆ័យវែកញែកជាមួយ ជំងឺសួតដែលមិនមែនបង្ករោគ** | |
|---|---|
| ជំងឺមហារីកសួត (lung cancer) | កត្តាប្រឈមមុខ (ជក់បារី, វ័យចាស់) |
| ខ្សោយបេះដូងដោយស្វះសរសៃឈាម (Congestive cardiac failure) | ថប់ដង្ហើម, orthopnoea, ថប់ដង្ហើម ពេលយប់, ក្អកឈាម, ហើម, ចុកខាងលើចុងដង្ហើម ដោយសារចុកច្រើម។<br>O/E lung crackles, gallop rhythm, ហើម |
| ជំងឺប្រតិកម្មតាមផ្លូវដង្ហើម (asthma) | ពាំរ៉ៃ, រោគសញ្ញាម្តងម្កាល; ដេកស្រមុកលឺពេលដកដង្ហើមចេញ (expiratory wheezes); រោគសញ្ញាទាំងនេះអាចកើតឡើង។ |
| ជំងឺស្វះផ្លូវដង្ហើមរ៉ាំរ៉ៃ (COPD) | កត្តាប្រឈមមុខ (ជក់បារី); រោគសញ្ញារ៉ាំរ៉ៃ ។ |

# ជំពូក ១៥. ជំងឺ Pneumocystis pneumonia (PCP)

*បង្កដោយមេរោគ Pneumocystis jiroveci* (ពីមុនហៅថា *Pneumocystis carinii)* គឺជាជំងឺរលាកសួតបង្ករោគជាញឹកញាប់ដោយពពួកផ្សិត ហើយកើតឡើងលើអ្នកជំងឺអេដស៍ដែលមានកោសិកា CD4 <២០០ កោសិកា/មម³។ ជំងឺ PJP ត្រូវបានចាត់ថា ជំងឺអេដស៍ដំណាក់កាលទី៤ នៃWHO ។
ជំងឺ PCP អាចកើតឡើងរួមគ្នា ជាមួយការបង្ករោគតាមផ្លូវដង្ហើមផ្សេងទៀត រួមទាំង ជំងឺរបេង។
**ការបង្ការ** ចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឱ្យបានឆាប់ និងផ្តល់ការព្យាបាលបង្ការដោយឱសថ cotrimoxazole ។

## រោគសញ្ញាគ្លីនិក

រោគសញ្ញា: មិនសូវស្រួចស្រាវ (១–២សប្តាហ៍) ពិបាកដកដង្ហើម (ហត់ដង្ហក់) ចាប់ផ្តើមរួមជាមួយ ការពិបាកដកដង្ហើមចេញ និងបន្ទាប់មក ពិបាកដង្ហើមពេលសំរាក ក្អកគ្មានកំហាក មាន/គ្មានគ្រុនក្តៅ ។
ការពិនិត្យ: ដង្ហើមដើរញាប់ (tachypnoea) សួតអាចថ្លា ឬមានសម្លេង crepitation ស្រួយ មាន/គ្មានឡើងស្វាយ (cyanosis) ថយចុះកម្រិត %$O_2$ ។

## ការពិនិត្យស្រាវជ្រាវ និងការធ្វើរោគវិនិច្ឆ័យ

ការថតសួតដោយកាំរស្មី X: ជាញឹកញាប់មិនបង្ហាញរូបភាពជាក់លាក់ មាន/គ្មានការប្រែប្រួល widespread interstitial "ground glass"ម្តងម្កាលមានខ្យល់ក្នុងទ្រូង (pneumothorax ។ ពិនិត្យស្រាវ ជ្រាវរកមូលហេតុផ្សេងៗនៃការបង្ករោគតាមផ្លូវដង្ហើម ឧ.ជំងឺរបេង (cavity, adenopathy, និង effusion) ជំងឺរលាកសួតបង្ករោគដោយពពួកបាក់តេរី (focal consolidation, effusion) ។
ការពិនិត្យស្រាវជ្រាវផ្សេងទៀត–ការឆ្លុះទងសួត (bronchoscopy) និងការបូមទឹកក្នុងសួត (lavage) ការធ្វើតេស្តអមគ្លីនិក៖ ធ្វើតេស្ត PCR និងតេស្ត silver stain ។

## ការព្យាបាលស្តង់ដា

- ឱសថ Cotrimoxazole ១៥-២០ក្រ/គ.ក្រ/ថ្ងៃ បែងចែកជា ៣–៤ កម្រិតដូស/ថ្ងៃ រយៈពេល២១ថ្ងៃ ។
- រក្សាជាតិទឹកក្នុងខ្លួនឱ្យបានល្អ (ចៀសវាងការចុះខ្សោយតម្រងនោម នៅពេលព្យាបាលដោយឱសថ cotrimoxazole ក្នុងកម្រិតដូសខ្ពស់) ។
- បន្ថែម folic acid ៥ ម.ក្រ/ថ្ងៃ (cotrimoxazole ធ្វើឱ្យថយចុះ folic acid ក្នុងរាងកាយ) ។

តារាងទី១៥-១ កម្រិតដូសឱសថ *cotrimoxazole* ផ្អែកតាមទម្ងន់អ្នកជំងឺក្នុងការព្យាបាលជំងឺ *PCP*

| ទម្ងន់ | កម្រិតដូសសរុប TMP១៥–២០ម.ក្រ/គ.ក្រ/ថ្ងៃ[៣១] | កម្រិតដូស DS (TMP ១៦០/SMX ៨០០ម.ក្រ) បែងចែកជា ៣ ឬ៤ដង/ថ្ងៃ |
|---|---|---|
| ៣០-៤០ គ.ក្រ | ៤៥០–៨០០ ម.ក្រ/ថ្ងៃ | ២គ្រាប់ DS ២ដង/ថ្ងៃ |
| ៤០-៥០ គ.ក្រ | ៦០០–១០០០ ម.ក្រ/ថ្ងៃ | ២គ្រាប់ DS ពេលព្រឹក ១គ្រាប់ DS ពេលថ្ងៃត្រង់ ២គ្រាប់ DS ពេលរសៀល ឬ ២គ្រាប់ DS ៣ដង/ថ្ងៃ |
| ៥០-៦០ គ.ក្រ | ៧៥០–១២០០ ម.ក្រ/ថ្ងៃ | ២គ្រាប់ DS ៣ដង/ថ្ងៃ |
| >៦០ គ.ក្រ | ៩០០-១២០០ ម.ក្រ/ថ្ងៃ | ២គ្រាប់ DS ៣-៤ដង/ថ្ងៃ ។ |

បើមានកង្វះអុកស៊ីស្សែន (hypoxemia) រួមជាមួយរោគសញ្ញាស្ទះផ្លូវដង្ហើម ឬឡើងស្វាយ ត្រូវបន្ថែមៈ

- Prednisolone: ៤០ម.ក្រ ២ដង/ថ្ងៃ x ៥ថ្ងៃ បន្ទាប់មក ៤០ម.ក្រ ១ដង/ថ្ងៃ x ៥ថ្ងៃ បន្ទាប់មក ២០ ម.ក្រ លេប១ដង/ថ្ងៃ x ១១ថ្ងៃ ។
- ការព្យាបាលដោយក្រុមឱសថ steroids ក្នុងកម្រិតដូសខ្ពស់ និងរយៈពេលយូរ លើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ដែលមានភាពស៊ាំចុះខ្សោយ នាំឱ្យប្រឈមមុខនឹង ការកើតជំងឺ disseminated strongyloidiasis និងលេចឡើងនូវ septic shock ត្រូវការព្យាបាលសាកល្បងដោយឱសថ albendazole ៤០០ម.ក្រ លេបពេលហូបអាហារដែលមានជាតិខ្លាញ់ រៀងរាល់ ១២ ម៉ោង/ម្តង រយៈពេល៧ថ្ងៃ[៣២] ។

## ការព្យាបាលជម្រើសផ្សេងទៀត

- Trimethoprim ៣០០ ម.ក្រ /ថ្ងៃ + dapsone ១០០ ម.ក្រ /ថ្ងៃ លេបរាល់ថ្ងៃ រយៈពេល ២១ថ្ងៃ ឬ
- Clindamycin ៦០០ ម.ក្រ លេប៤ដង/ថ្ងៃ + primaquine ១៥-៣០ ម.ក្រ លេប១ដង/ថ្ងៃ រយៈពេល ២១ថ្ងៃ ។

## ការតាមដានការព្យាបាល

- ការឆ្លើយតបជាមួយរោគសញ្ញាគ្លីនិកៈ បើគ្មានការឆ្លើយតបទេ ត្រូវពិចារណាព្យាបាលដោយជម្រើសផ្សេង ឬធ្វើការពិនិត្យរកមើលរោគវិនិច្ឆ័យផ្សេងទៀត ។
- ផលប៉ះពាល់នៃឱសថ cotrimoxazole –ស្នាមកន្ទួលលើស្បែក ស្លេកស្លាំង neutropenia ខ្សោយតម្រងនោម ។

[៣១] គោលការណ៍ ណែនាំ Sandford ឆ្នាំ ២០១៥ការព្យាបាលដោយការ ប្រឆាំងនឹងមេរោគ

[៣២] គោលការណ៍ ណែនាំ Sandford ឆ្នាំ ២០១៥ការព្យាបាលដោយការ ប្រឆាំងនឹងមេរោគ

រូបភាពទី១៥ -១ គំនូសបំព្រួញ: រោគសញ្ញាគ្លីនិកនៃជំងឺតាមផ្លូវដង្ហើម




<u>បើអ្នកជំងឺមិនបានធូរស្បើយដោយការព្យាបាល៖</u>

- ពិនិត្យពីប្រវត្តិជំងឺ ឬការវិវត្តន៍នៃជំងឺ ពិនិត្យរោគសញ្ញាគ្លីនិកឡើងវិញ។ ថតសួតដោយកាំរស្មីX ធ្វើតេស្ត CBC ពិនិត្យកំហាកដោយ microscopy ការបណ្តុះមេរោគ + GeneXpert ការបណ្តុះឈាម និងការវិភាគទឹកក្នុងសួត បើមានការជ្រាបទឹក ។

<u>ពិចារណា:</u>

- បញ្ជូនអ្នកទៅទទួលសេវាព្យាបាលមានកម្រិតខ្ពស់ជាង
- ការបង្ករោគលើសពីមួយមុខ
- ការព្យាបាលសាកល្បងនៃជំងឺរបេង ឬជំងឺ PCP អាស្រ័យតាមរោគសញ្ញាគ្លីនិក
- ជំងឺដែលមិនមែនបង្កដោយមេរោគ (ជំងឺហឺត (asthma) ជំងឺមហារីកសួត។ល។

# លក្ខខណ្ឌនៃប្រព័ន្ធប្រសាទ

# ជំពូក ១៦. ជំងឺរលាកស្រោមខួរ

ជំងឺរលាកស្រោមខួរ លើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ កើតឡើងជាញឹកញាប់បណ្តាលមកពីមេរោគ Cryptococcus មេរោគរបេង ឬពពួកបាក់តេរី រួមមាន *Streptococcus pneumonia (ញឹកញាប់ជាងគេ) មេរោគ Neisseria meningitidis មេរោគ H.influenza B* និងពពួកវីរុស រួមមាន មេរោគអេដស៍ខ្លួនឯង ឬវីរុស HSV ឬមេរោគស្វាយ។

**ការបង្ការ** ត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឱ្យបានឆាប់ ការពិនិត្យស្រាវជ្រាវរកជំងឺរបេង និងព្យាបាលដោយ IPT ការធ្វើតេស្តស្រាវជ្រាវរកអង់ទីស្សែន Cryptococcus។

## ១៦.១ រោគសញ្ញាគ្លីនិក

- គ្រុនក្តៅ ចង្អោរ និងក្អួត
- ឈឺក្បាលមិនឆ្លើយតបទៅនឹងថ្នាំបំបាត់ការឈឺចាប់ (analgesia) ឈឺក ខ្លាចពន្លឺ (photophobia) វង្វេងស្មារតី និងប្រកាច់ ។
- ការពិនិត្យ៖ គ្រុនក្តៅ ↓ consciousness សញ្ញារលាកស្រោមខួរ (រឹងក សញ្ញា Kernig វិជ្ជមាន) ហើម papill (ដោយសារ សម្ពាធក្នុងខួរក្បាលកើនឡើង) ។
- ស្នាមអុចៗលើស្បែកពណ៌ក្រហម (Petechial) ទាក់ទងជាចម្បងជាមួយនឹង ជំងឺmeningitis Neisseria និងជំងឺ *S. pneumonia* ផងដែរ ។
- រោគសញ្ញាជំងឺសរសៃប្រសាទបង្គោល (Focal neurological signs) ជាសញ្ញាបង្ហាញពីទំហំដំបៅ (ជំងឺរបេង ឬជំងឺដាច់សរសៃឈាមខួរក្បាល) ។

****** ការបង្ករោគដោយពពួកបាក់តេរីជាធម្មតា បង្ហាញពីភាពធ្ងន់ធ្ងរ និងទាមទារការសង្គ្រោះបន្ទាន់។ បើករណីសង្ស័យ ត្រូវផ្តល់ការព្យាបាលដោយឱសថ ceftriaxone ២ក្រាម ចាក់សរសៃ ឱ្យបានឆាប់នៅពេលបូមទឹកខួរឆ្អឹងខ្នង ឬ *មុនពេលបូមទឹកខួរឆ្អឹងខ្នង* ប្រសិនបើ ការព្យាបាលយឺតពេលជាង១ម៉ោងនៃការរំពឹងទុក ។ ******

ការធ្វើរោគវិនិច្ឆ័យបែងចែក: ត្រូវគិតពីជំងឺគ្រុនចាញ់ និងមូលហេតុនៃរោគសញ្ញាឈឺក្បាលដែលបណ្តាលមកពីជំងឺមិនឆ្លង (ឧ. migraine) ។

## ១៦.២ ការពិនិត្យគ្លីនិក និងការធ្វើរោគវនិច្ឆ័យជំងឺរលាកស្រោមខួរ

- ត្រូវបូមទឹកខួរឆ្អឹងខ្នង លើកលែងតែក្នុងករណី មានជំងឺឈាមកក (coagulopathy) ឬមានដំបៅធំពេក (ភស្តុតាងនៃសញ្ញាប្រសាទបង្គោល ប្រកាច់ ឬ ឃើញក្នុងរូបភាព CT ស្កេន) ។

- ការពិនិត្យផ្សេងទៀត: ថតសួតដោយកាំរស្មី X និងពិនិត្យកំហាកដោយ GeneXpert /អតិសុខុមទស្សន៍ តេស្ត CBC តេស្តជំងឺគ្រុនចាញ់ និងតេស្ត RPR ។

### ១៦.២.១ ការបូមទឹកឆ្អឹងខ្នង (LP)

**តារាងទី១៦-១ បច្ចេកទេសនៃការបូមទឹកខួរឆ្អឹងខ្នង និងការវិភាគទឹកខួរឆ្អឹងខ្នង**

| បច្ចេកទេសបូមទឹកខួរឆ្អឹងខ្នង និងការវិភាគខួរឆ្អឹងខ្នង |
|---|
| • ប្រើម្ជុលលេខ១៨ (១៨ gauge needle)<br>• វាស់សម្ពាធបើក (ប្រសិន គ្មាន manometer ប្រើបំពង់ IVI និងកត់សម្គាល់កម្រិតដែលបានវាស់ដោយម៉ែត្ររម្ងរភ្ជាប់ជាមួយបង្គោល IVI)<br>• ធម្មតាសម្ពាធបើក(OP) គឺ ១០-២០ $cmH_20$<br>• បើសម្ពាធកើនឡើងមិនដឹងមូលហេតុ-បូមទឹកខួរឆ្អឹងខ្នង ៥ml នៅពេលដំបូង<br>• បើសម្ពាធកើនឡើង និងសង្ស័យយ៉ាងខ្លាំងថា ជំងឺរលាកស្រោមខួរបង្កដោយមេរោគ Cryptococcus ត្រូវបូមយកទឹកខួរឆ្អឹងខ្នងចំនួន ២០-៣០mls<br>• ពិនិត្យទឹកខួរឆ្អឹងខ្នង រកជាតិស្ករ និងប្រូតេអ៊ីន<br>• ពិនិត្យទឹកខួរឆ្អឹងខ្នងដោយអតិសុខុមទស្សន៍ - គោលិកាស(leucocytes)<br>• ពិនិត្យដោយ Cryptococcus India (ប្រទេសចិន) ស្នាមប្រឡាក់ទឹកថ្នាំសម្រាប់យកទៅពិនិត្យដោយអតិសុខុមទស្សន៍ ធ្វើតេស្តរក antigen Cryptococcal (CCAg)<br>• Bacterial stain និងការបណ្ដុះមេរោគ<br>• ជំងឺរបេង: ពិនិត្យដោយអតិសុខុមទស្សន៍ តេស្ត GeneXpert និងការបណ្ដុះមេរោគរបេង ។ |

### ១៦.២.២ ការធ្វើរោគវិនិច្ឆ័យញែកចេញ នៃជំងឺរលាកស្រោមខួរ

**តារាងទី១៦-២ ការញែកចេញនៃមូលហេតុផ្សេងៗនៃជំងឺរលាកស្រោមខួរ**

| | ជំងឺបង្កដោយមេរោគ Cryptococcus | ជំងឺរបេង | ជំងឺបង្កដោយពពួកបាក់តេរី | ជំងឺបង្កដោយពពួកវីរុស |
|---|---|---|---|---|
| ចំនួនកោសិកា CD4 | ទាប (< ១០០) | ទោះបីជាចំនួនកោសិកា CD4 ប៉ុន្មានក៏ដោយ(ជាទូទៅពេលមានកោសិកាចំនួនតិច) | ទោះបីជាចំនួនកោសិកា CD4 ប៉ុន្មានក៏ដោយ | ទោះបីជាចំនួនកោសិកា CD4 ប៉ុន្មានក៏ ដោយ។ |
| លេចចេញរោគសញ្ញាភ្លាមៗ ឬវិវត្តន៍ទៅមុខ | រ៉ាំរ៉ៃ | មិនសូវស្រួចស្រាវ | ស្រួចស្រាវ | ស្រួចស្រាវ |

| | | | | |
|---|---|---|---|---|
| សម្ពាធបើកពេលបូមទឹកខួរឆ្អឹងខ្នង | ខ្ពស់– ខ្ពស់ខ្លាំង | ខ្ពស់ ឬធម្មតា | ខ្ពស់ | ជាទូទៅ ធម្មតា |
| រូបភាពនៃទឹកខួរឆ្អឹងខ្នង | ថ្លា | ជាទូទៅ ថ្លា | ជាទូទៅ ល្អក់ (Turbid) | ជាទូទៅ ថ្លា |
| កោសិកា (ភាគច្រើន) | Lymphocytes | Lymphocytes | Neutrophils ↑↑ | Lymphocytes |
| Glucose | ធម្មត /ទាប | ទាប | ទាប | ធម្មតា |
| Protein | ឡើងបន្តិចបន្តួច | ឡើង | ឡើង | ធម្មតា ឬ ឡើងបន្តិចបន្តួច |
| ការពិនិត្យដោយ Microscopy stains | India ink ជាទូទៅ វិជ្ជមាន | AFB ជាទូទៅ មើលមិនឃើញ | Gram +ve cocci (*S. Pneumoniae*), Gram –ve (*N. meningitides*) | អវិជ្ជមាន |
| ការពិនិត្យផ្សេងទៀត | CrAg វិជ្ជមាន | ពិនិត្យដោយ GeneXpert (moderate sensitivity in CSF) សុំធ្វើការបណ្ដុះមេរោគ ។ | សុំធ្វើ Grams stain និងបណ្ដុះមេរោគ | ធ្វើរោគវិនិច្ឆ័យទាត់ចោល HSV អាចបញ្ជាក់បានពេលធ្វើតេស្ត PCR ។ |

**ការពិនិត្យទឹកខួរឆ្អឹងខ្នងអ្នកជំងឺ neurosyphilis** ៖ ↑ គោលិកាសភាគច្រើនជា កោសិកា mononuclear និង ↑protein និង glucose ធម្មតា និង តេស្ត VDRL អាច វិជ្ជមាន ។

## ១៦.៣ ការព្យាបាលជំងឺរលាកស្រោមខួរ

- សូមអានជំពូក ១៧. ជំងឺរលាកស្រោមខួរបង្កដោយមេរោគ Cryptococcus (CM) និងជំងឺរលាកស្រោមខួរបង្កដោយជំងឺរបេង សូមអានផ្នែកជំងឺរបេងក្រៅសួត ក្នុងជំពូកទី១៣. ជំងឺរបេង ។

**ការព្យាបាលជំងឺរលាកស្រោមខួរបង្កដោយបាក់តេរី**

  - Ceftriaxone ២ក្រ ចាក់ IVI រាល់១២ម៉ោង/ម្តង រយៈពេល១០ថ្ងៃ ។
- ជំងឺសរសៃប្រសាទបង្កដោយមេរោគស្វាយ (Neurosyphilis)
  - Benzypenicillin ១,៨ក្រ (= ៣ million units) ចាក់រាល់៤ម៉ោង/ម្តង រយៈពេល១៥ថ្ងៃ ។
- ជំងឺរលាកខួរក្បាលបង្កដោយ Herpes simplex
  - Acyclovir ១០ម.ក្រ /គ.ក្រ ចាក់ IVI រាល់៨ម៉ោង/ម្តង រយៈពេល១០ថ្ងៃ ។

# ជំពូក ១៧. ជំងឺរលាកស្រោមខួរបង្កដោយមេរោគ Cryptococcus (CM)

## ១៧.១ ចំណុចគន្លឹះ

- *ជំងឺបង្កដោយមេរោគផ្សិតឈ្មោះ Cryptococcus neoformans* គឺជាជំងឺផ្សិតដែលគំរាមកំហែងដល់ជីវិតអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ហើយជួបប្រទះជាញឹកញាប់ ។ អត្រាស្លាប់មានកម្រិតខ្ពស់ ទោះបីជា បានទទួលការព្យាបាលក៏ដោយ ។
- ហានិភ័យនៃការវិវត្តន៍ទៅជំងឺ CM មានកម្រិតខ្ពស់បំផុត នៅពេលចំនួនកោសិកា CD4 <១០០កោសិកា/ម.ម$^{៣}$ ។
- ជំងឺ CM ជាញឹកញាប់មានការលេចចេញរោគសញ្ញាមិនសូវស្រួចស្រាវ ឈឺក្បាលខ្លាំង គឺជារោគសញ្ញាដែលកើតមានជាញឹកញាប់ ។
- ការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលឱ្យបានឆាប់ គឺជាគន្លឹះដ៏សំខាន់ ក្នុងការកែលម្អអត្រាមរណៈភាពនៃជំងឺ CM ។ ដូច្នេះ វាជាការសំខាន់ក្នុងការដាក់ការសង្ស័យពីជំងឺ CM និងចាប់ផ្តើមបូមទឹកខួរឆ្អឹងខ្នង (LP) ។
- ត្រូវបញ្ជូនអ្នកជំងឺ CM ទាំងអស់ ទៅថែទាំព្យាបាលនៅមន្ទីរពេទ្យ ។
- ការព្យាបាលដោយបូមទឹកខួរឆ្អឹងខ្នង សម្រាប់ការគ្រប់គ្រងសម្ពាធក្នុងខួរក្បាលខ្ពស់ (high intracranial pressure) គឺជាផ្នែកមួយដ៏សំខាន់នៃការព្យាបាល ដែលជះឥទ្ធិពលលើមរណៈភាពនៃជំងឺ CM ។
- សម្ពាធបើកនៃទឹកខួរឆ្អឹងខ្នងត្រូវវាស់នៅពេលដំបូង និងរាល់ពេលបូមទឹកខួរឆ្អឹងខ្នងជាបន្តបន្ទាប់។
- IRIS គឺជាការព្រួយបារម្ភ ជាពិសេស ជំងឺ CM ដោយសារហេតុផលនេះហើយ បានជាតម្រូវឱ្យពន្យារពេលចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ រហូតដល់ ៤-៦ សប្តាហ៍ បន្ទាប់ពីការចាប់ផ្តើមព្យាបាលជំងឺ CM ។

## ១៧.២ រោគសញ្ញាគ្លីនិក

ឈឺក្បាល គ្រុនក្តៅ មាន/គ្មានការផ្លាស់ប្តូរគំហើញ វង្វេងស្មារតី ពិការសរសៃប្រសាទ (cranial nerve palsy) រោគសញ្ញា meningismus (រឹងក) ប្រកាច់ និងថយចុះស្មារតី ។
រោគសញ្ញាអាចមានតិចតួចបំផុត មិនសូវស្រួចស្រាវ ឬជួលកាលពុំរ៉ៃ (ឧ.មានតែឈឺក្បាល និងគ្រុនក្តៅតែប៉ុណ្ណោះ) ។ រោគសញ្ញាស្រោមខួរក្បាល (ឧ. ឡើងរឹងក) គឺជាករណីកំរ ។
ចំពោះអ្នកជំងឺ ដែលមានការបង្ករោគរាលដាល អាចមានដំបៅស្បែកបង្កដោយមេរោគ cryptoco- ccus (អាចមើលទៅស្រដៀងគ្នាជាមួយជំងឺ contagiosum molluscum) ។

**រោគវិនិច្ឆ័យបែងចែក** ជំងឺរលាកស្រោមខួរបង្កដោយបាក់តេរី ជំងឺរលាកស្រោមខួរបង្កដោយជំងឺរបេង ជំងឺរលាកស្រោមខួរបង្កដោយ bacterial sinusitis (សូមមើល តារាងទី១៦-២ ការញែកចេញនៃមូលហេតុផ្សេងៗនៃជំងឺរលាកស្រោមខួរ ) ។

## ១៧.៣ រោគវិនិច្ឆ័យ

**រោគវិនិច្ឆ័យនៃការបូមទឹកខួរឆ្អឹងខ្នង** គឺមានសារៈសំខាន់ណាស់ក្នុងការធ្វើរោគវិនិច្ឆ័យជំងឺCM ។ ត្រូវបូមទឹកខួរឆ្អឹងខ្នង បើមេរោគ Cryptococcus ត្រូវបានរកឃើញនៅគ្រប់កន្លែងនៅពេលបណ្ដុះមេរោគ ឬតេស្តសេរ៉ូម CRAG វិជ្ជមាន និងអ្នកជំងឺមានរោគសញ្ញាគ្លីនិក (តារាងទី១៦-១ បច្ចេកទេសនៃការបូមទឹកខួរឆ្អឹងខ្នងនិងការវិភាគទឹកខួរឆ្អឹងខ្នងនិងរូបភាពទី៧-១ការពិនិត្យស្រាវជ្រាវ Cryptococcal Antigen)។

- បើគ្រឹះស្ថានព្យាបាលរបស់អ្នក មិនអាចអនុវត្តការបូមទឹកខួរឆ្អឹង ឬការវិភាគទឹកខួរឆ្អឹងខ្នងបានទេ ហើយមានការសង្ស័យថា ជាជំងឺ CM ត្រូវៈ
    - ចាប់ផ្តើមព្យាបាលដោយឱសថ fluconazole ១២០០ម.ក្រ/ថ្ងៃ និង
    - បញ្ជូនអ្នកជំងឺទៅទទួលសេវាថែទាំ និងព្យាបាលកម្រិតខ្ពស់ជាង ។

- ការបូមទឹកខួរឆ្អឹងខ្នង មិនត្រូវធ្វើទេ បើមានជំងឺឈាមកក (coagulopathy) ធ្ងន់ធ្ងរ ឬកន្លែងមានដំបៅធំ (ភស្តុតាងដោយមានរោគសញ្ញាប្រព័ន្ធប្រសាទនៅផ្នែកណាមួយនៃខួរក្បាល ប្រកាច់ ឬ CT ស្កេន appearance) ។

- បើអ្នកជំងឺមានរោគសញ្ញាបប្រព័ន្ធប្រសាទនៅផ្នែកណាមួយនៃខួរក្បាល (focal neurological signs) ត្រូវធ្វើតេស្តសេរ៉ូម CRAG បើតេស្ត វិជ្ជមាន និងមានរោគសញ្ញាគ្លីនិកនៃជំងឺ CM ត្រូវចាប់ ផ្តើមការព្យាបាលជំងឺ CM ។ ចូរចងចាំថា អ្នកជំងឺអាចមានជំងឺ toxoplasmosis និង មានតេស្តCRAG វិជ្ជមាន ដូច្នេះក្នុងករណីខ្លះ វាជាការល្អបំផុតក្នុងការព្យាបាល ទាំងជំងឺ toxoplasmosis និងជំងឺ CM រួមគ្នា។

- បើការពិនិត្យដោយអតិសុខុមទស្សន៍រកមេរោគ cryptococcus និង ធ្វើតេស្ត CRAG មានលទ្ធផលៈ អវិជ្ជមាន-ត្រូវពិនិត្យដោយអតិសុខុមទស្សន៍ និងធ្វើការបណ្ដុះរកមេរោគបាក់តេរី ។

- **រោគវិនិច្ឆ័យជំងឺ** CM **ដំណាក់កាលទី២**: ទាំងការពិនិត្យដោយអតិសុខុមទស្សន៍ដោយប្រើប្រាស់ India ink និងធ្វើតេស្ត CRAG នៅតែ វិជ្ជមានជាច្រើនខែ បន្ទាប់ពីការព្យាបាលបានជោគជ័យ ។ ដូច្នេះ នៅមានវិធីតែមួយគត់ ដើម្បីបញ្ជាក់ពីរោគវិនិច្ឆ័យឱ្យបានច្បាស់លាស់នៃការបង្ករោគក្នុងពេលបច្ចុប្បន្ន នៅក្នុងបរិបទនៃការលាប់ជំងឺឡើងវិញ ឬការបង្ករោគម្តងទៀត គឺ ការ  បណ្ដុះរកមេរោគផ្សិត ។

## ១៧.៤ ការព្យាបាលជំងឺរលាកស្រោមខួរក្បាលបង្កដោយមេរោគ cryptococcus

- អ្នកជំងឺ CM ត្រូវទទួលការគ្រប់គ្រង និងព្យាបាលនៅក្នុងមន្ទីរពេទ្យដែលមានលទ្ធភាពបូមទឹកខួរឆ្អឹងខ្នងបាន និងសមត្ថភាពក្នុងការបំពេញជាតិទឹកតាមសរសៃឈាម តាមដាន electrolytes និង Creatinine និងគ្រប់គ្រងវិបត្តិនៃ electrolytes និង ចុះខ្សោយតម្រងនោម ។

**ដំណាក់កាលដំបូង** (Induction phase):

- **Amphotericin** B ០,៧-១ម.ក្រ/គ.ក្រ ១ថ្ងៃ/ម្តង **រយៈពេល ២ សប្តាហ៍** និងបន្តដោយឱសថ Fluconazole ៨០០ម.ក្រលេប១ថ្ងៃ/ម្តង ។
- សូមមើលតារាងទី១៧-១ Amphotericin: របៀបប្រើប្រាស់ ការបង្ការការពុល ការតាមដាន និង ការគ្រប់គ្រងព្យាបាល ។
- បើមានការយឺតយ៉ាវក្នុងការបញ្ជូនអ្នកជំងឺ: ត្រូវចាប់ផ្តើមព្យាបាលដោយឱសថ fluconazole ១២០០ ម.ក្រ/ថ្ងៃ រហូតដល់ពេលដែលអ្នកជំងឺត្រូវបានបញ្ជូន ។
- គេបានផ្តល់អនុសាសន៍យ៉ាងមុតមាំថា អ្នកជំងឺត្រូវទទួលការគ្រប់គ្រងព្យាបាលនៅក្នុងមន្ទីរពេទ្យ ទោះជាយ៉ាងនេះក្តី បើអ្នកជំងឺមិនបានទៅព្យាបាលនៅមន្ទីរពេទ្យទេ ត្រូវតែព្យាបាលដោយឱសថ fluconazole ១២០០ម.ក្រ លេបរាល់ថ្ងៃ រយៈពេល ២ សប្តាហ៍ឱ្យបានចប់ពេញលេញ ។

**ការព្យាបាលដោយបូមទឹកខួរឆ្អឹងខ្នង** (LP)

- សម្ពាធក្នុងខួរក្បាលខ្ពស់ បណ្តាលមកពីជំងឺ CM ទាមទារនូវការគ្រប់គ្រងព្យាបាលដោយប្រុងប្រយ័ត្នខ្ពស់បំផុត ដោយការបូមទឹកខួរឆ្អឹងខ្នងច្រើនដង ។ ការព្យាបាលរបៀបនេះ អាចជួយបង្កើនលទ្ធផលល្អដល់អ្នកជំងឺ និងកាត់បន្ថយការឈឺក្បាលបានប្រសើរជាងការព្យាបាលដោយឱសថ analgesics ភាគច្រើន ។
- វាស់សម្ពាធពេលបើក នៅពេលបូមទឹកខួរឆ្អឹងម្តងៗ ។
- អ្នកជំងឺដែលមាន សម្ពាធបើកចំហ > ២៥ cm H2O ត្រូវបូមចេញម្តងពី ២០–៣០ml នៃទឹកខួរឆ្អឹងខ្នងក្នុងគោលបំណងបន្ថយសំពាធបើកចំហឱ្យនៅ < ២០cm H2O ឬ កាត់បន្ថយលើសពី > ៥០% ប្រសិនបើសម្ពាធបើកចំហនេះ មានកម្រិតខ្ពស់ខ្លាំងពេក ។
- ការបូមទឹកខួរឆ្អឹងខ្នងសារចុះសារឡើងរាល់ថ្ងៃ រហូតដល់សម្ពាធចំហ ស្ថិតនៅក្នុងចន្លោះកម្រិតធម្មតារយៈពេលបីថ្ងៃជាបន្តបន្ទាប់ ។
- បើបូមទឹកខួរឆ្អឹងខ្នងមួយថ្ងៃ/ម្តង មិនគ្រប់គ្រាន់ក្នុងការគ្រប់គ្រងរោគសញ្ញាធ្ងន់ធ្ងរ (ឈឺក្បាលខ្លាំង រោគសញ្ញានៃគំឃើញ និងភាពមិនប្រក្រតីនៃសរសៃប្រសាទខួរក្បាល) ទេ ត្រូវបូមទឹកខួរឆ្អឹងខ្នងចំនួន ២ ដង/ថ្ងៃ (អាចបូមទឹកខួរឆ្អឹងខ្នង ៣ -៤ដងរៀងរាល់ថ្ងៃ) ។

**តាមដានការឆ្លើយតបនៃការព្យាបាល**:

- តាមដានរោគសញ្ញាគ្លីនិក ។
- មិនចាំបាច់បូមទឹកខួរឆ្អឹងខ្នងជាប្រចាំ នៅពេលបញ្ចប់ការព្យាបាលទេ លុះត្រាតែអ្នកជំងឺនៅតែមានរោគសញ្ញាក្រោយរយៈពេល១៤ថ្ងៃ នៅពេលដែលបានអនុវត្តការបូមទឹកខួរឆ្អឹងខ្នងច្រើនលើកច្រើនសារ និងទឹកខួរឆ្អឹងខ្នងត្រូវបានបញ្ជូនទៅធ្វើការបណ្តុះរកពួកផ្សិត +/- ការធ្វើតេស្ត sensitivity (ប្រសិនបើអាចធ្វើបាន) ។

- ការធ្វើតេស្តទឹកខួរឆ្អឹងខ្នងជាមួយ India Ink និងតេស្តលើសេរ៉ូមរក CRAG គឺមិនមានប្រយោជន៍ដើម្បីតាមដានការឆ្លើយតបនៃការព្យាបាលទេ ដោយសារតែតេស្តនេះនៅតែមានភាពវិជ្ជមានជាច្រើនខែទោះបីជាការព្យាបាលទទួលបានជោគជ័យក៏ដោយ ។

ករណីដែលគ្មានភាពប្រសើរឡើងនូវរោគសញ្ញាគ្លីនិកទេ ត្រូវពិចារណាពី IRIS (សូមអានផ្នែកខាងក្រោម) ហើយវានឹងចាំបាច់ក្នុងការផាត់ចេញពីភាពស៊ាំជាមួយថ្នាំប្រឆាំងមីក្រុប នៃមេរោគ cryptococcus និងធ្វើការពិនិត្យស្រាវជ្រាវបន្តពីមូលហេតុជំងឺផ្សេងទៀត (រួមទាំង មូលហេតុនៃការបង្ករោគបន្ថែមទៀត) ។

**ការព្យាបាលក្នុងដំណាក់រួមបញ្ចូលគ្នា** (Consolidation phase therapy)

- ឱសថ Fluconazole ៤០០ម.ក្រ លេបរាល់ថ្ងៃ រយៈពេល ៨ សប្តាហ៍ ។

**ការព្យាបាលដំណាក់កាលថែទាំ (ការព្យាបាលបង្ការលើកទីពីរ)**

- Fluconazole ២០០ម.ក្រ លេបរាល់ថ្ងៃ ។

**បញ្ឈប់ការព្យាបាលដំណាក់កាលថែទាំ**:

- អ្នកជំងឺអាចបញ្ឈប់ការព្យាបាលក្រោយរយៈពេល ≥ ១២ខែ នៅពេលដែល៖

  ១. ស្ថានភាពសុខភាពអ្នកជំងឺមានលំនឹង និងការលេបថ្នាំបានទៀងទាត់ ត្រឹមត្រូវ និងជាប់លាប់ជាមួយថ្នាំ fluconazole និងថ្នាំ ARV និង

  ២. ចំនួនកោសិកា CD4 >១០០ ក្រោយពីធ្វើតេស្តពីរដង ឃ្លាតគ្នា៦ខែ/ម្តង និង ការធ្វើតេស្ត VL មានលទ្ធផល undetectable (ឬ បើគ្មានតេស្ត VL ទេ តេស្តរាប់ចំនួនកោសិកា CD4 > ២០០ ក្រោយពីធ្វើតេស្តពីរដង ឃ្លាតគ្នា៦ខែ/ម្តង) ។

## ១៧.៤.១ ការព្យាបាលនៅពេលមាន CRAG វិជ្ជមាន តែឯកឯង (IPCA)

ធានាថា ជំងឺ CM ត្រូវបានផាត់ចេញ ក្រោយពីបានពិនិត្យរោគសញ្ញាគ្លីនិក ឬ ការបូមទឹកខួរឆ្អឹងខ្នង៖

**ព្យាបាលដំណាក់កាលដំបូង**: ឱសថ Fluconazole 800ម.ក្រ លេប១ម្តង/ថ្ងៃ រយៈពេល ២ សប្តាហ៍ បន្តដោយ**ការព្យាបាលដំណាក់រួមគ្នា និងដំណាក់កាលថែទាំ**៖ ដូចគ្នាជាមួយការព្យាបាលជំងឺ CM ដែរ ។

តារាងទី១៧-១ *Amphotericin:* របៀបប្រើប្រាស់ ការបង្ការការពុល ការតាមដាន និង ការគ្រប់គ្រងព្យាបាល

| របៀបប្រើប្រាស់ Amphotericin – ការបង្ការការពុល ការតាមដាន និង ការគ្រប់គ្រងព្យាបាល[៣៣] |
|---|
| **បង្ការការបាត់បង់ជាតិទឹក និង បន្ថែមសារធាតុ electrolyte**<br>• សូលុយស្យុងសេរ៉ូមប្រៃធម្មតា១លីត្រលាយជាមួយ KCL មួយអំពូល (២០mmol) លើសពី ២-៤ ម៉ោង។ មុននឹងចាក់ amphotericin B បញ្ចូល (ជាមួយសេរ៉ូម ៥% dextrose ១លីត្រ)<br>• លេប KCL ៨mEq  ចំនួន ២ដង/ថ្ងៃ។<br>• លេបបន្ថែម១គ្រាប់ KCL ៨mEq ២ដង/ថ្ងៃ អាចបន្ថែមបាន ក្នុងកំឡុងសប្តាហ៍ទី២ ។<br>• បើបន្ថែម magnesium trisilicate លេប២គ្រាប់លេខ ២៥០ ម.ក្រ ២ដង/ថ្ងៃ រៀងរាល់ថ្ងៃ ។<br>• ការព្យាបាលជំនួស Potassium ត្រូវផ្អាកសិន ករណីមុខងារតម្រងនោមខ្សោយ ឬ មាន hyperkalaemia ។<br>• ការធ្វើតេស្តកម្រិតដូសឱសថ amphotericin B មិនត្រូវផ្តល់អនុសាសន៍ឱ្យធ្វើទេ។ |
| **របៀបប្រើប្រាស់ Amphotericin B**<br>• Amphotericin ម្សៅ (៥០ម.ក្រ vials) រក្សាទុកក្នុងសីតុណ្ហភាព ២– ៨$^{0}$C និងចៀសវាងត្រូវពន្លឺថ្ងៃ។ លាបម្សៅថ្នាំ ៥០ម.ក្រ  ជាមួយ ១០ ម.ល sterile water និងចាក់ចូលទៅសេរ៉ូម dextrose ៥% ១លីត្រ និងលាយល្បាយឱ្យបានសព្វល្អ (មិនត្រូវប្រើប្រាស់សេរ៉ូមប្រៃទេ)។<br>• ប្រើប្រាស់សេរ៉ូមដែលលាយហើយ ក្នុងកំឡុងពេល ២៤ម៉ោង ។<br>• ព្យួរសេរ៉ូមដោយចាក់ចូលតាមសរសៃឈាមវ៉ែន peripheral cannulas ≥ ៤ម៉ោង។ ក្រោយពីព្យួរសេរ៉ូម (infusion) រួចដកចេញថង់សេរ៉ូម និងព្យួរបន្តដោយសេរ៉ូមប្រៃធម្មតា ។ តាមដានស្នាមចាក់ព្យួរសេរ៉ូម ក្រែងមានការរលាកសរសៃវ៉ែន (phlebitis) និងត្រូវប្តូរកន្លែងចាក់សេរ៉ូមបើចាំបាច់។<br>**តាមដានជំងឺកំឡុងពេលព្យួរសេរ៉ូម**<br>• ជីពចរ សម្ពាធឈាម សីតុណ្ហភាព រៀងរាល់ ៣០នាទី/ម្តងក្នុងកំឡុងពេល ២ម៉ោងដំបូង បន្ទាប់រៀងរាល់ ១ម៉ោង/ម្តង ។<br>• ក្នុងករណី មានគ្រុនក្តៅ និងញាក់ញ័រ- ផ្តល់ឱសថ hydrocortisone ៥០ម.ក្រ ចាក់ IVI<br>• បើសម្ពាធឈាម < ៧០mmHg បញ្ឈប់ព្យួរសេរ៉ូម និង ចាក់សូលុយស្យុងតាម IVI និងវាយតម្លៃរោគសញ្ញាគ្លីនិក ។ |
| **តាមដានការពុលឱសថ**<br>• ធ្វើតេស្ត Serum potassium និង creatinine (នៅពេលដើមគ្រា និង រាល់២សប្តាហ៍ម្តង) ជាពិសេស នៅសប្តាហ៍ទី២ នៃការព្យាបាលដោយឱសថ amphotericin B ។<br>• ធ្វើតេស្ត Haemoglobin (នៅពេលដើមគ្រា និង រៀងរាល់សប្តាហ៍) |

[៣៣] ដំបូន្មានរហ័ស ក្នុងការធ្វើរោគវិនិច្ឆ័យ ការបង្ការ និងគ្រប់គ្រង ជំងឺ Cryptococcus ចំពោះមនុស្សពេញក្មេងជំទង់និង កុមារដែលឆ្លងមេរោគអេដស៍ ។ អង្គការសុខភាពពិភពលោក ខែធ្នូ ឆ្នាំ២០១១។

| |
|---|
| • ផ្តោតការប្រុងប្រយ័ត្នជាពិសេស ក្នុងការតាមដានជាតិទឹក ទាំងការបញ្ចូល និងការបញ្ចេញ និងតាមដាន *ទម្ងន់អ្នកជំងឺរៀងរាល់ថ្ងៃ* ។ |
| **គ្រប់គ្រងព្យាបាលការពុលឱសថ**<br>• បើ K < ៣,៣mmol/l បង្កើនការបន្ថែម potassium ដល់ ២អំពូលនៃ KCL (៤០mmol) ឬ លេប ១គ្រាប់ ឬ ២គ្រាប់នៃ ៨mEq KCL ៣ដង/ថ្ងៃ ។ តាមដានជាតិ potassium រាល់ថ្ងៃ ។<br>• បើ hypokalaemia នៅតែមិនអាចកែតម្រូវបាន (uncorrected) ត្រូវបន្ថែមឱ្យលេប magnesium ក្នុងកម្រិតដូសទ្វេដង ។<br>• តម្រងនោមចុះខ្សោយនៅពេលដើមគ្រា គ្មាន contraindications ជាមួយកម្រិតដូសស្តង់ដានៃឱសថ amphotericin B ទេ។ ត្រូវធានាថា អ្នកជំងឺមានការបំពេញជាតិទឹកបានល្អ និងបើ creatinine កើនឡើងប្រហែល > ២ដង ធៀបនឹងតម្លៃពេលដើមគ្រា ។ ករណីនេះ អាចមានជម្រើស២ អាចផ្អាកការព្យាបាលដោយឱសថ amphotericin B ជាបណ្តោះអាសន្ន ឬ បង្កើនជាតិទឹក ជាមុន១លីត្រ រៀងរាល់ ៨ម៉ោង/ម្តង ។ នៅពេលស្ថានភាពជំងឺបានប្រសើរឡើង ការចាប់ផ្តើមព្យាបាលសារឡើងវិញក្នុងកម្រិតដូស ០,៧ ម.ក្រ/គ.ក្រ/ថ្ងៃ អាចនឹងត្រូវពិចារណាក្នុងព្យាបាលដោយ amphotericin B ឆ្លាស់ថ្ងៃគ្នា ។<br>• បើ creatinine នៅតែកើនឡើង ឈប់ប្រើ amphotericin ហើយបន្តដោយ fluconazole ក្នុងកម្រិតដូស ១២០០ ម.ក្រ/ថ្ងៃ (សូមអានកំណត់សម្គាល់អំពីឱសថ fluconazole ខាងក្រោម)។ តាមដាន creatinine ប្រចាំថ្ងៃ ។ |

### ១៧.៤.២ អន្តរកម្មរវាងឱសថប្រឆាំងពពួកផ្សិត និងឱសថប្រឆាំងមេរោគអេដស៍

តារាងទី១៧-២ អន្តរកម្ម រវាងឱសថប្រឆាំងពពួកផ្សិត និងឱសថប្រឆាំងមេរោគអេដស៍

| ការព្យាបាលដោយឱសថប្រឆាំងពពួកផ្សិត | អន្តរកម្មជាមួយឱសថប្រឆាំងមេរោគអេដស៍ |
|---|---|
| Amphotericin B | គ្មានអន្តរកម្មនៃឱសថក្រុម PI និងក្រុម NNRTI<br>Amphotericin នាំឱ្យ nephrotoxic ត្រូវតាមដានមុខងារតម្រងនោមឱ្យបានដិតដល់ ហើយអាចទាមទារឱ្យកែសម្រួលកម្រិតដូសឱសថក្រុម NRTI ។ |
| Fluconazole | AZT និង NVP: ↑កំហាប់ មិនតម្រូវឱ្យកែសម្រួលកម្រិតដូសឱសថទេ តែត្រូវតាមដានផលប៉ះពាល់ ។ |

### ១៧.៤.៣ ឱសថ Fluconazole នាំឱ្យតម្រងនោមចុះខ្សោយ និងពុលថ្លើម [៣៤]

- **ឱសថ Fluconazole នាំឱ្យតម្រងនោមចុះខ្សោយ:** ឱសថ Fluconazole ត្រូវបញ្ចេញចោលតាមទឹកនោម ដូច្នេះត្រូវពិចារណាក្នុងការបន្ថយកម្រិតដូស ក្រោយពេលព្យាបាលដោយឱសថនេះ រយៈពេល ៣ថ្ងៃដំបូង បើ creatinine clearance < ៥0mL/min។
  - Cr Clearance ២១–៥០ ម.ល/មនាទី ផ្តល់កម្រិតដូសពាក់កណ្តាលនៃកម្រិតដូសផែនការរៀងរាល់ថ្ងៃ ។
  - Cr Clearance ១១–២០ម.ល/មនាទីផ្តល់កម្រិតដូស១/៤ នៃកម្រិតដូសផែនការរៀងរាល់ថ្ងៃ ។

- **ឱសថ Fluconazole និងថ្លើម** អ្នកជំងឺមួយចំនួនតូច ទាមទារឱ្យបញ្ឈប់ការព្យាបាលដោយឱសថ fluconazole បណ្តាលមកពីផលប៉ះពាល់នៃឱសថនេះ ប៉ុន្តែឱសថ fluconazole អាចបណ្តាលឱ្យកើនឡើងកម្រិតស្រាលនូវ ALT/AST និងកំរលេចចេញរោគសញ្ញាគ្លីនិកនៃជំងឺរលាកថ្លើម ថ្លើមខ្សោយខ្លាំង (Cholestasis and fulminant hepatic failure) អាចបណ្តាលឱ្យស្លាប់ ។ ហានិភ័យនឹងមានកម្រិតខ្ពស់ចំពោះអ្នកជំងឺដែលលេបឱសថ: ឱសថ rifampicin ឱសថ phenytoin ឱសថ isoniazid valproic acid ឬ ភ្នាក់ងារ sulfonylurea hypoglycaemic ។
- បើអ្នកជំងឺមានតេស្តមុខងារថ្លើម មិនធម្មតា នៅពេលកំពុងព្យាបាលដោយឱសថ fluconazole ៖
  - តាមដានឱ្យជិតដល់នៃការវិវត្តន៍ទៅ របួសថ្លើមកាន់តែធ្ងន់ធ្ងរ (↑Bilirubin និង ពេលពិនិត្យ ថ្លើមឃើញថា ថ្លើមមានសភាព tenderness គឺជាសញ្ញានៃភាពធ្ងន់ធ្ងរ) ។
  - ពិនិត្យឡើងវិញនូវអន្តរកម្មឱសថ ។
  - ណែនាំឱ្យអ្នកជំងឺ ឈប់ផឹកសុរា និងឈប់ប្រើឱសថរុក្ខជាតិ (ឱសថបុរាណ)។
  - ពិនិត្យមុខងារតម្រងនោម - ដូចជា ត្រូវបន្ថយកម្រិតដូសថ្នាំ ។
  - ចូរពិចារណាបន្ថយកម្រិតថ្នាំ ជាពិសេស ពេលប្រើ fluconazole កម្រិតដូសខ្ពស់ (៨០០ម.ក្រ ឬ ១២០០ ម.ក្រ) ។
  - ការគ្រប់គ្រងព្យាបាលអាស្រ័យទៅលើការប្រឈមមុខ: ការវាយតម្លៃពីផលប្រយោជន៍ - ស្វែងរកដំបូន្មានពីគ្រូពេទ្យជំនាញ ។

### ១៧.៤.៤ ការព្យាបាលប្រឆាំងពពួកផ្សិតនៃជំងឺរលាកស្រោមខួរបង្កដោយ Cryptococcus លើស្ត្រីមានផ្ទៃពោះ /ស្ត្រីបំបៅដោះកូន [៣៥]

- **ឱសថ Fluconazole** មានកម្រិតប្រឈមមុខចំពោះស្ត្រីមានផ្ទៃពោះក្នុងកាតេកូរី D: របាយការណ៍នៃទារកដែលមានភាពមិនប្រក្រតីពីកំណើត លើម្តាយបានព្យាបាលរយៈពេល ៣-៤ខែដោយ ឱសថ fluconazole ក្នុងកម្រិតដូសខ្ពស់ ទោះបីជា ទំនាក់ទំនងរវាងការប្រើឱសថ fluconazole និងព្រឹត្តិការណ៍ទាំងនេះ គឺនៅមិនទាន់ច្បាស់ក៏ដោយ។ ហានិភ័យ: ការប្រៀបធៀបនៃអត្ថប្រយោជន៍ នឹងត្រូវបានលើកទឹកចិត្តឱ្យប្រើឱសថ fluconazole ក្នុងបរិបទជំងឺរលាកស្រោមខួរបង្កដោយ

---

[៣៤] MIMS Fluconazone. 2015http://www.mims.com.au

[៣៥] គោលការណ៍ណែនាំ Johns Hopkins ABX Guide.200-2015។សកលវិទ្យាល័យ Johns Hopkins

cryptococcus (ការព្យាបាលក្នុងដំណាក់កាលរួមគ្នា និងដំណាក់កាលថែរក្សា) នេះ។ ស្ត្រីដែលគ្មានផ្ទៃពោះ គួរប្រើវិធីសាស្ត្រពន្យារកំណើតដែលមានប្រសិទ្ធភាព (បន្ថែមលើសពីការប្រើប្រាស់ស្រោមអនាម័យ) រហូតគាត់បានបញ្ចប់វគ្គនៃការព្យាបាលដោយឱសថ fluconazole ពេញលេញ ។

- ទោះបីជា ឱសថ fluconazole បញ្ចេញតាមទឹកដោះម្ដាយក៏ដោយ ក៏នៅមិនទាន់មានការបង្ហាញពីភាពពុលឱសថនេះទៅលើទារកនៅឡើយទេ។ដូច្នេះទំនងជាការពុលនៃឱសថគឺមានកម្រិតទាប។
- **Amphotericin B** គឺមានសុវត្ថិភាពក្នុងការព្យាបាលស្ត្រីមានផ្ទៃពោះ (ភាពមានផ្ទៃពោះគឺមានហានិភ័យក្នុងកាតេកូរីB) ដូច្នេះ ត្រូវពិចារណាក្នុងព្យាបាលដោយឱសថតែមួយមុខ (monotherapy) ចំពោះស្ត្រីមានផ្ទៃពោះក្នុងដំណាក់កាលដំបូង (induction phase) ។

### **១៧.៤.៥ ការលេចចេញ IRIS បង្កដោយ Cryptococcus**

- Cryptococcal IRIS កើតឡើងអាចជា "IRIS លាក់មុខ = unmasking IRIS" ដែលនឹងចេញរោគសញ្ញាក្រោយពេលចាប់ផ្ដើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ឬ អាចកើតឡើងនៅពេលកំពុងព្យាបាល ឬ ក្រោយពេលព្យាបាលជំងឺ CM ។
- ការធ្វើរោគវិនិច្ឆ័យវែកញែក នៃការលេបថ្នាំ fluconazole មិនបានត្រឹមត្រូវ ទៀងទាត់និងជាប់លាប់ជាមួយការបង្ករោគនៅប្រព័ន្ធប្រសាទកណ្ដាលផ្សេងទៀត (ឧ. ជំងឺរបេង ជំងឺ toxoplasmosis) ឬភាពស៊ាំជាមួយឱសថ fluconazole (ជាករណីកំរ)។
- ការព្យាបាលសម្ពាធខួរក្បាលខ្ពស់ បង្កដោយ cryptococcal IRIS គឺមានលក្ខណៈដូចគ្នាទៅនឹងការព្យាបាលខាងលើ។
- ប្រសិនបើការធ្វើរោគវិនិច្ឆ័យនៃ IRIS មិនច្បាស់លាស់ ត្រូវចាប់ផ្ដើមការព្យាបាលឡើងវិញ ឬបង្កើនការព្យាបាលប្រឆាំងពពួកផ្សិតឱ្យកាន់តែខ្លាំង (ឧ. ចាប់ផ្ដើមព្យាបាលដោយឱសថ amphotericin ឬបង្កើនកម្រិតដូសឱសថ fluconazole)។
- មិនត្រូវបញ្ឈប់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ទេ លុះត្រាតែក្នុងករណីធ្ងន់ធ្ងរ។
- បើមានផលវិបាកធ្ងន់ធ្ងរ ត្រូវពិចារណាប្រើឱសថ prednisolone 0,៥-១ ម.ក្រ/គ.ក្រ រៀងរាល់ថ្ងៃ រយៈពេល ២-៦សប្ដាហ៍ ដោយកាត់បន្ថយកម្រិតដូស ។
- ការប្រើកម្រិតដូសខ្ពស់/រយៈពេលយូរនៃឱសថ steroid លើអ្នកជំងឺអេដស៍ដែលមានភាពស៊ាំចុះខ្សោយ បណ្ដាលឱ្យបង្កើនហានិភ័យនៃការកើតជំងឺ strongyloidiasis រាលដាល និង septic shock ។ ប្រសិនបើប្រើ prednisolone កម្រិតដូសខ្ពស់ (>២០ម.ក្រ) អស់រយៈពេលលើសពី ២សប្ដាហ៍ ស្របតាមផែនការ ត្រូវព្យាបាលដោយឱសថ albendazole ៤០០ម.ក្រ លេបនៅពេលហូបអាហារមានជាតិខ្លាញ់ រៀងរាល់ ១២ម៉ោង/ម្ដង រយៈពេល៧ថ្ងៃ[៣៦] ។

---

[៣៦] គោលការណែនាំរបស់ សំរាប់ព្យាបាលប្រឆាំងនឹងមេរោគឆ្នាំ២០១៥

# ជំពូក ១៨. ជំងឺរលាកខួរក្បាលបង្កដោយ toxoplasma

- ជំងឺរលាកខួរក្បាលបង្កដោយ toxoplasma បណ្តាលមកពី ប្រតិកម្មកម្រើកឡើងវិញនៃពងរបស់ protozoa *Toxoplasma gondi* ដែលសម្ងំដេកក្នុងខួរក្បាល (ជាទូទៅ គ្មានរោគសញ្ញា)។
- ជំងឺរលាកខួរក្បាលបង្កដោយ toxoplasma កើតឡើងចំពោះអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺ អេដស៍ដែលថយចុះភាពស៊ាំខ្លាំងក្លា ហើយមានចំនួនកោសិកា CD4 < ១០០។
- ជំងឺរលាកខួរក្បាលបង្កដោយ toxoplasma គឺចាត់ថ្នាក់ក្នុងដំណាក់គ្លីនិកទី៤ នៃ WHO។

**ការបង្ការ**: កាព្យាបាលបង្ការដោយឱសថ Cotrimoxazole និងចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឱ្យបានឆាប់ ។

## ១៨.១ រោគសញ្ញាគ្លីនិក

- ឈឺក្បាល +/- គ្រុនក្តៅ
- រោគសញ្ញាប្រព័ន្ធប្រសាទនៅផ្នែកណាមួយនៃខួរក្បាល និងរោគសញ្ញា (ស្លាប់មួយចំហៀងខ្លួន និងដើរគ្មានលំនឹង និងនិយាយមិនច្បាស់(ataxia)។ល។
- រលាកខួរក្បាល - រោគសញ្ញា ដូចជា ថយចុះស្មារតី និងវង្វេងវង្វាន់ ភ្លេចភ្លាំង
- ការពិនិត្យដោយ Fundoscopy៖ +/- retinochorioditis + ឬ papilledema (ដោយសារតែ ↑ សម្ពាធក្នុងខួរក្បាល)។

## ១៨.២ ការពិនិត្យស្រាវជ្រាវ និងការធ្វើរោគវិនិច្ឆ័យ

- ការបូមទឹកខួរឆ្អឹងខ្នងគឺ contraindicated បើមានរោគសញ្ញាប្រព័ន្ធប្រសាទនៅផ្នែកណាមួយនៃខួរក្បាល (focal neurological signs)។
- បើគ្មាន ការពិនិត្យដោយ CT ស្កេន → ត្រូវព្យាបាលសាកល្បង និងតាមដានការឆ្លើយតបទៅនឹងការព្យាបាល ដើម្បីបញ្ជាក់ពីការធ្វើរោគវិនិច្ឆ័យនេះ ។
- បើមាន CT ស្កេន៖ ជាធម្មតា ឃើញមានដំបៅច្រើន មានរាងជា "ចិញ្ចៀនខ្ពស់"។
- ការធ្វើតេស្ត serology toxoplasmosis IgG ធ្លាប់មានលទ្ធផល វិជ្ជមានពីមុន ឬទើបមានការបង្ករោគដោយ toxoplasmosis ថ្មីៗ ដូច្នេះគឺវាមានប្រយោជន៍ បើលទ្ធផលតេស្ត អវិជ្ជមាន យើងអាចផាត់ចោលជំងឺ toxoplasmosis ចេញបាន។

## ១៨.៣ រោគវិនិច្ឆ័យបែងចែក

- មានដុំក្នុងសួត (Tuberculoma)៖ ថតសួតដោយកាំរស្មី X និងពិនិត្យកំហាកដោយ GeneXpert រកជំងឺរបេង គឺជាជំងឺសំខាន់បំផុតដែលអាចព្យាបាលបានជាសះស្បើយ នៃការធ្វើរោគវិនិច្ឆ័យបែង ចែក។
- មហារីកកូនកណ្តុរក្នុងខួរក្បាល បូសខួរក្បាលបង្កដោយបាក់តេរី ជំងឺដាច់សរសៃឈាមខួរក្បាល (stroke)។
- ប្រសិនបើ អ្នកជំងឺបានទទួលការព្យាបាលបង្ការដោយឱសថ cotrimoxazole គឺមិនទំនងក្នុងការធ្វើរោគវិនិច្ឆ័យថា ជាជំងឺ toxoplasmosisទេ។

## ១៨.៤ ការព្យាបាលស្តង់ដា

- ប្រើកម្រិតដូសខ្ពស់នៃឱសថ cotrimoxazole៖ ១០/៥០ម.ក្រ/គ.ក្រ លេបរាល់ថ្ងៃ ចែកជា២ដង/ថ្ងៃ រយៈពេល៦សប្តាហ៍ ។
    - មនុស្សពេញវ័យ > ៥០ គ.ក្រៈ ២ x DS គ្រាប់ លេប២ដង/ថ្ងៃ
    - មនុស្សពេញវ័យ < ៥០គ.ក្រៈ ៣ x SS គ្រាប់លេប២ដង/ថ្ងៃ
- បន្ថែម folic acid ៥ ម.ក្រ លេបរាល់ថ្ងៃ ដោយសារការប្រើកម្រិតដូសខ្ពស់នៃឱសថ cotrimoxazole រារាំងការសំយោគនៃ folate។
- ផ្តល់ប្រឹក្សា ឱ្យអ្នកជំងឺពិសារទឹកផ្លែឈើឱ្យបានច្រើន ដោយសារការប្រើកម្រិតដូសឱសថ cotrimoxazole អាចប៉ះពាល់ដល់មុខងារតម្រងនោម ។
- បើមានប្រតិកម្ម cotrimoxazole hypersensitivity – ផ្តល់ការព្យាបាល desensitization នៅសេវាពិគ្រោះជំងឺក្រៅ ឬអ្នកជំងឺសំរាកពេទ្យ (សូមមើលតារាងទី ៥- ៣ វិធីសារនៃការកាត់បន្ថយប្រតិកម្មនៃឱសថ Cotrimoxazole ចំពោះមនុស្សពេញវ័យ និងក្មេងជំទង់។

## ១៨.៥ តាមដានការឆ្លើយតបទៅនឹងការព្យាបាល

- ការឆ្លើយតបនឹងរោគសញ្ញាគ្លីនិក និងវិទ្យុសាស្ត្រ គឺរំពឹងថានឹងកើតឡើងក្នុងកំឡុង២–៣សប្តាហ៍។ បើគ្មានការឆ្លើយតបទេ ពិនិត្យរករោគវិនិច្ឆ័យផ្សេងវិញ និង ពិចារណាលើការព្យាបាលជំងឺរបេងសាកល្បង។

**ចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍**: កំឡុង ២សប្តាហ៍នៃការធ្វើរោគវិនិច្ឆ័យ។

## ១៨.៦ ការព្យាបាលបង្ការទី ២

ឱសថ Cotrimoxazole ១DS លេបរាល់ថ្ងៃ រហូតដល់ចំនួនកោសិកា CD4 > ៣៥០ រយៈពេល៦ខែ និង តេស្ត VL មានលទ្ធផល undetectable ។

# ជំពូក ១៩. ជំងឺ Cytomegalovirus (CMV)

- ជំងឺ CMV គឺជាជំងឺមួយបង្កដោយវីរុស ដែលកើតឡើងជាញឹកញាប់ ដោយសារមានសកម្មភាពឡើងវិញនៃមូលហេតុជំងឺមួយចំនួនកើតឡើងនៅសរីរាងណាមួយ ឬរាលដាលក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ដែលមានភាពស៊ាំដោយចុះខ្សោយខ្លាំង ចំនួនកោសិកា CD4 < ១០០ កោសិកា/មម$^{៣}$ (ជាពិសេសអ្នកជំងឺដែលមាន CD4 <៥០) ។
- ជំងឺ CMV ជាមូលហេតុបណ្តាលឱ្យកើតជំងឺរលាករ៉េទីនភ្នែក (retinitis ) ភាគច្រើន ប៉ុន្តែជាញឹកញាប់ផងដែរក្នុងការបង្កឱ្យមានជំងឺប្រដាប់រំលាយអាហារ (ជំងឺរលាកបំពង់អាហារ ជំងឺរលាកពោះវៀនធំ) និងជំងឺរលាកសួត (pneumonitis) និង ម្តងម្កាលមានជំងឺរលាកខួរក្បាល (encephalitis) ជំងឺរលាកថ្លើម ជំងឺរលាកក្រពេញ adrenalitis ជំងឺរលាកលំពែង និង/ឬ ជំងឺ epididymitis។
- ជំងឺ CMV ត្រូវចាត់ទុកក្នុងដំណាក់កាលទី៤ នៃ WHO។

**ការបង្ការ** ចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឱ្យបានឆាប់។

## ១៩.១ រោគសញ្ញាគ្លីនិកនៃជំងឺរលាករ៉េទីនភ្នែកបង្កដោយ CMV

- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ អាចបង្ហាញរោគសញ្ញាភ្នែកនៅក្នុងដំណាក់កាលធ្ងន់ធ្ងរនៃជំងឺអេដស៍ ឬការវិវត្តនៃរោគសញ្ញាភ្លាមៗ បន្ទាប់ពី ចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នៅពេលដែល វាអាចក្លាយទៅជា "unmask" ដូចជា IRIS បង្កដោយជំងឺ CMV ។
- រោគសញ្ញា: "គំហើញអណ្តែត" ខ្លាចពន្លឺ (photophobia) និងពិការភាពនៃគំឃើញ ។ គ្មានការឈឺចាប់ និង ក្រហមភ្នែកទេ។
- ពិនិត្យ Opthalmoscopic: ឃើញ exudate perivascular ពណ៌ស ដោយមាន ឬគ្មានការហូរ ឈាម ។

## ១៩.២ ការគ្រប់គ្រងព្យាបាល

- បញ្ជូនអ្នកជំងឺទៅចាក់ intravitreal ganciclovir ។
- បន្ត/ចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។

# ជំពូក ២០. ជំងឺខួរក្បាលបង្កដោយមេរោគអេដស៍/ជំងឺវិកលចរិក

## (dementia)

- ពាក្យវិបត្តិសរសៃប្រសាទវិញ្ញាណពាក់ព័ន្ធជាមួយមេរោគអេដស៍(*HIV-associated neurocognitive disorder*(HAND)) គិតទាំង វិបត្តិសរសៃប្រសាទវិញ្ញាណកម្រិតស្រាល (វិបត្តិសរសៃប្រសាទ វិញ្ញាណកម្រិតស្រាល MND) រហូតដល់ជំងឺវិកលចរិកបង្កដោយមេរោគអេដស៍ (HAD) ។
- កត្តាប្រឈមមុខនៃ HAND: ជំងឺអេដស៍ដំណាក់កាលធ្ងន់ធ្ងរដែលមានចំនួនកោសិកា CD4 កម្រិតទាបខ្លាំង មុនពេលចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ អ្នកជំងឺមានវ័យចាស់ ជំងឺសរសៃឈាម និងជំងឺមេតាបូលិក ដូចជា ជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម។
- ទម្រង់ធ្ងន់ធ្ងរនៃ HAND គឺមិនសូវកើតមានជាញឹកញាប់ទេ នៅក្នុងសម័យកាលដែលមានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដ៏មានប្រសិទ្ធភាព ។
- ទម្រង់កម្រិតស្រាលនៃ HAND បានជួបប្រទះជាញឹកញាប់ និងជាទូទៅ មិនបានធ្វើរោគវិនិច្ឆ័យទោះជាយ៉ាងណាក៏ដោយ វាអាចបណ្តាលមកពីអ្នកជំងឺមិនបានទទួលការព្យាបាលត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ រួមទាំងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ផងដែរ វិបត្តិអារម្មណ៍ និង ថយចុះសមត្ថភាពក្នុងការបំពេញមុខងារក្នុងក្រុមគ្រួសារ ការបំពេញការងារ និងការបំពេញមុខងារក្នុងសហគមន៍ ។
- ជំងឺវិកលចរិកបង្កដោយមេរោគអេដស៍ (dementia) គឺចាត់ចូលក្នុងដំណាក់កាលគ្លីនិកទី៤ នៃWHO។

**តារាងទី២០-១ រោគសញ្ញាគ្លីនិកនៃជំងឺវិកលចរិក ពាក់ព័ន្ធនឹងជំងឺអេដស៍**

| |
|---|
| **១ .ការខូចខាតសរសៃប្រសាទវិញ្ញាណ**<br>វិវត្តន៍ទៅរកការបាត់បង់ការចងចាំ ពិបាកផ្តោតអារម្មណ៍ វង្វេងស្មារតី និងការគិតយឺត (slowing of thought)។ |
| **២ .រោគសញ្ញាចលករ (Motor symptoms)** បាត់បង់លំនឹង ភាពល្ងង់ល្ងៅ (clumsiness) ប្តូររូបរាងអក្សរដែលសរសេរ(change in handwriting) ញ័រដៃ ដំណើរញ័រ(tremor) ដំណើរទ្រេតទ្រោត (unsteady gait) ការនោមឬ ជុះដោយមិនដឹងខ្លួន (incontinence)។ |
| **៣ .ផ្លាស់ប្តូរការប្រព្រឹត្ត**<br>ភាពព្រងើយកន្តើយ (Apathy) ដកខ្លួនចេញពីសង្គម ថយចុះការចាប់អារម្មណ៍ទៅនឹងអ្វីដែលកំពុងកើតឡើង និងពីសុខភាពរបស់ខ្លួនឯង។ |

## ២០.១ រោគវិនិច្ឆ័យ: HAND ឥឡូវជាការធ្វើរោគវិនិច្ឆ័យផាត់ចោល

### រោគវិនិច្ឆ័យបែងចែក

- ការបង្ករោគប្រព័ន្ធសរសៃប្រសាទកណ្តាល ជំងឺរលាកខួរក្បាលបង្កដោយ CMV ជំងឺរបេង ជំងឺ toxoplasmosis ។
- ជំងឺមហារីកប្រព័ន្ធសរសៃប្រសាទកណ្តាល ជំងឺមហារីកកូនកណ្តុរ (lymphoma)
- ការខូចមុខងារក្រពេញទីរ៉ូអ៊ីត
- ជំងឺធ្លាក់ទឹកចិត្ត ឬ លក្ខខណ្ឌវិកលចរិកផ្សេងទៀត
- វិបត្តិនៃការប្រើប្រាស់សារធាតុ- ឧ. ជំងឺវិកលចរិកបណ្តាលមកពីការផឹកស៊ុរ៉ា
- ការភ្លេចភ្លាំង (កំណត់ដោយការឡើងចុះនៃស្មារតី)
- កង្វះអាហារូបត្ថម្ភ: វីតាមីន $B_{12}$
- រោគសញ្ញាជំងឺវិកលចរិកផ្សេងទៀត រួមទាំង ជំងឺសរសៃឈាម (ជំងឺវិកលចរិកទាក់ទងនឹងជំងឺលើសសម្ពាធឈាម) ជំងឺភ្លេចភ្លាំង និងជំងឺ Parkinson ។ល។

## ២០.២ វាយតម្លៃរោគសញ្ញាគ្លីនិក

- ពិនិត្យស្រាវជ្រាវជំងឺធ្លាក់ទឹកចិត្ត ដូចក្នុងករណីជំងឺធ្លាក់ទឹកចិត្តធ្ងន់ធ្ងរ អាចមានសភាពដូចគ្នាជាមួយនឹងជំងឺវិកលចរិក (dementia) (សូមអានជំពូកទី ៤២.សុខភាពផ្លូវចិត្ត) ។

### ប្រយោជន៍នៃសាកសួរសំណួរអំពី HAND

- តើអ្នកភ្លេចរឿងអ្វីមួយជាញឹកញាប់ឬទេ?
- តើអ្នកមានអារម្មណ៍ថា អ្នកមានការយឺតយ៉ាវពេលលើកផែនការសកម្មភាព ឬក្នុងការដោះស្រាយបញ្ហា ឬទេ?
- តើអ្នកមានការលំបាកក្នុងការផ្តោតអារម្មណ៍ (ឧ. ពេលសន្ទនា ឬពេលបំពេញភារកិច្ច) ឬទេ?
- សួរដៃគូ/គ្រួសារ ប្រសិនបើពួកគេបានកត់សម្គាល់ឃើញចំណុចណាមួយខាងលើនេះ។

ត្រូវធ្វើការពិនិត្យប្រព័ន្ធប្រសាទពេញលេញ និងពិនិត្យជំងឺសរសៃឈាមបេះដូង។

### រោគសញ្ញារកឃើញ ពេលពិនិត្យ HAND

- ការយឺតយ៉ាវទាក់ទងនឹងការនិយាយ ចលនាមុខ និងចលនាជាទូទៅ
- ការយឺតយ៉ាវ ពេលធ្វើចលនាសាច់ដុំ
- Hyper-reflexia
- ភាពទន់ខ្សោយកម្លាំងជើងកម្រិតស្រាល
- Impaired tandem gait (កែងជើង - ម្រាមជើង)
- ភាពញាក់ញ័រ(Tremor)

- ឧបករណ៍ត្រូវបានបង្កើតឡើងដែលគេស្គាល់ថា ជញ្ជីងសម្រាប់វាស់វែងកម្រិតនៃជំងឺវិកលចរិក ទាក់ទងនឹងជំងឺអេដស៍(HDS) ដើម្បីជួយក្នុងការធ្វើរោគវិនិច្ឆ័យជំងឺវិកលចរិក ទាក់ទងនឹងជំងឺ អេដស៍នេះ។ ទោះជាយ៉ាងណាក៏ដោយ រង្វាស់មានដែនកំណត់ អំពី sensitivity និង specificity។

**តារាងទី២០-២ រង្វាស់អន្តរជាតិនៃជំងឺវិកលចរិកពាក់ព័ន្ធជាមួយមេរោគអេដស៍ *(IHDS)*** [៣៧]

| | | |
|---|---|---|
| **ការចងចាំ -ការចុះបញ្ជី** | សូមឱ្យ៥ពាក្យដើម្បីរំលឹកពី (ឆ្កែ មួក សណ្តែក ក្រហម) - និយាយពាក្យនិមួយមួយវិនាទី។ បន្ទាប់មក សួរអ្នកជំងឺពាក្យទាំង៤នេះ ក្រោយពីអ្នកបាននិយាយពាក្យទាំងអស់នោះ។ និយាយពាក្យទាំងនោះម្តងទៀត ប្រសិនបើអ្នកជំងឺមិនអាច រំលឹកឡើងវិញនូវពាក្យទាំងនោះភ្លាមៗ។ ចូរប្រាប់អ្នកជំងឺថា អ្នកសូមឱ្យអ្នកជំងឺរំលឹកពាក្យទាំងនេះជាថ្មីម្តងទៀត នៅពេលក្រោយបន្តិច។ | |
| **១. ល្បឿននៃចលករ** (Motor Speed): | ឱ្យអ្នកជំងឺប៉ះម្រាមដៃពីរដំបូងនៃម្រាមដៃដែលមិនលេចធ្លោ ឱ្យបានទូលំទូលាយ និងឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន។ | ៤ = ១៥ ក្នុង៥វិនាទី<br>៣= ១១-១៤ ក្នុង៥ វិនាទី<br>២= ៧-១០ ក្នុង៥ វិនាទី<br>១= ៣-៦ ក្នុង៥ វិនាទី<br>០= ០-២ ក្នុង៥ វិនាទី |
| **២. ល្បឿននៃចលករផ្លូវចិត្ត** (Psychomotor Speed) | ឱ្យអ្នកជំងឺធ្វើចលនាមួយចំនួនដូចខាងក្រោមនេះ ជាមួយនឹងដៃមិនមែនជាការលេចធ្លោ ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន៖ ១) ក្តាប់ដៃឱ្យណែន ទីមួយនៅលើផ្ទៃរាបស្មើ។ ២)ដាក់ដៃលើផ្ទៃរាបស្មើជាមួយនឹងបាតដៃចុះក្រោម។ ៣) ដាក់កែងទៅនឹងផ្ទៃរាបស្មើ នៅលើផ្នែកម្ខាងនៃខ្នង់ម្រាមដៃទី៥។ ធ្វើបង្ហាញអ្នកជំងឺ និងឱ្យអ្នកជំងឺបង្ហាញពីរដង។ | ៤= ៤ sequences ក្នុង១០ វិនាទី<br>៣=៣ sequences ក្នុង១០ វិនាទី<br>២=២ sequences ក្នុង១០ វិនាទី<br>១ =១ sequence ក្នុង១០ វិនាទី<br>០ = មិនអាចធ្វើបាន |
| **៣. ការចងចាំ-ការរំលឹកឡើងវិញ** (Memory-Recall) | សូមឱ្យអ្នកជំងឺរំលឹកពាក្យទាំងបួន។ ចំពោះពាក្យដែលមិនបានរំលឹក សូមឱ្យតម្រុយ ឬគន្លឹះដល់អ្នកជំងឺ (semantic) ដូចខាងក្រោម: សត្វ (សត្វឆ្កែ) សម្លៀកបំពាក់ណាមួយ (មួក) បន្លែ(សណ្តែក) ពណ៌(ក្រហម) | ឱ្យ ១ ពិន្ទុសម្រាប់ការរំលឹកពាក្យនិមួយៗដោយឯកឯង និងផ្តល់ ០,៥ ពិន្ទុសម្រាប់ចម្លើយដែលត្រឹមត្រូវបន្ទាប់ពីបានជួយឱ្យតម្រុយជា គន្លឹះ។ ពិន្ទុអតិបរមាគឺ - ៤ ពិន្ទុ។ |
| ពិន្ទុកសរុបនៃមាត្រដ្ឋានអន្តរជាតិនៃការវាស់វែងជំងឺវិកលចរិកទាក់ទងនឹងមេរោគអេដស៍ គឺជាការបូកពិន្ទុសរុបពីប្រធាន ១-៣។ ពិន្ទុអតិបរមាគឺ១២។ អ្នកជំងឺម្នាក់ដែលមានពិន្ទុ ≤ ១០ ត្រូវតែ វាយតម្លៃបន្ថែមទៀតអំពីលទ្ធភាពនៃកើតមានជំងឺវិកលចរិក(dementia)។ | | |

[៣៧] ការបោះពុម្ពឡើងវិញពី Sacktor NC, Wong M, Nakasujja N, et al. មាត្រដ្ឋាន អន្តរជាតិនៃ HIV Dementia:តេស្តថ្មីរហ័សសំរាប់រុករក HIV Dementia។ AIDS 2005;19:1367-1374

## ២០.៣ ការពិនិត្យស្រាវជ្រាវ

- តេស្ត Syphilis– RPR,
- ពិនិត្យរកជំងឺទឹកនោមផ្អែម-BSL.
- តេស្តមុខងារក្រពេញទីរ៉ូអ៊ីត(Thyroid) Vitamin $B_{12}$
- ពិចារណាក្នុងការបូមទឹកខួរឆ្អឹងខ្នង និងធ្វើ CT scan (ប្រសិនជាអាចធ្វើបាន) ដើម្បីផាត់ចោលជំងឺប្រព័ន្ធសរសៃប្រសាទកណ្តាល។

## ២០.៤ ការគ្រប់គ្រងព្យាបាល

- ចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ឱ្យបានឆាប់បំផុត (ជាទូទៅការឆ្លើយតបនឹងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានល្អ);
    - ចូរពិចារណាការចាប់ផ្តើម ឬផ្លាស់ប្តូរពីឱសថ EFV ទៅឱសថ NVP បើសិនជាមានការផ្តល់យោបល់ថា ឱសថ EFV មានផលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទកណ្តាល ។ លើសពីនេះទៅទៀត ឱសថ NVP មានការជ្រៀបចូលក្នុងប្រព័ន្ធសរសៃប្រសាទកណ្តាលបានល្អ ។

- ធានាឱ្យមានការគ្រប់គ្រងព្យាបាលឱ្យបានល្អនូវការមានជំងឺច្រើនរួមគ្នា ក្នុងពេលតែមួយ (comorbidities) - ជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម ។
- ស្រង់បញ្ជីសមាជិកក្រុមគ្រួសារអ្នកជំងឺ ដែលជួយគាំទ្រអ្នកជំងឺក្នុង៖
    - ការលេបឱសថឱ្យបានត្រឹមត្រូវ ទៀងទាត់និងជាប់លាប់ រួមទាំងឱសថប្រឆាំងមេរោគអេដស៍
    - ផ្តល់អាហារូបត្ថម្ភឱ្យបានសមស្រប
    - បរិដ្ឋានមានសុវត្ថិភាព (ពិចារណាទាំង អគ្គិសនី ចរាចរ)
- ផ្តល់យោបល់អ្នកជំងឺកុំឱ្យសេពសុរាច្រើន ឬឱ្យពិសារគ្រឿងស្រវឹងតិចតួចបំផុត ។

# ជំពូក ២១. ជំងឺសរសៃប្រសាទនៅផ្នែកខាងចុង (Peripheral Neuropathy)

ជំងឺសរសៃប្រសាទនៅផ្នែកខាងចុង (PN) កើតឡើងជាញឹកញាប់លើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ជាពិសេស អ្នកជំងឺដែលមានចំនួនកោសិកា CD4 < ២០០កោសិកា/ម.ម$^{៣}$ ។

## ២១.១ មូលហេតុនៃជំងឺ PN

- បង្កដោយមេរោគអេដស៍ខ្លួនឯង
- កង្វះ Vitamin (B6 B១2 thiamine។ល។)
- ផលប៉ះពាល់នៃឱសថផ្សេងៗ រួមទាំង ឱសថ ARVs (d4T ឬ ddi) និងឱសថប្រឆាំងជំងឺរបេង(INH)
- ជំងឺទឹកនោមផ្អែម
- ការសេពគ្រឿងស្រវឹងច្រើនពេក ។

## ២១.២ ការបង្ការជំងឺ PN

- ធានាថា pyridoxine ត្រូវបានផ្តល់ជូនអ្នកជំងឺជាប់ជានិច្ច នៅពេលព្យាបាលដោយឱសថ INH។
- ព្យាយាមចៀសវាងការព្យាបាលដោយឱសថ d4T ដែលជាឱសថមួយក្នុងរូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។
- ជំងឺទឹកនោមផ្អែម: ពិនិត្យស្រាវជ្រាវ និងព្យាបាល ដោយត្រួតពិនិត្យ glycemy ឱ្យបានល្អ ។
- ផ្តល់យោបល់ឱ្យគ្រប់គ្រងអាហារូបត្ថម្ភឱ្យបានល្អ និងពិសារគ្រឿងស្រវឹងក្នុងកម្រិតសុវត្ថិភាព ។

## ២១.៣ រោគសញ្ញាគ្លីនិក

- ថយចុះ +/- ប្រែប្រួលនៃ sensation ក្នុងភាពស៊ីមេទ្រី `glove and stocking distribution´ (ជើង និង នៅដៃម្តងម្កាល)។
- "Pins និង needles´ មានអារម្មណ៍ក្តៅ (burning sensation) "ត្រជាក់ជើង" រមួលក្រពើ ។
- អវត្តមាន reflexes កែងជើង និងចុះខ្សោយកម្លាំងកែងជើង/ជើង អាចកើតមានឡើង ។

## ២១.៤ ការគ្រប់គ្រងព្យាបាល

- ធានា ការធ្វើរោគវិនិច្ឆ័យឱ្យបានត្រឹមត្រូវ (ពិនិត្យនៃភាពស៊ីមេទ្រី)
- ពិនិត្យឱសថដែលបានប្រើ ការសេពគ្រឿងស្រវឹង និងពិនិត្យស្រាវជ្រាវរកជំងឺទឹកនោមផ្អែម (សូមអាន "ការបង្ការជំងឺ PN" ខាងលើ) និងការគ្រប់គ្រងព្យាបាល ។
- ព្យាបាលបំបាត់ការឈឺចាប់ (analgesia)
    - ឱសថ Paracetamol ៥០០ ម.ក្រ–១០០០ ម.ក្រ លេប ៤ដង/ថ្ងៃ ។

- ឱសថ Ibuprofen (ត្រូវប្រយ័ត្ន ករណីមុខងារតម្រងនោមនិងថ្លើម មិនធម្មតា ជំងឺក្រពះពោះវៀន ឬ ជំងឺលើសសម្ពាធឈាម)។
- ឱសថ Amitriptyline ចាប់ផ្តើមព្យាបាលក្នុងកម្រិត ២៥ ម.ក្រ នៅពេលយប់ អាចបង្កើនដល់ ៥០ ម.ក្រ ។ (ផ្តល់ដំណឹងជូនអ្នកជំងឺទាក់ទងនឹងរោគសញ្ញានៃការចុះសម្ពាធឈាម នៅពេលផ្លាស់ប្តូរស្ថានភាព(postural hypotension) ។

# ជំងឺរលាកថ្លើម បង្កដោយវីរុស និងជំងឺថ្លើមរ៉ាំរ៉ៃ

# ជំពូក ២២. ជំងឺរលាកថ្លើមប្រភេទ B

ជំងឺរលាកថ្លើមប្រភេទ B គឺជាវីរុស DNA ស្ថិតក្នុងគ្រួសារ hepadnavirus។
ជំងឺរលាកថ្លើមប្រភេទ B (HBV) គឺជាជំងឺមួយក្នុងចំណោមជំងឺដែលកើតឡើងជាញឹកញាប់ នៅក្នុងពិភពលោក និងនៅប្រទេសកម្ពុជា ដែលមានអត្រាប្រេវ៉ាឡង់ខ្ពស់នៃជំងឺរលាកថ្លើមប្រភេទ B > ៨% ក្នុងចំណោមប្រជាជនទូទៅ ។

## ២២.១ ទំនាក់ទំនងរវាង មេរោគអេដស៍ និង ជំងឺរលាកថ្លើមប្រភេទ B

- HIV និង HBV មានផ្លូវចម្លងរួមគ្នា
- ការបង្ករោគរួមគ្នាជាមួយមេរោគអេដស៍ បណ្តាលឱ្យជំរុញការវិវត្តន៍ខ្ពស់ នៃអ្នកជំងឺរលាកថ្លើមប្រភេទ B ទៅរកជំងឺថ្លើមក្រិន(cirrhosis) និងជំងឺមហារីកកោសិកាថ្លើម(hepatocellular carcinoma) និងមានភស្តុតាងបញ្ជាក់ថា ជំងឺរលាកថ្លើមប្រភេទ B ជំរុញការវិវត្តន៍លឿនទៅរកជំងឺអេដស៍ និងបណ្តាលឱ្យឆាប់ស្លាប់ ។
- ជំងឺរលាកថ្លើមប្រភេទ B នាំឱ្យមានការប្រឈមមុខខ្ពស់នៃការពុលថ្លើមនៅពេលព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងឱសថផ្សេងៗ ។
- ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ រួមមាន ឱសថមួយចំនួនប្រឆាំងជំងឺរលាកថ្លើមប្រភេទ B ដែលអាចមានឥទ្ធិពលក្នុងការគ្រប់គ្រងព្យាបាលការបង្ករោគរួមគ្នានៃជំងឺទាំងពីរនេះ។
- ការស្តារឡើងវិញនៃភាពស៊ាំ ក្រោយពេលទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ អាចនាំឱ្យមាន "flare" នៃជំងឺរលាកថ្លើមប្រភេទ B ។

## ២២.២ ការចម្លង និងការបង្ការការចម្លងជំងឺរលាកថ្លើមប្រភេទ B

ជំងឺរលាកថ្លើមប្រភេទB គឺឆ្លងតាមឈាមដែលមានវីរុស ឬតាមសារធាតុនៃសារពាងកាយ (ទឹកកាមបុរស និងទឹករំអិលយោនី) ។ វីរុសអាចជ្រៀតចូលទៅក្នុងឈាមតាមរយៈ mucous membranes ឬតាមរយៈស្បែកដាច់រលាត់។

**តារាងទី២២-១ ការចម្លង និងការបង្ការជំងឺរលាកថ្លើមប្រភេទ B**

| ការចម្លងជំងឺរលាកថ្លើមប្រភេទ B | ការបង្ការជំងឺរលាកថ្លើមប្រភេទ B |
|---|---|
| • ជុំវិញកំណើតកូន (Perinatal) ប្រឈមមុខនឹងការឆ្លង ពី ៣០ –៩០%<br>• តាមការចាក់ទម្លុះស្បែក (Parenteral)<br>– អ្នកចាក់គ្រឿងញៀន(IDU): ប្រឈមមុខខ្ពស់ខ្លាំងនឹងការឆ្លងមេរោគអេដស៍ | • ការចាក់ថ្នាំបង្ការ<br>– ទារក (↓ ៧០%)<br>– មន្ត្រីសុខាភិបាល<br>– ដៃគូ (ប្តីឬប្រពន្ធ)<br>• អនុវត្តវិធានការបង្ការជាសកល |

| | |
|---|---|
| – គ្រឹះស្ថានថែទាំព្យាបាលៈ<br>• បញ្ចូលឈាម<br>• ដំណើរការវេជ្ជសាស្ត្រ<br>• គ្រោះថ្នាក់ដោយការមុតម្ជុល (~ ប្រឈមមុខនឹងការឆ្លង ៣០%)<br>– នៅក្នុងផ្ទះៈ<br>• ពីកុមារម្នាក់ទៅម្នាក់<br>• ច្រាសដុះធ្មេញ ឡាមកោរពុកមាត់។ល។<br>• ចោះក្រវិលត្រចៀក សាក់លើស្បែក<br>• ការរួមភេទ រួមទាំង ការរួមភេទតាមមាត់។ | • ពិនិត្យស្រាវជ្រាវរកមេរោគលើសឈាម<br>• ស្រោមអនាម័យ<br>• ការប្រុងប្រយ័ត្ននៅក្នុងផ្ទះ |

## ២២.៣ ការធ្វើរោគវិនិច្ឆ័យជំងឺរលាកថ្លើមប្រភេទ B

**តេស្ត** Serology:

- តេស្ត HBsAg វិជ្ជមាន បញ្ជាក់ថា កំពុងមានការបង្ករោគជំងឺរលាកថ្លើមប្រភេទ B ។
- បើតេស្ត HBsAg អវិជ្ជមាន ប៉ុន្តែ តេស្ត HBsAb វិជ្ជមាន បញ្ជាក់ថា មានភាពស៊ាំប្រឆាំងជំងឺរលាកថ្លើមប្រភេទ B បណ្តាលមកពីការចាក់ថ្នាំបង្ការ ឬ ធ្លាប់កើតជំងឺរលាកថ្លើមប្រភេទ B ។
- តេស្ត HBcAb វិជ្ជមាន អាចធ្លាប់កើតជំងឺរលាកថ្លើមប្រភេទ B ឬជាមួយ HBsAg វិជ្ជមាន ដោយសារកំពុងតែមានការបង្ករោគ ។
- ការធ្វើតេស្តបន្ថែមទៀត មិនទាន់មាននៅប្រទេសកម្ពុជាទេ រួមទាំងតេស្ត HBeAg (active replication និង high infectivity) តេស្ត HBeAb និងតេស្ត HBV DNA Viral Load។ ការធ្វើតេស្តទាំងអស់នេះ អាចជួយក្នុងការវាយតម្លៃពីដំណាក់កាលនៃជំងឺដែលមានសារៈសំខាន់ក្នុងការកំណត់ការចាប់ផ្តើមព្យាបាលជំងឺរលាកថ្លើមប្រភេទ B លើអ្នកជំងឺដែលមានតែជំងឺរលាកថ្លើមប្រភេទ B តែឯកឯង។

## ២២.៤ រោគសញ្ញាគ្លីនិកនៃជំងឺរលាកថ្លើមប្រភេទ B និងប្រវត្តធម្មជាតិនៃជំងឺរលាកថ្លើមប្រភេទ B ស្រួចស្រាវ

**រយៈសម្ងំ:** ១០សប្តាហ៍ (ស្ថិតក្នុងចន្លោះ ៤– ២៦សប្តាហ៍)

រូបភាពទី២២-១   ការវិវត្តិន៍ធម្មជាតិនៃជំងឺរលាកថ្លើមប្រភេទ B ដែលមិនបានព្យាបាល




## ដំណាក់កាលទាំងបួននៃការបង្ករោគដោយជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ [៣៨]

**១. ការទ្រាំទ្រនៃភាពស៊ាំ (Immune tolerance):** មានសកម្មភាព/ឆ្លើយតបតិចតួចរបស់ភាពស៊ាំប្រឆាំងវីរុស។

- ពេលដែលការបង្ករោគជាច្រើនទសវត្សតាំងពីនៅវ័យកុមារ ភាគច្រើននៃជំងឺនេះ មិនបានកើតឡើងទេ ឬបាត់ទៅវិញនៅពេញពេញវ័យ ។
- តេស្ត ALT ធម្មតា តេស្ត HBeAg វិជ្ជមាន តេស្ត viral load (HBV DNA) ខ្ពស់ ។

**២. ការលាងសំអាតដោយភាពស៊ាំ (Immune clearance):**

- ការឡើងចុះនៃ ALT និងកម្រិត HBV DNA
- ៥%-១០% ក្នុងមួយឆ្នាំៗ មាន seroconvert ពី HBeAg → HBe Ab ដែលមានទំនាក់ទំនងនឹងការ ↓↓ HBV VL។

**៣. ការត្រួតពិនិត្យដោយភាពស៊ាំ (Immune control):** វីរុសគ្មានការបំបែកខ្លួន (រយៈពេលសម្ងំ)។

- តេស្ត HBeAg អវិជ្ជមាន តេស្ត HBV DNA ទាប ឬ undetectable តេស្ត ALT ធម្មតា។
- កាលពីគេហៅថា "ភ្នាក់ងារផ្ទុកមេរោគ" ក៏ប៉ុន្តែ វីរុសដែលសម្ងំនេះ អាចនឹងសកម្មឡើងវិញ។

---

[៣៨] សូមមើល គោលការណ៍ណែនាំសម្រាប់ ការបង្ការ, ការថែរក្សា និងការព្យាបាល អ្នកជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ។ អង្គការសុខភាព ពិភពលោក ខែមិនាឆ្នាំ២០១៥។

**៤. ការគេចខ្លួននៃភាពស៊ាំ** (Immune escape): ការមានសកម្មភាពឡើងវិញ។

- ការមានសកម្មភាពឡើងវិញដោយឯកឯងអាចនឹងកើតឡើង ២០%នៃបុគ្គលស្ថិតក្នុងដំណាក់កាល ត្រួតពិនិត្យដោយភាពស៊ាំ ។
- តេស្ត HBeAg អវិជ្ជមាន តេស្ត HBcAb វិជ្ជមាន តេស្ត VL detectable (ជាទូទៅ មានចំនួនមេរោគខ្ពស់)។

**រោគសញ្ញាក្រៅថ្លើមនៃជំងឺរលាកថ្លើមប្រភេទ** B មានការពាក់ព័ន្ធជាមួយចរាចរនៃ Ag-Ab immune complexes → ការរលាក:

- ឈឺសន្លាក់ដៃជើង (Arthralgia) និងរលាកសន្លាក់ដៃជើង(arthritis)
- Purpuric cutaneous lesions (leukocytoclastic vasculitis)
- Glomerulonephritis
- Polyarteritis nodosa (small/medium vessel vasculitis: ស្បែក ភ្នែក តម្រងនោម បេះដូង ប្រព័ន្ធសរសៃប្រសាទកណ្តាល។ល។)

## ២២.៥ ស្ត្រីមានផ្ទៃពោះ និង ជំងឺរលាកថ្លើមប្រភេទ B

- ឆ្លងពីម្តាយទៅកូន: អត្រាឆ្លង ១០% -៩០% (អាស្រ័យតាម DNA VL)
  - ចាក់វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B ចំពោះកុមារក្នុងកំឡុង២៤ម៉ោង ក្រោយពេលកើត នាំឱ្យកាត់បន្ថយការចម្លងបាន ៧០%។
  - បន្ថយការចម្លងរោគបន្ថែមទៀត ក្នុងករណី ដែលស្ត្រីបានទទួលការព្យាបាលដោយឱសថប្រឆាំងវីរុស។
  - គ្មានការណែនាំឱ្យធ្វើការវះកាត់ស្បូនយកកូនទេ(caesarean section) ។
  - គ្មានភស្តុតាងបញ្ជាក់ពីឆ្លងតាមទឹកដោះម្តាយទេ (ទោះបីជា ការយកទឹកដោះម្តាយ ទៅធ្វើ តេស្ត HBsAg និងតេស្ត HBV DNA មានលទ្ធផល detectable ក៏ដោយ) ។
- ស្ត្រីមានផ្ទៃពោះដែលមានជំងឺរលាកថ្លើមរ៉ាំរ៉ៃ ត្រូវតាមដានឱ្យបានជិតដល់ អំពីការវិវត្តន៍ទៅរកជំងឺថ្លើមធ្ងន់ធ្ងរ ។
- តាមដានជំងឺរលាកថ្លើមរហូតដល់ ៦ សប្តាហ៍ ក្រោយពេល សម្រាលកូនរួច (ជាពិសេស ករណីមិនបានព្យាបាលដោយឱសថប្រឆាំងវីរុស) ។

## ២២.៦ ការគ្រប់គ្រងព្យាបាលការបង្ករោគរួមគ្នា រវាងជំងឺរលាកថ្លើមប្រភេទ B និងមេរោគអេដស៍

| |
|---|
| **ការគ្រប់គ្រងព្យាបាលការបង្ករោគរួមគ្នា រវាងជំងឺរលាកថ្លើមប្រភេទ B និងមេរោគអេដស៍**<br>• ចំពោះអ្នកជំងឺដែលកើតតែជំងឺរលាកថ្លើមប្រភេទ B មានតែការព្យាបាលដោយឱសថប្រឆាំងវីរុស នាំឱ្យមានការលាងសំអាតវីរុសដោយភាពស៊ាំ (immune clearance) និងដំណាក់កាលនៃការភាសខ្លួននៃភាពស៊ាំនៃជំងឺរលាកថ្លើមប្រភេទ B នៅពេលដែលមានការប្រឈមមុខនឹងការវិវត្តទៅជំងឺក្រិនថ្លើម និងជំងឺមហារីកថ្លើម ។ អ្នកជំងឺស្ថិតក្នុងដំណាក់កាលណាមួយនៃដំណាក់កាលទាំងពីរនេះ ត្រូវតាមដានក្នុងរយៈពេលពី ៦ –១២ខែ ដោយធ្វើតេស្ត VL HBV និង តេស្តមុខងារថ្លើម ។<br>• លំបាកក្នុងការវាយតម្លៃ ដោយសារ តេស្តទាំងនេះ មិនទាន់អាចធ្វើបាននៅក្នុងប្រទេស ។<br>• ទោះយ៉ាងណា ឱសថប្រឆាំងមេរោគអេដស៍មួយចំនួនដែលយកមកព្យាបាលជំងឺអេដស៍ ក៏មានប្រសិទ្ធភាពប្រឆាំងជំងឺរលាកថ្លើមប្រភេទ B (TDF និង 3TC) ផងដែរ ។ បច្ចុប្បន្ននេះ អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ទាំងអស់នឹងត្រូវចាប់ផ្តើមព្យាបាលដោយឱសថ TDF + 3TC នៅក្នុងរូបមន្តព្យាបាលនៃឱសថប្រឆាំងមេរោគអេដស៍ ហើយការព្យាបាលនេះនឹងគ្របដណ្តប់ការបង្ករោគរួមគ្នារជាមួយជំងឺរលាកថ្លើមប្រភេទ B ដោយស្វ័យប្រវត្តិ ។<br>• វាជាការសំខាន់ណាស់ចំពោះអ្នកជំងឺដែលបង្ករោគរួមគ្នារវាងជំងឺរលាកថ្លើមប្រភេទ B និងជំងឺអេដស៍ទាំងអស់ ត្រូវបានចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជាមួយឱសថ TDF + 3TC ត្រូវតែបន្តការព្យាបាលដោយឱសថទាំងពីរនេះ បើទោះបី មានការផ្លាស់ប្តូរទៅព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ជួរទី២ ក៏ដោយ ។<br>• បើគ្រាន់តែប្រើឱសថតែមួយមុខ ក្នុងចំណោមឱសថទាំងពីរនេះ (ជាពិសេស 3TC) វានឹងវិវត្តន៍ទៅរកភាពស៊ាំជាមួយឱសថ ។ ហេតុនេះ រូបមន្តព្យាបាលជួរទី២ ស្តង់ដារសម្រាប់ព្យាបាលអ្នកជំងឺដែលបានបង្ករោគរួមគ្នា រវាងជំងឺរលាកថ្លើមប្រភេទ B និងជំងឺអេដស៍នេះ គឺ AZT + 3TC + TDF+ ATV/r ។<br>• តេស្ត HBsAg នឹងត្រូវធ្វើ មុនពេលចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ទោះជាយ៉ាងណា វាមិនចាំបាច់ក្នុងការធ្វើតេស្តនេះជាប្រចាំ នៅពេលដែលអ្នកជំងឺទទួលការព្យាបាលដោយរូបមន្តឱសថប្រឆាំងមេរោគអេដស៍ជួរទី១ ដែលមានឱសថ TDF នោះទេ។<br>• ទោះបីជាយ៉ាងណា ការធ្វើតេស្ត HBsAg គឺមានសារៈសំខាន់ បើសិនជាមានការពិចារណាក្នុងការផ្លាស់ប្តូររូបមន្តព្យាបាលទៅជួរទី២ និងលេចចេញរោគសញ្ញាគ្លីនិកដែលបញ្ជាក់ពីភាពមិនធម្មតានៃលទ្ធផលតេស្តមុខងារថ្លើម ។<br>• សូមអានជំពូកទី២៤ជំងឺថ្លើមរ៉ាំរ៉ៃ។ |

# ជំពូក ២៣. ជំងឺរលាកថ្លើមប្រភេទ C

ជំងឺរលាកថ្លើមប្រភេទ C (HCV) បណ្តាលមកពីវីរុស RNA ស្ថិតនៅក្នុងគ្រួសារនៃវីរុស flavivirus។ HCV genotypes ១–៦ លេចចេញនូវរោគសញ្ញាគ្លីនិកខុសគ្នា និងការឆ្លើយតបទៅនឹងការព្យាបាល ក៏ខុសគ្នាដែរ ។

## ២៣.១ ទំនាក់ទំនងរវាងជំងឺអេដស៍ និង ជំងឺរលាកថ្លើមប្រភេទ C

- ជំងឺរលាកថ្លើមប្រភេទ C ភាគច្រើនឆ្លងតាម ការចាក់ទម្លុះស្បែក និងជាញឹកញាប់កើតឡើង ចំពោះអ្នកចាក់គ្រឿងញៀន ។
- ទោះយ៉ាងណា ហានិភ័យនៃការឆ្លងតាមផ្លូវភេទ និងឆ្លងពេលសម្រាលកូន គឺមានកម្រិតខ្ពស់ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ជាជាងអ្នកគ្មានផ្ទុកមេរោគអេដស៍ ។
- ការបង្ករោគរួមគ្នា រវាងជំងឺរលាកថ្លើមប្រភេទ C និងមេរោគអេដស៍ បណ្តាលឱ្យមានហានិភ័យខ្ពស់នៃការវិវត្តន៍ពីជំងឺរលាកថ្លើមប្រភេទ C ទៅជំងឺក្រិនថ្លើម និង ជំងឺមហារីកកោសិកាថ្លើម ។
- ជំងឺរលាកថ្លើមប្រភេទ C បង្កើនហានិភ័យនៃការពុលថ្លើមជាមួយឱសថប្រឆាំងមេរោគអេដស៍ និងឱសថដទៃទៀត ។

## ២៣.២ ការចម្លងនៃ ជំងឺរលាកថ្លើមប្រភេទ C និងការបង្ការការចម្លង

- គ្មានវ៉ាក់សាំងសម្រាប់ចាក់បង្ការជំងឺរលាកថ្លើមប្រភេទ C ទេ ហើយការបង្ការការចម្លង គឺត្រូវពឹងផ្អែកលើការអនុវត្តន៍វិធានការបង្ការជាសកល ការពិនិត្យឈាមនៅក្នុងគ្រឹះស្ថានសុខាភិបាល យុទ្ធសាស្ត្រកាត់បន្ថយគ្រោះថ្នាក់នៃគ្រឿងញៀន ដោយផ្តោតលើការចាក់គ្រឿងញៀន ដូចជាការផ្លាស់ប្តូរម្ជុល សឺរ៉ាំង និងសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ ដូចជា មិនត្រូវប្រើប្រាស់ឡាមកោរពុកមាត់ ឬ ច្រាសដុសធ្មេញរួមគ្នា ។
- ការចម្លងតាមផ្លូវភេទ គឺជាករណីកំរ ប៉ុន្តែភាគច្រើននៃអ្នកដែលការឆ្លងជំងឺទាំងពីរនេះគឺបណ្តាល មកពីការប៉ះពាល់ឈាម ហើយត្រូវអប់រំឱ្យប្រើប្រាស់ស្រោមអនាម័យ ជាប់ជានិច្ច ។
- ការឆ្លងជុំវិញពេលសម្រាលកូន គឺ ~៥% ចំពោះស្ត្រីដែលគ្មានមេរោគអេដស៍។

## ២៣.៣ ការវិវត្តន៍ធម្មជាតិ និងរោគសញ្ញាគ្លីនិក

**រយៈពេលសម្ងំនៃ HCV:** ៧សប្តាហ៍ (ចន្លោះពី ២ –២១សប្តាហ៍) ។

រូបភាពទី២៣-១ ការវិវត្តន៍ធម្មជាតិនៃជំងឺរលាកថ្លើមប្រភេទ C ដែលមិនបានព្យាបាល




ការបង្ករោគរលាកថ្លើមប្រភេទ C ស្រួចស្រាវ ជាញឹកញាប់គ្មានរោគសញ្ញា និងជំងឺរលាកថ្លើមប្រភេទ C រ៉ាំរ៉ៃ ជាញឹកញាប់នៅតែគ្មានរោគសញ្ញាអស់រយៈពេលជាច្រើនឆ្នាំ។ បន្ទាប់ពី ពីឆ្លងមេរោគរលាកថ្លើមប្រភេទ C រ៉ាំរ៉ៃជាច្រើនឆ្នាំ អ្នកជំងឺអាចវិវត្តន៍ទៅជំងឺក្រិនថ្លើម មហារីកថ្លើម និងថ្លើមចុះខ្សោយ។ ការលេចចេញរោគសញ្ញានៅក្រៅថ្លើមនៃការបង្ករោគរលាកថ្លើមប្រភេទ C រ៉ាំរ៉ៃ រួមមាន រោគសញ្ញាលើស្បែក ដូចជា រោគសើស្បែក porphyria cutanea tarda និងរមាស់ vasculitic rashes បានផ្សារភ្ជាប់ជាមួយ cryoglobulinaemia ។ លេចចេញផងដែរនូវ rheumatological conditions និងការហូរឈាមមិនប្រក្រតី និង វិបត្តិក្រពេញទីរ៉ូអ៊ីត ។

## ២៣.៤ រោគវិនិច្ឆ័យជំងឺរលាកថ្លើមប្រភេទ C

- អង់ទីករជំងឺរលាកថ្លើមប្រភេទ C នៅតែ វិជ្ជមាន នៅគ្រប់អ្នកជំងឺដែលបង្ករោគដោយជំងឺរលាកថ្លើមប្រភេទ C ទាំងអស់ បើទោះជា វីរុសនេះត្រូវបានជម្រះដោយឯកឯង ឬ ដោយសារការព្យាបាលក៏ដោយ។
- ការធ្វើតេស្ត RNA នៃជំងឺរលាកថ្លើមប្រភេទ C គឺជាការចាំបាច់ ដើម្បីធ្វើរោគវិនិច្ឆ័យជំងឺរលាកថ្លើមប្រភេទ C ដែលកំពុងបង្ករោគរ៉ាំរ៉ៃ និងដើម្បីតាមដានការព្យាបាល ។

## ២៣.៥ ការគ្រប់គ្រងព្យាបាល ការបង្ករោគរួមគ្នា រវាងជំងឺរលាកថ្លើមប្រភេទ C និង ជំងឺអេដស៍

**ការគ្រប់គ្រងព្យាបាល ការបង្ករោគរួមគ្នា រវាងជំងឺរលាកថ្លើមប្រភេទ C និងជំងឺអេដស៍**

- ការគ្រប់គ្រងព្យាបាលជំងឺរលាកថ្លើមប្រភេទ C ធ្លាប់បានទទួលការព្យាបាលជាមួយឱសថ interferon ជាមូលដ្ឋាន ដែលមានការលំបាកយ៉ាងខ្លាំងក្នុងការទ្រាំទ្រ និងប្រសិទ្ធភាពនៃការព្យាបាលនៅមានកម្រិត ។
- ការរកឃើញរូបមន្តព្យាបាលតាមស្តង់ដារថ្មី គឺជាភ្នាក់ងារប្រឆាំងវីរុសរលាកថ្លើមប្រភេទCថ្មីដែលគេស្គាល់ថា ជាភ្នាក់ងារដែលមានសកម្មភាពប្រឆាំងវីរុសដោយផ្ទាល់ (DAA) និងមានប្រសិទ្ធភាពខ្ពស់ ភាពទ្រាំទ្របានល្អ រួមផ្សំទាំងការព្យាបាលដោយថ្នាំលេប រយៈពេលព្យាបាលពី ៨-២៤ សប្តាហ៍ ។
- ភ្នាក់ងារដែលមានសកម្មភាពប្រឆាំងវីរុសដោយផ្ទាល់(DAA)នេះ បានកំណត់គោលដៅប្រឆាំង genotype ជាក់លាក់ ឬប្រឆាំង genotype Pan ហើយភ្នាក់ងារនេះមានក្នុងឱសថរួមបញ្ចូលកម្រិតដូសគ្នា ផងដែរ។
- រូបមន្តព្យាបាលថ្មីមានប្រសិទ្ធភាពខ្ពស់ និងមានភាពទ្រាំទ្របានល្អ ក្នុងការព្យាបាលការបង្ករោគរួមគ្នា រវាងជំងឺអេដស៍ និងជំងឺរលាកថ្លើមប្រភេទ C ។
- ភ្នាក់ងារដែលមានសកម្មភាពប្រឆាំងវីរុសដោយផ្ទាល់(DAA) អាចរកបាននៅទូទាំងពិភពលោក រួមទាំង protease inhibitors Simepravir និង Paritaprevir NS5A inhibitors នោះ Ledipasvir Ombitasvir Daclatasvir និង NS5B inhibitors Sofosbuvir និង dasabuvir។
- ប្រទេសកម្ពុជា នឹងចាប់ផ្តើមអនុវត្តន៍គម្រោងសាកល្បងនៅខែមិថុនា ឆ្នាំ២០១៦ អំពីការធ្វើរោគវិនិច្ឆ័យ និង ព្យាបាលជំងឺរលាកថ្លើមប្រភេទ C ក្នុងចំណោមអ្នកជំងឺអេដស៍ដែលបង្ករោគរួមគ្នាជាមួយនឹងជំងឺរលាកថ្លើមប្រភេទ C ។ គេរំពឹងទុកថា ប្រទេសកម្ពុជា អាចនឹងទទួលបានឱសថ DAA និងតេស្ត viral load សម្រាប់តាមដានការព្យាបាលជំងឺរលាកថ្លើមប្រភេទ C ។
- គំនូសបំព្រួញនៃការធ្វើរោគវិនិច្ឆ័យ និងការវាយតម្លៃជំងឺរលាកថ្លើមប្រភេទ C បរិយាយនៅជំពូកទី៥១.ឧបសម្ព័ន្ធ: គំនូសបំព្រួញនៃការធ្វើរោគវិនិច្ឆ័យនៃជំងឺរលាកថ្លើមប្រភេទ C។
- គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងគ្លីនិកនៃការបង្ករោគរួមគ្នា រវាងជំងឺអេដស៍ និង ជំងឺរលាកថ្លើមប្រភេទ C ដោយប្រើប្រាស់ឱសថ DAA នឹងត្រូវបានអនុម័ត ហើយជាឧបសម្ព័ន្ធនៃគោលការណ៍នេះ ។
- សូមអានជំពូកទី២៤ ជំងឺថ្លើមពុំរ៉ៃ។

# ជំពូក ២៤. ជំងឺថ្លើមរ៉ាំរ៉ៃ

ការវាយតម្លៃនិងការគ្រប់គ្រងព្យាបាលជំងឺថ្លើមរ៉ាំរ៉ៃ គឺដូចគ្នា ទោះបីជា ជំងឺថ្លើមនោះបង្កដោយជំងឺរលាកថ្លើមប្រភេទ B ប្រភេទ C ឬ ដោយសារការសេពគ្រឿងស្រវឹង ក៏ដោយ ។

## ២៤.១ ការវាយតម្លៃរោគសញ្ញាគ្លីនិក

- ការស្រង់ប្រវត្តិជំងឺ: រោគសញ្ញាជំងឺថ្លើមស្រួចស្រាវនិងរ៉ាំរ៉ៃ និងលេចចេញរោគសញ្ញាក្រៅថ្លើម ។
- ការពិនិត្យរោគសញ្ញាគ្លីនិក: រោគសញ្ញាជំងឺថ្លើមរ៉ាំរ៉ៃ + ខ្សោយថ្លើម ។

## ២៤.២ ការវាយតម្លៃតេស្តអមវេជ្ជសាស្ត្រ

សម្គាល់នៃភាពធ្ងន់ធ្ងរជំងឺថ្លើមរ៉ាំរ៉ៃ

- តេស្ត ALT:
  - ជាប់ទាក់ទងគ្នាមួយចំនួន ជាមួយការរលាក
  - មិនសូវជាប់ទាក់ទងគ្នា ជាមួយជំងឺ fibrosis
- សមាមាត្របញ្ច្រាស់គ្នានៃ AST/ALT ratio (AST > ALT)
- ផ្លាកែត ចុះទាប (សម្ពាធ portal កើនឡើង + អណ្តើករីកធំ)
- អាល់ប៊ុយមីនចុះទាប (មុខងារសំយោគ)
- ពេលវេលា prothrombin កើនឡើង (PT) (អនុគមន៍សំយោគ)
- direct bilirubin ឡើងខ្ពស់ (មុខងារ secretory)
- របួសថ្លើមធ្ងន់ធ្ងរ អាចចង្អុលបង្ហាញ ប្រសិនបើ ALT ធ្លាក់ចុះ និង bilirubin កើនឡើង។
- ខណៈដែលការធ្វើ biopsy ត្រូវបានធ្វើដើម្បីវាយតម្លៃពីកម្រិត hepatic fibrosis ការធ្វើតេស្តដោយមិនចាំបាច់ចាក់ទម្លុះស្បែក រួមមាន តេស្ត Elastography (Fibro-ស្កេន) បានបំពេញតួនាទីនេះកាន់តែច្រើនឡើង ។

## ២៤.៣ ការគ្រប់គ្រងព្យាបាលជំងឺថ្លើមរ៉ាំរ៉ៃ

**តារាងទី២៤-១ ការគ្រប់គ្រងព្យាបាលផលវិបាកជំងឺថ្លើមរ៉ាំរ៉ៃ**

| ការគ្រប់គ្រងព្យាបាលទូទៅនៃផលវិបាកជំងឺរលាកថ្លើមរ៉ាំរ៉ៃ បណ្តាលមកពីមូលហេតុផ្សេងៗ (រួមមាន ជំងឺរលាកថ្លើមប្រភេទ B ប្រភេទ C និង សេពគ្រឿងស្រវឹង) |
|---|
| • ចៀសវាងប្រើឱសថពុលថ្លើម (ឧ. NSAIDS និងឱសថបុរាណ) |
| • ឈប់ ឬ សេពគ្រឿងស្រវឹងក្នុងកម្រិតអប្បបរិមា |
| • របបអាហារផ្តល់សុខភាព: អំបិលតិច + ខ្លាញ់ឆ្អែត បរិមាណប្រូតេអ៊ីនសមស្រប (១–១,៥ ក្រ/គ.ក្រ ទម្ងន់ខ្លួន/ថ្ងៃ) បន្លែ ផ្លែឈើ សូមអាន តារាងទី ២-៥ អនុសាសន៍សម្រាប់បង្ការ និង |

ការគ្រប់គ្រងព្យាបាលជំងឺមិនឆ្លង។

- ព្យាបាលមូលហេតុ (ជំងឺរលាកថ្លើមប្រភេទ B ប្រភេទ C) ។

**ការគ្រប់គ្រងព្យាបាលជំងឺ Ascites**

- កំណត់របបអាហារមានជាតិអំបិល និងទឹក ឧ.ផឹកទឹកក្នុងកម្រិត ១- ១,៥ លីត្រ/ថ្ងៃ
- សម្រាកស្ងៀម (លើគ្រែ) បើលើសជាតិទឹក
- ប្រើឱសថ Diuretic: ជ្រើសរើស spironolactone កម្រិតដូស: ២៥–២០០ម.ក្រ /ថ្ងៃ
- +/- furosemide កម្រិតដូសទាប (តម្រូវឱ្យបន្ថែម $K^+$)
- តាមដានការព្យាបាលដោយប្រុងប្រយ័ត្ន:
  - រោគសញ្ញាគ្លីនិក: សម្ពាធឈាម (ពេលសម្រាក + ពេលឈរ) ជីពចរ ទម្ងន់ខ្លួន ការហើមនៅផ្នែកចុង (peripheral oedema) សរសៃឈាមបេះដូង (CVS) ទាចទឹក
  - ពិនិត្យអមគ្លីនិក: $K^+$ $Na^+$ Creatinine albumin
- បង្ហូរទឹក ascites ចេញ ប្រសិនបើចាំបាច់
- ជាញឹកញាប់ ↑ extravascular volume ប៉ុន្តែ ↓ intravascular volume ដូច្នេះ គឺមានការប្រឈមមុខនឹងចុះខ្សោយតម្រងនោម ជាពិសេស នៅពេលបញ្ចុះទឹកនោម (diuresis) និងបង្ហូរទឹក ascites ចេញច្រើនពេក ។

**ការគ្រប់គ្រងព្យាបាលជំងឺរលាកស្រោមពោះបង្កដោយបាក់តេរីដោយឯកឯង (Spontaneous bacterial peritonitis (SBP)**

- ជាទូទៅទាក់ទងនឹងការខូចមុខងារថ្លើមធ្ងន់ធ្ងរ
- សង្ស័យ ascites គឺ ↑គ្រុនក្តៅ ឈឺពោះ និង tenderness encephalopathy
- ការព្យាបាល: ascitic tap - WCC > ៥០០/ម.ម៣ +/ឬ neutrophil > ២៥០/ម.ម៣
- មេរោគរោគបង្កហេតុ ជាញឹកញាប់គឺ ពពួក enteric Gram-negative bacilli ឧ. E coli + ប្រសិនបើព្យាបាលបង្ការ គឺបណ្តាលមកពីពពួក streptococcal ឬ enterococcus ។
- ការព្យាបាល: ceftriaxone ១g ចាក់ IVI រាល់ថ្ងៃ + បើទទួលការព្យាបាលបង្ការដោយ antibiotic ត្រូវបន្ថែម amoxicillin/ ampicillin ១ក្រ ចាក់ IV រាល់ ៦ម៉ោង/ម្តង ។
- ព្យាបាលបង្ការដោយ cotrimoxazole ១ DS លេបរាល់ថ្ងៃ បើ:
  - ហូរឈាមតាមបំពង់អាហារ (GIT bleeding)
  - ascitic protein ទាប (< ១០ក្រ /ល)
  - ធ្លាប់មាន episode of SBP ។

**ការគ្រប់គ្រងព្យាបាលជំងឺ portal hypertension**

- ជារួម អ្នកជំងឺក្រិនថ្លើមទាំងអស់ ត្រូវធ្វើ endoscopy ដើម្បីពិនិត្យរកមើល varices និងប្រសិនជាមាន varices ត្រូវ:
- ព្យាបាល oesophageal varices (ឧ. ចងភ្ជិត (banding) ឬ sclerosis)
- Non selective beta-blocking agents ដើម្បីបន្ថយ portal pressure (propranolol)។

| ការគ្រប់គ្រងព្យាបាលជំងឺ portal systemic encephalopathy |
| --- |
| • ពិនិត្យរកមើលមូលហេតុ: ជំងឺមហារីកថ្លើម ជំងឺ SBP ជំងឺខ្សោយតម្រងនោម ។ល។<br>• ប្រសិនជាធ្ងន់ធ្ងរ (កម្រិតទី៣ ឬ ទី៤ )<br>  • បញ្ឈប់ការផ្តល់ជាតិ protein រយៈពេល ២៤–២៨ ម៉ោង បន្ទាប់មកបង្កើនបន្តិចម្តងៗ រហូតដល់កម្រិតធម្មតាវិញ ។<br>  • ព្យាបាលសាកស្បូងប្រឆាំង sepsis ដោយប្រើប្រាស់ឱសថ ceftriaxone ១ក្រាម ចាក់ IVI /រាល់ថ្ងៃ។<br>• រក្សាការបំពេញជាតិទឹក និង electrolyte ឱ្យមានតុល្យភាព។<br>• Lactulose ដើម្បីលាងសម្អាតពោះវៀនធំ និងការប្រែប្រួលមេតាបូលីសជាតិអាម៉ូនីញាក់ និង ការសាយភាយ ។<br>• ប្រើប្រាស់កម្រិតដូស ឱ្យអ្នកជំងឺបន្ទោរបង់លាមកទន់ ២ដង/ថ្ងៃ និងបន្តប្រើប្រាស់កម្រិតដូសនេះក្នុងរយៈពេលយូរ។ |

# លក្ខខណ្ឌនៃជំងឺក្រពះ - ពោះវៀន

# ជំពូក ២៥. ជំងឺមាត់ធ្មេញ

- សុខភាពមាត់ធ្មេញ គឺមានសារៈសំខាន់ណាស់ដើម្បីឱ្យអ្នកជំងឺទទួលទានបានគ្រប់គ្រាន់នូវអាហារូបត្ថម្ភ មានគុណភាពនៃជីវិត និងការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់។
- មាត់គឺជាកន្លែងដែលបង្ករោគជាញឹកញាប់ ចំពោះអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ទៅតាមដំណាក់កាលគ្លីនិក ៖ ចំពោះអ្នកជំងឺស្ថិតក្នុងដំណាក់កាលទី៣ នៃ WHO: ជំងឺ candidiasis នៅមាត់ និងជំងឺ oral leukoplakia (OHL) និង អ្នកជំងឺដំណាក់កាលទី៤ នៃ WHO រួមមាន ជំងឺ candidiasis នៅបំពង់អាហារ ជំងឺ HSV> ១ខែ និងជំងឺ KS មាត់ ។

អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ត្រូវផ្តល់យោបល់ឱ្យអនាម័យមាត់ធ្មេញ ដូចខាងក្រោម៖

- ដុសធ្មេញទៀងទាត់(មិនត្រូវប្រើប្រាស់ច្រាសដុសធ្មេញរួមគ្នា)និងប្រើប្រាស់អំបោះអនាម័យធ្មេញ។
- លាងសំអាតមាត់ ដោយ (ប្រើសូលុយស្យុងដោយលាយ ទឹកសូដាមួយស្លាបព្រាកាហ្វេ អំបិលមួយស្លាបព្រាការហ្វេ និងទឹកក្តៅអ៊ុនៗ ២៥០ម.ល) ដើម្បីជួយបន្ធូរបន្ថយរោគសញ្ញា និងអនាម័យមាត់ធ្មេញ។
- ការពិនិត្យធ្មេញនៅពេលមានជំងឺអញ្ចាញធ្មេញ ឬ ធ្មេញបែកប្រហោង។

| **ជំងឺមាត់ធ្មេញលើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍** |
|---|
| **ជំងឺរលាកអញ្ចាញធ្មេញ (Gingivitis) និងបង្ករោគធ្មេញ**<br>ជំងឺរលាកអញ្ចាញធ្មេញ អាចបណ្តាលឱ្យបាក់ធ្មេញ និងឈឺចាប់ខ្លាំង ។<br>ពិនិត្យរោគសញ្ញា រកឃើញ ដង្ហើមស្អុយខ្លាំង អញ្ចាញធ្មេញពណ៌ក្រហម និងរលួយ ។<br>គ្រប់គ្រងព្យាបាល: លាងសំអាតមាត់ + លេប metronidazole ៥០០ ម.ក្រ ៣ដង/ថ្ងៃ ឬលេប clindamycin ៤៥០ម.ក្រ ៣ដង/ថ្ងៃ រយៈពេល៧ថ្ងៃ ឬលេប amoxicillin – clavulanate ៨៧៥/១២៥ម.ក្រ រាល់ ១២ម៉ោង/ម្តង ។ បូសធ្មេញ ត្រូវដោះបើកផ្លូវបង្ហូរខ្ទុះចេញ និងបង្ករោគបណ្តាលឱ្យរលួយធ្ងន់ធ្ងរ (Vincent's Angina, Norma, Cancrum oris) តម្រូវឱ្យធ្វើការវះកាត់យកជាលិការលួយចេញជាបន្ទាន់ ។ |
| **ជំងឺ candidiasis នៅមាត់:** មានជំងឺ candidiasis នៅមាត់ជានិច្ចជាកាល= ដំណាក់កាលគ្លីនិកទី៣នៃWHO<br>**រោគសញ្ញាគ្លីនិក**<br>រោគសញ្ញាគ្លីនិក: ឈឺចាប់ ពិបាកបរិភោគអាហារ<br>ការពិនិត្យ: មានស្នាមបន្ទះពណ៌សគ្រប់កន្លែងក្នុងមាត់ ហើយកន្លែងខ្លះរលាត់ចេញ (អាចចេញឈាម) ។ ការឡើងប្រាំងអណ្តាតតែឯកឯង ជាទូទៅ មិនមែនបណ្តាលមកពីការបង្ករោគដោយ candida ទេ ដូច្នេះត្រូវពិនិត្យមើលក្រអូមមាត់ខាងលើ និងជុំវិញអញ្ចាញធ្មេញ និងពិនិត្យមើលផងដែរនូវភាព "atrophic" thrush ដោយមានការឡើងពណ៌ក្រហម ប៉ុន្តែឡើង little plaque និង មានangular stomatitis ផងដែរ ។<br>**រោគវិនិច្ឆ័យ:** ជាទូទៅ ទាក់ទងនឹងប្រវត្តិរោគសញ្ញាគ្លីនិក និង ការលេចចេញរោគសញ្ញាគ្លីនិក។ បើមានលទ្ធភាព ត្រូវពិនិត្យ fungal microscopy បណ្តុះមេរោគ និងធ្វើតេស្ត sensitivity ករណី រោគ |

សញ្ញាគ្លីនិកមានភាពមិនច្បាស់លាស់(atypical) ឬ ការព្យាបាលគ្មានប្រសិទ្ធភាព។

**ការព្យាបាលស្តង់ដា (៧ថ្ងៃ)**

Local application of gentian violet, ១% aqueous solution ២ដង/ថ្ងៃ ឬ

Miconazole ២% gel ឬ gum patch ១ដង/ថ្ងៃ ឬ

Nystatin pessary, ១០០ ០០០ IU, លេប៤ដង/ថ្ងៃ ឬ

Nystatin oral solution ១–២ ម.ល លាបបង្វិលជុំវិញមាត់ ៥ដង/ថ្ងៃ ឬ

Nystatin គ្រាប់ ឬ amphotericin lozenges sucked ៤ដង/ថ្ងៃ។

**ការព្យាបាលជម្រើស**

Fluconazole ១០០mg លេបរាល់ថ្ងៃ រយៈពេល៧ថ្ងៃ ក្នុងករណីធ្ងន់ធ្ងរ/មិនឆ្លើយតបទៅនឹងការព្យាបាលដោយការលាបថ្នាំ) ។

---

**ជំងឺ Oral hairy Leukoplakia (OHL)**

បណ្តាលមកពីវីរុស Epstein –Barr កើតឡើងចំពោះអ្នកជំងឺអេដស៍ដែលមានភាពស៊ាំចុះខ្សោយខ្លាំង។ លេចចេញរោគសញ្ញាជាក់លាក់ រៀងជាបន្ទាត់ត្រង់ពណ៌សនៅគែមអណ្តាត។ មិនចាំបាច់ព្យាបាលទេ វានឹងបាត់ទៅវិញនៅពេលអ្នកជំងឺបានទទួលការព្យាបាលដោយឱសថប្រឆាំង មេរោគអេដស៍ ។

---

**ជំងឺ Kaposi's sarcoma** (ករណីកំរនៅកម្ពុជា)

ហើមពណ៌ស្វាយលើក្រអូមមាត់ខាងលើ ឬគែមអញ្ចាញធ្មេញ អាចជាការបង្ហាញពីការពាក់ព័ន្ធជាមួយជំងឺសួត ឬជំងឺប្រដាប់រំលាយអាហារ ។ ការគ្រប់គ្រងព្យាបាល រួមបញ្ចូលទាំងការចាប់ផ្តើមដោយឱសថប្រឆាំងមេរោគអេដស៍ភ្លាម និងបញ្ជូនអ្នកជំងឺទៅជួបគ្រូពេទ្យជំនាញ ដើម្បីពិចារណាអំពីការព្យាបាលដោយ chemo /ការព្យាបាលដោយវិទ្យុសកម្ម ។

---

**ជំងឺ Angular stomatis**

បណ្តាលមកពី candida ឬ bacteria លេចចេញរោគសញ្ញា ដូចជា ការឈឺចាប់នៅជ្រុងមួយនៃ មាត់។ ការគ្រប់គ្រងព្យាបាល: antifungal cream ឬ gel ២ដង/ថ្ងៃ រយៈពេល១០ថ្ងៃ និង/ឬ topical antibacterial

---

**ជំបៅមាត់ (Oral ulcers)** បណ្តាលមក **HSV**: ដំបៅរាក់តែឈឺចាប់ខ្លាំង ជាញឹកញាប់មានច្រើន។ បើដំបៅរីករាលដាល/ត្រូវព្យាបាលសារឡើងវិញជាមួយឱសថ acyclovir ៤០០ ម.ក្រ ៣ដង/ថ្ងៃ។

---

**ជំងឺ Syphilis chancre** ជាទូទៅមិនឈឺចាប់។ ពិនិត្យតេស្ត RPR ប៉ុន្តែវាត្រូវការពេលវេលា មុននឹងកើនឡើង។ ដូច្នេះ បើវាមានភាពស៊ីសង្វាក់គ្នា ត្រូវព្យាបាលជាមួយឱសថ Benzathine Penicillin ២,៤ million units ចាក់ IMI តែម្តងគត់ (អាចព្យាបាលជំនួសដោយ doxycycline ១០០ម.ក្រ លេប២ដង/ថ្ងៃ រយៈពេល១៤ថ្ងៃ)។

**ជំងឺ Syphilis mucous patches:** អាចមើលឃើញក្នុងមាត់អ្នកជំងឺស្វាយដំណាក់កាលទី២ (secondary syphilis) តេស្ត RPR ឡើងខ្ពស់ ត្រូវព្យាបាលដូចគ្នានឹងការព្យាបាលជំងឺស្វាយដំណាក់កាលទី១ ដែរ។

---

**ជំបៅមាត់: Apthous ulcers** – ជាញឹកញាប់ឈឺចាប់ខ្លាំង មិនដឹងមូលហេតុ។

**ការគ្រប់គ្រងព្យាបាល:** លាងសម្អាតមាត់ធ្មេញ និងប្រើប្រាស់ឱសថ steroid (Prednisolone ៥ ម.ក្រ កិនកំទេច និងរោយពីលើកន្លែងរបួស ។ ម្តងម្កាល ឱ្យលេប steroids បើអ្នកជំងឺធ្ងន់ធ្ងរ និងមានការប៉ះពាល់លើបំពង់អាហារ ។

# ជំពូក ២៦. ឈឺចាប់ពេលលេបអាហារ (Odynophagia)

**Odynophagia** គឺជាការឈឺចាប់ក្នុងបំពង់ករពេលលេប និងឈឺចាប់នៅដំបន់ក្រោយសន្ទះទ្រូងពេលលេបអាហារចូល។
**Dysphagia** : ពិបាកលេប។

ឈឺចាប់ពេលលេប និងការពិបាកលេប បណ្តាលឱ្យមានផលប៉ះពាល់ ទាំងលើសមត្ថភាពអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ដើម្បីរក្សានូវការទទួលទានអាហារូបត្ថម្ភគ្រប់គ្រាន់ និងការលេបថ្នាំឱ្យបានត្រឹមត្រូវទៀងទាត់ និងជាប់លាប់។
បណ្តាលមកពីជំងឺ Oesophageal Candida និងជំងឺ CMV ជំងឺរលាកបំពង់អាហារត្រូវចាត់ចូលក្នុងដំណាក់កាលគ្លីនិកទី៤ នៃ WHO។

## ២៦.១ រោគសញ្ញាគ្លីនិក និងការធ្វើរោគវិនិច្ឆ័យ

**ជំងឺរលាកបំពង់អាហារបង្កដោយ** Candida (Candida esophagitis): គឺជាមូលហេតុញឹកញាប់បំផុតនៃការឈឺចាប់ពេលលេប (odynophagia) និងការពិបាកលេប។ រោគវិនិច្ឆ័យត្រូវបានធ្វើឡើងលើមូលដ្ឋានប្រវត្តិនៃការឈឺចាប់ពេលលេប និងការពិបាកលេប ។ អ្នកជំងឺមានចំនួនកោសិកា CD4 <២០០ ហើយស្ទើរតែទាំងអស់នៃអ្នកជំងឺ គឺមានផ្សិតនៅក្នុងមាត់ (Oral candidiasis) ដែលអាចមើលឃើញ ។

**ជំងឺរលាកបំពង់អាហារបង្កដោយ** Herpes (Herpes esophagitis): ជាញឹកញាប់បានផ្សារភ្ជាប់ជាមួយនឹងដំបៅមាត់បង្កដោយ herpetic (គ្រាប់ដុំពកឈឺចាប់) រាលដាលទៅអញ្ចាញធ្មេញ (gingiva) ឬដំបៅនៅស្បែកបង្កដោយ herpes នៅតាមគែមមាត់ ។

**ជំងឺ** CMV: អ្នកជំងឺដែលមានរោគសញ្ញាប្រព័ន្ធរួមមាន គ្រុនក្តៅ ចង្អោរ ក្អួត ឈឺពោះ ថ្លើមរីកធំ(hepatomegaly) ឬលាមកលាយឈាមកើតឡើងនៅពេលថយចុះភាពស៊ាំខ្លាំង(CD4<៥០កោសិកា/ម.m$^3$) ។

**ជំងឺ** Reflux-esophagitis គឺជាទូទៅកើតឡើងចំពោះអ្នកជំងឺដែលមានចំនួនកោសិកា CD4 ខ្ពស់ជាងទំនងនឹងធ្វើរោគវិនិច្ឆ័យជាងគេបំផុត: រោគសញ្ញារួមមាន ការឈឺចាប់ក្តៅក្រោយសន្ទះទ្រូងឆ្លាស់គ្នា (intermittent retrosternal burning pain) មាន/គ្មាន ការភើរ (regurgitation) អាចមានការឈឺចាប់ជាប់ជានិច្ច ឬ ការពិបាកលេប គឺជាករណីកំរ ។
មូលហេតុផ្សេងទៀត: ដំបៅ Aphthous ជំងឺ Kaposi sarcoma។ ប៉ះពាល់ដល់ប្រព័ន្ធប្រសា ឧ. ដោយសារមានជំងឺដាច់សរសៃឈាមខួរក្បាល (stroke)ឬជំងឺខួរក្បាលបង្កដោយមេរោគអេដស៍(HIV encephalopathy) អាចបង្កឱ្យមានការលំបាក (ប៉ុន្តែគ្មានការឈឺចាប់) នៅពេលលេប។

## ២៦.២ ការព្យាបាលជំងឺរលាកបំពង់អាហារ

- ជំងឺ Candida: Fluconazole ២០០ ម.ក្រ លេបរាល់ថ្ងៃ រយៈពេល១៤ថ្ងៃ ។
- ជំងឺ HSV: Acyclovir ៨០០ ម.ក្រ ៣ដង/ថ្ងៃ លេបរាល់ថ្ងៃ រយៈពេល១៤ថ្ងៃ ។

## ២៦.៣ ការគ្រប់គ្រងព្យាបាល

- ចំពោះអ្នកជំងឺដែលទំនងក្នុងការធ្វើរោគវិនិច្ឆ័យថា ជំងឺ candidiasis (ផ្អែកលើរោគសញ្ញាជាក់លាក់ CD4> ២០០កោសិកា/ម.ម$^{៣}$ និងផ្សិត candidiasis នៅមាត់): ត្រូវព្យាបាលជំងឺ candidiasis និងតាមដានការវិវត្តជំងឺរយៈពេល៧ថ្ងៃ។
- ប្រសិនបើ គ្មានការឆ្លើយតបនឹងការព្យាបាលទេ អាចព្យាបាលជំងឺ HSV សាកល្បង។
- ប្រសិនបើ អ្នកជំងឺមានដំបៅមាត់បង្កដោយ herpes ត្រូវព្យាបាលជំងឺ HSV មុនគេ បន្ទាប់មកព្យាបាលជំងឺ Candida ។ ប្រសិនបើ ការឆ្លើយតបនឹងការព្យាបាលមិនបានពេញលេញទេ (ជំងឺទាំងពីរក៏អាចបង្ករោគក្នុងពេលជាមួយគ្នាដែរ) ។
- ការកើរ បណ្តាលមកពីជំងឺរលាកបំពង់អាហារ (Reflux esophagitis): ព្យាបាលសាកល្បងជាមួយឱសថ proton pump inhibitor ឬ ឱសថ Ranitidine។
- ទោះបីជាយ៉ាងណា ពិនិត្យមើលអន្តរកម្មឱសថ[៣៩] : ឱសថ omeprazole ត្រូវបានដឹងថា មាន contraindicated ជាមួយឱសថ ATV/r និង cimetidine ឬ Ranitidine គួរតែចៀសវាង ប្រសិនបើអាចធ្វើទៅបាន ដោយសារវាបន្ថយការស្រូបចូលឱសថ ATV/r ។ ប្រសិនបើ មិនអាចចៀសវាងបានទេ ត្រូវប្រើឱសថ Ranitidine/cimetidine ក្នុងកម្រិតដូសទាបបំផុត និងរយៈលេបឆ្ងាយពីការលេបឱសថ ATZ /r តាមដែលអាចធ្វើបាន ។
- ប្រសិនបើ នៅតែគ្មានការឆ្លើយតបនឹងការព្យាបាលទេ បញ្ជូនអ្នកជំងឺទៅពិនិត្យ endoscop ។

[៣៩] http://www.hiv-druginteractions.org/

រូបភាពទី២៦-១ គំនូសបំព្រួញនៃការគ្រប់គ្រងព្យាបាលរោគសញ្ញានៃការឈឺចាប់ពេលលេប




## ២៦.៤ ភ្នាក់ងារប្រឆាំងពពួកផ្សិត និង ការមានផ្ទៃពោះ/ការបំបៅដោះកូន[40]

ត្រូវចៀសវាងប្រើឱសថ Fluconazole ចំពោះស្ត្រីមានផ្ទៃពោះក្នុងត្រីមាសទី១ ទោះបីជាយ៉ាងណា ត្រូវធ្វើការវាយតម្លៃថ្លឹងថ្លែង រវាងផលប្រយោជន៍ និងកត្តាប្រឈមនៃការព្យាបាលដោយឱសថនេះ។ (សូមអានជំពូកទី១៧.៤.៤ ការព្យាបាលប្រឆាំងពពួកផ្សិតនៃជំងឺរលាកស្រោមខួរបង្កដោយ Cryptococcus លើស្ត្រីមានផ្ទៃពោះ /ស្ត្រីបំបៅដោះកូន )។

[40]គោលការណ៍ណែនាំ Sanford ឆ្នាំ២០១៥ សំរាប់ព្យាបាលប្រឆាំងមេរោគ

# ជំពូក ២៧. ការឈឺចាប់ក្នុងពោះ (Abdominal pain)

វិធីសាស្ត្រនៃការព្យាបាលរោគសញ្ញាឈឺពោះ សូមមើលគំនូសបំព្រួញខាងក្រោម។ ត្រូវបញ្ជូនអ្នកជំងឺជាបន្ទាន់ទៅផ្នែកវះកាត់ដើម្បីពិនិត្យ ក្នុងករណីមានភស្តុតាងមួយចំនួននៃជំងឺរលាកស្រោមពោះ(peritonitis) (ពោះមានសភាពរឹងនៅពេលពិនិត្យ) ។

**រូបភាពទី២៧-១ គំនូសបំព្រួញអំពីវិធីសាស្ត្រក្នុងការគ្រប់គ្រងព្យាបាលការឈឺចាប់ក្នុងពោះ[៩១]**




[៩១] ចម្លងពី គោលការណ៍ណែនាំគ្លីនិក របេងអេដស៍ របស់ MSF ២០១៥។ទំព័រ ២១៤

# ជំពូក ២៨. ជំងឺរាគរូស (Diarrhea)

អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ងាយរងគ្រោះទាំងជំងឺរាគរូសស្រួចស្រាវ និងរ៉ាំរ៉ៃ រួមទាំង ជំងឺដែលបង្ករោគជាញឹកញាប់ និងជំងឺឱកាសនិយមបង្កដោយមេរោគមិនប្រក្រតីផ្សេងៗ។

**ការបង្ការ:** សុវត្ថិភាពអនាម័យចំណីរអាហារនិងទឹក ព្រមទាំង ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ភ្លាមៗ ។

## ២៨.១ និយមន័យ

- **ជំងឺរាគរូស**: គឺជាការបន្ទោរបង់លាមកខាប់ ឬរាវ ជាធម្មតា លើសពី ៣ដង/ថ្ងៃ។
- **ជំងឺរាគរូសស្រួចស្រាវ**: រាគរូសមានរយៈពេល ≤១៤ថ្ងៃ។
- **ជំងឺរាគរូសជាប់ជានិច្ច**: រាគរូសមានរយៈពេល > ១៤ថ្ងៃ និង ≤ ៣០ថ្ងៃ។
- **ជំងឺរាគរូសរ៉ាំរ៉ៃ**: រាគរូសមានរយៈពេល > ៣០ថ្ងៃ។

## ២៨.២ ជំងឺរាគរូសស្រួចស្រាវ

ជំងឺរាគរូសស្រួចស្រាវ បង្ហាញថា អ្នកជំងឺអាចមាន **ជំងឺរលាកក្រពះសាមញ្ញ** (simple gastroenteritis) លាមករាវ ឬអាចជា **ជំងឺរាគរូសរាគត្បាត/ជំងឺរាគមូល** គឺជាជំងឺរាគរូសមានលាមកលាយឈាមអាចមើលឃើញ ជាទូទៅទាក់ទងនឹង រោគសញ្ញាគ្រុនក្តៅ ឈឺពោះ និងមានរោគសញ្ញានៅរន្ធគូថ (rectal symptoms) ។

### ២៨.២.១ មូលហេតុ

រួមមាន វីរុស (Norovirus) និងបាក់តេរី *(ឧ. E.coli, Salmonella spp*, *spp Shigella, Campylobacter spp )* និងប៉ារ៉ាស៊ីត *(ឧ. Entamoeba histolytica)*។
មូលហេតុមិនមែនបណ្តាលមកពីការបង្ករោគ រួមមាន៖ ផលប៉ះពាល់នៃឱសថ (ឧ. Lopinavir/r)។

### ២៨.២.២ ការគ្រប់គ្រងព្យាបាលជំងឺរាគរូសស្រួចស្រាវ

- សារៈសំខាន់នៃការព្យាបាលជំងឺរាគរូសស្រួចស្រាវ គឺការវាយតម្លៃ និងការគ្រប់គ្រងព្យាបាលការបាត់បង់ជាតិទឹក យោងតាមតារាងទី២៨-១ ការវាយតម្លៃ និងការគ្រប់គ្រងព្យាបាលការបាត់បង់ជាតិទឹក លើអ្នកជំងឺរាគរូស។
- **ការព្យាបាលប្រឆាំងពពួកមីក្រុប**
  បើជំងឺរាគរូសស្រួចស្រាវ មិនបានធ្វើឱ្យប្រសើរឡើងក្នុងរយៈពេលមួយសប្តាហ៍ និងអ្នកជំងឺបន្ទោបង់លាមកជាញឹកញាប់ (> ៦ដង/ថ្ងៃ) រួមជាមួយសីតុណ្ហភាពខ្ពស់ និង/ឬ ការឈឺចាប់ដោយរមួលក្រពើរខ្លាំង ត្រូវផ្តល់៖
  - Cotrimoxazole DS ១គ្រាប់ ២ដង/ថ្ងៃ និង metronidazole ៥០០ម.ក្រ ៣ដង/ថ្ងៃ រយៈពេល៥ថ្ងៃ។

- បើមានឈាមក្នុងលាមក រួមគ្នាជាមួយរោគសញ្ញាខាងលើ ឬជំងឺរាករូសមិនត្រូវបានធ្វើឱ្យប្រសើរឡើង ក្រោយពីការព្យាបាលខាងលើ ត្រូវផ្តល់៖
    - Ciprofloxacin ៥០០ម.ក្រ ២ដង/ថ្ងៃ រយៈពេល ៥ថ្ងៃ។

**តារាងទី២៨-១ ការវាយតម្លៃ និងការគ្រប់គ្រងព្យាបាលការបាត់បង់ជាតិទឹក លើអ្នកជំងឺរាករូស [៤២]**

| រោគសញ្ញា | ការបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (មានសញ្ញា២ដូចខាងក្រោម) | ការបាត់បង់ជាតិទឹកមួយចំនួន) មានសញ្ញា ២ ដូចខាងក្រោម( | មើលមិនឃើញការបាត់បង់ជាតិទឹក |
|---|---|---|---|
| កម្រិតនៃការដឹងខ្លួន (ស្មារតី) | ទន់ល្វិតល្វៃ ឬ បាត់បង់ស្មារតី | អន្ទះអន្ទែង និងឆេវឆាវ | ស្មារតីរហ័ស |
| ភ្នែក | ខូង)sunken( | ខូង | មិនខូង |
| លទ្ធភាពនៃការផឹកទឹក | ខ្សោយ ឬមិនអាចផឹកទឹក | ចង់ផឹកទឹក ,ស្រេកទឹក | ធម្មតា មិនស្រេកទឹក |
| ការចាប់ច្បិតស្បែក )ស្បែកហើម( | ត្រឡប់មកសភាពដើមយឺត > ២ វិនាទី | ត្រឡប់មកសភាពដើមយឺត < ២ វិនាទី | ត្រឡប់មកសភាពដើមវិញ ភ្លាមៗ |
| ការព្យាបាល | ការបំពេញជាតិទឹកតាម IV តាមសុង) (ច្រមុះក្រពះ រកមូលហេតុ និងព្យាបាលមូលហេតុ រាយការណ៍ករណី។ | ផ្តល់ជាតិទឹកនិងអាហារ ផ្តល់យោបល់ភ្លាមពេលអ្នកជំងឺមកជួប តាមដានអ្នកជំងឺរយៈពេល៥ថ្ងៃ ប្រសិនបើមិនបានប្រសើរឡើង។ | ព្យាបាលនៅផ្ទះ ផ្តល់យោបល់ឱ្យអ្នកជំងឺត្រឡប់មកវិញ តាមដានអ្នកជំងឺរយៈពេល៥ថ្ងៃ ប្រសិនបើមិនបានប្រសើរឡើង។ |

**ការបំពេញជាតិជាតិ:**

- ផឹកភេសជ្ជៈ ឱ្យបានច្រើននិងញឹកញាប់ តាមដែលអាចធ្វើទៅបាន ឧ. ផឹកភេសជ្ជៈមួយពែងរៀងរាល់ ១៥- ៣០នាទីម្តង។
- ប្រសិនបើមិនអាចផឹកបាន និង/ឬ ក្អួតធ្ងន់ធ្ងរ → រៀបចំបំពេញជាតិទឹកតាមរយៈការចាក់តាមសរសៃឈាមវ៉ែន។
- ការបំពេញជាតិទឹកដោយផឹក (Oral rehydration fluids)៖
    - បំពេញជាតិទឹកដោយផឹក Oral rehydration salts (ORS) ជាជម្រើសដ៏ល្អ ដោយលាយម្សៅ ORS មួយកញ្ចប់ជាមួយទឹក១លីត្រ ដោយប្រើទឹកបរិសុទ្ធ ឬទឹកដាំពុះ។

[៤២] អង្គការសុខភាពពិភពលោក២០១១។ សៀវភៅណែនាំ IMAIសំរាប់គ្រូពេទ្យ ថ្នាក់ស្រុកៈ ការថែទាំនៅមន្ទីរពេទ្យ សម្រាប់ ក្មេងជំទង់ និងមនុស្សពេញវ័យ បានចម្លងពី គោលការណ៍ណែនាំគ្លីនិក របេង អេដស៍ របស់អង្គការ MSF ឆ្នាំ ២០១៥

- សូលុយស្យុង Sugar salt solution (SSS) = ទឹកស្អាតដាំពុះមួយលីត្រ + ១/២ស្លាបព្រាកាហ្វេនៃអំបិល + ៨ស្លាបព្រាកាហ្វេនៃស្ករ។ បើអាច ត្រូវបន្ថែមជាតិ potassium ខ្លះ (ឧ. បន្ថែមទឹកក្រូច)។
- បបរ = បបរដោយដាក់អង្ករមួយកំប៉ុង លាយជាមួយទឹកស្អាត៥កែវ អំបិលបន្តិច ស្ងោរយៈពេល១ម៉ោង។

- រៀបចំសូលុយស្យុងបំពេញជាតិទឹកប្រចាំថ្ងៃ និង រក្សាទុកដាក់ប្រកបដោយអនាម័យល្អ និង រក្សាទុកនៅកន្លែងត្រជាក់។
- បន្តលើកទឹកចិត្តឱ្យអ្នកជំងឺបរិភោគ បើអាចបរិភោគបាន ដោយមិនគ្រាន់តែហូបបបរ/ORS ប៉ុណ្ណោះទេ។ ផ្លែចេក គឺជាប្រភពនៃសារធាតុប៉ូតាស្យូមដ៏ល្អ (ដែលបានបាត់បង់តាមលាមក)។

## ២៨.៣ ជំងឺរាករូសរ៉ាំរ៉ៃ

ជំងឺអេដស៍ក្នុងដំណាក់កាលធ្ងន់ធ្ងរ អាចបង្កឱ្យកើតជំងឺរាករូសរ៉ាំរ៉ៃ ហើយអ្នកជំងឺអេដស៍ដែលមានចំនួនកោសិកា CD4 តិចនឹងងាយរងគ្រោះទៅនឹងការបង្ករោគរ៉ាំរ៉ៃ រួមមាន ជំងឺបង្កដោយពពួក protozoa (Microsporidia, *Cryptosporidium spp. Isospora belli, Giardia lamblia, Entamoeba histoytica*) ។ ជំងឺបង្កដោយពពួកបាក់តេរី (*Salmonella spp. Mycobacterium avium* complex, MTB) និងជំងឺបង្កដោយពពួកវីរុស រួមទាំងជំងឺ CMV។

មូលហេតុមិនមែនជាការជំងឺឆ្លង បណ្តាលឱ្យរាករ៉ាំរ៉ៃ រួមមាន ជំងឺមហារីកពោះវៀន (gut neoplasms) រួមទាំង ជំងឺ Lymphoma និងជំងឺ Karposi's sarcoma ជំងឺខ្សោយលំពែង ឬផលប៉ះពាល់នៃឱសថ (ឧ. LPV/ r)។

### ២៨.៣.១ ការធ្វើរោគវិនិច្ឆ័យ

វាជាការសំខាន់ណាស់ដើម្បីពិនិត្យស្រាវជ្រាវរកជំងឺរបេង៖ ការវាយតម្លៃរោគសញ្ញាគ្លីនិក ការពិនិត្យកំហាក ការថតសួតដោយកាំរស្មី X ។

ការពិនិត្យលាមកដោយអតិសុខុមទស្សន៍៖ ពិនិត្យកោសិកាឈាមស (WBC) កោសិកាឈាមក្រហម (RBC) រកពពួកប៉ារ៉ាស៊ីត (កើនឡើងនៃ sensitivity ដោយពិនិត្យលើសំណាក ៣)។

ការពិនិត្យអេកូពោះ៖ ពិនិត្យមើលការរីកធំនៃកូនកណ្តុរ ថ្លើម និងអណ្តើករីកធំ (hepatosplenomegaly) (ជំងឺរបេង ជំងឺ MAC) ។

### ២៨.៣.២ ការគ្រប់គ្រងព្យាបាល[៤៣]

- វាយតម្លៃ និង គ្រប់គ្រងព្យាបាលការបាត់បង់ជាតិទឹក និងស្ថានភាពសារជាតិអាហារូបត្ថម្ភ ស្របតាមតារាងទី២៨-១ ការវាយតម្លៃ និងការគ្រប់គ្រងព្យាបាលការបាត់បង់ជាតិទឹក លើអ្នកជំងឺរាករូស និង

[៤៣] គោលការណ៍ណែនាំគ្លីនិក របេងអេដស៍ របស់ MSF ២០១៥ និង គោលការណ៍ណែនាំ The Sanford ២០១៥សំរាប់ព្យាបាលប្រឆាំងមេរោគ

ជំពូក៣៣. អាហារូបត្ថម្ភ និងការគ្រប់គ្រងទម្ងន់លើមនុស្សពេញវ័យនិងក្មេងជំទង់ដែលផ្ទុកមេរោគអេដស៍។

- **ការព្យាបាលរាល់ការបង្ករោគដែលបានធ្វើរោគវិនិច្ឆ័យ** ៖
    - ជំងឺ Isosporiasis: cotrimoxazole ១DS លេប៤ដង/ថ្ងៃ រយៈពេល១០ថ្ងៃ បន្ទាប់មក ២ដង/ថ្ងៃ រយៈពេល៣សប្តាហ៍។
    - ជំងឺ Strongyloidiasis: Albendazole ៤០០ម.ក្រ លេប២ដង/ថ្ងៃ (លេបពេលបរិភោគអាហារដែលមានជាតិខ្លាញ់) រយៈពេល៧ថ្ងៃ ។
    - ជំងឺ Giardiasis: Metronidazole ៥០០ម.ក្រ លេប៣ដង/ថ្ងៃ រយៈពេល៧ថ្ងៃ ។
    - ជំងឺរបេង: បញ្ជូនទៅ CENAT ដើម្បីទទួលការព្យាបាលតាមស្តង់ដា ។

- ការព្យាបាលប្រឆាំងពពួកមីក្រុបសាកល្បង (ដោយធានាថា មិនមែនជំងឺរបេងមុននឹងព្យាបាលដោយប្រើឱសថ ciprofloxacin)។
- Cotrimoxazole DS ១គ្រាប់ លេប២ដង/ថ្ងៃ និង metronidazole ៥០០ ម.ក្រ លេប៣ដង/ថ្ងៃ រយៈពេល ៥ថ្ងៃ ។
- បើបរាជ័យ៖ សាកល្បងប្រើ albendazole ៤០០ ម.ក្រ លេប២ដង/ថ្ងៃ (លេបពេលហូបអាហារមានជាតិខ្លាញ់) រយៈពេល៧ថ្ងៃ។

- **ឱសថប្រឆាំងការរាករូស** ត្រូវបានប្រើដោយប្រុងប្រយ័ត្នក្នុងករណីដែលការឆ្លើយតបទៅនឹងការព្យាបាលខាងលើខ្សោយ ហើយការរាករូសដែលមានលាមកសុទ្ធតែទឹក គ្មានឈាម ឬគ្មានការឈឺពោះ។
    - Loperamide ២ម.ក្រ គ្រាប់ ក្រោយពេលរាករូសម្តងៗ ឬលេបតាមរូបមន្ត ជាទូទៅ អាចលេបរហូតដល់ ៦-៨ គ្រាប់ក្នុងមួយថ្ងៃ ។
    - Codeine phosphate ៣០– ៦០ ម.ក្រ រហូតដល់៤ដង/ថ្ងៃ ។
- **ធានាថាអ្នកជំងឺបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។**

# ជំពូក ២៩. ជំងឺគ្រុនពោះវៀន

ជំងឺគ្រុនពោះវៀន(រួមទាំង ជំងឺ Salmonella) បង្កឡើងដោយ *Salmonella typhi* ដែលមិនមែនជា *Salmonella spp.* និងបាក់តេរីក្រាមអវិជ្ជមានផ្សេងទៀត រួមទាំង *Campylobacter* និងផលិតសារជាតិជាតិពុលនៃ *Shigella* និង *E.coli* ។

ការលេចឡើងនូវ septicaemia សារចុះសារឡើង (ជាពិសេស រួមទាំង non typhoidal Salmonella) ត្រូវបានចាត់ថ្នាក់ជា ដំណាក់កាលគ្លីនិកទី៤ នៃ WHO ។

**ការបង្ការ:** ត្រូវចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឱ្យបានឆាប់ ព្យាបាលបង្ការដោយឱសថ cotrimoxazole (អាចការពារបានមួយចំនួន) អនាម័យចំណីអាហារ/ទឹក (សូមអាន ជំពូក ៣៣. អាហារូបត្ថម្ភ និងការគ្រប់គ្រងទម្ងន់លើមនុស្សពេញវ័យនិងក្មេងជំទង់ដែលផ្ទុកមេរោគ អេដស៍ ផ្នែកសុវត្ថិភាពចំណីអាហារ) ។

## ២៩.១ រោគសញ្ញាគ្លីនិកជំងឺគ្រុនពោះវៀន

រោគសញ្ញា: គ្រុនក្តៅ លំបាកក្នុងខ្លួន (rigors) ចង្អោរ ក្អួត ឈឺពោះ រោគសញ្ញាប្រដាប់រំលាយអាហារ អាចមាន ការរាករូសដោយមានលាមករាវ ឬលាយឈាម ឬទល់លាមក (គ្រុនពោះវៀន) ។

## ២៩. ២ ការពិនិត្យស្រាវជ្រាវ និងការធ្វើរោគវិនិច្ឆ័យ

ការពិនិត្យលាមកដោយអតិសុខុមទស្សន៍៖ ឃើញ កោសិកាឈាមស(leukocytes) និងកោសិកាឈាមក្រហម និងពពួកប៉ារ៉ាស៊ីត ។

បណ្តុះមេរោគក្នុងលាមក និងក្នុងឈាម (បើអាចធ្វើបាន) អាចនឹងបែងចែកមូលហេតុនៃការបង្ករោគ និងការធ្វើតេស្តជំងឺគ្រុនចាញ់ ។

**រោគវិនិច្ឆ័យដែកញែក**: ជាមួយជំងឺបង្កដោយពពួកប៉ារ៉ាស៊ីតនៅប្រដាប់រំលាយអាហារ ឧ.ទា Amoebiasis ។

## ២៩. ៣ ការព្យាបាលស្តង់ដា[៤៤]

**ការព្យាបាលដំបូង៖**

[៤៤] គោលការណ៍ណែនាំ Sanford២០១៥ សំរាប់ព្យាបាលប្រឆាំងមេរោគ និង Panel ស្តីអំពីគោលការណ៍ណែនាំសំរាប់ជំងឺ ឱកាសនិយមចំពោះក្មេងជំទង់និង មនុស្សពេញវ័យដែលឆ្លងមេរោគអេដស៍:អនុសាសន៍របស់ មជ្ឈមណ្ឌលគ្រប់គ្រង និងការពារជំងឺ ,វិទ្យាស្ថានជាតិ សុខភាពនិង សមាគម វេជ្ជសាស្ត្រ អេដស៍ នៃសហគមន៍ ជំងឺឆ្លង អាមេរិកាំង ២០១៥ ។

- ការព្យាបាលដោយបំពេញជាតិទឹកខ្លាំងក្លាដោយចាក់តាមសរសៃវ៉ែន + ចាក់បញ្ចូលអាំងទីប៊ីយ៉ូទិកដែលមានសកម្មភាពទូលាយចូលតាមសរសៃវ៉ែន ដូចជា ceftriaxone (ឬ លេប ciprofloxacin ៥០០ ម.ក្រ) និង metronidazole ៥០០ម.ក្រ (ចាក់ IV ឬលេប) ២ដង/ថ្ងៃ។

ក្រោយពេលដែលបានធ្វើរោគវិនិច្ឆ័យ និងគ្មានការសង្ស័យពីការបង្ករោគនៅពោះវៀនផ្សេងៗត្រូវព្យាបាលដោយ ៖

- Ciprofloxacin ៥០០ ម.ក្រ គ្រាប់ លេបរាល់ ១២ម៉ោង/ម្តង រយៈពេល៧-១៤ថ្ងៃ ឬ
- Ceftriaxone ២ ក្រ ចាក់ IVI រាល់ថ្ងៃ ឬ
- Azithromycin ១ ក្រ នៅពេលដំបូង បន្ទាប់មក បន្ថយមក ៥០០ម.ក្រ រាល់ថ្ងៃ រយៈពេល៥ ថ្ងៃ។

ប្រសិនបើ មានការបញ្ជាក់ ឬសង្ស័យខ្លាំងថា វត្តមានពពួកបាក់តេរីក្នុងឈាម (bacteraemia) ត្រូវព្យាបាលដោយអង់ទីប៊ីយ៉ូទិកយ៉ាងហោចណាស់ ២សប្តាហ៍។
ប្រសិនបើ មានការសង្ស័យឬបញ្ជាក់ថា ការបង្ករោគនៅក្រៅពោះវៀន ឧ. ជំងឺរលាកឆ្អឹង ឬបង្ករោគនៅសរសៃឈាម (mycotic aneurism) ឬ ថយចុះភាពស៊ាំធ្ងន់ធ្ងរ (<២០០កោសិកា/ម.ម$^{៣}$) ត្រូវពន្យាពេលព្យាបាលដោយឱសថ ciprofloxacin រហូតដល់ ២-៦ សប្តាហ៍បន្ថែមទៀត។

## ២៩.៤ ការព្យាបាលបង្ការទី ២

- ព្យាបាលបង្ការដោយឱសថ Cotrimoxazole ស្របតាមរូបមន្តព្យាបាលស្តង់ដា ។

# លក្ខខណ្ឌនៅលើស្បែក និងជំងឺកាមរោគ

# ជំពូក ៣០. ជំងឺសើស្បែក

## ៣០.១ ចំណុចគន្លឹះ

- ដំបៅស្បែក កើតឡើងជាញឹកញាប់នៅដំណាក់កាលដំបូង នៃការបង្ករោគដោយមេរោគអេដស៍ ។
- ដំបៅស្បែក អាចលេចចេញរោគសញ្ញាមួយចំនួន ក្នុងចំណោមរោគសញ្ញាខាងក្រោម៖
    - វិបត្តិជាបឋមនៃរោគសើស្បែក ឧ. ជំងឺស្បែករបកក្រហម (psoriasis)
    - ការបង្ករោគ៖ នៅលើស្បែក (ឧ. folliculitis) ឬ នៅជ្រៅក្រោមស្បែក (រលាកកោសិកា) ឬរាលដាលច្រើនកន្លែង (ជំងឺ Cryptococcus)
    - Allergy (ស្នាមកន្ទួលលើស្បែកបង្កដោយឱសថ)
    - វិបត្តិនៃការរលាកឆ្លើយតបនឹង antigens (ឧ. PPE)
    - ជំងឺមហារីក (ឧ. Kaposi's sarcoma) ។

- ការធ្វើរោគវិនិច្ឆ័យនិងព្យាបាលភ្លាមៗ នៃរោគសញ្ញាដែលលេចចេញលើស្បែក គឺមានសារៈសំខាន់ណាស់ ដើម្បីបន្ធូរបន្ថយរោគសញ្ញា និងព្យាបាលជំងឺដែលមានសក្តានុពលគំរាមកំហែងដល់ជីវិត (ឧ. ការបង្ករោគជាប្រព័ន្ធ ឬប្រតិកម្មជាមួយឱសថធ្ងន់ធ្ងរ) ។

## ៣០.២ ប្រតិកម្មជាមួយឱសថ

- ប្រតិកម្មស្បែក កើតឡើងជាញឹកញាប់ មានលក្ខណៈប្រែប្រួលពីកម្រិតស្រាល រហូតដល់មានការគំរាមកំហែងដល់ជីវិត។
- បើអ្នកជំងឺលេចចេញស្នាមកន្ទួលលើស្បែក មាន/គ្មាន ជំងឺគ្រុនក្តៅ និងរោគសញ្ញាដែលតែងតែកើតឡើង ត្រូវពិចារណាអំពីប្រតិកម្មជាមួយឱសថ ។
- ប្រតិកម្មជាមួយឱសថក្លាស់ស៊ីក រួមបញ្ចូលទាំង ឱសថបង្កឱ្យមានការលេចចេញស្នាមកន្ទួលលើស្បែក (drug induced exanthems) កើតឡើងជាញឹកញាប់នូវ កន្ទាលត្រអាក/ឡើងកោសិកាក្រោមស្បែក (angioedema) ប្រតិកម្មជាមួយឱសថ (anaphylaxis) ចង្កោមរោគសញ្ញា Stevens –Johnson Syndrome ការពុលកោសិកាស្បែក រលាកសរសៃឈាម hypersensitivitiy exfoliative dermatitis ប្រតិកម្មឱសថ ដោយមាន eosinophilia និងរោគសញ្ញាប្រព័ន្ធ (DRESS) ផ្ទុះស្នាមកន្ទួលលើស្បែកបង្កដោយប្រតិកម្មឱសថ និងប្រតិកម្ម photosensitivity ជាដើម។ នៅពេលមានប្រតិកម្មជាមួយឱសថ បង្កឱ្យមានជំងឺលើស្បែកជាច្រើនទៀតអាចកើតឡើងដែរ តែមិនសូវញឹកញាប់ទេ ។
- ឱសថខាងក្រោម បង្កឱ្យមានប្រតិកម្មលើស្បែកជាញឹកញាប់៖
    - ឱសថ ARVs: nevirapine, efavirenz, abacavir (បង្កឱ្យមាន abacavir hypersensitivity syndrome) និងឱសថដែលមិនសូវបង្កប្រតិកម្មលើស្បែកញឹកញាប់ រួមមាន 3TC ឬ AZT ។
    - Cotrimoxazole

- ឱសថប្រឆាំងជំងឺរបេង
- ឱសថផ្សេងទៀត៖ anti-epileptics (ឧ. carbamazepine, phenobarbitone) NSAIDS allopurinol ។ល។

## ៣០.៣ រោគសញ្ញាគ្លីនិក[៩៥]

### រោគសញ្ញាគន្លឹះ

**១.លេចចេញស្នាមកន្ទួលលើស្បែកមានពណ៌ឈាននិងពងទឹកបង្កដោយឱសថ(mobillifomឬ exanthematous)** កើតឡើងជាញឹកញាប់នៃប្រតិកម្មជាមួយឱសថ ។ ស្នាមកន្ទួលលើស្បែកទាំងនេះលេចចេញឡើងនូវស្នាមបន្ទះតូចៗ និងដុំពកតូចៗ (macules និង/ឬ papules) មានលក្ខណៈស៊ីមេទ្រីគ្នា និងសាយភាព លេចចេញប្រហែលមួយសប្តាហ៍ បន្ទាប់ពីការចាប់ផ្តើមព្យាបាលដោយឱសថ (អាចនឹងលេចចេញរោគសញ្ញាឆាប់ជាងនេះ ប្រសិនបើ អ្នកជំងឺធ្លាប់បានប្រើឱសថនេះពីមុន)។ រោគសញ្ញាផ្សេងទៀត រួមមាន រមាស់ ក្តៅខ្លួនស្ទិញៗ និង eosinophilia កើនឡើងតិចតួច។
ឱសថ Cotrimoxazole ក៏បណ្តាលឱ្យមានប្រតិកម្មខាងលើនេះដែរ ហើយកើតមានជាញឹកញាប់លើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍។ ឱសថផ្សេងទៀត រួមមាន ឱសថព្យាបាលជំងឺ antiepileptic ឱសថក្រុម NSAIDS មួយចំនួន penicillins និងឱសថប្រឆាំងជំងឺរបេង ។

**២. ចង្កោមរោគសញ្ញាប្រតកម្មជាមួយឱសថ** (Drug hypersensitivity syndrome/DRESS)
ការលេចចេញស្នាមកន្ទួលក្រហមលើស្បែក (Erythroderma) ឬ ការផ្ទុះចេញ morbilliform សាយភាយលើ ៩០% ឬ ច្រើនជាងនេះនៃផ្ទៃស្បែក គ្រុនក្តៅ និងចុះខ្សោយសរីរាង្គចម្រុះជាច្រើន រួមមាន ថ្លើម តម្រងនោម បេះដូង សួត (ពិនិត្យមើលសម្ពាធឈាម ពិនិត្យទឹកនោមដោយ dipstick ថតសួតដោយកាំរស្មី X) ។ ជាទូទៅ រកឃើញ Eosinophilia ប៉ុន្តែមិនមានវត្តមានជានិច្ចនោះទេ ។ ជាធម្មតា ចាប់ផ្តើមកើតឡើងប្រហែលជា ៣សប្តាហ៍ ក្រោយពីបានចាប់ផ្តើមព្យាបាលដោយឱសថបង្កហេតុ។ ឱសថ Abacavir និងឱសថ Nevirapine បណ្តាលឱ្យមានប្រតិកម្ម hypersensitivity គឺជាឧទាហរណ៍នៃ DRESS និងឱសថផ្សេងទៀត រួមមានការប្រើឱសថ antiepileptic, dapsone, និង allopurinol ។

**៣.ចង្កោមរោគសញ្ញា**Stevens-Johnson syndrome(SJS) **និងការពុលរលួយស្បែក** (Toxic Epidermal Necrolysis = TEN)
SJS/TEN កើតមានឡើងរយៈពេល៨សប្តាហ៍ដំបូងនៃការព្យាបាល និងឱសថបង្កហេតុដែលជួបប្រទះញឹកញាប់ រួមមាន allopurinol, anticonvulsants, sulphonamides, Nevirapine និងឱសថមួយចំនួនក្នុងក្រុម NSAIDS ។ ប្រតិកម្ម Muco-cutaneous ធ្ងន់ធ្ងរ និងបានកំណត់ដោយ necrosis ទូលំទូលាយ និងរបកស្បែក។ SJS រួមបញ្ចូលទាំង ការរបកស្បែក < ១០% នៃផ្ទៃស្បែកគ្របដណ្តប់រាងកាយ ការពុល

[៩៥] ប្រភព: Samel A.D, Drug eruptions In: UpToDate, Post TW (Ed), UpToDate, Waltham, MA

រលួយស្បែក(TEN) របកស្បែក > ៣០% នៃផ្ទៃស្បែកគ្របដណ្តប់រាងកាយ និង SJS/TEN មានរោគសញ្ញាជាន់គ្នាពី ១០-៣០% ។ ភ្នាស mucous មានការប៉ះពាល់ > ៩០% ជាទូទៅចាប់ពី២កន្លែង ឬច្រើនជាង (នៅភ្នែក មាត់ និងប្រដាប់បន្តពូជ)។ គ្រុនក្តៅ កើតមានជាញឹកញាប់។ ដំបៅស្បែកបានចាប់ផ្តើមឡើងដោយមិនអាចកំណត់បានច្បាស់លាស់ មាន coalescing erythematous macules ដោយមានស្នាមកន្ទួលនៅចំកណ្តាល ឬ អាចលេចឡើងជាមួយជំងឺរលាកស្បែកសាយភាយ។ ស្បែកនេះគឺជាញឹកញាប់មានការឈឺចាប់ និងមានសភាពទន់។ ដំបៅតែងចាប់ផ្តើមនៅលើមុខនិងបំពង់ក និងនៅពេលជំងឺនេះវិវត្តន៍បណ្តាលឱ្យលេចចេញនូវ vesicles និងទម្រង់ bullae ហើយបន្ទាប់មកចាប់ផ្តើមចេញសំណាកជាលិកាស្លាប់ (slough) ។ ក្នុងករណីធ្ងន់ធ្ងរដែលមានផលវិបាកស្រួចស្រាវ រួមមាន sepsis ការបាត់បង់ជាតិទឹកតាមស្បែកធ្ងន់ធ្ងរ និងចុះខ្សោយសរីរាង្គជាច្រើន។ ផលប៉ះពាល់រយៈពេលវែង រួមមាន ការប៉ះពាល់ដល់សរីរាង្គ ដូចជា ស្បែក mucosal គ្រាប់ភ្នែក និងសួត។

## ៣០.៤ ការគ្រប់គ្រងព្យាបាល

- ចំពោះករណី ស្នាមកន្ទួលលើស្បែកធ្ងន់ធ្ងរ ជាពិសេស ការប៉ះពាល់ស្បែកទូលំទូលាយ និង/ឬមានរោគសញ្ញាប្រព័ន្ធ និងសង្ស័យថា មាន DRESS ឬ Stevens–Johnson /TEN ។
- បញ្ឈប់ការប្រើថ្នាំទាំងអស់ និងបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យ សម្រាប់គាំទ្រការព្យាបាល និងពិគ្រោះយោបល់ជាមួយគ្រូពេទ្យជំនាញ ។
- ប្រសិនបើមិនច្បាស់ថា ឱសថណាមួយជាបង្កឱ្យមានស្នាមកន្ទួលលើស្បែក- បញ្ឈប់ឱសថទាំងអស់ ហើយចាប់ផ្តើមប្រើឡើងវិញជាជំហានៗ (reintroduction stepwise) ដើម្បីធ្វើការពិចារណា បន្ទាប់ពីស្នាមកន្ទួលលើស្បែកបានធូរស្រាល ។
- ចំពោះព័ត៌មានបន្ថែមទាក់ទងនឹងការគ្រប់គ្រងព្យាបាល ប្រតិកម្មជាមួយឱសថជាក់លាក់ណាមួយ សូមអាន៖
  - ប្រតិកម្ម hypersensitivity នៃឱសថ Abacavir និងស្នាមកន្ទួលលើស្បែកបង្កដោយឱសថ ARV ផ្សេងទៀត ក្នុងជំពូកទី១០ ការតាមដាននិងការផ្លាស់ប្តូរដោយសារការពុលនៃឱសថប្រឆាំងមេរោគអេដស៍។
  - ស្នាមកន្ទួលលើស្បែកបង្កដោយឱសថ Cotrimoxazole នៅក្នុង ជំពូកទី៥. ការព្យាបាលបង្ការដំបូងនៃជំងឺឱកាសនិយម។

## ៣០.៥ ការបង្ករោគរាលដាលដោយលេចចេញនូវរោគសញ្ញាលើស្បែក

- បង្ករោគដោយបាក់តេរី៖ *Staphylococcus aureus, Bacilliary angiomatosis, Neisseria gonorrhoea, Syphilis* ។
- បង្ករោគដោយ Mycobacterium៖ ជំងឺរបេង មិនមែនជំងឺរបេង។
- បង្ករោគស្រួចស្រាវដោយវីរុសបណ្តាលឱ្យលេចចេញរោគសញ្ញាលើស្បែក(Acute viral exanthemas infections)។

- បង្ករោគដោយ Herpes simplex និង varicella zoster ស្រួចស្រាវ/កើតឡើងសារចុះសារឡើង ។
- បង្ករោគដោយពពួកផ្សិត៖ Cryptococcus (ប្រហែលជា ១០% នៃបង្ករោគដោយក្រិបតូកុក) បង្ករោគដោយ Histoplasmosis,  Sporotrichosis និង Penicillium។

### ៣០.៥.១ ជំងឺផ្សិតរាលដាលបណ្តាលឱ្យលេចចេញរោគសញ្ញាលើស្បែក

ជំងឺផ្សិតរាលដាល បង្កដោយ Cryptococcus, Penicillum ឬ Histoplasmosis អាចបណ្តាលឱ្យមានដំបៅស្បែក និងចង្កោមរោគសញ្ញាប្រព័ន្ធធ្ងន់ធ្ងរ ។ វាកើតឡើងលើគ្រប់អ្នកជំងឺអេដស៍ទាំងអស់ ក្នុងដំណាក់កាលធ្ងន់ធ្ងរ ត្រូវបានចាត់ចូលក្នុងដំណាក់កាលគ្លីនិកទី៤នៃ WHO និងមានអត្រាមរណភាព ខ្ពស់ ។

### ៣០.៥.២ ជំងឺ Penicilliosis

ជំងឺ Penicilliosis បង្កឡើងដោយមេរោគឈ្មោះ*Talaromyces* (ជាផ្លូវការ ហៅថា *Penicillium) marneffei* ឆ្លងរាលដាលនៅតំបន់អាស៊ីអាគ្នេយ៍ រួមទាំង ប្រទេសកម្ពុជា ។ ផ្លូវចម្លងត្រូវបានគេសង្ស័យថា ភាគច្រើនប្រព្រឹត្តតាមខ្យល់ (airborne) ។ សរីរាង្គនៃមេរោគនេះ បង្កកូនចៅឡើងនៅក្នុងកោសិកាMacrophages និងរាលដាលពេញរាងកាយ ជាពិសេស ក្នុងប្រព័ន្ធ reticulo-endothelial ។

#### រោគសញ្ញាគ្លីនិក

- ការចាប់ផ្តើមលេចចេញរោគសញ្ញាភ្លាមៗ គ្រុនក្តៅ ស្លេកស្លាំង ស្រកទម្ងន់ ដំបៅស្បែក មាន/គ្មាន ការឡើងកូនកណ្តុរ (lymphadenopathy) និងថ្លើមអណ្តើករីកធំ មាន/គ្មាន បញ្ហាផ្លូវដង្ហើម (ក្អក ពិបាកដកដង្ហើម)។
- ការពិនិត្យឃើញ កោសិកាធ្លាក់ចុះទាំងអស់ (cytopenias) និង ALP កើនឡើង និងមានការប៉ះពាល់ថ្លើម។
- ដំបៅស្បែកលេចចេញដោយមាន ដំបៅដុំពក (papular lesions) មួយឬច្រើនដែលជាញឹកញាប់មានចំណុចផ្ចិតកណ្តាល ឬដំបៅដូចគ្នាជាមួយនឹងជំងឺសើស្បែកបង្កដោយជំងឺ contagiosum molluscum ឬជំងឺ Cryptococcus ។ ដំបៅនេះគឺជាធម្មតាកើតនៅលើមុខ ស្បែកក្បាល និងលើដងខ្លួនផ្នែកខាងលើ អាចកើតផងដែរ នៅតំបន់ប្រដាប់ភេទ ។

#### ការធ្វើរោគវិនិច្ឆ័យ

- មានការលំបាកក្នុងការធ្វើរោគវិនិច្ឆ័យ បើគ្មានដំបៅស្បែក ហើយមានការលំបាកក្នុងការបែងចែកពីជំងឺ Cryptococcus ។ គេបានផ្តល់អនុសាសន៍ឱ្យសាកសួរយោបល់ពីគ្រូពេទ្យជំនាញទាក់ទងនឹងការពិនិត្យស្រាវជ្រាវ និងការគ្រប់គ្រងព្យាបាល ប្រសិនបើ ការធ្វើរោគវិនិច្ឆ័យជំងឺនេះ កំពុងត្រូវបានពិចារណា ។
- កំណត់អត្តសញ្ញាណនៃពពួកផ្សិតតាមរយៈការបណ្តុះឈាម ការពិនិត្យដំបៅស្បែកដោយអតិសុខុមទស្សន៍ ជាមួយនឹងការធ្វើតេស្ត Wright's stain កូនកណ្តុរ ឬទឹកបូមពីខួរឆ្អឹង ។

## ការព្យាបាលស្តង់ដា

- Amphotericin B 0,៧ ម.ក្រ/គ.ក្រ ចាក់ IV រាល់ថ្ងៃរយៈពេល ២ សប្តាហ៍ បន្ទាប់មកប្រើ itraconazole ៨០០ម.ក្រ/ថ្ងៃ រយៈពេល ១០ សប្តាហ៍ បន្ទាប់មកប្រើ itraconazole ២០០ម.ក្រ/ថ្ងៃ រហូតដល់ចំនួនកោសិកា CD4 > ១០០ ក្នុងកំឡុងពេល ៦ខែ ។[៨៦]
- Fluconazole មានសកម្មភាពខ្សោយប្រឆាំងជំងឺ Penicillium ដូច្នេះ ត្រូវប្រើ amphotericin B ចាក់ IVI រហូតដល់មានឱសថ itraconazole សម្រាប់យកមកព្យាបាល ។
- បើគ្មានឱសថ itraconazole ទេ ត្រូវប្រើឱសថ ketaconazole ២០០ម.ក្រ ២ដង/ថ្ងៃ ឬឱសថ fluconazole ៨០០ម.ក្រ ២ដង/ថ្ងៃ រយៈពេល ១០ សប្តាហ៍ ។
- ចំពោះករណីមិនសូវធ្ងន់ធ្ងរ ប្រើឱសថ itraconazole ៨០០ម.ក្រ/ថ្ងៃ រយៈពេល១២សប្តាហ៍ បន្ទាប់មក ២០០ម.ក្រ/ថ្ងៃ រហូតដល់ចំនួនកោសិកា CD4 > ១០០ ក្នុងរយៈពេល៦ខែ ។

## ការព្យាបាលបង្ការទី ២

ការព្យាបាលដោយបង្ក្រាបមេរោគរយៈពេលវែង គួរតែត្រូវផ្តល់ការព្យាបាលដោយឱសថ itraconazole ២០០ម.ក្រ រៀងរាល់ថ្ងៃ ដើម្បីទប់ស្កាត់ការលាប់ឡើងវិញ រហូតដល់អ្នកជំងឺមានចំនួនកោសិកា CD4 ខ្ពស់ជាង ១០០កោសិកា/$mm^3$ ។

## ៣០.៥.៣ ជំងឺ Histoplasmosis

ជំងឺ *Histoplasma capsulatum* គឺជាជំងឺបង្កដោយពពួកផ្សិត dimorphic fungus រស់នៅក្នុងដីដែលសម្បូរដោយកាកសំណល់ទម្លាក់ចុះដោយបក្សី និងសត្វប្រចៀវ ។ ដោយសារការដកដង្ហើមស្រូបចូលនូវស្ព័រនៃ H.capsulatum ចូលទៅដល់ alveoli នៃសួត ហើយបង្កឱ្យមានប្រតិកម្ម granulomatous ខ្លាំង។ ការរលួយ (Caseous necrosis) ឬ ការឡើងកំណកមានសភាពដូចគ្នានឹងជំងឺរបេង ។ ភាពធ្ងន់ធ្ងរនៃជំងឺ គឺអាស្រ័យលើកម្រិតនៃការប៉ះពាល់ និងភាពស៊ាំនៃអ្នកជំងឺ ។ ការបង្ករោគស្លាមៗ និងស្រួចស្រាវអាចបណ្តាលឱ្យស្លាប់ ក្នុងចំណោមអ្នកជំងឺអេដស៍ដែលមានភាពស៊ាំចុះខ្សោយខ្លាំង ។ អ្នកជំងឺអេដស៍ខ្លះ អាចបង្ហាញប្រតិកម្មនៃជំងឺ នៅពេលមានការថយចុះនៃភាពស៊ាំ ។ ជំងឺ Histoplasmosis ត្រូវបានគេរាយការណ៍ដោយកំរនៅប្រទេសកម្ពុជា ។

## រោគសញ្ញាគ្លីនិក

- ជំងឺសួតស្រួចស្រាវបង្កដោយ histoplasmosis បង្ហាញរោគសញ្ញា ដូចជាក្អក គ្រុនក្តៅ ស្រកទម្ងន់ អស់កម្លាំងល្ហិតល្ហៃ រងាររញាក់ញ័រ ឈឺចាប់សាច់ដុំ មិនឃ្លានអាហារ និងឈឺដើមទ្រូង ។ វាមាន ការលំបាកក្នុងការបែងចែកពីជំងឺ PCP ។ ការថតសួតដោយកាំរស្មី X បង្ហាញពី ការរលាកសួត(pneumonitis) និង lymphadenopathy hilarity ឬ មានលក្ខណៈដូចគ្នាជាមួយនឹង miliary ។

---

[៨៦] គោលការណ៍ណែSanford នាំឆ្នាំ២០១៥ សំរាប់ព្យាបាលប្រឆាំងមេរោគ

- ការថតសួតដោយកាំរស្មី X នៃជំងឺសួតរ៉ាំរ៉ៃ បង្កដោយ histoplasmosis បង្ហាញ ការរួមតូច និងឃើញមាន cavitation នៅឡូបសួតខាងលើ និងរាលដាលទៅឡូបខាងក្រោម និងតំបន់ផ្សេងទៀតនៃសួត ហើមសួត និង bulla ។
- ជំងឺ histoplasmosis រាលដាល ត្រូវបានកំណត់ដោយ គ្រុនក្តៅរយៈពេលយូរ ស្រកទម្ងន់ ថ្លើមនិងអណ្តើករីកធំ ហើមប៉ោងកូនកណ្តុរ ដំបៅធំនៅមាត់ ឬមានដុំពក ឬមានដុំពិណាក្រហមលើស្បែកដែលមានជាតិអាស៊ីត (discrete erythematous fungating skin papules or masses) ។

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល

- ករណីភាគច្រើន គេមិនអាចធ្វើរោគវិនិច្ឆ័យបានទេ។ ពិគ្រោះយោបល់ជាមួយគ្រូពេទ្យជំនាញ ប្រសិនបើការធ្វើរោគវិនិច្ឆ័យជំងឺនេះត្រូវបានពិចារណា សុំយោបល់ពិនិត្យស្រាវជ្រាវឡើងវិញ និងការគ្រប់គ្រងព្យាបាលករណីនេះ ។
- ការធ្វើរោគវិនិច្ឆ័យច្បាស់លាស់ អាចត្រូវបានធ្វើឡើងដោយកំណត់អត្តសញ្ញាណតាមរយៈការធ្វើតេស្ត histopathology នៃទម្រង់ផ្សិតក្នុងកោសិកាឈាមស និងក្នុងកោសិកា Macrophages ដោយលាប Giemsa បន្តិចលើសំណាកឈាម សំណាកខួរឆ្អឹង ឬ BAL ទោះជាយ៉ាងណា ការពិនិត្យស្រាវជ្រាវបែបនេះគឺកំរនឹងធ្វើបានណាស់ ។
- ការព្យាបាល៖ Amphotericin B ០,៧ម.ក្រ/គ.ក្រ/ថ្ងៃ ចាក់ IV រយៈពេល ២ សប្តាហ៍ បន្ទាប់មកប្រើឱសថ itraconazole ២០០ម.ក្រ ២ដង/ថ្ងៃ យ៉ាងហោចណាស់រយៈពេល ១២ ខែ ។

## ៣០.៥.៤ ការបង្ករោគដោយបាក់តេរីលើស្បែក និងលើជាលិកាទន់

តារាងទី ៣០-១ ការបង្ករោគដោយបាក់តេរីលើស្បែក និងលើជាលិកាទន់

| ការបង្ករោគដោយបាក់តេរីលើស្បែក | បាក់តេរីបង្ករោគ | ការពិពណ៌នា | ការព្យាបាល |
|---|---|---|---|
| Folliculitis | *Staphylococcus aureus* | ការរលាក ការបង្ករោគនៅគល់រោម | • គ្រប់ពីលើដោយស្បែក្តៅអ៊ុនៗ (Warm compress)<br>• ការលាងសំអាត<br>• Topical Genitian Violent<br>• Cloxacillin ក្នុងករណី ធ្ងន់ធ្ងរ |
| Cellulitis (រលាកកោសិកា) | *Streptococcus spp. Staphylococcus aureus, Haemophilus influenzae* | រលាកស្បែក និង ជាលិកា subcutaneous ដែលមាន លក្ខណ: ហើម ក្រហម និង ឈឺចាប់ +/-គ្រុនក្តៅ | Cloxacillin ៥០០ម.ក្រ ៤ដង/ថ្ងៃ រៀងរាល់ថ្ងៃរយៈពេល១០ថ្ងៃ។ ករណីធ្ងន់ធ្ងរត្រូវប្រើអង់ទីប៊ីយ៉ូទិកចាក់ IV (cloxacillin ឬ cetriaxone)។ |

| | | | |
|---|---|---|---|
| បូសទ្រនិក (Boils) ជាលិការទន់ បូស | *Staphylococcus aureus, Haemophilus influenzae* | ខ្ទុះប្រមូលផ្តុំនៅនឹងកន្លែងនៅ ក្នុងប្រហោង អាច មានផលវិបាកជាការរលាក កោសិកា (cellulitis) បើមិនបានព្យាបាល។ | • សំខាន់បំផុតគឺ ការវះកាត់ចោះបង្ហូរខ្ទុះ<br>• បើករណីស្រាល ត្រូវយក compress ក្តៅឧណ្ឌៗបិទ<br>• ព្យាបាលដោយ Systemic antibiotics បើមានជំងឺ cellulitis នៅជំបន់ជុំវិញ។ |
| Impetigo | *Staphylococcus aureus, Streptococcus spp.* | ដំបៅពិណលឿងក្រៀម ឬពងទឹករមាស់ | លាងដំបៅជាមួយទឹកក្តៅឧណ្ឌៗ។ លាបអង់ទីប៊ីយ៉ូទិក ឬ លាយអង់ទីប៊ីយ៉ូនទិក/អាស៊ីសាលីស៊ីលិក<br>Cloxacillin សម្រាប់ដំបៅដែលសាយភាព។ |
| Paronychia | *Staphylococcus aureus* | ការបង្ករោគកើតនៅជាលិកាជុំវិញក្រចកដៃ និងក្រចកជើង។ | • វះកាត់ចោះបង្ហូរខ្ទុះនៅក្រោមក្រចកចេញ<br>• Cloxacillin រយ:ពេល៥-៧ ថ្ងៃ |
| Pyomyositis | *Staphylococcus aureus* | បង្កជាបូសជ្រៅក្នុងសាច់ដុំ មានសភាពមិនស្រួលខ្លួនជាទៅទៅ គ្រុនក្តៅ ឈឺចាប់ | • វះកាត់ចោះបង្ហូរខ្ទុះចេញ<br>• Ceftriaxone ១-២ ក្រាម ចាក់តាមសសៃ IV ៤ដង/ ថ្ងៃ ឬ Ceftriaxone ២ក្រាម ចាក់តាមសរសៃ ជារៀងរាល់ថ្ងៃ រយ:ពេល១០ថ្ងៃ។ |
| Bacillary angiomatosis "cat scratch disease" | *Bartonella henselae* | ដំបៅសរសៃឈាម (vascular) រាលដាលដែលមានលក្ខណ: ដូចគ្នាជាមួយជំងឺ Kaposi's sarcoma | • ពិគ្រោះជាមួយគ្រូពេទ្យជំនាញ<br>• Erythromycin ៥០០ម.ក្រ ៤ ដង/ថ្ងៃ ឬប្រើ doxycycline ១០០ម.ក្រ ២ដង/ថ្ងៃ រយ:ពេល២ខែ។ |

| | | | |
|---|---|---|---|
| Necrotising soft tissue infections including necrotizing fasciitis (ការបង្ករោគបណ្ដាលឱ្យរលួយជាលិកាទន់ រួមមាន ការ necrotizing fasciitis) | *Streptococcus pyogenes, Clostridium perfringens (gas gangrene), of Vibrio spp. or polymicrobial mixed aerobic and anaerobic bacteria* | ឈឺចាប់ខ្លាំង ទោះជាមានការរលាកស្បែកតិចតួចក៏ដោយ មាន Bullae រលួយស្បែក ហើម ខ្យល់ក្នុងជាលិកាទន់ រាលដាលយ៉ាងលឿនទៅប្រព័ន្ធសរីរាង្គផ្សេងៗ នាំឱ្យធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ។ | វះកាត់ជាបន្ទាន់ការកំទេចកំទីសាច់ដែលរលួយចេញ។ ចាក់អង់ទីប៊ីយ៉ូទិកដែលមានសកម្មភាពទូលាយ ចាក់ IV ។ ឧ. ceftriaxone + metronidazole/ clindamycin, ឬ meropenem + metronidazole/ clindamycin<br>ប្រើអង់ទីប៊ីយ៉ូទិកដែលគ្មានសកម្មភាពទូលាយ បើបានទទួលលទ្ធផលនៃការបណ្ដុះមេរោគ។ |
| Staphylococcal Scalded Skin Syndrome | *Staphylococcus aureus* | ដំបៅសាយភាយដោយ ចាប់ផ្ដើមលើផ្ទៃមុខដែលជួប ញឹកញាប់លើកុមារ។ អាចដូចគ្នានឹង Stevens Johnson Syndrome ប៉ុន្តែ គ្មានការប្រឈមមុខជំរុញ និង មិនប៉ះពាល់ដល់ mucosa ទេ។ | • Cloxacillin ២០០ម.ក្រ/គ.ក្រ/ថ្ងៃចាក់ IV រាល់៦ម៉ោងម្ដង<br>• ពិគ្រោះជាមួយគ្រូពេទ្យពីការវះកាត់<br>• ព្យាបាលរបួសនិងយកចិត្តទុកដាក់ ចំពោះស្ថានភាពខ្សោះជាតិទឹក។ |
| Syphilis | *Treponema pallidum* | ដំបៅគ្មានការឈឺចាប់ រឹង (chancre) នៅត្រង់កន្លែងដែលឆ្លងរោគស្វាយ។ រោគសញ្ញាគ្លីនិង ការធ្វើតេស្តអមវេជ្ជសាស្ត្រ (RPR ត្រូវការពេលវេលាពី៤–៦ សប្តាហ៍ ដើម្បីឱ្យតេស្តនេះ វិជ្ជមាន)។ | Benzathene penicillin ២,៤M IU x ១ដង<br>doxycycline ជួរទី២ ១០០ម.ក្រ ២ដង/ថ្ងៃ **រយៈពេល**១៤ថ្ងៃ<br>erythromycin ជួរទី៣ លេប ៥០០ ម.ក្រ ៤ដង/ថ្ងៃ **រយៈពេល** ៤ សប្តាហ៍។ |

| | | | |
|---|---|---|---|
| Syphilis | *Treponema pallidum* | ស្នាមកន្ទួលលើស្បែកMaculo-papular, condylomata lata, គ្រុនក្តៅ ហើមប៉ោងកូនកណ្តុរ, oral mucus patches. រោគវិនិច្ឆ័យដោយការធ្វើតេស្ត RPR។ | Benzathene penicillin ២,៤M IU x ១ដង<br>doxycycline ជួរទី២ ១០០ម.ក្រ ២ដង/ថ្ងៃ **រយៈពេល** ១៤ថ្ងៃ<br>erythromycin ជួរទី៣ លេប ៥០០ ម.ក្រ ៤ដង/ថ្ងៃ **រយៈពេល** ៤ សប្តាហ៍។ |

## ៣០.៥.៥ រោគសើស្បែកបង្កដោយវីរុស

### តារាងទី៣០-២ រោគសើស្បែកបង្កដោយវីរុស

| រោគសើស្បែកបង្កដោយវីរុស |
|---|
| **Herpes simplex ១, ២**<br>Orolabial lesions ដំបៅប្រដាប់ភេទ<br>ពងទឹកមានបាតពិណក្រហមនៅបបូរមាត់ ច្រមុះ អណ្តាត បំពង់ក អញ្ចាញធ្មេញ និងជំបន់ប្រដាប់បន្តពូជ ។<br>ការពិនិត្យគ្លីនិក និងធ្វើតេស្ត Tzank<br>ការគ្រប់គ្រងព្យាបាល: Acyclovir ៤០០ម.ក្រ ៥ដង/ថ្ងៃ រយៈពេល៧ថ្ងៃ ។<br>លាប Gentian violet អាចជួយកាត់បន្ថយការបង្ករោគដោយពពួកបាក់តេរី ។ |
| **ជំងឺរើម** (**Herpes Zoster, shingles**)<br>បង្កដោយវីរុស Herpes Zoster (reactivation)<br>កើតឡើងជាញឹកញាប់លើអ្នកជំងឺអេដស៍។ មានដុំពងទឹក ហើយឈឺ នៅពាសពេញស្បែក – បន្ទាប់មកស្បែកឡើងក្រៀម កំរឆ្លងកាត់ខ្សែបន្ទាត់ពាក់កណ្តាលខ្លួន អាចបណ្តាលឱ្យខូចភ្នែក។<br>រោគវិនិច្ឆ័យ ផ្អែកលើគ្លីនិក និងតេស្ត Tzank។<br>ការព្យាបាល: Acyclovir ៨០០ម.ក្រ ៥ដង/ថ្ងៃរយៈពេល ៧–១០ថ្ងៃ។<br>លាប Gentian violet អាចជួយកាត់បន្ថយការបង្ករោគបន្ថែមទៀត។<br>លាប Calamine lotion លើដំបៅស្បែក។ |

| |
|---|
| **ជំងឺអុតធំ** (Herpes Zoster, chicken pox)<br>បង្កដោយវីរុស Herpes Zoster (បង្ករោគដំបូង)<br>រយៈពេលសម្ងំ ៣ថ្ងៃ លេចចេញស្នាមដុំពងទឹកលើស្បែកពាសពេញស្បែក ជា "គ្រាប់"ៗ ។<br>អាចបណ្តាលឱ្យមានផលលំបាក ទៅជា ជំងឺរលាកសួត រលាកថ្លើម និង រលាកខួរក្បាល ។<br>ការព្យាបាល: Acyclovir ៨០០ម.ក្រ ៥ដង/ថ្ងៃ រយៈពេល៧–១០ថ្ងៃ ។<br>លាប Gentian violet អាចជួយកាត់បន្ថយការបង្ករោគបន្ថែមទៀត ។<br>លាប Calamine lotion ។ |
| ជំងឺ **Molluscum contagiosum**<br>មូលហេតុបង្ករោគដោយ វីរុស *Molluscum contagiosum* ។<br>ពងទឹករាងដូចសាជីខូងចំណុចកណ្តាល និងអ្នកជំងឺមិនស្រួលខ្លួន ។<br>ត្រូវវែកញែកភាពខុសគ្នារវាងជំងឺ Cryptococcus ឬ ជំងឺ Penicillium ឬ Histoplasmosis (ជាធម្មតា មានសភាពមិនស្រួលខ្លួន) ។<br>ការព្យាបាល: ដោយខ្លួនឯងនៅមានកំរិត (Self-limiting) ឬ បើកមុខពងទឹកដោយប្រើប្រាស់ម្ជុលដែលរម្ងាប់មេរោគត្រឹមត្រូវ និងបូបទឹកចេញ លាងសំអាត ឬ ទឹក liquid nitrogen cryotherapy ។ |
| **ជំងឺសិរមាន់** (Warts)<br>បង្កដោយវីរុស Human papilloma<br>ដំបៅស្បែករាងដូចផ្កាខាត់ណា (Cauliflower-like lesions) នៅដំបន់ប្រដាប់ភេទ និងជុំវិញរន្ធគូថ អាចកើតមាននៅដំបន់ផ្សេងៗ និង ដំបៅរាបស្មើលើផ្ទៃបាតជើង ។<br>ការព្យាបាល: បើមិនប៉ះពាល់ស្រទាប់ក្រោមស្បែក (Non-mucosal affected areas): លាបសូលុយស្យុង podophyllotoxin ០,៥% ២ដង/ថ្ងៃ រយៈពេល ៣ថ្ងៃបន្តបន្ទាប់គ្នាក្នុង១សប្តាហ៍ រហូតដល់ ៤សប្តាហ៍(អតិបរិមា)។ ការពារស្បែកមិនប៉ះពាល់ដោយលាប vaseline ឬ zinc ointment បន្ទាប់មកលាងទឹកនិងសាប៊ូចេញ ក្រោយរយៈពេល ១-៤ ម៉ោង។ មិនត្រូវព្យាបាលដោយឱសថទាំងនេះ ក្នុងកំឡុងពេលមានផ្ទៃពោះទេ ។ ត្រូវព្យាបាលដោយ Cryotherapy ប្រសិនជាមាន។ |

## ៣០.៥.៦ ការបង្ករោគស្បែកដោយពពួកផ្សិត

**តារាងទី៣០-៣ ការបង្ករោគសើស្បែកដោយពពួកផ្សិត**

| ការបង្ករោគសើស្បែកដោយពពួកផ្សិត |
|---|
| **ជំងឺអង្គែក្បាល** (រោគស្រែងលលាដ៍ក្បាល)<br>បង្កដោយ **Tinea corporis, Tinea capitis, Tinea pedis.**<br>កើតនៅ ដងខ្លួន មុខ អវយវៈ ដំបៅរាងដូចរង្វង់ចិញ្ចៀនមានគែមពណ៌ក្រហម និងចំណុចកណ្តាលជាសះស្បើយ ។<br>**ការធ្វើរោគវិនិច្ឆ័យ**: ភាគច្រើនរោគសញ្ញាគ្លីនិក |

| |
|---|
| **ការព្យាបាល**: ធ្វើដំបន់សើមឱ្យស្ងួត។<br>Whitfield's ointment (benzoic acid ជាមួយ salicylic acid) ២ដង/ថ្ងៃ រយៈពេល ២ទៅ ៥ សប្តាហ៍លើកន្លែងដំបៅស្បែក ។<br>ឬ ២% miconazole ឬ ១% clotrimazole cream រយៈពេល ២ទៅ ៥សប្តាហ៍ ។<br>ជំងឺមានការរាលដាល និងព្យាបាលជំងឺ tinea capitis ដោយប្រើ systemic fluconazole ១៥០ម.ក្រ ១សប្តាហ៍/ម្តង រយៈពេល ៤ សប្តាហ៍ ។ |
| **ជំងឺ** Tinea onichomycosis<br>បង្កដោយ Tinea unguium<br>ក្រើនខ្លាំងនៅផ្ទៃខាងក្រោមក្រចក ។<br>**ការធ្វើរោគវិនិច្ឆ័យ**: ការពិនិត្យរកពពួកផ្សិតដោយអតិសុខុមទស្សន៍ និងការបណ្តុះមេរោគផ្សិត<br>**ការព្យាបាល**: ព្យាបាលការបង្ករោគដោយ onychomycosis តែក្នុងករណីធ្ងន់ធ្ងរប៉ុណ្ណោះ ដោយប្រើឱសថ Itraconazole ២០០ម.ក្រ ២ដង/ថ្ងៃ លេបរាល់ថ្ងៃក្នុងរយៈពេល៧ថ្ងៃដំបូង នៃរយៈពេល ៤ខែជាប់គ្នា ឬ ព្យាបាលដោយឱសថ Terbenafine ប្រសិនបើមាន។<br>ពិនិត្យមើលអន្តរកម្មឱសថជាមួយឱសថ ARV ។ |
| **ជំងឺស្បែកបង្កដោយកង់ឌីដា** (Cutaneous candidiasis)<br>បង្កដោយកង់ឌីដា អាល់ប៊ីកង់<br>កើតនៅតំបន់បែកញើសមានសំណើម - ស្បែកផ្នត់ ស្នាមកន្ទួលលើស្បែកពណ៌ក្រហម មានគែមកំណត់ច្បាស់ ។ កើតឡើងផងដែរនៅលើប្រដាប់ភេទ ឬ paronychia ។<br>**ការព្យាបាល**: លាបសូលុយស្យុងTopical ១% aqueous gentian violet, Topical nystatin ឬ miconazole ៣ដង/ថ្ងៃ រហូតដល់ ៤៨ម៉ោង ក្រោយពេលស្នាមកន្ទួលលើស្បែកបានប្រសើរឡើង។ |

### ៣០.៥.៧ រោគថៃ (Scabies)

**តារាងទី៣០-៤ ការបង្ករោគដោយ *Scabies***

| ការបង្ករោគដោយ Scabies |
|---|
| **រោគថៃ**<br>បង្ករោគដោយ Sarcoptes scabiei var. hominis<br>ដំបៅរមាស់ពងបែក ជាពិសេស នៅចង្កេះម្រាមដៃ និងម្រាមជើង ផ្នត់កដៃ តំបន់គន្លាក់ដៃ និងក្លៀក។<br>**ការព្យាបាល:** Benzyl Benzoate ២៥% lotion ឬ Permethrin ៥% cream: លាបលើដងខ្លួន លើកលែងតែនៅក្បាល/មុខ ទុករយៈពេល១២ម៉ោង បន្ទាប់មកលាងសំអាតចេញ លាបសារជាថ្មីម្តងទៀតក្នុងរយៈពេល៧ថ្ងៃ ។ |
| **រោគថៃ** Crusted (Norwegian) scabies<br>បង្កដោយ Sarcoptes scabiei var. hominis |

| |
|---|
| បង្ករោគដោយពពួកសត្វល្អិតរាប់លាន និងឆ្លងខ្លាំងណាស់ ។<br>ស្បែករបកស្រកាក្រាស់ ជាពិសេស នៅត្រង់កែងដៃ ក្រោយកញ្ចឹងកនិងត្រចៀក គូថ។ មិនមែនតែងតែរមាស់ទេ ការបង្ករោគដោយបាក់តេរីជាលើកទី២ កើតមានជាញឹកញាប់ ។<br>ការព្យាបាលៈ ជាញឹកញាប់ ត្រូវព្យាបាលរោគកមរមាស់ (ថៃ) ដល់សមាជិកគ្រួសារទាំងមូល - និងបោកសម្អាតសម្លៀកបំពាក់ទាំងអស់ រួមទាំង ភួយ ខ្នើយ កំរាលពូកនិងគ្រែ ។<br>ការព្យាបាលជាប្រព័ន្ធ ដោយប្រើឱសថ Ivermectin ២០០ម.ក្រ/គ.ក្រ លេបតែ១កម្រិតដូស នឹងបន្តការព្យាបាលឡើងវិញនៅថ្ងៃទី០ ថ្ងៃទី៧ ថ្ងៃទី១៤ ។<br>ប្រសិនជាគ្មាន ត្រូវព្យាបាលដោយ topical therapy លាបរាល់ថ្ងៃនៅថ្ងៃទី២ ជាមួយ topical keratolytics ដោយឆ្លាស់ថ្ងៃគ្នា (ឧ. salicylic acid ៥–១០% in sorbolene, ឬ lactic acid ៥% + urea ១០% in sorbolene)។<br>ពិភាក្សាជាមួយគ្រូពេទ្យជំនាញ។ |

## ៣០.៥.៨ ដំបៅស្បែកដែលមិនមែនបង្កដោយជំងឺឆ្លង (Non infective skin lesions)

**តារាងទី៣០-៥ ដំបៅស្បែកដែលមិនមែនបង្កដោយជំងឺឆ្លង**

| ដំបៅស្បែកដែលមិនមែនបង្កដោយជំងឺឆ្លង |
|---|
| *ការរលាកស្បែក ក្រពេញបញ្ចេញញើស (Seborrheic Dermatitis)*<br>ការរលាកស្បែកក្រពេញបញ្ចេញញើស កំណត់ដោយស្បែកស្ងួត ស្បែកឡើងស្រកា (flaky) ឬរបកស្រកា ដែលកើតឡើងនៅលើស្បែកក្បាល គេអាចមើលឃើញនៅមុខ លើគន្លាក់ខ្នងច្រមុះ និងបបូរមាត់ (nasolabial) លើស្បែកនៅពីក្រោយត្រចៀក និងចិញ្ចើម។<br>**ការព្យាបាល**: Selenium sulfide ឬសាប៊ូ ketoconazole កក់លើស្បែកក្បាលដែលមានដំបៅ។ លាប Topical steroids លើកន្លែងមានដំបៅ ៣ដង/ថ្ងៃ។ ត្រូវប្រើតែ ១% hydrocortisone cream លាបលើផ្ទៃមុខ ព្រោះវាអាចបណ្តាលឱ្យស្បែកស្វិត ។ ករណីធ្ងន់ធ្ងរ អាចប្រើ (betamethasone ១០%) លាបនៅដំបន់ផ្សេងៗបានដែរ ។ |
| *ជំងឺ Pruritic Papular Eruption (PPE)*<br>កើតមានជាញឹកញាប់ លើអ្នកជំងឺអេដស៍ដែលមានចំនួនកោសិកា CD4 < ២០០កោសិកា/ម.ម³<br>ផ្លាយបែកដំបៅពងទឹកលើស្បែក ជាទូទៅកើតនៅពាសពេញដងខ្លួន និងនៅចុងដៃចុងជើង អាចពាក់ព័ន្ធនឹងវិបត្តិនៃការឆ្លើយតបនឹងការរលាកបង្កដោយអង់ទីស្សែន ដូចជា ដូចជាកន្លែងមូសខាំញឹកញាប់ ។<br>រមាស់ខ្លាំងណាស់។<br>**ការព្យាបាល**: ជាទូទៅ មិនឆ្លើយតបទៅនឹងការព្យាបាល ក្រៅពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។ លេប antihistamines អាចជួយបន្ធូរបន្ថយរោគសញ្ញា ។ |

| |
|---|
| ***ជំងឺ Eosinophilic folliculitis***<br>ហើម ក្រហម ស្បែកពងទឹកឡើងក្រហម និងពងខ្ទុះ (pustules)<br>នៅលើមុខ ស្បែកក្បាល ក និងទ្រូង រមាស់។<br>ការព្យាបាល: អាចកើតសារចុះសារឡើង និងរោគសញ្ញាប្រសើរឡើងវិញក្រោយពេលចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ លេប antihistamines អាចជួយបន្ធូរបន្ថយរោគសញ្ញា ។ |
| ***ជំងឺ Psoriasis***<br>រោគស្បែករបកក្រហមរាលដាល សង្កេតឃើញកើតឡើងលើអ្នកជំងឺដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយខ្លាំង។<br>បានបង្ហាញជាមួយ បន្ទះស្បែកក្រាស់ ស្បែកក្បាលពណ៌ទឹកប្រាក់ ភាគច្រើននៅលើផ្ទៃសាច់ដុំ ។ អាចមាននៅម្រាមដៃ និងក្រចកជើង ក្លៀក និងក្រចកឡើងក្រាស់ មិនទៀងទាត់ (onychodystrophy) ។<br>**ការព្យាបាល**: រួមមានការហាលកំដៅថ្ងៃ ប្រើ coal tar ៥-១០% ointment in salicylate ointment ២ ដង/ថ្ងៃ រាល់ថ្ងៃ ជាមួយសាប៊ូ coal tar (បើមានការប៉ះពាល់ដល់ស្បែកក្បាល) និងប្រើ potent topical steroids (betamethasone 0,១% ឬ Diprosalic cream លាបលើកន្លែងដំបៅ ១-២ដង/ថ្ងៃ រយៈពេល១៤ថ្ងៃ ។<br>ជាទូទៅ មិនឆ្លើយតបទៅនឹងការព្យាបាល ក្រៅពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ |
| ***ជំងឺ Kaposis Sarcoma (កំរមានណាស់នៅ អាស៊ី)***<br>ជាជំងឺមហារីកបង្កដោយវីរុស HHV8 ដំណាក់កាលគ្លីនិកទី៤ នៃ WHO។<br>មានផ្ទាំងពងទឹកមួយ ឬច្រើន ពណ៌ស្វាយ ជាញឹកញាប់មានផ្ទៃរលូន ប៉ុន្តែអាចមានស្រកាស្បែក ឬដំបៅ ។<br>កើតមាននៅគ្រប់ទីកន្លែងលើស្បែក ជាញឹកញាប់នៅ ក្រអូមមាត់ខាងលើ នៅជើង អាចមាន/គ្មានការហើមជើង។<br>សរីរាងខាងក្នុង នៃជំងឺ KS រួមមាន ទ្រូង - ឡើងខ្ទុះក្នុងសួត សរីរាង្គក្នុងពោះ (ឈាមក្នុងលាមក)។<br>ការព្យាបាលៈ ចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ពិភាក្សាជាមួយគ្រូពេទ្យជំនាញ អំពីតម្រូវការនៃការព្យាបាលដោយ radio /chemotherapy ។ |

រូបភាពទី៣០-១ គំនូសបំព្រួញអំពីស្នាមកន្ទួលលើស្បែកដែលមានការឈឺចាប់



រូបភាពទី៣០-២ គំនូសបំព្រួញអំពីស្នាមកន្ទួលលើស្បែកដែលគ្មានការឈឺចាប់ រមាស់



រូបភាពទី៣០-៣ គំនូសបំព្រួញអំពីស្នាមកន្ទួលលើស្បែកដែលមានរមាស់



រូបភាពទី៣០-៤ គំនូសបំព្រួញអំពីស្នាមកន្ទួលលើស្បែកធ្ងន់ធ្ងរ



# ជំពូក ៣១. ការបង្ករោគតាមផ្លូវបន្តពូជនិងកាមរោគ

- វាជាការសំខាន់ណាស់ដែលអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ និងដៃគូរបស់ពួកគាត់ ត្រូវបានទទួលការថែទាំនិងព្យាបាលជំងឺកាមរោគ ១)ក្នុងគោលបំណងដើម្បីថែទាំសុខភាពរបស់អ្នកជំងឺ និង ២)ដោយសារតែជំងឺកាមរោគបង្កើនហានិភ័យការឆ្លងរាលដាលនៃមេរោគអេដស៍ ។
- ជាទូទៅ ការវាយតម្លៃនិងការព្យាបាលជំងឺកាមរោគលើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ គឺដូចគ្នាជាមួយបុគ្គលដែលមិនផ្ទុកមេរោគអេដស៍ ។
- សូមអានគោលការណ៍ណែនាំព្យាបាលជំងឺកាមរោគរបស់ NCHADS ជាពិសេស ម៉ូឌុលទី៥ ជំពូកទី៦៖ ការថែទាំនិងព្យាបាលជំងឺកាមរោគ/បង្ករោគនៅប្រដាប់បន្តពូជ លើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍[៤៧] ។
- សូមអានផ្នែកគោលការណែនាំនេះ ក្នុង ជំពូក ៣. ស្ត្រីដែលស្ថិតក្នុងវ័យបន្តពូជ។

## ៣១.១ ជំងឺបង្កដោយកង់ឌីដាលើទ្វារមាស (Vaginal candidiasis)

ជំងឺ Vaginal candidiasis កើតឡើងញឹកញាប់ជាងគេ បង្កជាបញ្ហាលើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ភេទស្រីមួយចំនួន ។

## ៣១.២ រោគសញ្ញាគ្លីនិក

រោគសញ្ញា: រមាស់ ឬ អារម្មណ៍ក្តៅ និងធ្លាក់ស ។
ការពិនិត្យ: ធ្លាក់សតាមទ្វារមាស ដែលមានសភាពដូចបន្ទះឈីស (cheese-like plaques) នៅតំបន់ទ្វារមាសមានពណ៌ក្រហម ហើម និងរឹងតិចៗ(tender) ។

## ៣១.៣ ការធ្វើរោគវិនិច្ឆ័យ

ការព្យាបាល ត្រូវឈរលើមូលដ្ឋានរោគសញ្ញាគ្លីនិក និងការរកឃើញរោគសញ្ញាពេលពិនិត្យគ្លីនិក ។
សូមពិចារណាផងដែរ ពីមូលហេតុផ្សេងទៀតនៃការធ្លាក់សតាមទ្វារមាស រួមទាំង ការបង្ករោគដោយបាក់តេរីនៅទ្វារមាស (Bacterial Vaginaosis) និងជំងឺរលាកទ្វារមាសបង្កដោយមេរោគប្រមេះ Chlamydia និង Trichomonas ។ ជាពិសេស នៅពេលគ្មានរោគសញ្ញាគ្លីនិកច្បាស់លាស់ ឬការព្យាបាលគ្មានប្រសិទ្ធភាព។

---

[៤៧] ព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាល។ គោលការណ៍ ណែនាំជាតិសំរាប់គ្រប់គ្រងករណីការឆ្លងកាមរោគ និងការបង្ករោគតាមប្រព័ន្ធបន្តពូជ។ ឆ្នាំ២០១០ ម៉ូឌុល៦ ជំពូក៦ ទំព័រ ២១៧ -២២២

## ៣១.៤ ការព្យាបាលស្ពូងជា

(ជំរើសណាមួយ នៃជំរើសខាងក្រោម)

- Clotrimazole vaginal cream ៥ក្រ/ថ្ងៃ ឬ clotrimazole vaginal suppository ១០០ម.ក្រ សុល១ថ្ងៃ/ម្ដង រយៈពេល ៣-៧ថ្ងៃ ឬ clotrimazole ៥០០ ម.ក្រ suppository សុលតែម្ដងគត់ ។
- Miconazole cream ៥ក្រាម/ថ្ងៃ ឬ ១០០ម.ក្រ vaginal suppository រាល់ថ្ងៃ រយៈពេល ៧ ថ្ងៃ ។
- Nystatin ១០០.០០០ units vaginal suppository រាល់ថ្ងៃ រយៈពេល ១៤ថ្ងៃ ។

## ៣១.៥ ការព្យាបាលជំងឺបង្កដោយគង់ឌីដានៅទ្វារមាស

- Fluconazole ១៥០-២០០ ម.ក្រ ប្រើតែម្ដង (ប្រើឱសថដែលមានឥទ្ធិពលយូរ អាចនឹងពិចារណាយក ប្រើប្រាស់ ក្នុងករណីធ្ងន់ធ្ងរ) ។

# ជំងឺមហារីក បណ្ដាលមកពីមេរោគអេដស៍

# ជំពូក ៣២. ជំងឺមហារីកបណ្ដាលមកពីមេរោគអេដស៍

ជំងឺមហារីកប្រភេទ lymphoma លើប្រព័ន្ធសរសៃប្រសាទកណ្ដាល (Primary CNS lymphoma) ឬ B cell non-Hodkin's lymphoma (ពាក់ព័ន្ធជាមួយវីរុស EBV) មហារីកមាត់ស្បូនក្នុងដំណាក់កាលរាលដាល (invasive cervical carcinoma ទាក់ទងនឹងវីរុស HPV) និងមហារីក Kaposi's sarcoma (បណ្ដាលមកពីវីរុស HHV-8) គឺជាប្រភេទជំងឺ ដែលចាត់ចូលក្នុងដំណាក់កាលគ្លីនិកទី៤ នៃ WHO ។ អត្រាជំងឺមហារីកដែលមិនទាក់ទងនឹងជំងឺមេរោគអេដស៍ ក៏មានកម្រិតខ្ពស់ផងដែរ ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ឧ.មហារីកសួត ។

ជម្រើសនៃការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺមហារីក នៅប្រទេសកម្ពុជានៅមានកម្រិត ។ ការ ផ្ដោតសំខាន់បំផុត គឺការបង្ការជំងឺមហារីក តាមរយៈការធ្វើរោគវិនិច្ឆ័យមេរោគអេដស៍ឱ្យបានឆាប់រហ័ស និងការចាប់ផ្ដើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ភ្លាមៗ ។ លើសពីនេះទៅទៀត ត្រូវជម្រុញវិធានការបង្ការផ្សេងទៀត ជាពិសេស ការអប់រំក្នុងការបញ្ឈប់ការជក់បារី (សូមមើលរូបភាពទី ៣៥-១៖ ឧបករណ៍ផ្ដល់ប្រឹក្សាជាជំនួយដល់បុគ្គលដែលចង់ឈប់ជក់បារី យោងតាម WHO) ។

## ៣២.១ ជំងឺមហារីក Non-Hodgkin's lymphoma (NHL)

ជំងឺមហារី NHL កើតឡើងជាញឹកញាប់ លើអ្នកជំងឺអេដស៍ក្នុងដំណាក់ធ្ងន់ធ្ងរ (CD4 < ៥០កោសិកា/មម$^{៣}$) និងលេចចេញរោគសញ្ញាខាងក្រោម ៖

- Systemic NHL (>៨០%)
- ជំងឺមហារីក lymphoma នៅប្រព័ន្ធសរសៃប្រសាទកណ្ដាល (១៥%)
- ជំងឺមហារីក lymphoma ដំបូង រាលដាលច្រើនកន្លែង (ឬនៅ body cavity) (<៥%) ។

### រោគសញ្ញាគ្លីនិក

លេចចេញរោគសញ្ញាគ្លីនិក ស្រដៀងគ្នាទៅនឹងជំងឺរបេង និងត្រូវបានចាត់ទុកថា ជាជំងឺមហារីក ប្រសិនបើបរាជ័យក្រោយពីការព្យាបាលជំងឺរបេង ក្នុងនោះរួមមាន គ្រុនក្ដៅ ឡើងកូនកណ្ដុរ (lymphadenopathy) អស់កម្លាំង ស្រកទម្ងន់ បែកញើសពេលយប់ អណ្ដើករីកធំ (splenomegaly) ថ្លើមរីកធំ (hepatomegaly) និងមានភស្តុតាងបញ្ជាក់ពីការជ្រៀតចូលនៅផ្នែកណាមួយ (focal infiltrates) និងថយចុះកោសិកាឈាមទាំងអស់ (CBC)។

តារាងទី ៣២-១ រោគសញ្ញានៃ *NHL* អាស្រ័យតាមកន្លែងបង្ករោគ

| ដុំមហារីកនៅជំបន់ Mediastin ឬនៅបំពង់ក | ដុំមហារីកនៅក្នុងពោះ |
|---|---|
| ពិបាកដកដង្ហើម ដកដង្ហើមញាប់ ដកដង្ហើមលឺសំលេង ក្អក ថយចុះសំលេងដង្ហើមនៅតាមកន្លែង។ | ការប៉ោងតឹងពោះ ទាចទឹក ដុំពោះ កើតលឿងការឈឺចាប់ ។ |
| **ជំងឺប្រព័ន្ធប្រសាទកណ្តាល** | **ដុំមហារីកនៅតំបន់មុខនិងថ្គាម (Maxillofacial tumor)** |
| ឈឺក្បាល ក្អួត វិបត្តិគំហើញ បាត់លំនឹងពេលដើរ ខ្វិនសរសៃប្រសាទខួរក្បាល (Cranial nerve palsies) ខ្វិនមួយចំហៀងខ្លួន ប្រកាច់។ | ដុះដុំនៅតំបន់ថ្គាម ស្ពឹកស្រពន់ចង្កា (ការគៀបសង្កត់សរសៃប្រសាទបញ្ជាផ្ទៃមុខ) (peripheral facial nerve compression ) ។<br>ការសំដែងទឹកមុខពុំមានលក្ខណៈស៊ីមេទ្រីគ្នា (Asymmetric facial expression) ។ |

**ការធ្វើរោគវនិច្ឆ័យ**

ក្នុងស្ថានភាពភាគច្រើន មានការលំបាកក្នុងការធ្វើរោគវិនិច្ឆ័យ អ្នកជំងឺត្រូវទទួលការព្យាបាលជំងឺរបេងសាកល្បងជាមុនសិន ។ ប្រសិនបើ គ្មានការឆ្លើយតបនឹងការព្យាបាលទេ ត្រូវបញ្ជូនអ្នកជំងឺទៅធ្វើការវាយតម្លៃ និងគ្រប់គ្រងព្យាបាលបន្ថែមទៀត ។ ការធ្វើរោគវិនិច្ឆ័យជាក់លាក់ គឺតម្រូវឱ្យច្រិបយកជាលិកាទៅវិភាគ (histopathology) ។

**ជម្រើសនៃការព្យាបាលជំងឺមហារីក** នៅប្រទេសកម្ពុជានៅមានកម្រិត។ប្រសិនបើអាចត្រូវបញ្ជូនអ្នកជំងឺទៅព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតដើម្បីធ្វើការវាយតម្លៃនិងព្យាបាលជំងឺមហារីក។

## ៣២.២ មហារីកមាត់ស្បូន

ជំងឺមហារីកមាត់ស្បូន កើតញឹកញាប់ជាងគេនៅទូទាំងពិភពលោក ។ វាបង្កឡើងដោយការបង្ករោគដោយវីរុស HPV នៅមាត់ស្បូន ដោយមិនត្រូវបានជម្រះដោយឯកឯង បន្តវិវត្តន៍ទៅតាមពេលវេលា ចូលក្នុងកោសិកាអេពីតេលីយ៉ូមនៃមាត់ស្បូន (cervical intraepithelial dysplasia= CIN) និងបង្កជាជំងឺមហារីកមាត់ស្បូនរាលដាល ។ អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ មានសំណាងតិចតួចក្នុងការជម្រះការបង្ករោគដោយវីរុស HPV និងមានអត្រាអាំងស៊ីដង់ជំងឺ CIN ខ្ពស់ និងទំនងនឹងមានការវិវត្តន៍ទៅជំងឺមហារីករាលដាល បើប្រៀបធៀបជាមួយស្ត្រីដែលមិនផ្ទុកមេរោគអេដស៍ ។ កត្តាហានិភ័យរួមចំណែកដទៃទៀតនៃជំងឺមហារីកមាត់ស្បូន រួមមាន ការជក់បារី និងការបង្ករោគដោយជំងឺកាមរោគ ផ្សេងៗ ។

## ការបង្ការជំងឺមហារីកមាត់ស្បូន

- ចាក់វ៉ាក់សាំងបង្ការវីរុស HPV (មិនបានធ្វើជាប្រចាំនៅប្រទេសកម្ពុជាទេ) គឺជាវីរុសបង្កហេតុជំងឺមហារីកមាត់ស្បូន គួរតែត្រូវចាក់វ៉ាក់សាំងបង្ការដល់ក្មេងស្រីជំទង់មុនពេលចាប់ផ្តើមសកម្មភាពផ្លូវភេទ ។
- ឆ្លើយតបទៅនឹងកត្តាហានិភ័យផ្សេងទៀត៖ បញ្ឈប់ការជក់បារី ចៀសវាងការឆ្លងជំងឺកាមរោគ និងព្យាបាលជំងឺកាមរោគឱ្យបានឆាប់ ។
- ធ្វើរោគវិនិច្ឆ័យការឆ្លងមេរោគអេដស៍ឱ្យបានឆាប់ និងចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំង មេរោគភ្លាមៗ ។
- ការពិនិត្យស្រាវជ្រាវ (Screening)៖ រកឃើញតាមរយៈការពិនិត្យស្រាវជ្រាវ អាចកើតឡើងក្នុងរយៈពេលជាច្រើនឆ្នាំ មុនពេលលេចចេញរោគសញ្ញាគ្លីនិកនៃជំងឺមហារីករាលដាល ។ វិធីសាស្ត្រនៃការពិនិត្យស្រាវជ្រាវ រួមមាន ការវិភាគកោសិកា (Cytology) (Papanicolou ឬ លាប "Pap" លើសំណាកកោសិកាមាត់ស្បូន និង/ឬធ្វើតេស្ត HPV PCR ដែលកំណត់ពីដំបៅដែលអាចព្យាបាលធម្មតា ។ នៅក្នុងប្រទេសដែលធនធាននៅមានកំរិត វិធីសាស្ត្រក្នុងការពិនិត្យផ្ទាល់ភ្នែក ត្រូវបាន អនុវត្តន៍ (លាយអាស៊ីត acetic (VIA) ឬអ៊ីយ៉ូតរបស់ Lugol ) ក្រោយពីព្យាបាលដោយ cryotherapy ប្រសិនជាអាចធ្វើបាន ដូចជា សេវាពិនិត្យស្រាវជ្រាវ និងព្យាបាលតែមួយ ។ ប្រសិនបើមាន លទ្ធភាពត្រូវបញ្ជូនស្ត្រីដែលមានអាយុលើសពី ៣៥ឆ្នាំទាំងអស់ មកធ្វើការពិនិត្យស្រាវជ្រាវជំងឺមហារីកមាត់ស្បូន ។

## រោគសញ្ញាគ្លីនិក

ជំងឺ Cervical dysplasia និងជំងឺមហារីក ជាធម្មតា គ្មានរោគសញ្ញា រហូតដល់ដំណាក់កាលចុងក្រោយ ប៉ុន្តែវាអាចបង្ហាញរោគសញ្ញាឆ្លាស់គ្នារវាងការហូរឈាមតាមទ្វារមាស និងការធ្លាក់ស ការហូរឈាមបន្ទាប់ពីសកម្មភាពផ្លូវភេទ ធ្លាក់សតាមទ្វារមាស ។ ស្ត្រីដែលកើតជំងឺមហារីករាលដាល អាចបង្ហាញរោគសញ្ញាដោយ គ្រុនក្តៅ ស្រកទម្ងន់ ឈឺចាប់នៅដំបន់ឆ្អឹងអាងត្រគាក ឬផ្នែកខាងក្រោមពោះ ស្ទះតម្រងនោម ឬទល់លាមក ហូរលាមកតាមទ្វារមាស ឬអាចលាយឈាម ឬលាមកក្នុងទឹកនោម ។ វាជាការសំខាន់ណាស់ ក្នុងការពិនិត្យអាងត្រគាក រួមបញ្ចូលទាំង ការត្រួតពិនិត្យមើល និងការស្ទាប(palpation) រកមើលរោគសញ្ញាទាំងអស់នេះ ។

## ការព្យាបាល

ជម្រើសនៃការព្យាបាលនៅមានកម្រិតនៅក្នុងប្រទេសកម្ពុជា ទោះជាយ៉ាងណា ប្រសិនបើអាច ត្រូវបញ្ជូនអ្នកជំងឺទៅព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត សម្រាប់ពិនិត្យស្រាវជ្រាវ និងព្យាបាលបន្ថែមទៀតនៃជំងឺ cervical dysplasia ដោយធ្វើការវះកាត់ ឬ ដុតមាត់ស្បូនដោយប្រើចរន្ត អគ្គីសនី ឬវិធី វះកាត់យកមាត់ស្បូនចេញ (cone excision procedures)។ ការព្យាបាលជំងឺមហារីកមាត់ស្បូន រួមមាន ការវះកាត់យកស្បូនចេញ ការព្យាបាលដោយបាញ់កាំរស្មី និងប្រើឱសថប្រឆាំងមហារីក (chemotherapy) ។

# អាហារូបត្ថម្ភ និង ជំងឺមិនឆ្លងរ៉ាំរ៉ៃ

# ជំពូក ៣៣. អាហារូបត្ថម្ភ និងការគ្រប់គ្រងទម្ងន់លើមនុស្សពេញវ័យនិងក្មេងជំទង់ដែលផ្ទុកមេរោគ អេដស៍

## ៣៣.១ ចំណុចគន្លឹះ

- អ្នកជំងឺអេដស៍ (ជាពិសេសអ្នកជំងឺដែលមិនទាន់បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍) បានបង្កើនអត្រាមេតាប៉ូលីស និងតម្រូវការអាហារូបត្ថម្ភ បណ្តាលមកពីការបង្ករោគ ឱកាសនិយមសារចុះសារឡើង និងការបង្ករោគដោយមេរោគអេដស៍ ។
- ជំងឺកង្វះអាហារូបត្ថម្ភទាក់ទងនឹងជំងឺអេដស៍ បណ្តាលឱ្យកើនឡើងការប្រឈមមុខនឹងការបង្ករោគឱកាសនិយម និងកើនឡើងអត្រាមរណៈភាព ។
- អ្នកជំងឺអេដស៍ បង្កើនតម្រូវការកាល់ឡូរីបន្ថែមពី ១០-៣០% ។
- ការបរិភោគអាហារមិនគ្រប់គ្រាន់ អាចបណ្តាលមកពីកង្វះលទ្ធភាពទទួលបានអាហារសមស្រប មិនសូវចង់ហូបអាហារ មានរោគសញ្ញាគ្លីនិក ឬវិបត្តិនៃការស្រូបយកនៃសារជាតិចិញ្ចឹម(malabsorption) បណ្តាលមកពី វិបត្តិប្រដាប់រំលាយអាហារ ។
- ម៉្យាងទៀត អ្នកជំងឺអេដស៍ដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ អាចនឹងលើសទម្ងន់ និងមានហានិភ័យជំងឺទឹកនោមផ្អែម ជំងឺលើសសម្ពាធឈាម និងជំងឺសរសៃឈាមបេះដូង ។
- វាជាការសំខាន់ណាស់ ក្នុងការតាមដានទម្ងន់ សន្ទស្សន៍ body mass index (BMI) និងស្ថានភាពអាហារូបត្ថម្ភលើគ្រប់អ្នកជំងឺអេដស៍ទាំងអស់ ។

## ៣៣.២ និយមន័យនៃជំងឺកង្វះអាហារូបត្ថម្ភ

និយមន័យធម្មតានៃជំងឺកង្វះអាហារូបត្ថម្ភគឺ ″ជាលក្ខខណ្ឌមួយដែលជាលទ្ធផលនៃការបរិភោគចំណីអាហារជាមូលដ្ឋាន និងសារជាតិចិញ្ចឹម មិនបានសមស្រប អាចធ្វើឱ្យចុះខ្សោយសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត ព្រមទាំង បង្កើនការប្រឈមមុខនឹងការបង្កជំងឺផ្សេងៗ″ ។

រូបភាពទី៣៣-១ វដ្តនៃជំងឺកង្វះអាហារូបត្ថម្ភ និងជំងឺអេដស៍[៤៨]




## ៣៣.៣ ការពិនិត្យស្រាវជ្រាវជំងឺកង្វះអាហារូបត្ថម្ភ និងការគ្រប់គ្រងទម្ងន់

### ៣៣.៣.១ ការវាយតម្លៃលើកដំបូង

១. សួរអ្នកជំងឺ ប្រសិនកបើ អ្នកជំងឺដឹងពីទម្ងន់ខ្លួន (BBW) នៅដំណាក់កាលដើមគ្រា មុនពេលធ្លាក់ខ្លួនឈឺ។

- វាយតម្លៃការផ្លាស់ប្តូរទម្ងន់ជា % ធៀបនឹងទម្ងន់ BBW
  ការផ្លាស់ប្តូរទម្ងន់ជា % = (BBW - ទម្ងន់បច្ចុប្បន្ន) / BBW x ១០០
- ស្រកទម្ងន់នៃដំណាក់កាល WHO គឺផ្អែកតាមការផ្លាស់ប្តូរទម្ងន់ធៀបនឹងទម្ងន់ BBW
  <១០% = ដំណាក់កាលទី២នៃ WHO > ១០% = ដំណាក់ទី៣ នៃ WHO និង HIV wasting syndrome = ដំណាក់កាលទី៤ នៃ WHO ។

២. គណនា body mass index (BMI) – វាស់កម្ពស់ និងថ្លឹងទម្ងន់

- BMI = ទម្ងន់គិតជា(គ.ក្រ) ចែកជាមួយនឹងការ៉េនៃកម្ពស់ជាម៉ែត្រ = (គ.ក្រ/ម$^{២}$) ។
- ការបែងចែក BMI ស្របតាមតារាងទី៣៣-១ ការធ្វើចំណាត់ថ្នាក់ BMI ចំពោះមនុស្សពេញ វ័យ ដើម្បីកំណត់ថា ទម្ងន់ស្រាល លើសទម្ងន់ និងធាត់ស្របតាមWHO និងរូបភាព ៣៣.២ចំណាត់ថ្នាក់ BMI របស់ WHO សំរាប់ក្មេងនិង ក្មេងជំទង់ ។

៣. ការវាស់វែងបរិវេណចង្កេះ

[៤៨] កែសម្រួលមកពី គំរោង *RCQHC* និង *FANTA* ២០០៣,អាហារូបត្ថម្ភ និង អេដស៍ *:* សៀវភៅ បណ្តុះបណ្តាល

- វិធីសាស្ត្រ: ឈរ សន្ទឹងដៃ ដាក់ជើងស្របគ្នា ។ ប្រើម៉ែត្រសំពាត់សម្រាប់វាស់វែងកុំសង្កត់ស្បែក ។ ការវាស់វែងនៅត្រង់ចន្លោះឆ្អឹងជំនីផុត (lower ribs) និងកំពូលឆ្អឹងផាល(iliac crest)។
- លើសទម្ងន់ = បុរស ≥ ៨៥ ស.ម និង ស្ត្រី ≥ ៨០ ស.ម ។

៤. សូមអានផ្នែកពាក់ព័ន្ធ ប្រសិនបើ អ្នកជំងឺមាន **ទម្ងន់ស្រាល ទម្ងន់ធម្មតា** ឬ **លើសទម្ងន់**។

## ៣៣.៣.២ ការវាយតម្លៃទម្ងន់រាល់ពេល ពិនិត្យពិគ្រោះជំងឺ

- ពិនិត្យទម្ងន់ តាមដាន និងរៀបចំផែនការគ្រប់គ្រងទម្ងន់
  - បើមានការផ្លាស់ប្តូរទម្ងន់–គណនា BMI, % នៃការផ្លាស់ប្តូរទម្ងន់ + ទំហំចង្កេះ ។
  - បើទម្ងន់ថយចុះ – គណនា % នៃទម្ងន់ដែលថយចុះពី BBW និងធ្វើចំណាត់ថ្នាក់ជំណាក់នៃ WHO ឱ្យបានសមស្រប។

**ពិនិត្យពិគ្រោះជំងឺនៅពេលដំបូង និងនៅពេលតាមដានជំងឺ–** សូមអានផ្នែកខាងក្រោម (ក្នុងជំពូកនេះ) ទាក់ទងនឹងស្ថានភាពជំងឺ ៖

- ទម្ងន់ស្រាល (លក្ខណៈវិនិច្ឆ័យរបស់ WHO និង BMI): ផ្នែក៣៣.៤ទម្ងន់ស្រាលឬស្រកទម្ងន់
- លើសទម្ងន់ (លក្ខណៈវិនិច្ឆ័យនៃ BMI ឬ ទំហំចង្កេះ): ផ្នែក៣៣.៥.លើសទម្ងន់
- ទម្ងន់ធម្មតា): ផ្នែក៣៣.៦.ទម្ងន់ធម្មតាពេលពិនិត្យពិគ្រោះជំងឺដំបូង ឬពេល មកពិនិត្យតាមដាន។

**តារាងទី៣៣-១ ការធ្វើចំណាត់ថ្នាក់ *BMI* ចំពោះមនុស្សពេញវ័យ ដើម្បីកំណត់ថា ទម្ងន់ស្រាល លើសទម្ងន់ និងធាត់ ស្របតាម*WHO*** [៤៩]

| ចំណាត់ថ្នាក់ | ទម្ងន់កំណត់ដោយ WHO | ទម្ងន់កំណត់ដោយកម្ពុជា* |
|---|---|---|
| **ទម្ងន់ស្រាល** | **< ១៨,៥០** | **< ១៨,៥០** |
| ស្គមខ្លាំង | <១៦.០ | <១៦.០ |
| ស្គមមធ្យម | ១៦.០ - ១៦.៩ | ១៦.០ - ១៦.៩ |
| ស្គមតិចតួច | ១៧.០ - ១៨.៤ | ១៧.០ - ១៨.៤ |
| **ចន្លោះទម្ងន់ធម្មតា** | **១៨,៥ – ២៤,៩** | **១៨,៥ - ២២,៩** |
| **លើសទម្ងន់** | **≥២៥,០** | **២៣,០-២៤,៩** |
| មុនធាត់ | ២៥,០ - ២៩,៩ | |
| **ធាត់ខ្លាំង** | **≥៣០,០** | **≥ ២៥** |
| ការប្រឈមមុខនឹងបញ្ហាសុខភាពទាក់ទងនឹងការលើសទម្ងន់ អាចកើតឡើងនៅក្រោមចន្លោះកម្រិតទម្ងន់ដែលកំណត់ដោយ WHO ក្នុងចំណោមប្រជាជនអាស៊ី ។ អង្គការ WHO បានបន្ថែមនៅចំណុចសម្គាល់ជាជម្រើសផ្សេងទៀត (cut off points) ដែលអាចយកមកសម្របសម្រួលសម្រាប់ប្រជាជនកម្ពុជា[៥០] ។ | | |

[៤៩]កែសម្រួលពីចំណាត់ថ្នាក់របស់អង្គការសុខភាពពិភោពលោក: http://apps.who.int/bmi/index.jsp?introPage=intro_3.html

[៥០] តួលេខនេះស្របតាម គោលការណ៍ណែនាំអនុវត្តគ្លីនិករបស់ MoH កម្ពុជា។ជំងឺទឹកនោមផ្អែមប្រភេទទី២។ការថែទាំបន្ត អ្នកជំងឺទឹកនោមផ្អែមដែលមានឬគ្មានផលវិបាក នៅគ្លីនិកជំងឺមិនឆ្លង កា.រិ.មន្ទីរពេទ្យបង្អែកសំរាប់បង្ការនិង គ្រប់គ្រងជំងឺមិនឆ្លង Dept.Preventive medicine ២០១៥។

## រូបភាពទី៣៣-២ ចំណាត់ថ្នាក់ *BMI* ចំពោះកុមារ/ក្មេងជំទង់ ស្របតាម *WHO*

### BMI-for-age BOYS

5 to 19 years (z-scores)

World Health Organization




2007 WHO Reference

### BMI-for-age GIRLS

5 to 19 years (z-scores)

World Health Organization




2007 WHO Reference

## ៣៣.៤ ទម្ងន់ស្រាល ឬស្រកទម្ងន់: ការវាយតម្លៃ និង ការគ្រប់គ្រងព្យាបាល

### ការវាយតម្លៃ

*ប្រសិនបើអ្នកជំងឺមានទម្ងន់ស្រាល ឬស្រកទម្ងន់ > ៥% នៃទម្ងន់ → ត្រូវពិនិត្យពីប្រវត្តិអ្នកជំងឺ និង ពិនិត្យគ្លីនិក ដើម្បីវាយតម្លៃអំពីៈ*

- ការបរិភោគអាហារជាទូទៅ
- ចំណេះដឹងអំពី អាហារូបត្ថម្ភ
- ចំណេះដឹងអំពីសុវត្ថិភាពទឹក
- លទ្ធភាពក្នុងការទទួលបានអាហារ– បញ្ហាសេដ្ឋកិច្ចទាក់ទងនឹងសុវត្ថិភាពស្បៀង
- ចង់ហូបអាហារ(Appetite)
- ផលវិបាកឱសថ -ឧ. ចង្អោរ
- ការហូបអាហារ
  - រស់ជាតិអាហារប្រែប្រួល
  - ដំបៅមាត់ រលោកអញ្ចាញធ្មេញ ជំងឺផ្សិតបង្កដោយពពួក candidiasis នៅមាត់
  - ឈឺចាប់ ឬពិបាកលេប
  - សរសៃប្រសាទលេបមានបញ្ហា
  - ការឈឺចាប់សាច់ដុំពោះ ឬការឈឺចាប់ពោះ។
- ជំងឺរាករូស (រួមទាំង ភស្តុតាងនៃវិបត្តិនៃការស្រូបយកសារជាតិចិញ្ចឹម ដោយឃើញ-ជាតិខ្លាញ់/អាហារក្នុងលាមក) ។

### ការគ្រប់គ្រងព្យាបាល

- ព្យាបាលជំងឺដែលអាចព្យាបាលជា - ឧ. ជ្រាំងមាត់ ដំបៅមាត់ រលោកអញ្ចាញធ្មេញ
- ធានាថាអ្នកជំងឺ និងក្រុមគ្រួសារឱ្យយល់ថា ពួកគេត្រូវការបង្កើនការទទួលទានអាហារ ដើម្បីទទួលបានសុខភាពល្អ (ហើយការហូបតែបបរមួយមុខ គឺមិនគ្រប់គ្រាន់ទេ) ។
- អ្នកជំងឺដែលមានទម្ងន់ស្រាល ត្រូវរក្សាតុល្យភាពរបបអាហារ (រៀបរាប់លម្អិតក្នុង តារាងទី៣៤- ១ អនុសាសន៍សម្រាប់បង្ការនិង គ្រប់គ្រងព្យាបាលជំងឺមិនឆ្លង) តែត្រូវបរិភោគជាតិខ្លាញ់ និងស្ករច្រើន រហូតទម្ងន់ឡើងមកធម្មតាវិញ ។
- បើអ្នកជំងឺមិនចង់ហូបអាហារ គាត់ត្រូវខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការបរិភោគអាហារឱ្យបានគ្រប់គ្រាន់ ។
- បញ្ជូនអ្នកជំងឺទៅកម្មវិធីសន្តិសុខស្បៀងអាហារ ដើម្បីទទួលបានការគាំទ្រ បើសិនជាចាំបាច់។
- រោគសញ្ញាដែលបានកំណត់ សូមមើលតារាងដូចខាងក្រោម ។
- តាមដានទម្ងន់ រោគសញ្ញាគ្លីនិក និង ពិភាក្សាអំពីអាហារូបត្ថម្ភ រាល់ពេលមកពិនិត្យពិគ្រោះជំងឺ ។

**តារាងទី៣៣-២ រោគសញ្ញាដែលជាគោលដៅ ក្នុងការគ្រប់គ្រងព្យាបាលនៃការបរិភោគអាហារមិនគ្រប់គ្រាន់**

| រោគសញ្ញា | ការគ្រប់គ្រងព្យាបាល [៥១] |
|---|---|
| មិនឃ្លានអាហារ | • ហូបអាហារតិចៗ, ញឹកញាប់ ៥-៦ ដង/ថ្ងៃ<br>• ហូបអាហារសម្រន់ដែលមានសារជាតិចិញ្ចឹម<br>• ផឹកទឹកឱ្យច្រើន<br>• ហាត់ប្រាណកម្រិតស្រាល ដូចជា ដើរចុះដើរឡើង មុនហូបអាហារ- ដើម្បីជម្រុញឱ្យឃ្លានអាហារ<br>• មានគ្រួសារ និងមិត្តភក្តិជួយរៀបចម្អិនម្ហូបអាហារ<br>• ធ្វើលំហាត់ប្រាណបន្តិចបន្តួច និងធ្វើសកម្មភាពបន្តិចបន្តួច<br>• បន្ថែមរសជាតិ លើភេសជ្ជៈនិងអាហារដើម្បីឱ្យមានរសជាតិឆ្ងាញ់ពិសារ ។ |
| ដំបៅមាត់ | • ចៀសវាងផ្លែឈើរស់ជាតិជូរ ជាតិអាស៊ីត និងអាហារជាតិហើរ<br>• ហូបអាហារនៅក្នុងបន្ទប់មានសីតុណ្ហភាព<br>• ហូបអាហារទន់ និងស្រស់<br>• ចៀសវាងផឹកកាហ្វេ និងសុរា |
| មាត់ស្ងួត និងរលាកបំពង់ក | • លាងមាត់ថ្មមៗជាមួយទឹកអំបិលក្តៅអ៊ុនៗ ដោយប្រើទឹកដាំពុះ<br>• លាងមាត់ឱ្យញឹកញាប់<br>• ប្រើតែ cinnamon សម្រាប់លាងមាត់ (១/៤ ស្លាបព្រានៃ cinnamon ដាក់ក្នុងទឹកក្តៅ១កែវ គ្របឱ្យជិតហើយទុកឱ្យត្រជាក់) ។ |
| ចង្អោរ និងក្អួត | • ហូបអាហារបន្តិចម្តងៗ និងញឹកញាប់<br>• កុំទុកក្រពះឱ្យនៅទទេ ព្រោះវាបណ្តាលឱ្យចង្អោរកាន់តែខ្លាំង<br>• ហូបអាហារមានរស់ជាតិសាប<br>• ចៀសវាងហូបអាហារមានក្លិនមិនល្អ<br>• ផឹកទឹកឱ្យបានច្រើន<br>• សំរាក សំរាន្ត ក្រោយពេលហូបអាហារ<br>• កុំទម្រេតខ្លួន ក្រោយពេលហូបអាហារហើយភ្លាម<br>• កុំផឹកកាហ្វេ និងសុរា។ |

[៥១] ប្រែសម្រួល ពី ការគ្រប់គ្រងការ ឆ្លងមេរោគអេដស៍ និងការព្យាបាលដោយ ថ្នាំប្រឆាំងនឹងមេរោគអេដស៍ ចំពោះមនុស្សពេញវ័យ និងក្មេងជំទង់ អង្គការ WHO / SEARO ឆ្នាំ ២០០៧

| | |
|---|---|
| រាករូស | • បន្តហូបចំណីអាហារឱ្យច្រើន តាមដែលអ្នកជំងឺអាចទ្រាំទ្របាន។<br>• ផឹកទឹកឱ្យច្រើនៈ លើសពី៨កែវក្នុង១ថ្ងៃ ដើម្បីការពារការបាត់ជាតិទឹក។<br>• ផឹកទឹកស្អាតដាំពុះ និង/ឬផឹកទឹក Oral Rehydration Solution (ORS)<br>• ហូបផ្លែចេកទុំ ផ្លែឈើចម្អិន កុំហូបផ្លែឈើខ្ចី<br>• បកសំបក និងចម្អិនបន្លែឱ្យឆ្អិន កុំហូបបន្លែឆៅ<br>• រៀបចំបបរដោយ (ដាក់អង្ករស្ងោ ១ពែង ក្នុងទឹកស្អាត ៥ កែវ ដាក់អំបិលបន្តិច ប្រើរយៈពេល ១ម៉ោង) ហូបទាំងទឹកបបរ និងកាកបបរ ព្រមទាំងហូបអាហារផ្សេងទៀតផង។<br>• ត្រូវចៀសវាងហូបផលិតផលធ្វើពីទឹកដោះគោរយៈពេលមួយថ្ងៃ បន្ទាប់មក ហូបបន្តិចម្តង រហូតដល់ ២កែវក្នុងមួយថ្ងៃ។ |
| ទល់លាមក | • ហូបអាហារសម្បូរដោយជាតិសរសៃ<br>• ហាត់ប្រាណបន្តិចបន្តួច និងធ្វើសកម្មភាពស្រាលៗ<br>• ហូបទឹកឱ្យបានច្រើន។ |

## ៣៣.៥ ការឡើងទម្ងន់: ការវាយតម្លៃ និងការគ្រប់គ្រងព្យាបាល

- អ្នកជំងឺច្រើនតែក្លាយជាអ្នកធាត់លើសទម្ងន់ នៅពេលដែលការព្យាបាលជំងឺឱកាសនិយមទទួលបានជោគជ័យ និងក្រោយពីបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។
- អ្នកជំងឺលើសទម្ងន់ ឬធាត់ ជាពិសេស នឹងមានហានិភ័យខ្ពស់ជំងឺទឹកនោមផ្អែម ជំងឺលើសសម្ពាធឈាម និងជំងឺសរសៃឈាមបេះដូង (CVD) រួមមាន ជំងឺខ្វះឈាមទៅចិញ្ចឹមបេះដូង (ischemic heart) និងជំងឺសរសៃឈាមនៅផ្នែកចុង ជំងឺសរសៃឈាមក្នុងខួរក្បាល និងជំងឺតម្រងនោមរ៉ាំរ៉ៃ ។

### ការវាយតម្លៃ

*បើអ្នកជំងឺលើសទម្ងន់ → ស្រង់ប្រវត្តិជំងឺ និងពិនិត្យគ្លីនិក ដើម្បីវាយតម្លៃ:*

- កត្តាហានិភ័យផ្សេងទៀតនៃជំងឺរ៉ាំរ៉ៃ
  - ប្រវត្តិជំងឺទឹកនោមផ្អែមក្នុងអំឡុងពេលមានផ្ទៃពោះ ប្រវត្តិគ្រួសារកើតជំងឺទឹកនោមផ្អែម ឬ ជំងឺ CVD
  - ការជក់បារី ការផឹកស្រា។
- វាស់សម្ពាធឈាម ពិនិត្យសរសៃឈាមបេះដូង/ការពិនិត្យផ្លូវដង្ហើម
- ការពិនិត្យស្រាវជ្រាវ:

- ពិនិត្យរកជំងឺទឹកនោមផ្អែម ធ្វើតេស្តសេរ៉ូម cholesterol និង triglyceride ។

## ការគ្រប់គ្រងព្យាបាល

- ធានាអ្នកជំងឺយល់ច្បាស់ថា គាត់នឹងត្រូវកាត់បន្ថយការទទួលទានកាឡូរី ហើយយកចិត្តទុកដាក់ នឹងកត្តាហានិភ័យផ្សេងទៀត ដើម្បីរក្សាសុខភាពឱ្យបានល្អ ។
- ឈប់ជក់បារី (សូមមើលរូបភាពទី៣៥-១: ឧបករណ៍ផ្តល់ប្រឹក្សាជំនួយការឈប់ជក់បារីតាម WHO)។
- បន្ថយការផឹកសុរា (ជាប្រភពកាល់ឡូរីខ្ពស់)
- បន្ថយការហូបអាហារ- ការស្រូបចូលកាល់ឡូរី ជាពិសេស ប្រេង/ខ្លាញ់ និងស្ករ (បញ្ឈប់ផឹកភេសជ្ជ:) តែត្រូវធានាគុណភាពរបបអាហារដែលសម្បូរដោយប្រូតេអ៊ីននិងបន្លែ ។ (សូមមើល តារាងទី៣៤-១)។
- ធ្វើលំហាត់ប្រាណរាល់ថ្ងៃ – ឧ. ការដើរលឿន យ៉ាងហោចណាស់ ៣០នាទី/ថ្ងៃ
- បើលើសសម្ពាធឈាម(>១៤០/៨០)–សូមអានជំពូក ៣៦. ជំងឺលើសសម្ពាធឈាម។
- បើមានជំងឺទឹកនោមផ្អែមឬមិនទ្រាំទ្រជាមួយជាតិស្ករ–សូមអានជំពូកទី៣៧៖ជំងឺទឹកនោមផ្អែមប្រភេទទី២។
- តាមដានទម្ងន់ BMI បរិវេណចង្កេះ និងពិភាក្សាអំពីអាហាររូបត្ថម្ភ រាល់ពេលមកពិនិត្យពិគ្រោះជំងឺ។

## ៣៣.៦ ទម្ងន់ធម្មតា – ពេលពិនិត្យពិគ្រោះជំងឺលើកដំបូង និងពេលមកពិនិត្យតាមដានជំងឺ

- ធានាថា អ្នកជំងឺ និងក្រុមគ្រួសារឱ្យយល់ថា ពួកគេត្រូវការទទួលទានអាហារ ដើម្បីមានសុខភាពល្អ ហើយការហូបតែបបរមួយមុខ គឺមិនគ្រប់គ្រាន់ទេ ។
- ពិនិត្យមើលពីការយល់ដឹង របស់អ្នកជំងឺ អំពីម្ហូបអាហារ និងសុវត្ថិភាពទឹក ។
- របបអាហារ គួរតែរួមបញ្ចូលជាមួយអាហារគាំទ្រសុខភាពជាទៀងទាត់ ដោយមានគុណភាព ជាតិខ្លាញ់ ប្រូតេអ៊ីន និងកាបូអ៊ីដ្រាដ (សូមមើល តារាង៣៤-១)
- តាមដានទម្ងន់រាល់ពេលមកពិនិត្យពិគ្រោះជំងឺ ។
- បើសិនបើ មានការថយចុះទម្ងន់ដែលមិនមានបំណង សូមអានផ្នែកពាក់ព័ន្ធអំពី៖៣៣.៤ ទម្ងន់ស្រាលឬស្រកទម្ងន់: ការវាយតម្លៃ និង ការគ្រប់គ្រងព្យាបាល។
- បើសិនបើ ឡើងទម្ងន់ដែលមិនមានបំណង សូមអានផ្នែកពាក់ព័ន្ធអំពី៖៣៣.៥ការឡើងទម្ងន់:ការវាយតម្លៃ និងការគ្រប់គ្រងព្យាបាល។

## ៣៣.៧ អាហារ និងឱសថ

ត្រូវពិនិត្យជានិច្ចជាកាល ក្រែងមានការកែតម្រូវអំពីទំនាក់ទំនងរវាង ពេលវេលានៃការបរិភោគអាហារ និងការលេបឱសថ ។ (ឧ.ឱសថ TDF ត្រូវលេបពេលហូបអាហារ ឱសថ cotrimoxazole ត្រូវលេបពេលបរិភោគអាហារដែរដើម្បីទទួលបានប្រសិទ្ធភាពល្អ) ។

## ៣៣.៨ អាហារូបត្ថម្ភ និង ការមានផ្ទៃពោះ

ទម្ងន់កូនពេលកើត គឺជាកត្តាកំណត់មួយដ៏សំខាន់បំផុតនៃការរស់រានមានជីវិតរបស់កុមារ និងទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីស្ថានភាពអាហារូបត្ថម្ភរបស់មាតា មុននិងក្នុងអំឡុងពេលមានផ្ទៃពោះ ។ ទម្ងន់ទារកមុនពេលមានផ្ទៃពោះទាប (Low pre-pregnancy weight) និងការឡើងទម្ងន់មិនគ្រប់គ្រាន់ពេលមានផ្ទៃពោះ គឺជាការស្មានទុកមុនដ៏សំខាន់បំផុតនៃភាពលូតលាស់យឺតយ៉ាវរបស់ទារក (intrauterine growth retardation =IUGR) និង ទារកមានទម្ងន់ស្រាលនៅពេលកើត (កើតមិនគ្រប់គីឡូ) ។

ស្ត្រីមានផ្ទៃពោះ ដែលមាន BMI <១៨,៥០ ត្រូវបង្កើនការហូបចូលថាមពលរាល់ថ្ងៃ ដើម្បីឱ្យឡើងទម្ងន់យ៉ាងហោចណាស់ ១២,៥០ គីឡូក្រាម ក្នុងពេលមានផ្ទៃពោះ ។ សូមបញ្ជូនគាត់ទៅផ្នែកគាំពារមាតានិងទារក សម្រាប់ទទួលសេវាអាហារូបត្ថម្ភចំពោះស្ត្រីមានផ្ទៃពោះ រួមទាំង ការផ្តល់ជាតិដែក និងបន្ថែមសារជាតិចិញ្ចឹម ។

## ៣៣.៩ ការរៀបចំ និងសុវត្ថិភាពចំណីអាហារ

- លាងសំអាតដៃយ៉ាងហ្មត់ចត់ មុន និងក្រោយចម្អិនអាហារ
- ប្រើប្រាស់ទឹកស្អាត ឬទឹកដាំពុះ
- រក្សាផ្ទៃផ្ទះបាយឱ្យស្អាត
- ចម្អិនអាហារឱ្យឆ្អិនល្អ
- ចូរញ៉ាំអាហារចម្អិនភ្លាមៗ
- រក្សាទុកអាហារក្នុងកន្លែងអនាម័យ និងត្រជាក់
- កំដៅអាហារចម្អិនហើយ យ៉ាងហ្មត់ចត់
- ចៀសវាងការទុកដាក់ច្រឡូកច្រឡំ រវាងអាហារឆៅ និងអាហារឆ្អិន
- ការពារអាហារពីពពួកសត្វកកេរ សត្វល្អិត និងសត្វផ្សេងៗ
- កុំបរិភោគស៊ុតឆៅ
- កុំបរិភោគអាហារដែលមិនបានចម្អិនឱ្យឆ្អិនល្អ ជាពិសេស សាច់ និងសាច់មាន់
- កុំផឹកទឹកដែលមិនដាំពុះ ឬទឹកផ្លែឈើ លាយជាមួយទឹកដែលមិនបានដាំពុះ ។

# ជំពូក ៣៤. ជំងឺមិនឆ្លងរ៉ាំរ៉ៃ លើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

## ៣៤.១ ចំណុចគន្លឹះ

- ជាមួយនឹងប្រសិទ្ធភាពនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ អាចរស់នៅបានយូរដោយមិនបានធ្វើតេស្ត VL ចំណែកឯ ការថយចុះភាពស៊ាំ និងការបង្ករោគដោយជំងឺឱកាសនិយម ក្លាយជាបញ្ហាបន្តិចបន្តួច ។
- ទោះយ៉ាងណា ការបង្ករោគដោយមេរោគអេដស៍ ការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍រយៈពេលវែង និងការវិវត្តិន៍ទៅមុខនៃវ័យ ធ្វើឱ្យអ្នកជំងឺអេដស៍កើនឡើងហានិភ័យជំងឺមិនឆ្លង(NCD) ។
- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ មានហានិភ័យខ្ពស់ក្នុងការវិវត្តន៍ទៅរកជំងឺមេតាបូលីស និងជំងឺមិនឆ្លង រួមទាំង ជំងឺសរសៃឈាមបេះដូង ជំងឺទឹកនោមផ្អែម ជំងឺសួតរ៉ាំរ៉ៃ និងជំងឺមហារីក។
- វាជាការសំខាន់ណាស់ដែលគ្រូពេទ្យព្យាបាលជំងឺអេដស៍ យល់ដឹងអំពីជំងឺមិនឆ្លង និងរៀបចំវិធានការបង្ការទី១ និងទី២ ជាទៀងទាត់ ជាមួយអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ក្នុងអំឡុងពេលពិនិត្យពិគ្រោះជំងឺ ។
- បន្ថែមលើនេះទៀត អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ដែលទទួលការព្យាបាលដោយ ឱសថប្រឆាំងមេរោគអេដស៍រយៈពេលវែង ត្រូវពិនិត្យរកជំងឺ NCD (យោងទៅតាមការណែនាំនេះ) ហើយបញ្ជូនគាត់ទៅទទួលសេវា ថែទាំ និងព្យាបាលសមស្រប ។
- គ្រូពេទ្យព្យាបាលជំងឺអេដស៍ ត្រូវតែពិនិត្យមើលអន្តរកម្មឱសថជាមួយឱសថប្រឆាំងមេរោគអេដស៍ និងប្រើថ្នាំតាមវេជ្ជបញ្ជាណាមួយ ទាំងក្នុង ឬក្រៅគ្លីនិកជំងឺអេដស៍ និងការពិនិត្យតាមដានការពុលឱសថ ជាប់ជានិច្ច ។

## ៣៤.២ ការបង្ការជំងឺមិនឆ្លងៈ របបអាហារគាំទ្រសុខភាព និងរបៀបរស់នៅ

- អ្នកជំងឺទាំងអស់ ត្រូវបានណែនាំឱ្យយកចិត្តទុកដាក់ចំពោះរបបអាហារគាំទ្រសុខភាព និងពីរបៀបរស់នៅ ដើម្បីកាត់បន្ថយហានិភ័យជំងឺមេតាបូលិក និងជំងឺមិនឆ្លង ។[៥២]

**តារាងទី៣៤-១ អនុសាសន៍សម្រាប់បង្ការនិង គ្រប់គ្រងព្យាបាលជំងឺមិនឆ្លង**

| |
|---|
| ការសង្កត់ធ្ងន់លើរបបអាហារ និងការផ្លាស់ប្តូររបៀបរស់នៅ នឹងប្រែប្រួលអាស្រ័យ ថាតើអ្នកជំងឺ មានទម្ងន់ស្រាល/លើសទម្ងន់/ ទម្ងន់ធម្មតា និងកត្តាហានិភ័យដទៃទៀត ដូចជា លើសសម្ពាធឈាម ជំងឺទឹកនោមផ្អែមជាដើម ។ |
| **របបអាហារ:** មនុស្សភាគច្រើន ផ្តោតការយកចិត្តទុកដាក់ខ្លាំង លើការបរិភោគអាហារ<br>• ប្រូតេអ៊ីនបន្ថែម (តៅហ៊ូ សណ្តែក សាច់មាន់ ត្រី) |

[៥២] ការបង្ការ និងការត្រួតពិនិត្យ ជំងឺមិនឆ្លង : គោលការណ៍ណែនាំសម្រាប់ ការថែទាំសុខភាពបឋម ក្នុងស្ថានភាពមាន ធនធានតិច។ អង្គការសុខភាពពិភពលោក ឆ្នាំ២០១២។

| |
|---|
| • បន្លែច្រើន (៥ x៨០០ - ឈុត ៥០០ម.ក្រ បន្លែនិងផ្លែឈើក្នុងមួយថ្ងៃ)<br>• ជាតិខ្លាញ់តិច (ចៀសវាងអាហារចៀន ឬបំពងខ្លាំង សាច់កាត់/ស្បែកជាប់ខ្លាញ់ ឧ. សាច់ជ្រូក/មាន់)<br>• ជាតិស្ករតិច (ភេសជ្ជៈ ជាតិផ្អែម ទឹកដោះគោខាប់)<br>• អំបិលតិច (ប្រហុក ប៊ីចេង ទឹកត្រី ទឹកស៊ីអ៊ីវ និង សាច់ ឬត្រីប្រឡាក់អំបិល) ជំនួសដោយហូបរស់ជាតិផ្សេងវិញ (ឧ.ទឹកក្រូចឆ្មារ( lemon)  ម្រេច) និងជីរដទៃទៀត<br>• កាត់បន្ថយអាហារកែច្នៃ (ជាធម្មតាមានជាតិអំបិល ជាតិខ្លាញ់ ស្ករច្រើន) ។ |
| **ទម្ងន់:** រក្សាកម្រិត BMI ចន្លោះ ១៨,៥០ – ២២,៩។ |
| **សុរា:** កម្រិតអតិបរិមា ផឹកសុរាពីរស្តង់ដានៃកែវ/ថ្ងៃ ≥ ២ ថ្ងៃទៀតមិនត្រូវផឹកទេ ។ |
| **មិនជក់បារី** |
| **ហាត់ប្រាណ** ៣០នាទីក្នុងមួយថ្ងៃ (ឧ. ការដើរញាប់) ត្រូវហាត់ប្រាណខ្លាំងជាងនេះ ដើម្បីសម្រកទម្ងន់ ។ |

# ជំពូក ៣៥. ការឈប់ជក់បារី

- គ្រូពេទ្យព្យាបាលត្រូវលើកទឹកចិត្ត និងផ្តល់យោបល់អ្នកជំងឺឱ្យឈប់ជក់បារី ។
- ឧបករណ៍ខាងក្រោមអាចជួយគ្រូពេទ្យព្យាបាលណែនាំអ្នកជំងឺឱ្យឈប់ជក់បារី ។

**រូបភាពទី៣៥-១ ឧបករណ៍ផ្តល់ប្រឹក្សាជាជំនួយដល់បុគ្គលដែលចង់ឈប់ជក់បារីស្របតាម *WHO*[៥៣]**

**A1: សួរ**

តើអ្នកជក់បារីដែរឬទេ?

→ ទេ → សង្កត់ធ្ងន់អំពីសារ ដោយសង្កត់ធ្ងន់ថា ការជក់ថ្នាំបង្កើនហានិភ័យជំងឺបេះដូង

→ បាទ

**A2: ផ្តល់យោបល់**

ផ្តល់យោបល់ឱ្យច្បាស់លាស់ រឹងមាំ និងលក្ខណៈបុគ្គល

“ការជក់បារីបង្កើនហានិភ័យជំងឺគាំងបេះដូង ដាច់សរសៃឈាមក្នុងខួរក្បាល មហារីកសួត និងជំងឺតាមផ្លូវដង្ហើម។ ការឈប់ជក់បារី គឺ មានសារៈសំខាន់ណាស់ ដែលអ្នកអាចធ្វើបាន ដើម្បីការពារបេះដូងរបស់អ្នក និងសុខភាពរបស់អ្នក អ្នកត្រូវបញ្ឈប់ជក់បារីឥឡូវនេះ”។

**A3: វាយតម្លៃ**

តើអ្នកមានបំណងចង់ឈប់ជក់បារីដែរឬទេ?

→ ទេ → **ជំរុញការលើកទឹកចិត្តឱ្យឈប់ជក់បារី**

ផល់ព័ត៌មានអំពី ការគ្រោះថ្នាក់នៃការជក់បារី ដល់បេះដូង និងផ្តល់ខិត្តប័ណ្ណជូនគាត់។

→ បាទ

**A4: ជំនួយ**

**ជួយរៀបចំផែនការឈប់ជក់បារី**

កំណត់កាលបរិច្ឆេទឈប់ជក់បារី
ផល់ព័ត៌មានដល់គ្រួសារនិងមិត្តភ័ក្រ
សុំការគាំទ្រពីគ្រួសារ និងមិត្តភ័ក្រ
យកបារី/ថ្នាំជក់ចេញ
យកសម្ភារៈ/ឧបករណ៍ដែលរម្លឹកអ្នកឱ្យចង់ជក់បារីចេញ
រៀបចំការណាត់ជួប ដើម្បីតាមដាន*

**A5: រៀបចំ**

**នៅពេលមកពិនិត្យតាមដាន**

ផ្តល់ការកោតសរសើរអំពី ភាពជោគជ័យ និងជំរុញបន្តទៀត
ប្រសិនបើគាត់ជក់សារជាថ្មីវិញ ត្រូវខិតខំប្រឹងប្រែងខ្លាំងជាងមុនថែមទៀត
បន្តការតាមដាន និងការគាំទ្រពីក្រុមគ្រួសារ។

* គោលការណ៍ នៅពេលមកពិនិត្យតាមដានលើកទី២ ក្នុងកំឡុងខែតែមួយ និងរៀងរាល់ខែរយៈពេល៤ខែ និងការវាយតម្លៃក្រោយរយៈពេល១ឆ្នាំ ។ ប្រសិនជាមិនអាច ត្រូវពង្រឹងការផ្តល់ប្រឹក្សា នៅពេលណាដែលបានជួបអ្នកជំងឺដើម្បីតាមដានសម្ពាធឈាមអ្នកជំងឺ ។

[៥៣] ឧបករណ៍ ការអនុវត្តន៍ : កញ្ចប់សកម្មភាពចាំបាច់នៃបទអន្តរាគមន៍ជំងឺមិនឆ្លងសំរាប់ សុខភាពបឋម ក្នុងស្ថានភាពមាន ធនធានតិច។ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣។

# ជំពូក ៣៦. ជំងឺលើសសម្ពាធឈាម (Hypertension)

## ៣៦.១ ការពិនិត្យស្រាវជ្រាវ និងការធ្វើរោគវិនិច្ឆ័យជំងឺលើសសម្ពាធឈាមលើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

ត្រូវពិនិត្យសម្ពាធឈាម គ្រប់អ្នកជំងឺទាំងអស់ រៀងរាល់ពេលពិនិត្យពិគ្រោះជំងឺ ។

- បើសម្ពាធឈាម > ១៤០/៩០ កើតឡើងលើសពីការវាស់វែងមួយលើក= ជំងឺលើសសម្ពាធឈាម។

## ៣៦.២ ការគ្រប់គ្រងព្យាបាលជំងឺលើសសម្ពាធឈាម

គោលការណ៍ណែនាំគ្លីនិកជាតិរបស់ប្រទេសកម្ពុជា បានរៀបរាល់លម្អិតអំពី ការគ្រប់គ្រងព្យាបាលជំងឺលើសសម្ពាធឈាម[៥៩] ។

**ជំងឺលើសសម្ពាធឈាម តម្រូវឱ្យមានការគ្រប់គ្រងព្យាបាល ទាំងការព្យាបាលដោយប្រើឱសថ និង មិនប្រើឱសថ ។**

១. ត្រូវផ្តល់យោបល់ឱ្យអ្នកជំងឺ ពីវិធីបញ្ចុះសម្ពាធឈាម និងប្រាប់ពីហានិភ័យនៃការវិវត្តន៍ទៅ ជំងឺសរសៃឈាមបេះដូង ៖

- សម្រកទម្ងន់ បើលើសទម្ងន់
- របបអាហារគាំទ្រសុខភាពនិងរបៀបរស់នៅដូចដែលបានរៀបរាប់លម្អិតក្នុងមើល តារាងទី៣៤-១ ផ្តោតសំខាន់លើការកាត់បន្ថយការហូបជាតិអំបិល ។
- បើលើសសម្ពាធឈាមកម្រិតស្រាល ឧ. សម្ពាធឈាមត្រឹម SBP ១៥៩ និង/ឬ DBP ៩៩ ត្រូវព្យាយាមដោយមិនព្យាបាលដោយឱសថរយៈពេល៣–៦ខែ មុននឹងពិចារណាក្នុងការព្យាបាលដោយប្រើឱសថប្រឆាំងការលើសសម្ពាធឈាម ។

- វាយតម្លៃពីលក្ខខណ្ឌផ្សេងៗទាក់ទងនឹងការលើសសម្ពាធឈាម ៖
  - ជំងឺសរសៃឈាមបេះដូង (ប្រវត្តិជំងឺ ការពិនិត្យ ធ្វើតេស្ត ECG បើអាចធ្វើបាន)
  - ជំងឺសរសៃឈាមខួរក្បាល –ជំងឺ stroke ជំងឺវិកលចរិក (dementia)
  - ធ្វើតេស្តអមវេជ្ជសាស្ត្រដូចខាងក្រោម ៖
    - ជំងឺទឹកនោមផ្អែម – ពិនិត្យជាតិស្ករ (fasting glucose)
    - ពិនិត្យជាតិខ្លាញ់ក្នុងឈាម (Serum lipids)– total cholesterol, HDL cholesterol, triglycerides ។

[៥៩] ក្រសួងសុខាភិបាល គោលការណ៍ណែនាំ គ្លីនិក សំរាប់ជំងឺលើសឈាម មនុស្សពេញវ័យ។ ការ ថែទាំបន្ត អ្នកជំងឺ លើសឈាម ដែលមាន និង មិនមាន ផលវិបាក នៅគ្លីនិក ជំងឺមិនឆ្លង / ការិយាល័យ មន្ទីរពេទ្យបង្អែក សម្រាប់ ការបង្ការ និងត្រួតពិនិត្យជំងឺមិនឆ្លងនៃ នាយកដ្ឋានការពារសុខភាព ឆ្នាំ២០១៥។

- ជំងឺតម្រងនោម– ពិនិត្យ serum creatinine, potassium, sodium វិភាគទឹកនោម ។

២. ការព្យាបាលដោយប្រើឱសថ

**តារាងទី៣៦-១ គោលការណ៍ណែនាំក្នុងការចាប់ផ្ដើមព្យាបាលដោយឱសថប្រឆាំងជំងឺលើសសម្ពាធឈាម របស់កម្ពុជា**

| អ្នកជំងឺលើសសម្ពាធឈាម | ការចាប់ផ្ដើមព្យាបាលដោយឱសថ | គោលបំណងនៃសម្ពាធឈាម |
|---|---|---|
| ≥ ៦០ ឆ្នាំ | SBP ≥ ១៥០ mm Hg<br>ឬ<br>DBP ≥ ៩០ mm Hg | SBP < ១៥០ mm Hg<br>ឬ<br>DBP < ៩០ mm Hg |
| < ៦០ ឆ្នាំ | | |
| ១៨ ៥៩ ឆ្នាំ | SBP ≥ ១៤០ mm Hg | SBP < ១៤០ mmHg |
| | DBP ≥ ៩០ mm Hg | DBP < ៩០ mm Hg |
| ≥ ១៨ ឆ្នាំ ដែលមាន | | |
| CKD ឬ/និង ទឹកនោមផ្អែម | SBP ≥ ១៤០ mm Hg<br>ឬ<br>DBP ≥ ៩០ mm Hg | SBP < ១៤០ mm Hg<br>ឬ<br>DBP < ៩០ mm Hg |

- គោលការណ៍ណែនាំគ្លីនិករបស់កម្ពុជាក្នុងការចាប់ផ្ដើមព្យាបាលដោយឱសថប្រឆាំងជំងឺលើសសម្ពាធឈាម ដោយប្រើរូបមន្តខាងក្រោម ៖
  - អ្នកជំងឺអាយុ > ៥៥ ឆ្នាំ- Thiazide diuretic
  - អ្នកជំងឺអាយុ < ៥៥ ឆ្នាំ– Angiotensin converting enzyme inhibitor (ACE I)
  - អ្នកជំងឺទឹកនោមផ្អែម ឬជំងឺតម្រងនោម (មិនគិតអាយុ) - ACE I

- បើមិនអាចរក្សាសម្ពាធឈាមនៅក្នុងកម្រិតដែលចង់បាន ត្រូវបន្ថែមថ្នាក់ងារឱសថប្រឆាំងជំងឺលើសសម្ពាធឈាមមួយមុខទៀត ។ ឱសថដែលប្រើប្រាស់ជាមួយគ្នាគឺ ៖
  - Thiazide diuretic + ACE I
  - Thiazide diuretic + calcium channel blocker
  - ACE I + calcium channel blocker

- ឧទាហរណ៍នៃកម្រិតដូសឱសថ៖
  - ACE I; Enalopril –ចាប់ផ្ដើម៥ ម.ក្រ OD-បង្កើនដល់កម្រិតអតិបរិមា ២០ម.ក្រ OD
  - ACE I; Captopril –ចាប់ផ្ដើម ១២,៥ ម.ក្រ BID–បង្កើនដល់កម្រិតអតិបរិមា ១៥០ម.ក្រ TID
  - Thiazide; Hydrochlorthiaide -ចាប់ផ្ដើម១២,៥ ម.ក្រ –បង្កើនដល់កម្រិតអតិបរិមា ៥០ម.ក្រ

- Thiazide; Indapamide -ចាប់ផ្ដើម១,២៥ ម.ក្រ –បង្កើនដល់កម្រិតអតិបរិមា២,៥ម.ក្រ
- B blocker; Atenolol –ចាប់ផ្ដើម២៥ ម.ក្រ OD-បង្កើនដល់កម្រិតអតិបរិមា៥០ម.ក្រ OD
- B blocker; Metoprolol –ចាប់ផ្ដើម២៥ ម.ក្រ BID–បង្កើនដល់កម្រិតអតិបរិមា១០០ម.ក្រ BID
- Calcium channel blocker;- Amilodipineចាប់ផ្ដើម២,៥ម.ក្រ OD–បង្កើនដល់កម្រិតអតិបរិមា ១០ម.ក្រ។

- តាមដាន ក្រោយពេលចាប់ផ្ដើមព្យាបាលដោយឱសថប្រឆាំងជំងឺលើសសម្ពាធឈាម រៀងរាល់២ សប្ដាហ៍ រហូតដល់សម្ពាធឈាមមានលំនឹង។

## អន្តរកម្ម រវាងឱសថប្រឆាំងជំងឺលើសសម្ពាធឈាម និងឱសថប្រឆាំងមេរោគអេដស៍

**តារាងទី៣៦-២ អន្តរកម្ម រវាងឱសថប្រឆាំងជំងឺលើសសម្ពាធឈាម និងឱសថប្រឆាំងមេរោគអេដស៍**[៥៥]

| ឱសថ | អន្តរកម្មជាមួយឱសថប្រឆាំងមេរោគអេដស៍ |
|---|---|
| **ACEI** : enalopril, captopril, ramipril; | គ្មានការរៀបរាប់ពីប្រតិកម្មជាមួយឱសថ NNRTI, NRTI ឬ PI ទេ។ |
| **Calcium channel blockers**: including amilodipine, nifedipine; | កម្រិត CCB អាចថយចុះ ដោយសារឱសថ NNRTI និង កើនឡើងដោយសារឱសថ PI → តាមដានសម្ពាធឈាម ដោយប្រុងប្រយ័ត្ន និងកែសម្រួលកម្រិតដូសឱសថ ។ |
| **Beta blockers**: atenolol, metoprolol, propranolol; | សក្ដានុពលនៃអន្តរកម្ម អាចពន្យាពេល PR interval→ តាម ដានសម្ពាធឈាមដោយប្រុងប្រយ័ត្ន និងកែប្រែកម្រិតដូស ឱសថ និងពិចារណាក្នុងការធ្វើ ECG ។ |
| **ARB** (angiotensin 2 receptor blockers) | កម្រិត Losartan នឹងថយចុះ ដោយសារឱសថ NNRTI និង កើនឡើងដោយសារឱសថ PI → តាមដានសម្ពាធឈាម ដោយប្រុងប្រយ័ត្ន និងកែប្រែកម្រិតដូសឱសថ ។ |

[៥៥] http://www.hiv-druginteractions.org/

# ជំពូក ៣៧. ជំងឺទឹកនោមផ្អែមប្រភេទទី ២

គោលការណ៍ណែនាំគ្លីនិករៀបរាប់លម្អិត អំពីការធ្វើរោគវិនិច្ឆ័យ និងការគ្រប់គ្រងព្យាបាលជំងឺទឹកនោមផ្អែម[៥៦] ។

## ៣៧.១ ពិនិត្យស្រាវជ្រាវរកជំងឺទឹកនោមផ្អែម ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍

បុគ្គលដែលមានហានិភ័យខ្ពស់ ត្រូវទទួលការពិនិត្យស្រាវជ្រាវជំងឺទឹកនោមផ្អែមប្រភេទទី២ រួមមាន៖

- លើសទម្ងន់ (BMI> ២៣ និង/ឬ បរិវេណចង្កេះចំពោះបុរស ≥ ៨៥ ស.ម និងចំពោះស្ត្រី ≥ ៨០ស.ម)
- ប្រវត្តិគ្រួសារកើតជំងឺទឹកនោមផ្អែម
- លើសសម្ពាធឈាម (BP> ១៤០/៩០)
- វិបត្តិជាតិខ្លាញ់ (Dyslipidaemia)
- ប្រវត្តិជំងឺដាច់សរសៃឈាមខួរក្បាល (stroke) ឬជំងឺខ្វះឈាមទៅចិញ្ចឹមបេះដូង (ischaemic heart disease)
- ស្ត្រីដែលមានប្រវត្តិកើតជំងឺទឹកនោមផ្អែមអំឡុងពេលមានផ្ទៃពោះ ឬ ទារកកើតមកថ្លោសពេក ( > ៣,៥០ គីឡូក្រាម)
- អាយុលើសពី ៣៥ ឆ្នាំ
- ខ្សោយតម្រងនោមរ៉ាំរ៉ៃ
- ជាតិស្ករក្នុងទឹកនោម ពេលធ្វើតេស្ត dipstick ។

**អ្នកជំងឺអេដស៍ដែលព្យាបាលដោយឱសថ Protease Inhibitor ក្នុងរូបមន្តព្យាបាល**

អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ត្រូវបានពិនិត្យស្រាវជ្រាវរកជំងឺទឹកនោមផ្អែម មុនពេលចាប់ផ្តើមព្យាបាលដោយឱសថ PI អាចបង្កឱ្យមានភាពស៊ាំជាមួយឱសថ insulin ។ ការពិនិត្យស្រាវជ្រាវតាមដាននៅខែទី៣ ក្រោយពេលចាប់ផ្តើមព្យាបាលដោយឱសថ PI និងរៀងរាល់១២ខែម្តង ។

---

[៥៦] ក្រសួងសុខាភិបាល កម្ពុជា គោលការណ៍ណែនាំអនុវត្ត គ្លីនិក ។ ជំងឺទឹកនោមផ្អែម ប្រភេទទី២។ ការ ថែទាំបន្ត អ្នកជំងឺ លើសឈាម ដោយមាន និងមិនមាន ផលវិបាក នៅគ្លីនិក ជំងឺមិនឆ្លង / ការិយាល័យ មន្ទីរពេទ្យបង្អែក សម្រាប់ ការបង្ការ និងត្រួតពិនិត្យជំងឺមិនឆ្លងនៃ នាយកដ្ឋានការពារសុខភាព ឆ្នាំ២០១៥។

## ៣៧.២ ការធ្វើរោគវិនិច្ឆ័យជំងឺទឹកនោមផ្អែមប្រភេទ ២ និងជំងឺមិនអាចទ្រាំទ្របានជាមួយជាតិស្ករ ( impaired glucose tolerance)

តារាងទី៣៧-១ លក្ខណៈវិនិច្ឆ័យនៃការធ្វើរោគវិនិច្ឆ័យជំងឺទឹកនោមផ្អែម និងភាពអាចទ្រាំទ្របានជាមួយជាតិស្ករ ស្របតាម *WHO*

| | កំហាប់ជាតិស្ករ, mmol/l (mg/l) | | |
|---|---|---|---|
| | ឈាមសុទ្ធ | | ផ្លាស់ស្មា |
| | សរសៃវ៉ែន | សរសៃឈាមក្រហម | |
| ជំងឺទឹកនោមផ្អែម mellitus | | | |
| មុនពេលហូបអាហារ(fasting) | ≥ ៦,១ (១១០) | ≥ ៦,១ (១១០) | ≥ ៧ (១២៦) |
| ឬ | | | |
| ២ម៉ោងក្រោយពេលមានជាតិស្ករក្នុងឈាម ឬ រួមគ្នា | ≥ ១០ (១៨០) | ≥ ១១,១ (២០០) | ≥ ១១,១ (២០០) |
| ការចុះខ្សោយនៃការទ្រាំទ្រជាមួយជាតិស្ករ | | | |
| កំហាប់ជាតិស្ករមុនពេលហូបអាហារ (បើសិនជាវាស់) | ≤ ៦,១ (១១០) | ≤ ៦,១ (១១០) | ≤ ៧,១ (១២៦) |
| និង | | | |
| ២ម៉ោងក្រោយពេលមានជាតិស្ករក្នុងឈាម។ | ៦,៧-៩,៩ (១២០-១៧៩) | ៧,៨-១១ (១៤០-១៩៩) | ៧,៨-១១ (១៤០-១៩៩) |
| ការឡើងជាតិស្ករក្នុងឈាម | | | |
| មុនពេលហូបអាហារ | ៥,៦-៦ (១០០-១០៩) | ៥,៦-៦ (១០០-១០៩) | ៦,១-៦,៩ (១១០-១២៥) |
| ២ម៉ោងក្រោយ (បើសិនជាវាស់) | ≤ ៦,៧ (១២០) | ≤ ៧,៨ (១៤០) | ≤ ៧,៨ (១៤០) |

*កំណត់សម្គាល់ អំពីការធ្វើតេស្តរកជំងឺទឹកនោមផ្អែម:* ផ្លាស់ស្មាបូមពីឈាមវ៉ែន (Venous plasma)គឺជាតេស្តជម្រើសមួយ ប៉ុន្តែសំណាកឈាមនេះត្រូវតែធ្វើតេស្តក្នុងកំឡុងពេល១ម៉ោង ឬបូមឈាមដោយប្រើបំពង់ទីបដែលមានជាតិ sodium fluoride ដែលឃាត់ឃាំងការរលាយជាតិស្ករ និងរក្សាទុកដោយដាក់ទឹកកកឱ្យត្រជាក់រហូតដល់ពេលធ្វើតេស្តវិភាគ ។ សមត្ថភាពតម្លៃនៃការធ្វើតេស្តនេះ មានលក្ខណៈដូចគ្នាជាមួយការធ្វើតេស្តលើសំណាកឈាម fasting samples និងមានលក្ខណៈខុសគ្នាដោយសំណាកឈាមនេះ អាចធ្វើបានក្នុងរយៈពេល ២ ម៉ោង ។

## ៣៧.៣ ការគ្រប់គ្រងព្យាបាលអ្នកជំងឺ ដែលមិនអាចទ្រាំទ្រជាមួយជាតិស្ករ

- សម្រកទម្ងន់ បើលើសទម្ងន់
- របបអាហារគាំទ្រសុខភាពនិងរបៀបរស់នៅ ដូចបានរៀបរាប់លម្អិតក្នុងតារាងទី៣៩-១។
- ធ្វើតេស្តតាមដាននៅខែទី ១២ ។

## ៣៧.៤ ការគ្រប់គ្រងព្យាបាលជំងឺទឹកនោមផ្អែមប្រភេទទី ២

- សូមអានគោលការណ៍ណែនាំជាតិ សម្រាប់ការគ្រប់គ្រងព្យាបាលជំងឺទឹកនោមផ្អែមគ្រប់ជ្រុងជ្រោយ[៥៧] ។
- ត្រូវបញ្ជូនអ្នកជំងឺទៅទទួលសេវាព្យាបាលនៅគ្លីនិកថែទាំនិងព្យាបាលជំងឺទឹកនោមផ្អែម ប្រសិនជាមាន ។

## ការគ្រប់គ្រងព្យាបាលជំងឺទឹកនោមផ្អែម ទាំងការគ្រប់គ្រងដោយប្រើប្រាស់ឱសថ និងមិនប្រើប្រាស់ឱសថ

**១. វិធានការមិនប្រើប្រាស់ឱសថ** បន្ថយហានិភ័យនៃផលវិបាកជំងឺទឹកនោមផ្អែម ៖

- របបអាហារគាំទ្រសុខភាព និងរបៀបរស់នៅល្អ ដូចបានរៀបរាប់លម្អិតក្នុង តារាងទី៣៤-១ ការផ្លាស់ប្តូររបបអាហារ → របបអាហារសម្រាប់អ្នកជំងឺទឹកនោមផ្អែម វាមានសារៈសំខាន់ក្នុងការបន្ថយមួយផ្នែកនៃ carbohydrate រួមមាន ការបរិភោគបាយ (សូមមើល រូបភាពទី ៤៨-១ ពីរ៉ាមីតរបបអាហារសម្រាប់អ្នកជំងឺទឹកនោមផ្អែមប្រភេទទី២ ឧបសម្ព័ន្ធ ៤៨. ជំងឺទឹកនោមផ្អែម រូបភាពទី ៤៨-១ ពីរ៉ាមីតរបបអាហារសម្រាប់អ្នកជំងឺទឹកនោមផ្អែមប្រភេទទី២ ។

**វាយតម្លៃអ្នកជំងឺ អំពីលក្ខខណ្ឌផ្សេងៗទាក់ទងនឹងជំងឺទឹកនោមផ្អែម ដូចជា៖**

- ទម្ងន់ BMI (សូមមើលតារាងទី៣៣-១ ចំណាត់ថ្នាក់ BMI ចំពោះមនុស្សពេញវ័យដែលមានទម្ងន់ស្រាល លើសទម្ងន់ និងធាត់ ស្របតាម WHO) *និង* បរិវេណចង្កេះ (លើសទម្ងន់ = បុរស ≥៨៥ ស.ម, ស្ត្រី ≥ ៨០ស.ម) ។
- ជំងឺលើសសម្ពាធឈាម > ១៤០/៩០ ឬ > ១៣០/៨០ ប្រសិនបើមានជាតិប្រូតេអ៊ីនក្នុងទឹកនោម (proteinuria) ។
- ជំងឺសរសៃឈាមបេះដូង (ប្រវត្តិជំងឺ ការពិនិត្យជំងឺ និងធ្វើតេស្ត ECG ប្រសិនបើមាន) ។
- ជំងឺសរសៃឈាមខួរក្បាល- ជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺវង្វេងវង្វាន់ (dementia) ។
- ជំងឺតម្រងនោម-ធ្វើតេស្តសេរ៉ូម Creatinine ប៉ូតាស្យូម សូដ្យូម វិភាគទឹកនោម ។
- ឡើងជាតិខ្លាញ់ក្នុងឈាម - តេស្ត serum lipids។
- ការពិនិត្យជើងលម្អិត :
  - សរសៃឈាមដែលផ្គត់ផ្គង់ឈាម ជីពចរ សរសៃឈាមដែលនាំឈាមត្រឡប់មកបេះដូងវិញ (capillary return) ។
  - សរសៃប្រសាទ sensation reflexe កែងជើង។

---

[៥៧] ក្រសួងសុខាភិបាល កម្ពុជា គោលការណ៍ណែនាំអនុវត្ត គ្លីនិក ។ ជំងឺទឹកនោមផ្អែម ប្រភេទទី២។ ការ ថែទាំបន្ត អ្នកជំងឺ លើសឈាម ដោយមាន និងមិនមាន ផលវិបាក នៅគ្លីនិក ជំងឺមិនឆ្លង / ការិយាល័យ មន្ទីរពេទ្យបង្អែក សម្រាប់ ការបង្ការ និងត្រួតពិនិត្យជំងឺមិនឆ្លងនៃ នាយកដ្ឋាន ការពារសុខភាព ឆ្នាំ២០១៥។

- ភាពមុតនៃគំឃើញ (Visual acuity) និងពិនិត្យដោយ fundoscopy រកមើលជំងឺភ្នែកឡើងបាយ (cataracts) និងជំងឺរេទីនភ្នែក (retinopathy) បណ្តាលមកពី ជំងឺទឹកនោមផ្អែម ។

**២. ការគ្រប់គ្រងការព្យាបាលជំងឺទឹកនោមផ្អែមដោយឱសថ** យោងតាមអនុសាសន៍នៃជំងឺមិនឆ្លងរួមមាន ៖

- ឱសថជួរទី១: Metformin ៥០០–២០០០ម.ក្រ បែងចែកជា២កម្រិតដូស លេបពេលហូបអាហារ។
- ជម្រើសឱសថជួរទី១: Gliclazide ៤០–៣២០ម.ក្រ បែងចែកជា ២ កម្រិតដូស លេបពេលហូបអាហារ ។
- ឱសថជួរទី២: Metformin + sulfonylurea ។
- ឱសថជួរទី៣: basal ឬ premix insulin + ឱសថលេប ឬ basal + insulin ពេលហូបអាហារ ។

## អន្តរកម្ម រវាងឱសថ ព្យាបាលជំងឺទឹកនោមផ្អែម និងឱសថប្រឆាំងមេរោគអេដស៍[៥៨]

**តារាងទី៣៧-២ អន្តរកម្ម រវាងឱសថ ព្យាបាលជំងឺទឹកនោមផ្អែម និងឱសថប្រឆាំងមេរោគអេដស៍**

| ឱសថ | អន្តរកម្មជាមួយឱសថប្រឆាំងមេរោគអេដស៍ |
|---|---|
| Gliclazide និង Glimepiride; | សក្តានុពលក្នុងការបន្ថយកម្រិត ដោយឱសថ PI និងបង្កើនកម្រិតដោយឱសថ EVF។ តាមដានដោយប្រុងប្រយ័ត្ននិងអាចតម្រូវឱ្យធ្វើកែសម្រួលកម្រិតដូសឱសថ gliclazide។ |
| Glibenclamide | សក្តានុពលក្នុងបន្ថយកម្រិត ដោយឱសថ EFV និង NVP ហើយបង្កើនកម្រិតដោយឱសថ PI។ |
| Metformin និង insulin | មិនដឹងពីអន្តរកម្មជាមួយឱសថ NNRTI, NRTI PI, និងឱសថប្រឆាំងមេរោគអេដស៍ ប៉ុន្តែឱសថ dolutegravir អាចមានសក្តានុពលបង្កើនកំហាប់ឱសថ metformin ។ |

[៥៨] http://www.hiv-druginteractions.org/

# ជំពូក ៣៨. ជំងឺលើសជាតខ្លាញ់ក្នុងឈាម (Hyperlipidaemia)

## ៣៨.១ ការពិនិត្យស្រាវជ្រាវការលើសជាតខ្លាញ់ក្នុងឈាម លើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

- ហានិភ័យជំងឺសរសៃឈាមបេះដូង ស្របគ្នានឹងការកើនឡើងនូវ low–density lipoprotein cholesterol (LDL-C) និង/ឬ hypertriglyceridemia ជាពិសេស ប្រសិនបើមានទំនាក់ទំនងនឹងការថយចុះនូវ high-density lipoprotein cholesterol (HDL-C) ។
- ជាតិខ្លាញ់ទាក់ទងនឹងហានិភ័យជំងឺសរសៃឈាមបេះដូង (CVD) មិនបានឆ្លុះបញ្ចាំងពី កូឡេស្តេរ៉ុលសរុប(TC)ដែលវាស់វែងតែឯងនោះទេ ដោយសារវាជាផ្នែកមួយនៃ LDL-C និង HDL–C (HDL-C ឡើងខ្ពស់ គឺជា ភ្នាក់ងារការពារជំងឺបេះដូង) ។
- កម្រិត Triglyceride > ១0mmol/L បង្កើនហានិភ័យជំងឺរលាកលំពែង ។
- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ដែលព្យាបាលដោយមានឱសថ PI ក្នុងរូបមន្តព្យាបាលនឹងបង្កើនហានិភ័យកើនឡើងជាតិខ្លាញ់ក្នុងឈាម (Hyperlipidaemia) បើទោះបីជា មានការកើនឡើងតិចនៅពេលព្យាបាលដោយឱសថ ATV/r បើធៀបទៅនឹងការប្រើឱសថ LPV/r ។
- ការធ្វើតេស្តកម្រិតជាតិខ្លាញ់ក្នុងឈាម (serum lipids) និងការកំណត់កម្រិតនៃការព្យាបាលជាមួយឱសថដែលធ្វើឱ្យថយចុះជាតិខ្លាញ់ អាស្រ័យលើអ្នកជំងឺដែលមានហានិភ័យជំងឺសរសៃឈាមបេះដូង ។ ក្នុងស្ថានភាពដែលមានហានិភ័យខ្ពស់ ត្រូវផ្តល់អនុសាសន៍ឱ្យប្រើថ្នាំ Statins ដោយមិនគិតពីរង្វាស់ជាតិខ្លាញ់ក្នុងឈាមនោះទេ ។ ឧ. អ្នកជំងឺទាំងអស់ដែលមានជំងឺគាំងបេះដូង (myocardial infarct) ឬ ជំងឺដាច់សរសៃឈាមខួរក្បាល នឹងទទួលបានផលប្រយោជន៍ពីការចាប់ផ្តើមព្យាបាលដោយឱសថ Statin លើកលែងតែ ក្នុងករណីមាន contraindicated ។

### អ្នកជំងឺអេដស៍ដែលចាប់ផ្តើមព្យាបាលដោយឱសថ PI ក្នុងរូបមន្តព្យាបាល

- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ទាំងអស់ ត្រូវធ្វើតេស្តពិនិត្យជាតិខ្លាញ់ក្នុងឈាម (fasting serum lipids) មុននឹងចាប់ផ្តើមព្យាបាលដោយឱសថ PI ដែលមានក្នុងរូបមន្តព្យាបាលដោយ ឱសថប្រឆាំងមេរោគអេដស៍ (ជាទូទៅ ក្នុងរូបមន្តព្យាបាលជួរទី២) និងត្រូវពិនិត្យតាមដាននៅ៣ខែក្រោយ និងបន្ទាប់មករៀងរាល់១២ខែម្តងដោយសារឱសថ PI អាចបង្កឱ្យមានHyperlipidaemia ។
- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ អាចទទួលការព្យាបាលដោយឱសថផ្សេងទៀត សម្រាប់គ្រប់គ្រងការកើនឡើងជាតិខ្លាញ់ក្នុងឈាម ឧ. ការព្យាបាលជំងឺទឹកនោមផ្អែម ។

## ៣៨.២ ការគ្រប់គ្រងព្យាបាលការលើសជាតខ្លាញ់ក្នុងឈាម (hyperlipidaemia)

Hyperlipidaemia តម្រូវឱ្យមានការគ្រប់គ្រងទាំងការព្យាបាលដោយប្រើប្រាស់ឱសថ និងមិនប្រើប្រាស់ឱសថ ។

**១. ការគ្រប់គ្រងដោយមិនប្រើប្រាស់ឱសថ**

- យោងតាមតារាងទី៣៨-១ អំពីទំនាក់ទំនងនៃផលប៉ះពាល់នៃកម្រិតជាតិខ្លាញ់ដោយផ្ទាល់ ឬ កត្តាហានិភ័យនៃជំងឺមិនឆ្លង ។
- បន្ថយការបរិភោគជាតិខ្លាញ់ឆ្អែត (ខ្លាញ់សត្វ) ជំនួសដោយមនោ/ខ្លាញ់មិនឆ្អែត(mono/polyun-saturated fats) ។
- បង្កើនប្រសិទ្ធភាពការត្រួតពិនិត្យជំងឺទឹកនោមផ្អែម ។

**២. ការគ្រប់គ្រងព្យាបាលដោយប្រើប្រាស់ឱសថ**

- ប្តូរពីឱសថ LPV/r ទៅប្រើឱសថ ATV/r (លើកលែងករណីមាន contraindicated)
  - បើឡើង LDL-C លើសលប់
    - ប្រើ Statin
  - បើឡើង TG (> ១០mmol/l) ជាពិសេស ឡើងជាមួយនឹងការកើនឡើង low HDL-C
    - ប្រើ Fibrate និង/ឬ ខ្លាញ់ត្រី ។

- **គោលដៅនៃការព្យាបាល** (បង្កើនកម្រិតដូសឱសថ រហូតដល់កម្រិតដូសមានសុវត្ថិភាព ដើម្បីសម្រេចបានដូចខាងក្រោម) ។
  - Total Cholesterol < ៤,០mmol/L
  - HDL–C ≥ ១,០mmol/L
  - LDL-C < ២mmol/L
  - TG < ២mmol/L

## ៣៨.២.១ អន្តរកម្មឱសថ រវាងឱសថបន្ថយជាតខ្លាញ់ក្នុងឈាម និងឱសថប្រឆាំងមេរោគអេដស៍

តារាងទី៣៨-១ អន្តរកម្មឱសថរវាងឱសថបន្ថយជាតិខ្លាញ់ក្នុងឈាម និងឱសថប្រឆាំងមេរោគអេដស៍

| Statins |
| --- |
| • **Simvastatin និង lovastatin មាន *contraindicated* ជាមួយឱសថ PI ដែលមានក្នុងរូបមន្តព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នាំឱ្យមានហានិភ័យខ្ពស់ជំងឺរលាកឆ្អឹង និងសាច់ដុំ** (rhabdomyolysis) ។<br>• ឱសថ statins ផ្សេងទៀត អាចយកមកប្រើប្រាស់ជាមួយឱសថ PI តែត្រូវប្រើក្នុងកម្រិតដូសទាប:<br>  • Atorvastatin ចាប់ផ្តើម ១០ ម.ក្រ → កម្រិតដូសអតិបរិមាជាមួយឱសថ PI = ៤០ម.ក្រ<br>  • Pravastatin ចាប់ផ្តើម ២០ម.ក្រ → កម្រិតដូសអតិបរិមាជាមួយឱសថ PI = ៤០ម.ក្រ<br>  • Rosuvastatin ចាប់ផ្តើម ៥ ម.ក្រ → កម្រិតដូសអតិបរិមាជាមួយឱសថ PI = ២០ ម.ក្រ |

| |
|---|
| • **Fibrates**<br>o Gemfibrozil :<br>▪ កម្រិតឱសថអាចនៅទាប ដោយសារការប្រើឱសថ PI ។<br>▪ ចៀសវាងប្រើរួមគ្នាជាមួយ statin បណ្តាលឱ្យមានហានិភ័យរលាកសាច់ដុំ (myositis) ។<br>o Fenofibrate<br>▪ តាមដាន ALT/CK បើប្រើរួមគ្នាជាមួយ statins បណ្តាលឱ្យកើតឡើងហានិភ័យផលប៉ះពាល់ ។ |
| • គេមិនទាន់ដឹងពីអន្តរកម្មរវាង **ខ្លាញ់ត្រី** ជាមួយឱសថប្រឆាំងមេរោគអេដស៍ទេ ។ |

## ៣៨.២.២ តាមដានផលប៉ះពាល់នៃឱសថ

**ឱសថបន្ថយជាតិខ្លាញ់ អាចបណ្តាលឱ្យមានវិបត្តិមុខងារថ្លើម និងជំងឺសាច់ដុំ** (myopathy)

- អ្នកជំងឺត្រូវដឹងពីរោគសញ្ញានៃការឈឺសាច់ដុំ (សាច់ដុំមានការឈឺចាប់ ឡើងរឹង ខ្សោយ) និងរលាកថ្លើម (ឈឺចាប់ក្នុងពោះ ក្អួត) ។
  - ធ្វើតេស្ត ALT និង creatinine kinase(CK) នៅពេលដើមគ្រា ។
  - ធ្វើតេស្ត CK និង ALT ម្តងទៀត បើមានរោគសញ្ញាណាមួយ ។
  - បញ្ឈប់ការប្រើឱសថ បើសាច់ដុំនៅតែមានការឈឺចាប់ ឬសាច់ដុំខ្សោយ ឧ. បើ CK > ៥០០ U/L ។
  - បញ្ឈប់ការប្រើឱសថ បើ CK > ១០០០U/L ដោយគ្មានរោគសញ្ញា ។
  - បញ្ឈប់ការប្រើឱសថ បើ ALT កើនឡើង > ៣ដង x ULN ។

# ជំពូក ៣៩. ជំងឺពុកឆ្អឹង (Osteoporosis)

- ជំងឺពុកឆ្អឹង ត្រូវបានកំណត់ដោយការថយចុះភាពរឹងមាំនៃឆ្អឹង នាំឱ្យមានហានិភ័យខ្លាំងនៃការ បាក់ឆ្អឹង ។
- Osteopenia (ថយចុះជាតិកាល់ស្យូម និងភាពរឹងមាំនៃឆ្អឹង) ត្រូវបានកំណត់ដោយ "ភាពបាត់បង់នៃឆ្អឹង" និងអាចបណ្តាលឱ្យមានជំងឺពុកឆ្អឹង ។

## ៣៩.១ កត្តាហានិភ័យជំងឺពុកឆ្អឹង

- អាយុ > ៥០ឆ្នាំ ភេទស្រី មាន BMI ទាប រាងកាយអសកម្ម ជក់បារី អ្នកចាក់គ្រឿងញៀន (IDU) ។
- ប្រើថ្នាំ Corticosteroid ។
- ការឆ្លងមេរោគអេដស៍ ជាពិសេស អ្នកជំងឺអេដស៍ក្នុងដំណាក់កាលធ្ងន់ធ្ងរ ។
- ការព្យាបាលដោយឱសថ tenofovir នាំឱ្យមានការបាត់បង់ឆ្អឹងក្នុងដំណាក់កាលដំបូង ជាធម្មតាវាមានស្ថេរភាពឡើងវិញ ក្រោយការព្យាបាលរយៈពេល ២ ទៅ ៣ ឆ្នាំ ។
- ជំងឺទឹកនោមផ្អែម hyperthyroidism ជំងឺរលាកថ្លើមប្រភេទC និងជំងឺថ្លើមរ៉ាំរ៉ៃ ។
- ជំងឺរ៉ាំរ៉ៃផ្សេងៗ ដូចជា ជំងឺ myeloma ភាពមិនប្រក្រតីនៃក្រពេញអង់ដូគ្រីន ។

## ៣៩.២ ការវាយតម្លៃ

- ឧបករណ៍វាយតម្លៃហានិភ័យការបាក់ឆ្អឹង យោងតាម WHO (FRAX) គឺជាការគណនាអនឡាញ (online) បានបង្កើតឡើងដើម្បីធ្វើការប៉ាន់ស្មានហានិភ័យការបាក់ឆ្អឹងក្នុងកំឡុងពេល ប្រហែលជា ១០ ឆ្នាំខាងមុខ ផ្អែកតាមកត្តាហានិភ័យគ្លីនិក (អាយុ BMI ។ល។) ដោយមិនចាំបាច់ធ្វើតេស្ត DXA (bone mineral density) ។[៥៩]
- ថយចុះកម្ពស់ អាចកើតឡើងដោយសារការបាត់បង់ឆ្អឹងធ្ងន់ធ្ងរ និងបាត់បង់កម្ពស់នៃឆ្អឹងកងខ្នង ។

## ៣៩.៣ ការបង្ការនិងការគ្រប់គ្រងព្យាបាលជំងឺពុកឆ្អឹង និងការបាក់ឆ្អឹង

- តារាងទី៣៩-១ លម្អិតអំពីវិធានការសំខាន់ៗសម្រាប់ការបង្ការ និងការគ្រប់គ្រងព្យាបាលជំងឺពុកឆ្អឹង ។ ការផ្តោតសំខាន់គឺ លើការឈប់ជក់បារី គុណភាពរបបអាហារ រួមទាំង ការទទួលទានឱ្យបានគ្រប់គ្រាន់នូវជាតិកាល់ស្យូម វីតាមីន D ហើយរក្សាបាននូវកម្រិតទម្ងន់ដែលមានសុខភាពល្អ ហាត់ប្រាណស្របតាមទម្ងន់ខ្លួន (ឧ. ការដើរ) និងបន្ថយទទួលទានគ្រឿងស្រវឹង ។
- ចៀសវាងប្រើឱសថ corticosteroids រយៈពេលយូរ លើកលែងតែករណីចាំបាច់ និងប្រើកម្រិតដូសទាបបំផុតដែលមានប្រសិទ្ធភាព ។
- បើអ្នកជំងឺបាក់ឆ្អឹង ដោយសារបញ្ហាពុកឆ្អឹង (ឆ្អឹងកដៃ ឆ្អឹងត្រគាក ឆ្អឹងកងខ្នង បណ្តាលមកពីការប៉ះទង្គិច ឬរបួសបន្តិចបន្តួច) ពិចារណាផ្លាស់ប្តូរពីការប្រើឱសថ TDF ទៅប្រើឱសថផ្សេងវិញ ប្រសិនបើអាចធ្វើទៅបាន ។

---

[៥៩] ការគណនាអនឡាញ( online) គឺធ្វើតាមប្រទេសនិមួយៗ, ការគណនាសមស្របតាម លក្ខណៈ របស់អ្នកជំងឺ អាចរកបានជាភាសាថៃ: http://www.shef.ac.uk/FRAX/tool.aspx?country=57

# ជំពូក ៤០. ជំងឺតម្រងនោម

កត្តារួមចំណែកជាច្រើន នាំឱ្យមានជំងឺតម្រងនោម លើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ និងការរង របួសតម្រងនោម ជាទូទៅ ត្រូវបានធ្វើរោគវិនិច្ឆ័យយឺតពេល ដោយសារតែអ្នកជំងឺអាចគ្មានរោគសញ្ញា ឬ រោគសញ្ញាមិនជាក់លាក់ ។

## ៤០.១ ការពិនិត្យស្រាវជ្រាវជំងឺតម្រងនោម

**តារាងទី៤០-១ ការធ្វើតេស្តអមវេជ្ជសាស្ត្រដើម្បីស្រាវជ្រាវមុខងារតម្រងនោម**

| ការធ្វើតេស្តទឹកនោម |
|---|
| ការធ្វើតេស្ត dipstick ទឹកនោម រួមមាន៖<br>• ជាតិស្ករ៖ វិជ្ជមានលើអ្នកជំងឺទឹកនោមផ្អែមដែលមិនបានត្រួតពិនិត្យ និង ការពុលតម្រងនោម ដោយឱសថ TDF ។<br>• ជាតិ Nitrites និង កោសិកា leukocytes៖ វិជ្ជមាន ករណីមានការបង្ករោគតាមបំពង់បង្ហូរនោម (urinary tract infections =UTI) ។<br>• ឈាម៖ បើវិជ្ជមាន ជាមួយ nitrites + leukocytes = UTI, បើអវិជ្ជមាន ពិចារណា លើការរលាក តម្រងនោម (nephritis) (→ វាស់សម្ពាធឈាម) ។<br>• ជាតិ Protein: វិជ្ជមាន ករណីរបួសតម្រងនោម រួមមាន៖<br>    • UTI (រួមជាមួយ nitrites និង leukocytes)<br>    • Nephritis (រួមជាមួយឈាម)<br>    • Nephritic syndrome – ជាញឹកញាប់ ≥ ២+<br>    • ខូចខាតបង្ហូរនោមស្រួចស្រាវ ឬរ៉ាំរ៉ៃ (ឧ. មកពីការប្រើប្រាស់ឱសថ TDF) ។ |
| Urine albumin / creatinine ratio (ACR):<br>• កើនឡើងលើអ្នកជំងឺ diabetic nephropathy (ជាទូទៅ តេស្ត dipstick អវិជ្ជមាន ជាតិ protein និង creatinine +/- N) ។ |
| ពិនិត្យទឹកនោម ដោយ microscopy<br>• កោសិកាឈាមស កោសិកាឈាមក្រហម និងមេរោគបង្ក (UTI)<br>    • បើអាចធ្វើបាន ត្រូវបណ្ដុះមេរោគ ដើម្បីកំណត់រកមេរោគបង្ក និង antimicrobial sensitivity ។<br>• ទម្រង់កោសិកាឈាមក្រហម<br>    • ខូចទ្រង់ទ្រាយកោសិកាឈាមក្រហម ដែលមានដើមកំណើតមកពីតម្រងនោម (nephritis) ។<br>    • កោសិកាសឈាមក្រហមធម្មតា មានដើមកំណើតមកពីផ្នែកខាងក្រោមនៃបង្ហូរនោម។ |

| ការធ្វើតេស្តឈាម |
|---|
| តេស្ត Serum Creatinine<br>• Creatinine គឺសារធាតុគីមីធម្មជាតិបញ្ចេញក្នុងទឹកនោម ។<br>• Serum creatinine កើនឡើង នៅពេលដែលមិនបានលាងសម្អាតល្អ និងជាទូទៅ បញ្ជាក់ថាតម្រងនោមមានរបួស ។ |
| • Creatinine clearance/estimated Glomerular Filtration Rate (eGFR)<br>  • ជាការវាយតម្លៃមុខងារតម្រងនោម ដែលមានលក្ខណៈជាក់លាក់ ជាងការធ្វើតេស្ត serum creatinine ។<br>  • eGFR ថយចុះពេលមានរបួសតម្រងនោម (កម្រិតធម្មតានៃ eGFR = > ៩០ម.ល/នាទី)<br>  • eGFR អាចគណនាតាម Cockroft – សមីការ Gault:<br>eGFR ml/min = (១៤០ –អាយុ) x ទម្ងន់ (គ.ក្រ)/serum creatinine (μmol/l) (ចំពោះបុរស)<br>eGFR ml/min = (១៤០ –អាយុ) x ទម្ងន់ (គ.ក្រ) x ០,៨៥ /serum creatinine (μmol/l) (ចំពោះស្ត្រី) ។ |
| • Serum electrolytes: potassium, sodium, phosphate, bicarbonate, urate |
| • CBC: normocytic anaemia (MCV ធម្មតា) កើតឡើងជាញឹកញាប់ ក្នុងករណីរបួសតម្រងនោមរ៉ាំរ៉ៃ ។ |
| **កាពិនិត្យតម្រងនោមដោយអេកូ** |
| • ជំងឺរលាកតម្រងនោមរ៉ាំរ៉ៃ ជាទូទៅ → តម្រងនោមតូច (<៩ស.ម)<br>• ជំងឺរលាកតម្រងនោមស្រួចស្រាវ → តម្រងនោមរីកធំ (>១២ ស.ម)ឧ. HIVAN<br>• ការស្ទះបង្ហូរនោម<br>  • ការស្ទះបង្ហូរនោមទាំងសងខាង (ជាញឹកញាប់បណ្តាលមកពីជំងឺរបេងកូនកណ្តុរ)<br>  • ការស្ទះបង្ហូរនោមខាងក្រោម –ឧ. ប្រូសស្តាតរីកធំ (prostatic enlargement) ។ |

សូមមើលគំនូសបំព្រួញអំពី ការស្រាវជ្រាវភាពមិនធម្មតានៃ creatinine និងការធ្វើតេស្ត dipstick ទឹកនោម
រូបភាពទី៤៧-១គំនូសបំព្រួញកាវាយតំលៃ creatinine
រូបភាពទី ៤៧-២ គំនូសបំព្រួញអំពីការពិនិត្យទឹកនោម ដោយ dipstick។

## ៤០.២ របួសតម្រងនោមស្រួចស្រាវ

### ៤០.២.១ របួសផ្នែកខាងមុខតម្រងនោមស្រួចស្រាវ

ជាទូទៅ បណ្តាលមកពីដំណាក់កាលថយចុះសម្ពាធឈាម ដោយសារៈ

- បង្ករោគធ្ងន់ធ្ងរ (Sepsis)

- បាត់បង់ជាតិទឹកច្រើន ឧ. បាត់ជាតិទឹកដោយសាររាករូស
- មូលហេតុសរសៃឈាម ឧ. myocardial infarct ។
- **ការធ្វើរោគវិនិច្ឆ័យ**: ការវាយតម្លៃគ្លីនិក អំពីស្ថានភាពជាតិទឹក មានភស្តុតាងថាមាន sepsis ។
- **ការគ្រប់គ្រងព្យាបាល**:
    - ការបំពេញជាតិទឹក ជាញឹកញាប់តម្រូវឱ្យចាក់តាមបញ្ចូលជាតិទឹកតាមសរសៃឈាម ។
    - ព្យាបាលមូលហេតុ sepsis បើរកឃើញ
    - ចៀសវាងប្រើឱសថនាំឱ្យពុលតម្រងនោម (NSAIDS, aminoglycosides)
    - បើមុខងារតម្រងនោម មិនប្រសើរឡើងបានឆាប់រហ័សទេ ត្រូវ៖
        - ស្រាវជ្រាវពីមូលហេតុផ្សេងទៀតនៃជំងឺតម្រងនោម ។
        - កែសម្រួលកម្រិតដូសឱសថ ដែលបញ្ចេញចោលតាមតម្រងនោម ស្របតាម creatinine clearance (សូមមើលតារាងទី៤៧-១ការកែតម្រូវកម្រិតដូសឱសថលើអ្នកជំងឺដែលខ្សោយតម្រងនោម) ។
        - តាមដានមុខងារតម្រងនោមតាមរយៈការប្រែប្រួល eGFR, ប្រសិនបើតម្រូវឱ្យមានការកែសម្រួលកម្រិតដូសឱសថបន្ថែមទៀត ។

### ៤០.២.២ របួសផ្នែកខាងក្រោយតម្រងនោមស្រួចស្រាវ

ការស្ទះតម្រងនោម (ឧ. ការស្ទះតម្រងនោមបង្កដោយជំងឺរបេង) ។

- ការធ្វើរោគវិនិច្ឆ័យ: ការឆ្លុះអេកូ ដើម្បីបញ្ជាក់ពីការស្ទះបង្ហួរនោម និងតម្រងនោមរីកធំដោយសារទឹក (hydronephrosis) ។
- បើគ្មានអេកូទេ ត្រូវបញ្ជូនអ្នកជំងឺទៅឆ្លុះអេកូនៅសេវាដែលអាចធ្វើបាន ប៉ុន្តែការឆ្លុះអេកូ មិនអាចរកឃើញសញ្ញាគ្លីនិកពាក់ព័ន្ធនឹងជំងឺរបេងទេ ដូច្នេះ វាជាការសមហេតុផល ក្នុងការចាប់ផ្តើមព្យាបាលជំងឺរបេង និងតាមដានមុខងារតម្រងនោម ។

### ៤០.២.៣ របួសតម្រងនោមខាងក្នុង

**មូលហេតុជាច្រើនបណ្តាលឱ្យចុះខ្សោយតម្រងនោម ដូចជាប្រតិកម្ម ឱសថ រួមមាន ៖**

- ការពុលឱសថ Tenofovir (TDF) (សូមមើលផ្នែកខាងក្រោម)
- ការពុលឱសថ Cotrimoxazole និង rifampicin
    - ជំងឺ Interstitial nephritis – អ្នកជំងឺមានរោគសញ្ញា ដូចរោគសញ្ញាផ្តាសសាយ ឈឺចាប់មួយចំហៀងខ្លួន (flank pain) គ្រុនក្តៅ ។
    - ការពុលឱសថ Rifampicin កើតឡើងជាញឹកញាប់ នៅពេលឈប់ប្រើ និងនៅពេលចាប់ផ្តើមប្រើឱសថ Rifampicin ឡើងវិញ ។

## ៤០.៣ ជំងឺតម្រងនោមរ៉ាំរ៉ៃ

### ៤០.៣.១ ជំងឺតម្រងនោមរ៉ាំរ៉ៃ បណ្តាលមកពីជំងឺលើសសម្ពាធ និង/ឬ ជំងឺទឹកនោមផ្អែម

- ការធ្វើរោគវិនិច្ឆ័យ ផ្អែកលើប្រវត្តិន៍ជំងឺ និងតេស្តអមវេជ្ជសាស្ត្រ
  - កើនឡើង creatinine រយៈពេលវែង ជាច្រើនខែ ។
  - តេស្តប្រូតេអ៊ីនក្នុងទឹកនោម (Proteinuria) ដោយប្រើ dipstick កើនឡើង ACR (ប្រសិនជាអាចធ្វើបាន) ។
  - ជំងឺស្លេកស្លាំងតិចតួច (normocytic MCV) ។
  - តម្រងនោមរួមតូច ពេលពិនិត្យដោយអេកូ (ប្រសិនជាអាចធ្វើបាន) ។

### ការគ្រប់គ្រងព្យាបាល

- បញ្ឈប់ការជក់បារី
- ជម្រើសការព្យាបាលជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម ។
- រួមបញ្ចូល ACE I ក្នុងរូបមន្តព្យាបាល ឧ. enalopril ២,៥០ម.ក្រ ២ដង/ថ្ងៃ (វាស់សម្ពាធឈាម និង potassium) ។
- ចៀសវាងប្រើឱសថពុលតម្រងនោម ជាពិសេស ឱសថ NSAIDS
- កែសម្រួលកម្រិតដូសឱសថ ដែលបញ្ចេញចោលតាមតម្រងនោម អាស្រ័យតាម creatinine clearance (សូមមើលតារាងទី ៩៧-១ ការកែតម្រូវកម្រិតដូសឱសថលើអ្នកជំងឺខ្សោយតម្រងនោម) ។
- តាមដានលើការប្រែប្រួលកម្រិត eGFR ដែលអាចតម្រូវឱ្យមានការលៃសម្រួលកម្រិតដូសឱសថបន្ថែមទៀតតាមពេលវេលា
- តាមដាន creatinine និងប្រសិនបើ Cr > ២៥០ បញ្ជូនទៅទទួលសេវានៅផ្នែកឯកទេសតម្រងនោម ប្រសិនបើ មានសេវានេះ ។

### ៤០.៣.២ ការពាក់ព័ន្ធរវាងជំងឺអេដស៍ និង ជំងឺតម្រងនោម (HIV AN)

- ការពាក់ព័ន្ធរវាងជំងឺអេដស៍ និងជំងឺតម្រងនោម (HIVAN) បណ្តាលមកពីផលប៉ះពាល់ដោយផ្ទាល់នៃមេរោគអេដស៍ទៅលើតម្រងនោម ។ ជាទូទៅ កើតឡើងចំពោះអ្នកជំងឺដែលស្ថិតក្នុងដំណាក់កាលធ្ងន់ធ្ងរនៃជំងឺអេដស៍ និងមានចំនួនកោសិកា CD4 ទាប ប៉ុន្តែ វាក៏អាចកើតឡើងលើអ្នកជំងឺ អេដស៍ដែលមានចំនួនកោសិកា CD4 ខ្ពស់ផងដែរ ។
- HIV AN ស្ថិតក្នុងដំណាក់កាលគ្លីនិកទី៤ នៃ WHO ។
- HIV AN អាចកើតឡើងក្នុងរយៈពេលពីរទៅបីខែ បណ្តាលឱ្យមានជំងឺតម្រងនោមក្នុងដំណាក់ចុងក្រោយ (End Stage Renal Disease =ESRD) ។

## ការធ្វើរោគវិនិច្ឆ័យ

- ≥ ២+ proteinuria, creatinine ជាទូទៅមានការកើនឡើង (តែមិនមែនកើតឡើងជានិច្ចជាកាលនោះទេ) ។
- លើសសម្ពាធឈាម និងការហើម កើតមានដោយកំរ ហើយប្រសិនបើមាន ត្រូវពិនិត្យរកមូលហេតុផ្សេង ។
- ការធ្វើរោគវិនិច្ឆ័យ ត្រូវបានបញ្ជាក់ដោយការធ្វើ biopsy ប៉ុន្តែតេស្តនេះមិនសូវអាចធ្វើបានទេ។

## ការគ្រប់គ្រងព្យាបាល

- ចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន
- ព្យាបាលជាតិប្រូតេអ៊ីនក្នុងទឹកនោម (proteinuria) ដោយប្រើឱសថ enalopril ២,៥ម.ក្រ ២ដង/ថ្ងៃ - វាស់សម្ពាធឈាម និងធ្វើតេស្តរក potassium ។
- តាមដានជាតិ proteinuria និង creatinine រៀងរាល់ ៣ខែ/ម្តង រយៈពេល២ដង បន្ទាប់មករៀងរាល់ ៦ខែ/ម្តង ។
- ចៀសវាងប្រើប្រាស់ឱសថដែលធ្វើឱ្យពុលតម្រងនោម (nephrotoxic drugs) និងកែសម្រួលកម្រិតដូសឱសថដែលបញ្ចេញចោលតាមតម្រងនោម អាស្រ័យតាម eGFR សូមមើលតារាងទី៤៧-១ ការកែតម្រូវកម្រិតដូសឱសថលើអ្នកជំងឺដែលខ្សោយតម្រងនោម)។
- តាមដានមុខងារតម្រងនោម តាមការប្រែប្រួល eGFR ដែលតម្រូវឱ្យកែសម្រួលកម្រិតដូស ឱសថបន្ថែមទៀត ។

# ជំពូក ៤១. ការប្រើប្រាស់គ្រឿងញៀន

- អ្នកចាក់គ្រឿងញៀន (PWID) និងអ្នកប្រើប្រាស់គ្រឿងញៀន (PWUD) នៅកម្ពុជា មានអត្រាឆ្លងមេរោគអេដស៍ខ្ពស់ជាងប្រជាជនទូទៅ (សូមមើល តារាងទី៤៣-២ ការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍តាមក្រុមប្រជាជន នៅកម្ពុជា) ។
- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ ដែលប្រើប្រាស់គ្រឿងញៀន រួមទាំង ការផឹកសុរាច្រើន ការញៀនកញ្ឆា ការប្រើប្រាស់ amphetamines(យ៉ាម៉ា) និងការញៀនអាភាន អាចជួបប្រទះបញ្ហាជាច្រើនដែលប៉ះពាល់ដល់សុខភាពរបស់ពួកគេ ។
- ការពុល ការបន្ថយកម្រិតដូសនិងការប្រើហួសកម្រិតដូស អាចមានលទ្ធផលមិនល្អសម្រាប់អ្នកជំងឺ ។
- ជាការសំខាន់ ការប្រើប្រាស់គ្រឿងញៀនអាចនាំឱ្យមានការរំខានដល់ការលេបឱសថប្រឆាំងមេរោគអេដស៍ឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ និងការទទួលទានអាហារូបត្ថម្ភឱ្យបានគ្រប់គ្រាន់ ។
- ការចាក់គ្រឿងញៀនប្រឈមមុខនឹងការឆ្លងវីរុសតាមឈាម ដូចជា វីរុសរលាកថ្លើមប្រភេទ B និងC ការបង្ករោគត្រង់កន្លែងចាក់ ការរាលដាលមេរោគក្នុងឈាម (septicaemia) និង រលាកសាច់ដុំបេះដូងបង្កដោយបាក់តេរី ។
- ប្រើប្រាស់គ្រឿងញៀន អាចបណ្តាលឱ្យខ្វះសុភៈវិនិច្ឆ័យ និងការប្រព្រឹត្តិដែលបង្កើនការប្រឈមមុខខ្ពស់ក្នុងការឆ្លងមេរោគអេដស៍ ។
- អ្នកជំងឺត្រូវបានផ្តល់ការអប់រំអំពីហានិភ័យទាក់ទងនឹងការប្រើប្រាស់គ្រឿងញៀន ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃគ្រឿងញៀន (រួមទាំង ការចោលឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនដែលបានប្រើប្រាស់រួចដោយសុវត្ថិភាព) និងបញ្ជូនទៅកម្មវិធីកាត់បន្ថយគ្រោះថ្នាក់នៃគ្រឿងញៀន និងកម្មវិធីពាក់ព័ន្ធ ដូចជា ការព្យាបាលជំនួសដោយ methadone ។ សំរាប់ការព្យាបាលជំនួសដោយ ឱសថមេតាដូន សូមបញ្ជូនអ្នកចាក់គ្រឿង ញៀនទៅសេវាព្យាបាល នៅគ្លីនិកនៅមន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត និងនៅមន្ទីរពេទ្យបង្អែកមានជ័យ ខ័ណ្ឌច្បារអំពៅ(គ្រោងនឹងដំណើរការឆ្នាំ២០១៦។

# ជំពូក ៤២. សុខភាពផ្លូវចិត្ត

- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ រងគ្រោះបញ្ហាសុខភាពផ្លូវចិត្តជាច្រើន រួមទាំង ធ្លាក់ទឹកចិត្តថប់បារម្ភ រំលោភបំពានសារធាតុញៀន និងលក្ខខណ្ឌវិកលចរិក ផ្សេងទៀត ។
- អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ មានហានិភ័យនៃការវិវត្តន៍ទៅ ជំងឺវង្វេងវង្វាន់(dementia) ទាក់ទងនឹងការបង្ករោគដោយមេរោគអេដស៍ ។
- បញ្ហាសុខភាពផ្លូវចិត្តទាំងនេះ អាចបណ្តាលឱ្យមានការរំខានការលេបឱសថប្រឆាំងមេរោគអេដស៍ឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ហើយការព្យាបាលអាចនឹងមានសក្តានុពល លើផលប៉ះពាល់ និងអន្តរកម្មឱសថ ។
- ផលប៉ះពាល់នៃ Efavirenz នាំឱ្យមានបញ្ហាសុខភាពផ្លូវចិត្តកាន់តែធ្ងន់ធ្ងរ ដូច្នេះ ត្រូវពិចារណាផ្លាស់ប្តូរឱសថនេះ ប្រសិនបើ វាមានផលប៉ះពាល់ ។

- សូមអានឧបសម្ព័ន្ធ ៤៩. សុខភាពផ្លូវចិត្ត
- រូបភាពទី៤៩-១ រោគសញ្ញាដែលកើតឡើងជាញឹកញាប់នៃស្ថានភាពសុខភាពផ្លូវចិត្ត។
- សម្រាប់ព័ត៌មានបន្ថែម សូមអានអន្តរាគមន៍ mhGAP គោលការណ៍ណែនាំអំពី សុខភាពផ្លូវចិត្ត វិបត្តិសរសៃប្រសាទបណ្តាលមកពីការប្រើប្រាស់សារធាតុញៀននៅក្រៅគ្រឹះស្ថានសុខាភិបាល ។ កម្មវិធីសកម្មភាពសុខភាពផ្លូវចិត្ត Gap ២០១០។អង្គការសុខភាពពិភពលោក។អាចរកបាននៅ: http://www.paho.org/mhgap/en/ ។

## ៤២.១ ជំងឺធ្លាក់ទឹកចិត្ត (Depression)

ជំងឺធ្លាក់ទឹកចិត្ត កើតឡើងជាញឹកញាប់ ហើយមិនត្រូវបានធ្វើរោគវិនិច្ឆ័យលើអ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ទេ ។ វាអាចរួមចំណែកដល់ការបាត់បង់ការតាមដានជំងឺ និងការលេបថ្នាំប្រឆាំងមេរោគអេដស៍មិនបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ។

### ៤២.១.១ រោគសញ្ញាគ្លីនិកជំងឺធ្លាក់ទឹកចិត្ត

- អារម្មណ៍ក្រៀមក្រំ ខ្វះការលើកទឹកចិត្ត ខ្វះការប្រមូលអារម្មណ៍ ខ្វះថាមពល
- ស្រក់ទឹកភ្នែក ឬភ័យរន្ធត់
- វិបត្តិដំណេក
- ខ្វះការជឿជាក់លើខ្លួនឯង ខ្វះការថែទាំ/អនាម័យផ្ទាល់ខ្លួន
- ផ្លាស់ប្តូរការចង់ហូបអាហារ និងទម្ងន់
- ការសេពជាតិសុរា ឬប្រើប្រាស់គ្រឿងញៀនផ្សេងទៀត
- ថយចុះសមត្ថភាពក្នុងការបំពេញមុខងារជាមូលដ្ឋានប្រចាំថ្ងៃ ។

### ៤២.១.២ ការពិនិត្យស្រាវជ្រាវជំងឺធ្លាក់ទឹកចិត្ត

**តារាងទី៤២-១ កម្រងសំនួរសម្រាប់ស្រាវជ្រាវជំងឺធ្លាក់ទឹកចិត្ត**

1. ក្នុងអំឡុង១ខែកន្លងមក តើអ្នកមានអារម្មណ៍ថា ដូចជាអ្នកកំពុងតែបាត់បង់អារម្មណ៍ ឬបាត់បង់ក្តីសប្បាយរីករាយក្នុងការធ្វើរឿងអ្វីមួយដែរឬទេ ?
2. តើអ្នកមានអារម្មណ៍ធ្លាក់ចុះ ជំងឺធ្លាក់ទឹកចិត្ត ឬការអស់សង្ឃឹមដែរឬទេ ?

- ប្រសិនបើ អ្នកជំងឺហាក់ដូចជាធ្លាក់ទឹកចិត្ត វាជាការសំខាន់ត្រូវវាយតម្លៃពីហានិភ័យនៃការចង់ធ្វើអត្តឃាត៖
  - តើអ្នកធ្លាប់បានគិតអំពីការបញ្ចប់អ្វីៗទាំងអស់ ឬទេ ?
  - តើអ្នកធ្លាប់បានគិតអំពីការបញ្ចប់ជីវិតរបស់អ្នកឬទេ ?
- ប្រសិនបើមាន ចម្លើយថា បាទ/ចាស សូមសួរអំពី តើក្នុងកាល:ទេស:បែបណា បានជាគាត់គិតរបៀបនេះ ហើយតើគាត់មានគំនិត ឬផែនការណាមួយដើម្បីធ្វើឱ្យខ្លួនគាត់មានការឈឺចាប់ ?

### ៤២.១.៣ ការវាយតម្លៃ និងការគ្រប់គ្រងព្យាបាលជំងឺធ្លាក់ទឹកចិត្ត

- ច្រានចោលមូលហេតុផ្សេងៗនៃជំងឺធ្លាក់ទឹកចិត្ត (ឧ. ធ្វើតេស្ត TFT ប្រសិនជាអាចធ្វើបាន)
- ពិនិត្យរកមើលមូលហេតុផ្សេងទៀត: ស្វែងយល់ពីបញ្ហាផ្លូវចិត្តនិងសង្គម
- បញ្ជូនទៅសេវាផ្តល់ប្រឹក្សា ក្រុមគាំទ្រ ឬសេវាសុខភាពផ្លូវចិត្តសមស្រប
- ករណីធ្ងន់ធ្ងរ ត្រូវវាយតម្លៃ អំពីតម្រូវការនៃការព្យាបាលដោយឱសថប្រឆាំងជំងឺធ្លាក់ទឹកចិត្ត (antidepressant medication) និងត្រូវចាប់ផ្តើមព្យាបាលក្នុងរយៈពេល ១ សប្តាហ៍ ។

#### ការព្យាបាលដោយឱសថ

អន្តរកម្មជាច្រើនរវាងឱសថព្យាបាលជំងឺផ្លូវចិត្ត និងឱសថប្រឆាំងមេរោគអេដស៍ ដូច្នេះត្រូវពិនិត្យមើលអន្តរកម្មឱសថ មុននឹងចាប់ផ្តើមព្យាបាល ឬ អ្នកជំងឺកំពុងតែព្យាបាលដោយឱសថប្រឆាំងជំងឺធ្លាក់ទឹកចិត្ត (antidepressant)[៦០] ។

**តារាងទី៤២-២ អន្តរកម្ម រវាងឱសថព្យាបាលជំងឺផ្លូវចិត្ត និងឱសថប្រឆាំងមេរោគអេដស៍**

| ឱសថព្យាបាលជំងឺផ្លូវចិត្ត | NRTI | NNRTI | PI |
|---|---|---|---|
| Diazepam (ថ្នាំលេប) | OK | EFV potentially ↓ ពេលប្រើ diazepam | PI potentially ↑ ពេលប្រើ diazepam |
| Midazolam (IMI) | OK | Contraindicated ដោយសារ EFV ↑↑ ពេលលេប midazolam | ប្រុងប្រយ័ត្នពេលប្រើ PI ↑ ពេលប្រើជាមួយ midazolam។ |
| Haloperidol (ថ្នាំលេប /IMI) | OK | EFV potentially ↓ ពេលប្រើជាមួយ haloperidol | ត្រូវប្រយ័ត្នពេលប្រើ PI ↑ ពេលប្រើប្រាស់ amitryptaline/SSRI/ haloperidol, គ្រប់មូលហេតុនៃ QT prolongation. ចៀសវាងបើអាចធ្វើបាន ចៀសវាងបន្ថយកម្រិតដូសនៃ amitryptaline/SSRI/ haloperidol និងធ្វើតេស្ត ECG តាមដាន ។ |
| Amitriptyline | OK | OK | |
| SSRI – fluoxetine, sertraline | OK | OK | |
| SSRI – sertraline, venlafaxine, citralopram | OK | EFV potentially ↓ កម្រិតនៃ SSRI | |

[៦០] www.hiv-druginteractions.org/

## ៤២.២ ជំងឺវង្វេងវង្វាន់: ជំងឺផ្លូវចិត្ត និង ជំងឺផ្នែកវេជ្ជសាស្ត្រ?

វាសំខាន់ណាស់ក្នុងការបែងចែក រវាងអ្នកជំងឺវង្វេងវង្វាន់ ក្នុងករណីដែលអ្នកជំងឺមានភាពរវើរវាយ (delirium) ដោយសារតែការព្យាបាលមូលហេតុជំងឺណាមួយ ឬការបង្កជំងឺផ្លូវចិត្តដំបូង ។

- ការវើរវាយ ត្រូវបានកំណត់ដោយការឡើងចុះនៃវិញ្ញាណចងចាំជារួម ដោយមានទំនាក់ទំនងនឹងការប្រព្រឹត្តិខុសប្រក្រតី ។

**តារាងទី៤២-៣ ការវែកញែក រវាងជំងឺវេជ្ជសាស្ត្រ ចេញពីជំងឺឆ្កួត**[៦១]

| | ការវើរវាយ កើតក្រោយពី មូលហេតុវេជ្ជសាស្ត្រ | Psychosis (ជំងឺផ្លូវចិត្ត) ដែលជារោគសញ្ញានៃជំងឺឆ្កួត |
|---|---|---|
| **មូលហេតុ** | *វេជ្ជសាស្ត្រ:*<br>ការបង្ករោគ/ខ្វះអុកស៊ីសែន/ខ្វះជាតិស្ករក្នុងឈាម/ជំងឺខួរក្បាល/ជំងឺថ្លើម ជំងឺខួរក្បាល/ទាក់ទងនឹងការប្រើឱសថ ។ | *ជំងឺផ្លូវចិត្ត(Psychiatric):*<br>វិកលចរិក(Schizophrenia),<br>វិបត្តិអារម្មណ៍ជាមួយនឹងលក្ខណ: វិកលចរិក ។ |
| **ការលេចចេញរោគសញ្ញា** (Onset) | ចាប់ផ្តើមជាច្រើនម៉ោង ឬច្រើនថ្ងៃ ។ | ចាប់ផ្តើមដោយមានរោគសញ្ញាកាន់តែខ្លាំងឡើងជាបណ្តើរៗ ។ |
| | ស្ថានភាពផ្លូវចិត្តឡើងចុះ | ស្ថានភាពផ្លូវចិត្តមិនឡើងចុះ |
| | ការបាត់បង់វដ្តនៃដំណេក/វដ្តនៃការភ្ញាក់ពីដំណេក<br>វិបត្តិស្មារតី<br>អន្ទះអន្ទែង(agitation) វញ្ញាក់រញ៉ូវ ។ | គ្មានការរំខានស្មារតី<br>បាត់បង់ស្មារតី(Delusion) ។ |
| **ការតម្រង់ទិស** | ការច្រឡំពេលវេលា មនុស្ស ទីកន្លែង | ជាទូទៅ អាចចំណាំបាន |
| **ការមើមមាយ** (Hallucination) | ការមើលអ្វីមួយមិនច្បាស់ | Hallucinations – ជាទូទៅការស្តាប់មិនច្បាស់ ។ |
| **ការចងចាំ** | បាត់បង់ការចងចាំរយ:ពេលខ្លី | មិនបាត់បង់ការចងចាំ |
| **ការប្រុងប្រយ័ត្ន** | ពិបាកក្នុងការផ្តោតអារម្មណ៍លើអ្វីមួយ ។ | ការប្រុងប្រយ័ត្ន ឬផ្តោតអារម្មណ៍នៅធម្មតា ។ |
| **ប្រវត្តិជំងឺ** | ភាពមិនធម្មតា មានប្រវត្តិជំងឺដូចគ្នា ។ | ប្រវត្តិជំងឺដែលធ្លាប់កើតលើកមុន ជាញឹកញាប់ ។ |

[៦១] ប្រែសម្រួល ពី គោលការណ៍ណែនាំគ្លីនិក ជំងឺរបេង/អេដស៍ អង្គការ MSF ២០១៥

**ការវាយតម្លៃ និងការគ្រប់គ្រងព្យាបាលជំងឺវង្វេងវង្វាយ**(delirium)

- ស្រង់ប្រវត្តិជំងឺ (រួមទាំង ការប្រើប្រាស់គ្រឿងញៀន) និងការពិនិត្យរាងកាយពេញលេញ ដើម្បីរុករកមូលហេតុវេជ្ជសាស្ត្រ ។
- ត្រួតពិនិត្យឡើងវិញនៃការប្រើប្រាស់ឱសថ និងបញ្ឈប់ឱសថណាមួយដែលអាចធ្វើឱ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរឡើង ។
- អនុវត្តការធ្វើតេស្តកម្រិតជាតិស្ករក្នុងឈាម និងការស្រាវជ្រាវពាក់ព័ន្ធផ្សេងទៀត ។
- ពិចារណាក្នុងការបូមទឹកខួរឆ្អឹងខ្នង (LP) ដើម្បីផាត់ចេញការបង្ករោគនៅប្រព័ន្ធសរសៃប្រសាទកណ្តាល (ឧ. ជំងឺរបេង ជំងឺ cryotococcus) ។
- ពិនិត្យភាពឆ្អែតនៃអុកស៊ីសែន (ប្រសិនបើមានម៉ាស៊ីនអាចធ្វើបាន) ។
- បើសង្ស័យថា ទើបតែផឹកស្រា ចាក់ Thiamine តាមសរសៃ (មុននឹងចាក់បញ្ចូលគ្លុយកូសតាមសរសៃ IVI) ។
- គ្រប់គ្រងព្យាបាលអ្នកជំងឺក្នុងបន្ទប់ស្ងប់ស្ងាត់ និងមានសមាជិកគ្រួសារនៅជាមួយគាត់ ។
- ពន្យល់អ្នកជំងឺឱ្យបានច្បាស់ អំពីអ្វីដែលនឹងកើតឡើង និងពន្យល់សារឡើងវិញ បើសិនជាចាំបាច់ ។
- ការវង្វេងវង្វាយ អាចមានបន្តទៀតនៅពេលខ្លះ បន្ទាប់ពីបញ្ហាវេជ្ជសាស្ត្រត្រូវបានដោះស្រាយ និងណែនាំឱ្យក្រុមគ្រួសារ ផ្តល់ការថែទាំអ្នកជំងឺឱ្យមានសុវត្ថិភាព ក្រោយពីចេញពីមន្ទីរពេទ្យ ។

**ការគ្រប់គ្រងព្យាបាលជំងឺផ្លូវចិត្ត**

- បញ្ជូនអ្នកជំងឺទៅ សេវាសុខភាពផ្លូវចិត្ត ។

## ៤២.៣ ការគ្រប់គ្រងព្យាបាលអ្នកជំងឺដែលមានឥរិយាបថត្រូវសង្គ្រោះបន្ទាន់

ជួនកាលស្ថានភាពមួយបានកើតឡើងនៅពេលដែលបុគ្គលម្នាក់មានការភិតភ័យខ្លាំងហើយបង្កឥរិយាបថក្នុងរបៀបមួយ ដែលអាចបង្កហានិភ័យដល់ខ្លួនឯង និងអ្នកដទៃទៀត ។

- សូមព្យាយាមរក្សាអ្នកជំងឺឱ្យស្ថិតនៅបរិស្ថានស្ងប់ស្ងាត់ និងមានការចូលរួមការគាំទ្រពីក្រុមគ្រួសារ ឬមិត្តភក្តិដែលអាចជួយគាត់ និងឱ្យអ្នកផ្សេងទៀតដែលអាចធ្វើឱ្យភិតភ័យចាកចេញពីគាត់ ។
- និយាយជាមួយអ្នកជំងឺដោយស្ងៀមស្ងាត់ និងច្បាស់លាស់ និងពន្យល់យ៉ាងច្បាស់អំពីអ្វីដែលកំពុងកើតឡើង ។

ចំពោះការគ្រប់គ្រងករណីសង្គ្រោះបន្ទាន់ នៃការភិតភ័យ/ភាពកាចសាហាវរបស់អ្នកជំងឺ (ជាបណ្តោះអាសន្ន) ខណៈពេលកំពុងរៀបចំបញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យ អាចនឹងពិចារណារប្រើប្រាស់ឱសថក្នុងក្រុម antipsychotic និង sedative medication ក្រោយពេល វិធានការមិនប្រើប្រាស់ឱសថទទួលបរាជ័យ។

ត្រូវពិចារណា អំពីអន្តរកម្មឱសថ មុននឹងព្យាបាលដោយឱសថ (សូមមើលតារាងទី ៤២-២ អន្តរកម្ម រវាងឱសថព្យាបាលជំងឺផ្លូវចិត្ត និងឱសថប្រឆាំងមេរោគអេដស៍) ។

ប្រើថ្នាំលេបជាមុនសិន (ចំណាយពេលវេលាដើម្បីបញ្ចុះបញ្ចូលអ្នកជំងឺដោយទន់ភ្លន់ និងមានជំនួយពីសមាជិកគ្រួសារ ឬមិត្តភក្តិដែលគាត់ជឿទុកចិត្ត) ។

- ឱសថជួរទី១: Diazepam ៥ –១០ ម.ក្រ លេបរាល់២– ៦ម៉ោង/ម្តង អាស្រ័យទៅតាមការឆ្លើយនៃរោគសញ្ញាគ្លីនិក អាចប្រើរហូតដល់កម្រិតបរិមា ៦០ម.ក្រ ក្នុងរយៈពេល ២៤ ម៉ោង ។
- ឱសថជួរទី២: Haloperidol ០,៥–២ម.ក្រ លេបរាល់២ម៉ោង/ម្តង អាស្រ័យទៅតាមការឆ្លើយនៃរោគសញ្ញាគ្លីនិក អាចប្រើរហូតដល់កម្រិតបរិមា ៥-១០ម.ក្រ ក្នុងរយៈពេល ២៤ ម៉ោង ។

ប្រសិនបើមិនអាចលេបថ្នាំបាន ត្រូវប្រើថ្នាំចាក់:

- Haloperidol ៥–១០ ម.ក្រ ចាក់ IMI ។

**ការតាមដាន**

- ចូរប្រយ័ត្នមិនឱ្យលើសកម្រិតដូសរម្ងាប់អារម្មណ៍ទេ (over-sedate) និងត្រូវយល់ដឹង អំពីផលប៉ះពាល់បន្ថែមរយៈពេលយូរ ដែលជាលទ្ធផលនៃការប្រើកម្រិតដូសច្រើនលើកច្រើនសារ និងការបង្កើនឥទ្ធិពលរួមគ្នានៃឱសថ ។

- តាមដានអ្នកជំងឺឱ្យបានជិតដល់ –រៀងរាល់ ១៥នាទី/ម្តង ដើម្បី៖
  - បន្ថយស្ថានភាពនៃការដឹងខ្លួន(conscious state) ។
  - ថយចុះសម្ពាធឈាម ជំងឺថប់ដង្ហើម (respiratory depression) ស្ទះផ្លូវដង្ហើម ការបូមវត្ថុរាវចេញពីសួត (aspiration) ។
  - ចៀសវាងការរងរបួសដល់អ្នកជំងឺ ឬអ្នកដទៃទៀត ។

បញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យភ្លាម ដើម្បីបន្តការពិនិត្យស្រាវជ្រាវ និងការគ្រប់គ្រងព្យាបាលបន្ថែមទៀត។

# ការព្យាបាលបន្ទាន់ ក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍

# ជំពូក ៤៣. ការព្យាបាលបង្ការក្រោយពេលមានគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ (PEP)

ការព្យាបាលបង្ការក្រោយពេលមានគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ (PEP) សំដៅទៅលើការលេបឱសថប្រឆាំងមេរោគអេដស៍ ដោយបុគ្គលដែលមានលទ្ធផលតេស្តឈាមរកពោគអេដស៍ អវិជ្ជមាន ដើម្បីបង្ការកុំឱ្យឆ្លងមេរោគអេដស៍ក្រោយពីមានការប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ពីបុគ្គលដែលផ្ទុកមេរោគអេដស៍ (ឬបុគ្គលដែលមិនដឹងពីស្ថានភាពមេរោគអេដស៍) ។

- PEP គឺជាការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍៣មុខ ដែលត្រូវបានចាប់ផ្តើមឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីមានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ និង បន្តការព្យាបាលរៀងរាល់ថ្ងៃរហូត ២៨ថ្ងៃ ក្រោយការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ។
- PEP អាចនឹងត្រូវពិចារណា ក្រោយពីមានរបួសនៅពេលបំពេញការងារ ដូចជា របួសដោយមុតម្ជុលចំពោះបុគ្គលិកសុខាភិបាល ឬបន្ទាប់ពីការប្រឈមមុខនឹងសកម្មភាពផ្លូវភេទ ជាពិសេស ចំពោះជនរងគ្រោះនៃការរំលោភផ្លូវភេទ ។
- រាល់ការចេញវេជ្ជបញ្ជាណាមួយនៃ PEP ត្រូវធ្វើតាមគោលការណ៍យល់ព្រមគ្នា ដោយផ្អែកលើការយល់ដឹង ពីហានិភ័យ និងពីអត្ថប្រយោជន៍ រួមទាំង ការពិភាក្សាអំពីផលប៉ះពាល់ដែលអាចកើតឡើង និងពីសារៈសំខាន់នៃការលេបថ្នាំឱ្យត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់នៃ PEP ។

## ៤៣.១ ការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍

**សារធាតុរាវនៃសរីរាងដែលអាចនាំឱ្យមានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ៖**

- ការប៉ះពាល់ឈាម ឈាមលាយទឹកមាត់ ការបំបៅកូនដោយទឹកដោះម្តាយដែលផ្ទុកមេរោគអេដស៍ ទឹករំអិលបញ្ចេញដោយប្រដាប់ភេទ ទឹកខួរឆ្អឹងខ្នង ទឹកភ្លោះ ទឹករន្ធគូថ ទឹកសន្លាក់ (synovial) ទឹកស្រោមបេះដូង ឬ ទឹកស្រោមសួត ។

**សារធាតុរាវសរីរាងដែលមិនបង្កហានិភ័យខ្ពស់នៃការឆ្លងមេរោគអេដស៍ហើយមិនតម្រូវឱ្យព្យាបាលបង្ការដោយ PEP ទេ ដូចជា ទឹកភ្នែក ទឹកមាត់ដែលមិនលាយឈាម ទឹកនោម និងញើស ។**

តារាងទី៤៣-១ ផ្លូវចម្លងនៃមេរោគអេដស៍ និងកម្រិតមធ្យមនៃហានិភ័យនៃការឆ្លងមេរោគអេដស៍តាមដំណាក់កាល

| ការប្រឈមមុខជាមួយនឹងប្រភពនៃការឆ្លងមេរោគអេដស៍ | ការប៉ាន់ស្មាននៃហានិភ័យនៃការឆ្លងមេរោគអេដស៍ តាមដំណាក់កាល[៦២] |
|---|---|
| *ប្រឈមមុខនឹងការឆ្លងតាមផ្លូវភេទ (តាមរយៈឈាម ទឹកកាមបុរស និង ទឹករំអិលទ្វារមាស)* | |
| • ការរួមភេទដោយស៊កបញ្ចូលតាមទ្វារមាស (ឆ្លងពីស្ត្រីមកបុរស) | ១/២៥០០ (០,០៤%) |
| • ការរួមភេទតាមទ្វារមាសជាកន្លែងទទួល (ឆ្លងពីបុរសទៅស្រី) | ១/១២៥០ (០,០៨%) |
| • ការរួមភេទតាមរន្ធគូថជាកន្លែងទទួល (ឆ្លងពីបុរសទៅបុរស(MSM) ឬពីបុរសទៅស្រី) *ដោយគ្មាន* ការដកចេញមុនពេលចេញទឹកកាម។ | ១/៧០ (១,៤៣%) |
| • ការរួមភេទតាមរន្ធគូថជាកន្លែងទទួល *ដោយមាន* ការដកចេញមុនពេលចេញទឹកកាម។ | ១/១៥៥ (០,៦៤%) |
| • ការរួមភេទដោយស៊កបញ្ចូលតាមរន្ធគូថ ដោយមិនបានកាត់ស្បែកគ្របលិង្គ (បុរសរួមភេទជាមួយបុរស)។ | ១/១៦០ (០,៦២%) |
| • ការរួមភេទតាមរន្ធគូថដោយស៊កបញ្ចូល ដោយបានកាត់ស្បែកគ្របលិង្គ(បុរសរួមភេទជាមួយបុរស)។ | ១/៩០០ (០,១%) |
| • រួមភេទតាមមាត់: ដោយស៊កបញ្ចូល ឬជាកន្លែងទទួល (ប្រុសឬស្រី)។ | កម្រិតទាបណាស់ |
| *ការប្រឈមមុខជាមួយឈាម* | |
| • ការចាក់គ្រឿងញៀនតាមសរសៃ: ឆ្លងតាមសម្ភារៈចាក់ទំលុះស្បែក | ១/១២៥ |
| • ការមុតម្ជុលពេលបំពេញការងារ(NSI) ឬសម្ភារៈមុតស្រួចផ្សេងទៀត | ១/៤៤០ |
| • ការបញ្ចូលឈាម | ១/១,១ (៩០%) |
| *ការប្រឈមមុខផ្សេងទៀត* | |
| • ការប្រឈមមុខដោយការប៉ះពាល់ Mucus membrane ឬស្បែកដែលមិនដាច់រលាត់។ | < ១/១០០០ |

[៦២] ការព្យាបាលបង្ការក្រោយពេលមានគ្រោះថ្នាក់ប្រឈមនឹងការឆ្លងមេរោគអេដស៍នៅពេលបំពេញការងារ ឬមិននៅពេលបំពេញការងារ។ គោលការណ៍ណែនាំជាតិ។ ASHM 2013. មាននៅ www.ashm.org.au.

## កត្តាបង្កើនហានិភ័យនៃការឆ្លងមេរោគអេដស៍

- អ្នកផ្ទុកមេរោគ ដែលមានចំនួនមេរោគអេដស៍ (Viral load) ខ្ពស់-នៅដំណាក់កាល seroconverting ឬជំងឺអេដស៍ក្នុងដំណាក់កាលធ្ងន់ធ្ងរ ។
- ការឆ្លងតាមការចាក់ថ្នាំ៖
  - មេរោគអេដស៍ជ្រៀតចូលតាមមុខរបួសដោយសារមុតម្ជុល និង/ឬ ចាក់ម្ជុលចូលទៅក្នុងសរសៃឈាមវ៉ែន ឬសរសៃឈាមក្រហមដោយផ្ទាល់ ។
- ការចម្លងតាមផ្លូវភេទ៖
  - ប្រភពចម្លងរោគ ឬបុគ្គលដែលប្រឈមមុខនឹងការឆ្លងជំងឺកាមរោគ ជាពិសេស ជំងឺដំបៅប្រដាប់បន្តពូជ និងការបង្ករោគដោយ gonococcus ។
  - ដាច់រលាត់ភ្នាស់ mucosa ក្នុងប្រដាប់បន្តពូជ (មានរបួស ការបង្ករោគ) ។
  - ដាច់រលាត់ភ្នាស mucosa ក្នុងមាត់ ករណីរួមភេទតាមមាត់ ។
  - បុរសដែលមិនផ្ទុកមេរោគអេដស៍ ហើយមិនបានកាត់ស្បែកគ្របលិង្គ និងរួមភេទដោយស៊កបញ្ចូលតាមទ្វារមាស ឬតាមរន្ធគូថ ។

## ការប៉ាន់ស្មានគ្រោះថ្នាក់អំពីការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ពីប្រភពដែលមិនដឹងច្បាស់

ការប្រឈមមុខនៃការឆ្លងមេរោគអេដស៍ = ហានិភ័យនៃការឆ្លង ផ្អែកតាមការប្រឈមមុខ x ការប្រឈមមុខនៃការឆ្លងមេរោគអេដស៍ពីបុគ្គលដែលមានតេស្តមេរោគអេដស៍ វិជ្ជមាន (ប្រេវ៉ាឡង់)

**តារាងទី៤៣-២ ការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍តាមក្រុមប្រជាជន នៅកម្ពុជា**

*(ប្រភព NCHADS 2015)*

| ប្រជាជន/ក្រុមប្រជាជន | ប្រេវ៉ាឡង់ |
|---|---|
| ប្រជាជនទូទៅជាមនុស្សពេញវ័យ | ០,៦% |
| អ្នកចាក់គ្រឿងញៀន (PWID) | ២៤,៨% |
| អ្នកប្រើប្រាស់គ្រឿងញៀនដោយមិនចាក់ (PWUD) | ៤,៤% |
| ស្ត្រីបម្រើសេវាកំសាន្ត (មានដៃគូរួមភេទ > ៧ នាក់ /សប្តាហ៍) | ១៣,៩% |
| អ្នកប្លែងភេទពីបុរស →ស្ត្រី | ៩,៨% |
| បុរសរួមភេទជាមួយបុរស | ២,៣% |

**ឧទាហរណ៍ គណនាការប៉ាន់ប្រមាណនៃការប្រឈមមុខនឹងព្រឹត្តិការណ៍ពិសេស នៅប្រទេសកម្ពុជា ប៉ុន្តែគួរកត់សម្គាល់ថា ៖**

១. ហានិភ័យពិតប្រាកដអាចកើនឡើង ដោយសារតែកត្តាជីវសាស្ត្រ ដែលបានរៀបរាប់ខាងលើ ។

២. ក្នុងករណីនៃការរំលោភផ្លូវភេទ ប្រភពប្រជាសាស្ត្រនេះ អាចមិនត្រូវបានគេដឹងទេ ។

- ហានិភ័យនៃការឆ្លងមេរោគអេដស៍ ទៅមន្ត្រីសុខាភិបាល ដែលរងរបួសដោយការមុតម្ជុលក្រោយពេលចាក់ថ្នាំអ្នកផ្ទុកមេរោគអេដស៍ដែលបានដឹង = ១/៤៤០ ឬ ០,២៣% ។
- ហានិភ័យនៃមន្ត្រីសុខាភិបាល ដែលមានរបួសដោយមុតម្ជុល ពីមនុស្សពេញវ័យម្នាក់ដែលជាប្រជាជនទូទៅ ដោយមិនដឹងពីស្ថានភាពមេរោគអេដស៍=១/៤៤០ (០,២៣%) x ០,៦% = ០,០០១៤% ។
- ហានិភ័យនៃបុរសដែលធ្លាប់បែកធ្លាយស្រោមអនាម័យនៅពេលរួមភេទតាមទ្វារមាស ជាមួយស្ត្រីបំរើសេវាកំសាន្ត = ១/២៥០០ x ១៣,៩% = ០,០០៥៦% ។
- ហានិភ័យនៃបុរសដែលត្រូវបានគេរំលោភតាមរន្ធគូថ (សន្មតិថា ក្រុមបុរសរួមភេទជាមួយបុរស) = ១/៧០ x ២,៣% = ០,០៣៣% ។
- ហានិភ័យនៃស្ត្រីដែលត្រូវបានគេចាប់រំលោភតាមទ្វារមាស ដោយបុរសម្នាក់ជាប្រជាជនទូទៅ = ១/១២៥០ x ០,៦% = ០,០០០៤៨% ។
- ហានិភ័យនៃស្ត្រីដែលត្រូវបានគេចាប់រំលោភតាមទ្វារមាសដោយអ្នកចាក់គ្រឿងញៀនម្នាក់ = ១/១២៥០ x ២៤,៨% = ០,០២% ។

## ការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍កាន់តែខ្លាំង និងមកពីប្រភពច្រើន ត្រូវបូកបន្ថែមសម្រាប់ការប៉ាន់ស្មាននៃកម្រិតហានិភ័យ

- ហានិភ័យនៃស្ត្រីម្នាក់ដែលត្រូវបានគេរំលោភតាមទ្វារមាស និងតាមរន្ធគូថ ដោយអ្នកប្រើប្រាស់គ្រឿងញៀនម្នាក់គឺ (១/១២៥០ x ៤,៤%) + (១/៧០ x ៤,៤%) = ០,០០៣៥% + ០,០៦% = ០,០៧%។
- ហានិភ័យនៃស្ត្រីម្នាក់ដែលត្រូវបានគេចាប់រំលោភតាមទ្វារមាស ដោយក្រុមអ្នកប្រើប្រាស់គ្រឿងញៀន៥នាក់ = ៥ x ១/១២៥០ x ៤,៤% = ០,០១៨% ។

## ៤៣.២ ការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ក្នុងចំណោមបុគ្គលិកសុខាភិបាលនៅពេលបំពេញការងារ

- PEP មានប្រសិទ្ធភាពខ្លាំងបំផុត ប្រសិនបើ បានចាប់ផ្តើម PEP ក្នុងកំឡុងពេល ៤ ម៉ោង ក្រោយពេលមានគ្រោះថ្នាក់ ប៉ុន្តែគេអាចផ្តល់ PEP បានរហូតដល់ទៅ ៧២ ម៉ោង ក្រោយពេលមានគ្រោះថ្នាក់ ។
- ការផ្តល់ PEP ក្នុងករណីនៃការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍នៅពេលបំពេញការងារ ដែលមានប្រភពពីអ្នកជំងឺអេដស៍ ៖
  - មុតចាក់ជ្រៅ មុខរបួសធំ ដោយម្ជុលមានមុខកាត់ធំ ។
  - របួសដោយមុតម្ជុល បន្ទាប់ពី បានប្រើប្រាស់សម្រាប់ចាក់សាច់ដុំ/សរសៃឈាម/ចាក់សើរស្បែក។

- ការរងរបួស ដោយឧបករណ៍មុតស្រួចកខ្វក់ ហើយប្រឡាក់ឈាមដែលអាចមើលឃើញ ។
- ការប៉ះពាល់ > ១នាទី នៃបរិមាណឈាមដ៏ច្រើន ជាមួយស្បែកដែលគ្មានការដាច់រលាត់ ឬភ្នាសស្តើងនៃស្បែក ។
- ការប៉ះពាល់ស្រដៀងគ្នាជាមួយឈាមដែលប៉ះពាល់នឹងទឹកខួរឆ្អឹងខ្នង ទឹកសន្លាក់ ទឹកស្រោមសួត ទឹកស្រោមបេះដូង ឬទឹកភ្លោះ ។

**ទាក់ទងនឹងប្រភពនៃជំងឺ**

- ប្រសិនបើ ប្រភពត្រូវបានគេដឹងថា មាន VL undetectable ហានិភ័យនៃការឆ្លងមេរោគអេដស៍ អាចត្រូវបានកាត់បន្ថយ ទោះជាយ៉ាងណា ការចម្លងមេរោគអេដស៍តាមរយៈឈាម នៅតែជាហេតុផលដ៏សមស្រប ក្នុងការពិចារណាព្យាបាលបង្ការការចម្លងរោគអេដស៍ក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (PEP) ។
- បើសិនបើ ប្រភពជាអ្នកជំងឺដែលមិនទាន់ដឹងពីស្ថានភាពមេរោគអេដស៍ → ផ្តល់ប្រឹក្សាអ្នកជំងឺនោះឱ្យធ្វើតេស្តឈាមរកមេរោគអេដស៍ឱ្យបានឆាប់ តាមដែលអាចធ្វើបាន ។
- ត្រូវផ្តល់ប្រឹក្សាអំពីប្រភពចម្លង ដោយគោរពគោលការណ៍រក្សាការសម្ងាត់ និងគោរពសិទ្ធិស្របច្បាប់របស់គាត់ ក្នុងការបដិសេធមិនធ្វើតេស្តឈាម ។
- ប្រសិនបើ ប្រភពត្រូវបានគេដឹងថា ធ្លាប់បរាជ័យក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគ អេដស៍ ត្រូវចាប់ផ្តើមផ្តល់ PEP និងពិភាក្សាជាមួយគ្រូពេទ្យជំនាញ ។

## ៤៣.៣ ការប្រឈមមុខនឹងការឆ្លងតាមផ្លូវភេទ

- PEP គួរចាប់ផ្តើមឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន និងស្ថិតក្នុងកំឡុងពេល ៧២ ម៉ោង។
- ប្រសិនបើ មានការប្រឈមមុខនឹងការឆ្លងតាមផ្លូវភេទ មកពីអ្នកជំងឺដែលគេដឹងថា មានតេស្ត VL undetectable (ឧ.ធ្លាយស្រោមអនាម័យពេលរួមភេទជាមួយដៃគូដែលផ្ទុកមេរោគអេដស៍) ហានិភ័យគឺមានកម្រិតទាបខ្លាំងណាស់ ហើយ PEP មិនត្រូវបានលើកទឹកចិត្តឱ្យព្យាបាលទេ ។

## ៤៣.៤ រូបមន្តព្យាបាល PEP

- ត្រូវលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ គ្រប់រយៈពេល **២៨ ថ្ងៃពេញលេញ** គឺមានសារៈសំខាន់ ដើម្បីទទួលបានប្រសិទ្ធភាពនៃការព្យាបាល ។
- **រូបមន្តព្យាបាលជាជម្រើសគឺ ២ NRTI + ឱសថក្នុងក្រុម PI** ក្នុងកម្រិតដូសស្តង់ដា ។
  - **TDF ៣០០ ម.ក្រ + 3TC ៣០០ម.ក្រ + ATV /r ៣០០/១០០ម.ក្រ លេប១ដង/ថ្ងៃ x២៨ថ្ងៃ** ។

- ឆ្អឹងខ្នងក្រុមឱសថ NRTI នៃ TDF + 3TC គឺមានភាពអត់ទ្រាំល្អ និងឱសថក្រុម PI គឺមានប្រសិទ្ធភាពក្នុងករណីមានការចម្លងភាពស៊ាំជាមួយឱសថក្រុម NNRTI ។

- ប្រសិនបើ មិនទាន់មានឱសថជួរទី៣ទេ ឬមាន contraindicated រូបមន្តដែលមានឱសថក្រុម NRTI ២ មុខ គឺអាចទទួលយកបាន បើប្រភពចម្លងមេរោគអេដស៍ត្រូវបានគេដឹង ឬសង្ស័យថា ធ្លាប់បរាជ័យនៃការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។
- Efavirenz ជារូបមន្តព្យាបាល PEP ជួរទី៣ ទោះជាយ៉ាងណា វាអាចមិនមានប្រសិទ្ធភាព ករណីដែលមានការចម្លងវីរុសអេដស៍ដែលស៊ាំជាមួយ NNRTI និងមានផលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទកណ្តាល អាចបង្កការលំបាកដល់អ្នកជំងឺណាដែលមានជំងឺថប់បារម្ភ ទាក់ទងទៅនឹងការប្រឈមមុខនឹងការឆ្លងថ្មីនៃមេរោគអេដស៍ ។
- គ្មាន contraindications ទេ ក្នុងការផ្តល់ PEP សម្រាប់ស្រ្តីមានផ្ទៃពោះឬ ស្ត្រីកំពុងបំបៅដោះកូន។
- មានទ្រឹស្តីហានិភ័យនៃការរលាកថ្លើម (hepatic flare) ក្នុងចំណោមអ្នកជំងឺរលាកថ្លើមប្រភេទ B នៅពេលព្យាបាលដោយឱសថ TDF+ 3TC ដែលត្រូវបានជ្រើសរើសយកមកព្យាបាល PEP ត្រូវបានបញ្ឈប់ដូចដែលបានឃើញអ្នកជំងឺអេដស៍ដែលទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។ ការវាយតម្លៃពីស្ថានភាពជំងឺរលាកថ្លើមប្រភេទ B មិនត្រូវយកប្រើជាលក្ខខណ្ឌក្នុងការប្រើ ឱសថ TDF+ 3TC សម្រាប់ការព្យាបាល PEP នោះទេ ប៉ុន្តែ អ្នកជំងឺដែលដឹងថា មានការបង្ករោគរលាកថ្លើមប្រភេទ B ត្រូវធ្វើការតាមដាន hepatic flare ក្រោយពីបញ្ឈប់ការព្យាបាលដោយឱសថបង្ការការចម្លងមេរោគអេដស៍ ដែលមានរូបមន្ត TDF+3TC ជាមូលដ្ឋាន ។

## ៤៣.៥ ការព្យាបាលបង្ការក្រោយពីមានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍

| ១. ការវាយតម្លៃ និងការគ្រប់គ្រងព្យាបាលភ្លាមៗ<br>(តារាងទី៥០-១ ទម្រង់នៃការមកពិនិត្យពិគ្រោះជំងឺ និងទម្រង់របាយការណ៍អំពី PEP) |
|---|
| ➢ **ការសង្គ្រោះបឋម**<br>○ ការប្រឈមមុខដោយការរួមភេទតាមមាត់៖ ស្តោះឈាម/សារធាតុរាវនៃរាងកាយចេញក្រៅ ហើយលាងជម្រះជាមួយទឹក ។<br>○ របួស៖ លាងមុខរបួស/លាងស្បែកដែលប៉ះពាល់ជាមួយឈាម/សារធាតុរាវនៃរាងកាយ។<br>○ ភ្នាសស្តើងនៃស្បែក និងភ្នែក៖ ចាក់ទឹកតិចៗ/លាយអំបិល ហើយលាង (យកកញ្ចក់កែវភ្នែកចេញបើសិនជាមាន) ។<br>○ មិនត្រូវចាក់ថ្នាំសម្លាប់មេរោគ ឬចាក់ disinfectants ចូលទៅក្នុងមុខរបួសទេ ។<br>○ មិនត្រូវប្រើទឹកថ្នាំបាញ់លាងទ្វារមាស ឬរន្ធគូថ បន្ទាប់ពីមានការរួមភេទទេ ។<br><br>➢ **ធ្វើតេស្តឈាមរកមេរោគអេដស៍ទាំងអ្នកដែលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ និងប្រភពចម្លង (ប្រសិនជាអាចធ្វើបាន)**<br>○ មិនត្រូវពន្យាពេលចាប់ផ្តើម PEP ក្នុងកំឡុងពេលធ្វើតេស្តឈាមរកមេរោគអេដស៍ យើងអាចចាប់ផ្តើម និងបញ្ឈប់ PEP បើប្រភពចម្លង ត្រូវបានរកឃើញថា មានលទ្ធផលតេស្តឈាមរកមេរោគ |

អេដស៍ អវិជ្ជមាន ឬអ្នកដែលបានប៉ះពាល់ ត្រូវបានរកឃើញថា ផ្ទុកមេរោគអេដស៍ ។

- **វាយតម្លៃហានិភ័យ និងលក្ខណៈវិនិច្ឆ័យក្នុងការទទួលការព្យាបាលដោយ PEP** ដោយផ្អែកលើធម្មជាតិនៃស្ថានភាពដែលមានការប្រឈមមុខ(ការប៉ះពាល់)នៃការឆ្លងមេរោគអេដស៍ និងស្ថានភាពមេរោគអេដស៍នៃប្រភពចម្លង

↓

**២. ការផ្តល់ប្រឹក្សាអំពី កម្រិតនៃការប្រឈមមុខ និងជម្រើសនៃ PEP**

- ពន្យល់ពីការប៉ាន់ស្មានហានិភ័យនៃការចម្លងមេរោគអេដស៍ (សូមអានផ្នែកខាងលើ)
- ពន្យល់ពីហានិភ័យ និងផលប្រយោជន៍នៃ PEP៖
  - PEP កាត់បន្ថយការឆ្លងមេរោគអេដស៍ គួរឱ្យកត់សម្គាល់ ប៉ុន្តែ វាមិនអាចលប់បំបាត់ការប្រឈមមុខនឹងចម្លងមេរោគអេដស៍ បានទាំងស្រុងទេ ។
  - PEP ត្រូវបន្តការព្យាបាលរយៈពេល ២៨ថ្ងៃ ជាបន្តបន្ទាប់ ។
  - ផលប៉ះពាល់នៃឱសថប្រឆាំងមេរោគអេដស៍ ដែលបានជ្រើសរើសយកព្យាបាល PEP ។
- ទទួលបាននូវការយល់ព្រមពីអ្នកជំងឺដោយផ្ទាល់មាត់ (verbal informed consent) មុននឹងចាប់ផ្តើម PEP ។

↓

**៣**. ចាប់ផ្តើម **PEP** ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ក្រោយពីមានការប្រឈមមុខ ដោយ**ចាប់ផ្តើមកម្រិតដូសឱសថប្រឆាំងមេរោគអេដស៍ភ្លាម !** ។

- ពិនិត្យអន្តរកម្មឱសថ ជាមួយថ្នាំផ្សេងទៀតដែលកំពុងប្រើប្រាស់ ។
- ផ្តល់ប្រឹក្សា ដើម្បីឱ្យអ្នកជំងឺលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ និងផ្តល់ព័ត៌មានអំពីឱសថដែលប្រើ ។
- កុំពន្យាពេលចាប់ផ្តើម PEP ខណៈពេលដែលកំពុងប្រមូលព័ត៌មាន ឬ ការបំពេញបែបបទព្យាបាល ។
- រូបមន្តឱសថប្រឆាំងមេរោគអេដស៍ស្តង់ដានៃ PEP :
  - **TDF ៣០០ ម.ក្រ + 3TC ៣០០ម.ក្រ + ATV /r 300/១០០ម.ក្រ លេប១ដង/ថ្ងៃ រយៈពេល ២៨ ថ្ងៃ** ។
  - លេបកម្រិតដូសដំបូងភ្លាមៗ ។
  - ផ្តល់វេជ្ជបញ្ជាលើកដំបូង សម្រាប់រយៈពេល ៤ ថ្ងៃ ។

↓

**៤. វាយតម្លៃ និងការសង្គ្រោះបន្ទាន់នៃការពន្យាកំណើត និងការព្យាបាលជំងឺកាមរោគ ក្នុងបរិបទនៃការរំលោភផ្លូវភេទ ។**

- ការព្យាបាលជំងឺកាមរោគសាកល្បង ជាមួយឱសថ Azithromycin១ក្រាមនិង Cefixime ៤០០ម.ក្រ ។
- ការសង្គ្រោះបន្ទាន់នៃការពន្យាកំណើត និង ការធ្វើតេស្តគិភ នៅពេលដើមគ្រា និងតេស្តតាមដាន ។

↓

**៥. ការវាយតម្លៃកម្រិតប្រឈមមុខនឹងបង្ករោគផ្សេងៗ**

- ការបង្ករោគដោយវីរុសរលាកថ្លើមប្រភេទ B ៖ ហានិភ័យខ្ពស់តាមរយៈការឆ្លងតាមឈាម និងតាមការរួមភេទ ។
- ការបង្ករោគដោយវីរុសរលាកថ្លើមប្រភេទ C ៖ ហានិភ័យខ្ពស់តាមរយៈការឆ្លងតាមឈាម និងតាមការរួមភេទដែលមានដាច់រលាត់ស្បែក ។
- តេតាណូស - បុគ្គលដែលមានរបួស (សត្វខាំ ដាច់រលាត់ ឬមុតដាច់) ត្រូវពិនិត្យវាយតម្លៃពីស្ថានភាពតេតាណូស និងត្រូវផ្តល់ជូនការចាក់ថ្នាំបង្ការជំងឺតេតាណូសផង ។

**៦. ពន្យល់ពីតម្រូវការការព្យាបាលបង្ការលើកទី២**

- វិធានការត្រូវបានប្រតិបត្តិ ដើម្បីចៀសវាងការចម្លងមេរោគអេដស៍លើកទី២ រហូតដល់មានការធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុង ៣ខែទៀត ។
- ការប្រើប្រាស់ស្រោមអនាម័យ ការអនុវត្តន៍ការចាក់ថ្នាំដោយសុវត្ថិភាព និងចៀសវាងការបរិច្ចាគឈាម ។ ហានិភ័យ និងអត្ថប្រយោជន៍នៃការបន្តបំបៅដោះកូន គួរតែត្រូវបានលើកមកពិភាក្សា ។

**៧. ចំពោះករណីរំលោភផ្លូវភេទ/បញ្ជូនទៅទទួលការគាំទ្រផ្នែកចិត្តសាស្ត្រ និងសង្គមសាស្ត្រ[៦៣]**

- សូមអានគោលការណ៍ណែនាំអំពីការគ្រប់គ្រងនិងព្យាបាលជំងឺកាមរោគ របស់ NCHADS ដែលបានរៀបរាប់លម្អិតអំពីការគ្រប់គ្រងព្យាបាលនៃការរំលោភបំពានផ្លូវភេទ[៦៤] ។

**៨. ការបំពេញឯកសារព្យាបាល**

- សូមមើល តារាងទី៥០-១ ទម្រង់នៃការមកពិនិត្យពិគ្រោះជំងឺ និងទម្រង់របាយការណ៍អំពី PEP។

**៩. ការតាមដាន ក្រោយពីបានទទួលការព្យាបាលបង្ការក្រោយពីការប្រឈមមុខក្នុងការឆ្លងរោគ**

- ត្រឡប់មកគ្លីនិកវិញក្នុងកំឡុងពេល ៣ -៤ថ្ងៃ ដើម្បីវាយតម្លៃនៃការលេបថ្នាំបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ និងភាពទ្រាំទ្រជាមួយថ្នាំ និងការពិនិត្យមើលពីលទ្ធផលទាំងអស់ និង អំពី ការព្យាបាលបង្ការក្រោយពីការប្រឈមមុខនឹងការឆ្លងត្រូវបានផ្តល់ជូន ។

---

[៦៣] ឆ្លើយតបទៅនឹង អំពើហិង្សា ដៃគូជិតស្និទ្ធនិង អំពើហិង្សាផ្លូវភេទ ប្រឆាំងនឹងស្ត្រី : គោលការណ៍ណែនាំ និងគោលនយោបាយ របស់ អង្គការសុខភាពពិភពលោក។ ក្រុងហ្សឺណែវ : អង្គការសុខភាពពិភពលោក ឆ្នាំ២០១៣។

[៦៤] គោលការណ៍ណែនាំ ជាតិស្តីពី ការឆ្លងជំងឺ កាមរោគ និងការគ្រប់គ្រង ករណីឆ្លងមេរោគលើផ្លូវបន្តពូជ ។២០១០ម៉ូឌុល៦ ជំពូក៥ ទំព័រ២១២។

- ប្រសិនបើប្រភពចម្លងត្រូវបានបញ្ជាក់ថា មានលទ្ធផលតេស្តមេរោគអេដស៍ អវិជ្ជមាន ត្រូវបញ្ឈប់ ការព្យាបាលបង្ការក្រោយពេលមានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍(PEP) ។
- ត្រូវផ្តល់វេជ្ជបញ្ជា ២៨ថ្ងៃ បន្ថែមទៀត ។

↓

**១០. ការធ្វើតេស្តតាមដាន**

- ធ្វើតេស្តរកមេរោគអេដស៍៣ខែ បន្ទាប់ពីការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ។
- ធ្វើតេស្តរកមេរោគស្វាយនៅខែទី៣ បន្ទាប់ពីមានការរំលោភផ្លូវភេទ ។
- ធ្វើតេស្តរកវីរុសរលាកថ្លើមប្រភេទB និងC នៅខែទី៦ បន្ទាប់ពីការប្រឈមមុខនឹងការឆ្លងរោគនេះ ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ៤៤: តារាងចំណាត់ថ្នាក់គ្លីនិករបស់ អង្គការសុខភាពពិភពលោក

តារាងទី៤៤-១ ប្រព័ន្ធចំណាត់ថ្នាក់ដំណាក់កាលគ្លីនិក នៃជំងឺអេដស៍សម្រាប់មនុស្សពេញវ័យ និងក្មេងជំទង់ ស្របតាម *WHO (≥ ១៥ឆ្នាំ)*

| ដំណាក់កាលគ្លីនិកទី១(Clinical stage ១) |
|---|
| • គ្មានរោគសញ្ញា(Asymptomatic)<br>• ហើមប៉ោងកូនកណ្ដុរពេញខ្លួនជាប់ជាប្រចាំ (Persistent generalized lymphadenopathy) |
| **ដំណាក់កាលគ្លីនិកទី២(Clinical stage 2)** |
| • ស្រកទម្ងន់មិនដឹងមូលហេតុកំរិតមធ្យម (តិចជាង ១០% នៃទម្ងន់ខ្លួន)<br>• បង្ករោគនៅផ្លូវដង្ហើម សារចុះសារឡើង (រលាក sinus, ការរលាកអាមីដាល, រលាកត្រចៀកកណ្ដាល, រលាកបំពង់ក)<br>• ជំងឺរើម (herpeszoster)<br>• Angular cheilitis<br>• Seborrhoeic dermatitis<br>• ដំបៅមាត់ សាចុះសាឡើង<br>• Papular pruritic eruptions (PPE)<br>• ដុះផ្សិតនៅក្រចក ។ |
| **ដំណាក់កាលគ្លីនិកទី៣ (Clinical stage 3)** |
| • ស្រកទម្ងន់មិនដឹងមូលហេតុ កម្រិតធ្ងន់ធ្ងរ លើសពី១០% នៃទម្ងន់ខ្លួន<br>• រាគរូសរ៉ាំរ៉ៃ មិនដឹងមូលហេតុ រយៈពេលលើសពី១ខែ<br>• ផ្សិតក្នុងមាត់ ជាប់ជានិច្ច<br>• Oral hairy leukoplakia<br>• ជំងឺរបេងសួត<br>• បង្ករោគដោយពពួកបាក់តេរីធ្ងន់ធ្ងរ (ឧទាហរណ៍: រលាកសាច់សួត, ខ្ទុះក្នុងសួត (empyema), រលាកស្រោមខួរ(meningitis), រលាកនិងដំបៅសាច់ដុំមានខ្ទុះ (pyomyositis), បង្ករោគនៅឆ្អឹង ឬសន្លាក់, bacteraemia, ជំងឺ pelvic inflammatory ធ្ងន់ធ្ងរ) ។<br>• Acutenecrotizing ulcerative stomatitis, gingivitis or periodontitis<br>• ស្លេកស្លាំងមិនដឹងមូលហេតុ (hb <៨g/dl ), neutropenia (< ០,៥ x ១០៩/l) និង/ឬ chronic thrombocytopenia (< ៥០ x ១០៩/l) ។ |
| **ដំណាក់កាលគ្លីនិកទី៤ (Clinical stage 4)** |
| • រោគសញ្ញាចុះស្គមខ្លាំង បណ្ដាលមកពីការឆ្លងមេរោគអេដស៍ (HIV wasting syndrome)<br>• រលាកសាច់សួតបង្កដោយ Pneumocystis jiroveci<br>• រលាកសាច់សួតធ្ងន់ធ្ងរ បង្កដោយបាក់តេរីសារចុះសារឡើង |

- បង្ករោគដោយ herpes simplex វ៉ាំរ៉ៃ (នៅតាមមាត់, បបូរមាត់  ប្រដាប់បន្តពូជ ឬ តំបន់រន្ធគូថ រយៈពេលលើសពី១ខែ ឬ នៅសរីរាង្គណាមួយក្នុងពោះ)
- ផ្សិតនៅបំពង់អាហារ (ឬ ផ្សិត candidiasis នៅបំពង់ខ្យល់ ទងសួតឬ សួត)
- ជំងឺរបេងក្រៅសួត
- Kaposi sarcoma
- ជំងឺបង្កដោយ Cytomegalovirus (retinitis ឬ បង្ករោគនៅសរីរាងផ្សេងៗ លើកលែងតែ នៅថ្លើម អណ្តើក និងកូនកណ្តុរ)
- Central nervous system toxoplasmosis
- HIV encephalopathy
- Extrapulmonary cryptococcosis including meningitis
- Disseminated non tuberculous mycobacteria infection
- Progressive multifocal leukoencephalopathy
- Chronic cryptosporidiosis
- Chronic isosporiasis
- Disseminated mycosis (histoplasmosis, coccidiomycosis)
- Recurrent septicaemia (including nontyphoidal Salmonella)
- Lymphoma (cerebral or B cell non-Hodgkin)
- Invasive cervical carcinoma
- Atypical disseminated leishmaniasis
- Symptomatic HIV-associated nephropathy or HIV-associated cardiomyopathy

*ប្រភព: Revised WHO clinical staging and immunological classification of HIV and case definition of HIV for surveillance. 2006.*

# ឧបសម្ព័ន្ធ៤៥: ការណែនាំ អំពីការពិគ្រោះជំងឺ

គោលការណ៍ណែនាំខាងក្រោម គឺមានភាពស៊ីសង្វាក់គ្នា ជាមួយទម្រង់សម្រាប់បំពេញព័ត៌មាននៅពេលពិនិត្យពិគ្រោះអ្នកជំងឺលើកដំបូង និងនៅពេលតាមដាន ជាបន្តបន្ទាប់ ។

### តារាងទី៤៥-១ ការណែនាំ អំពីការពិគ្រោះជំងឺលើកដំបូង

| | |
|---|---|
| យោងតាមទម្រង់បញ្ជីផ្ទៀងផ្ទាត់សម្រាប់វាយតម្លៃថ្នាក់ជាតិ និងឯកសារ ។ | • ទម្រង់ថ្នាក់ជាតិ នៃការពិនិត្យជំងឺលើកដំបូង<br>• ទម្រង់ថ្នាក់ជាតិ នៃការពិនិត្យអ្នកជំងឺពេញវ័យ<br>• ទម្រង់នៃការវាយតម្លៃលើកដំបូង អំពីការកំណត់ស្វែងរកដៃអ្នកផ្ទុកមេរោគអេដស៍មកធ្វើតេស្តឈាម (ការផ្តល់ប្រឹក្សា) |
| ចំណុចដែលត្រូវដាក់បញ្ចូលក្នុងទម្រង់ថ្នាក់ជាតិនៃការពិនិត្យជំងឺលើកដំបូង | |
| ប្រវត្តិន៍ជំងឺរបេង<br>ប៉ះពាល់អ្នកជំងឺរបេង<br>ការពិនិត្យស្រាវជ្រាវជំងឺរបេង និងការព្យាបាលបង្ការជំងឺរបេង(IPT) | PHx ជំងឺរបេង *(Drug-sensitive ឬ ស៊ាំជាមួយឱសថ?)*<br>ប៉ះពាល់ករណីជំងឺរបេង នៅពេលថ្មីៗ/បច្ចុប្បន្ន ?<br>ពិនិត្យស្រាវជ្រាវជំងឺរបេង (គ្រុនក្តៅ ក្អក បែកញើសពេលយប់ ស្រកទម្ងន់)<br>បើរោគសញ្ញាណាមួយ វិជ្ជមាន (នៅពេលមកពិនិត្យពិគ្រោះជំងឺពេលណាក៏ដោយ) → ពិនិត្យគ្លីនិក ពិនិត្យកំហាករកមេរោគរបេង៣ដង និងថតសួត<br>បើលទ្ធផលទាំងអស់ អវិជ្ជមាន ធ្វើតេស្ត ALT/AST → ព្យាបាលបង្ការជំងឺរបេងដោយ INH ។ |
| ប្រវត្តិជំងឺផ្សេងទៀត រួមមានៈ ការបង្ករោគរួមគ្នា ជាមួយជំងឺមិនឆ្លង សុខភាពផ្លូវចិត្ត | ពិនិត្យរកវីរុសរលាកថ្លើមប្រភេទB និងC និងជំងឺកាមរោគ សម្ពាធឈាមលើស ជំងឺតម្រងនោម ។ល។ ទោះបីជាអ្នកជំងឺមិនទាន់ទទួលការព្យាបាលក៏ដោយ ។<br>ជំងឺធ្លាក់ទឹកចិត្ត (Depression) ឬ ប្រវត្តិន៍ជំងឺសរសៃប្រសាទផ្សេងទៀត ។ |
| ប្រវត្តិន៍នៃការព្យាបាលដោយ ARV | រួមទាំង ឱសថ ARV ណាមួយដែលធ្លាប់បានព្យាបាលពីមុន, ដោយគិតទាំងការព្យាបាល PEP ផងដែរ ។ |
| ប្រវត្តិន៍នៃការព្យាបាលបង្ការជំងឺឱកាសនិយម | ពិនិត្យមើលពីការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ នៅពេលដែលកំពុង/ធ្លាប់ព្យាបាលបង្ការជំងឺឱកាសនិយម ។ |
| ឱសថ | ប្រើប្រាស់ឱសថ generic drug names ។<br>កាត់ត្រាពីពេលវេលា រយៈពេល ផលប៉ះពាល់ និងការលេបថ្នាំឱ្យបានទៀងទាត់ ត្រឹមត្រូវ និងជាប់លាប់ (adherence)<br>កត់ត្រាពីឱសថបុរាណដែលបានប្រើ<br>ពិនិត្យមើលឱសថ – អន្តរកម្មឱសថ |
| allergies ជាមួយឱសថ | ប្រភេទនៃប្រតិកម្ម (ស្នាមកន្ទួលលើស្បែក គ្រុនក្តៅ ។ល។ |
| សុខភាពបន្តពូជ និងជំងឺកាមរោគ | ពិនិត្យពីប្រវត្តិន៍ជំងឺកាមរោគ និងរោគសញ្ញាកំពុងកើតឡើង<br>សួរអ្នកជំងឺអំពីសុខភាពបន្តពូជ ទាក់ទងនឹងការចង់មានកូន និងមានគម្រោងមានកូន ? |

| | |
|---|---|
| ប្រវត្តិន៍ជំងឺបច្ចុប្បន្ន | បញ្ហាកំពុងកើតឡើង |
| ការប្រើប្រាស់គ្រឿងញៀនកំសាន្ត | ផឹកគ្រឿងស្រវឹង (ញឹកញាប់, ប្រភេទ, បរិមាណ)<br>ជក់បារី<br>គ្រឿងញៀនប្រភេទផ្សេង - រៀបរាប់ឈ្មោះឱសថ និងរបៀបប្រើប្រាស់គ្រឿងញៀនទាំងនោះ តើគ្រឿងញៀនចាក់តាមសរសៃរជាប្រភេទអ្វី ? |
| ការបើកចំហាពីស្ថានភាពមេរោគអេដស៍ | ការបើកចំហាពីស្ថានភាពមេរោគអេដស៍ បច្ចុប្បន្ន ? ផែនការក្នុងបើកចំហ ? |
| ការពិនិត្យជំងឺនៅពេលពិនិត្យពិគ្រោះលើកដំបូង តម្រូវឱ្យធ្វើការពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ | សញ្ញាគ្រោះថ្នាក់ដល់ជីវិត (Vital signs) ទម្ងន់ កម្ពស់→ គណនា BMI[៦៥] បរិវេណចង្កេះ ។<br>ការពិនិត្យ រួមមាន ស្ថានភាពផ្លូវចិត្ត សរសៃរប្រសាទ–កណ្តាល + peripheral, ស្បែក/មាត់ ប្រព័ន្ធសរសៃរឈាមបេះដូង ប្រដាប់ដង្ហើម ពោះ ។ |
| ដំណាក់កាលគ្លីនិកនៃ WHO | ស្រង់ប្រវត្តិទាក់ទងនឹងដំណាក់កាលគ្លីនិកនៃជំងឺអេដស៍ រួមមាន ស្រកទម្ងន់ ការបង្ករោគបច្ចុប្បន្ន ជំងឺ herpes zoster ។ល។ |
| ការពិនិត្យស្រាវជ្រាវ | ការពិនិត្យស្រាវជ្រាវផ្សេងទៀត ទាក់ទងនឹង៖<br>· ការពិនិត្យស្រាវជ្រាវជាប្រចាំ -<br>· ការពិនិត្យស្រាវជ្រាវបន្ត ផ្អែកតាមរោគសញ្ញាគ្លីនិក ។ |
| ការគ្រប់គ្រង -ព័ត៌មាន និងការ ផ្តល់ប្រឹក្សា | ផ្តល់ព័ត៌មានអំពី HIV រួមទាំង ការព្យាបាលបង្ការជំងឺឱកាសនិយម និងការព្យាបាល ART ។<br>ផ្តល់យោបល់អំពី អាហារូបត្ថម្ភ ការប្រើប្រាស់គ្រឿងញៀន និងរបៀបរស់នៅនាំឱ្យមានសុខភាពល្អ ។<br>បញ្ជូលអ្នកជំងឺទៅទទួលការផ្តល់ប្រឹក្សាអំពី ការលេបថ្នាំឱ្យបានត្រឹមត្រូវទៀងទាត់ និងជាប់លាប់ ។<br>ចូលប្រជុំ MMM គាំទ្រផ្លូវចិត្ត ឬ សេវាគាំទ្រផ្សេងៗទៀត ដែលត្រូវការ[៦៦] ។ |
| ការគ្រប់គ្រងព្យាបាល- វេជ្ជសាស្ត្រ | ព្យាបាលជំងឺកំពុងកើតឡើង តាមរោគសញ្ញាគ្លីនិក ។<br>បញ្ជូលអ្នកជំងឺទៅទទួលសេវាវេជ្ជសាស្ត្រផ្សេងៗ ប្រសិនជាចាំ បាច់ ។ |
| ឱសថ | ការព្យាបាលបង្ការជំងឺឱកាសនិយមដំបូង ស្របតាមកម្មវិធី ។ |
| ការតាមដាន | កម្មវិធីណាត់ជួបកំឡុង១ សប្តាហ៍ ។ |

[៦៥] BMI = ទំងន់ (គក្រ) / កំពស់ (ម)$^{២}$

[៦៦] ក្របខ័ណ ប្រតិបត្តិកាសំរាប់ថែទាំបន្តដល់អ្នករស់នៅជាមួយមេរោគអេដស៍ជាមធ្យោបាយសំរាប់ភ្ជាប់ការព្យាបាលទៅនឹងការថែទាំគ្រប់ជ្រុងជ្រោយ។

## តារាងទី៤៥-២ ការណែនាំអំពី ការពិគ្រោះជំងឺលើកទីពីរ និងនៅពេលតាមដានជាបន្តបន្ទាប់

| យោងតាមទម្រង់បញ្ជីផ្ទៀងផ្ទាត់សម្រាប់វាយតម្លៃថ្នាក់ជាតិ និងឯកសារ | • ទម្រង់ថ្នាក់ជាតិការពិនិត្យអ្នកជំងឺពេញវ័យ<br>• បច្ចុប្បន្នភាពព័ត៌មាននៃទម្រង់សម្រាប់អ្នកជំងឺពេញវ័យ |
|---|---|
| ចំណុចដែលត្រូវដាក់បញ្ចូលក្នុងទម្រង់វាយតម្លៃ និងឯកសារ នៃការពិនិត្យជំងឺ | |
| ប្រវត្តិន៍ជំងឺ | រោគសញ្ញាថ្មី ?<br>ពិនិត្យបញ្ហាវេជ្ជសាស្ត្រកំពុងកើតឡើងសកម្ម |
| ការពិនិត្យស្រាវជ្រាវជំងឺរបេង រាល់ពេលពិនិត្យពិគ្រោះជំងឺ បើសិន មានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ ចាប់ព្យាបាលបង្ការជំងឺរបេងដោយ INH នៅសប្តាហ៍ទី ២ ក្រោយពីចាប់ព្យាបាល ដោយ ART ។ | ប៉ះពាល់ករណីជំងឺរបេង នៅពេលថ្មីៗ/បច្ចុប្បន្ន? *(Drug-sensitive ឬ ស៊ាំជាមួយឱសថ?)*<br>ពិនិត្យស្រាវជ្រាវជំងឺរបេង (គ្រុនក្តៅ ក្អក បែកញើសពេលយប់ ស្រកទម្ងន់)<br>បើ រោគសញ្ញាណាមួយ វិជ្ជមាន → ពិនិត្យគ្លីនិក ពិនិត្យកំហាករកមេរោគរបេង៣ដង ដោយតេស្ត AFB និងថតសួត<br>បើលទ្ធផលទាំងអស់ អវិជ្ជមាននិង ALT/AST < ៣ដង x ULN →<br>លក្ខណៈវិនិច្ឆ័យគ្រាប់គ្រាន់ក្នុងការព្យាបាលបង្ការជំងឺរបេងដោយ INH ។ |
| ព្យាបាលបង្ការជំងឺឱកាសនិយម | លេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ផលប៉ះពាល់ |
| ឱសថ ARV | ត្រៀមខ្លួនរួចរាល់ក្នុងការចាប់ផ្តើម ? បើចាប់ផ្តើមព្យាបាលដោយ ARV ត្រូវពិនិត្យមើលពីការលេបឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ និងផលប៉ះពាល់នៃឱសថ ។ |
| សុខភាពបន្តពូជ និងជំងឺកាមរោគ | ពិនិត្យមើលពីស្ថានភាពមានផ្ទៃពោះ និងផែនការនៃការមានគិភ ?<br>ស្រោមអនាម័យ + ប្រើប្រាស់មធ្យោបាយពន្យាកំណើត<br>រោគសញ្ញាជំងឺកាមរោគ ។ |
| សុខភាពផ្លូវចិត្ត | រោគសញ្ញាថ្មី?<br>ពិនិត្យពីបញ្ហាសុខភាពផ្លូវចិត្តកំពុងកើតឡើង ។ |
| ការប្រើប្រាស់គ្រឿងញៀនកំសាន្ត | គាំទ្រការឈប់ជក់បារី និង កាត់បន្ថយហានិភ័យនៃការប្រើប្រាស់គ្រឿងញៀន ។ |
| ការបើកចំហពីស្ថានភាពមេរោគអេដស៍ | ពិនិត្យឡើងវិញ គាំទ្រការបើកចំហពីស្ថានភាពមេរោគអេដស៍ |
| ការពិនិត្យ | សញ្ញាគ្រោះថ្នាក់ដល់ជីវិត (Vital signs) គណនា BMI វាស់បរិវេណចង្កេះ សង្កេតការផ្លាស់ប្តូរស្ថានភាពផ្លូវចិត្ត + សភាពរាង្គកាយ<br>ពិនិត្យដោយផ្តោតលើរោគសញ្ញាកំពុងកើតឡើង សង្កេតពេលពិនិត្យពិគ្រោះជំងឺ រកឃើញរោគសញ្ញាថ្មី និង ពិនិត្យលទ្ធផល តេស្ត ។ |
| ការពិនិត្យស្រាវជ្រាវឱសថ | តាមដានលទ្ធផលតេស្ត ជាប្រចាំ និងរោគសញ្ញាគ្លីនិកដែលចង្អុលបង្ហាញពីការពិនិត្យស្រាវជ្រាវ ។<br>ពិនិត្យបន្ថែមទៀត ពិនិត្យស្រាវជ្រាវ ស្របតាមរោគសញ្ញាគ្លីនិក ។ |
| | បច្ចុប្បន្នភាពតារាងបញ្ជីឱសថ |

| | |
|---|---|
| | ពិនិត្យឡើងវិញអំពី ផលប៉ះពាល់ និង ការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ។<br>ពិនិត្យឱសថ –កម្រិតដូសឱសថ និងអន្តរកម្មឱសថ ។ |
| allergies ជាមួយឱសថ | ធ្វើបច្ចុប្បន្នភាព |
| ដំណាក់កាលគ្លីនិកនៃ WHO | វាយតម្លៃដំណាក់កាលគ្លីនិកនៃ WHO → កែតម្រូវដំណាក់កាលគ្លីនិក/កាន់តែធ្ងន់ធ្ងរ ប្រសិនជា ចាំបាច់ ។ |
| ការគ្រប់គ្រង -ព័ត៌មាន និង ការផ្តល់ប្រឹក្សា | ពង្រឹងព័ត៌មាន អំពីការព្យាបាលបង្ការជំងឺឱកាសនិយម និងការព្យាបាល ART ។<br>ផ្តល់យោបល់អំពី អាហារូបត្ថម្ភ ការប្រើប្រាស់គ្រឿងញៀន និងរបៀបរស់នៅនាំឱ្យមានសុខភាពល្អ ។<br>បញ្ជូលអ្នកជំងឺទៅទទួលការផ្តល់ប្រឹក្សាអំពី ការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ។<br>ចូលប្រជុំ MMM គាំទ្រផ្លូវចិត្ត ឬ សេវាគាំទ្រផ្សេងៗទៀត ដែលត្រូវការ ។ |
| ការគ្រប់គ្រងព្យាបាល-វេជ្ជសាស្ត្រ | ព្យាបាលជំងឺកំពុងកើតឡើង តាមរោគសញ្ញាគ្លីនិក ។<br>ចាប់ផ្តើម/បញ្ឈប់ព្យាបាលបង្ការជំងឺឱកាសនិយម ស្របតាមកម្មវិធី ។<br>ចាប់ផ្តើម/ផែនការ/បន្តការព្យាបាលដោយ ART ។<br>បញ្ជូលអ្នកជំងឺទៅទទួលសេវាវេជ្ជសាស្ត្រផ្សេងៗ ប្រសិនជាចាំបាច់ ។ |
| ការតាមដាន (Follow up) | បើការពិនិត្យពិគ្រោះជំងឺលើកទី២– តាមដាន ១ សប្តាហ៍សម្រាប់ការព្យាបាលដោយ ART ។<br>បើចាប់ផ្តើម ART នៅពេលមកពិនិត្យពិគ្រោះជំងឺលើកនេះ– ត្រូវតាមដានក្នុងរយៈពេល ២សប្តាហ៍ ។<br>បើស្ថានភាពសុខភាពអ្នកជំងឺមានលំនឹង–តាមដានពី១ –៣ ខែ (អាស្រ័យតាមករណី អ្នកជំងឺព្យាបាលបង្ការដោយ INH) ។ |

# ឧបសម្ព័ន្ធ៤៦ ជំងឺរបេង: រូបភាពនៃជំងឺរបេង/អេដស៍

រូបភាពខាងក្រោមនេះ ត្រូវបានចម្លងពី គោលការណ៍ណែនាំជាតិ នៃជំងឺរបេង/អេដស៍[៦៧]

**រូបភាពទី៤៦-១ គំនូសបំព្រួញទី១៖ ការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលជំងឺរបេង ក្នុងចំណោមអ្នកជំងឺអេដស៍**

**គំនូសបំព្រួញទី១៖ ការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលជំងឺរបេងក្នុងចំណោមអ្នកជំងឺអេដស៍**




[៦៧] ព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាល ។ គោលការណ៍ណែនាំ គ្លីនិក ជាតិសំរាប់គ្រប់គ្រង ការឆ្លងរួមគ្នាជំងឺរបេង / មេរោគអេដស៍។ ភាសាអង់គ្លេស ឆ្នាំ ២០០៨, ខ្មែរ ឆ្នាំ ២០១៣។រកបាន http://www.cenat.gov.kh/km/documents/guidelines-and-sops

សំគាល់៖

a. ប្រើឱសថ Amoxciline, Amoxiciline + Clavulanic Acid, ឬ Cefuroxime ។
b. សញ្ញាគ្រោះថ្នាក់ រួមមាន លេចចេញរោគសញ្ញាមួយក្នុងចំណោមរោគសញ្ញាទាំងអស់នេះ៖ ចង្វាក់ដង្ហើម > ៣០ដង/នាទី, គ្រុនក្តៅ > ៣៩អង្សាសេ, សង្វាក់ជីពចរ > ១២០ដង/នាទី, មិនអាចដើរបានដោយខ្លួនឯង ។
c. AFB វិជ្ជមាន កំណត់ដោយ យ៉ាងតិចមានតេស្តមួយ វិជ្ជមាន រីឯ AFB អវិជ្ជមាន កំណត់ដោយតេស្ត ពិនិត្យកំហាក អវិជ្ជមាន ២ ឬ ៣ឡើងទៅ។
d. បើអ្នកជំងឺធ្លាប់ព្យាបាលជំងឺរបេង ឬកំពុងព្យាបាលជំងឺរបេងដល់ខែទី៥ ត្រូវសង្ស័យពីភាពស៊ាំ និងត្រូវបណ្តុះមេរោគ ( MTB) ។
e. ត្រូវពិចារណាប្រើ Erythromycine ឬ Doxycycline ព្យាបាល atypical bacteria ។ ចៀសវាងប្រើ Fluoroquinolones ដើម្បីបង្ការភាពស៊ាំជាមួយថ្នាំរបេង ។

## រូបភាពទី៤៦-២ គំនូសបំព្រួញទី២៖ ការធ្វើរោគវិនិច្ឆ័យជំងឺរបេង លើអ្នកជំងឺអេដស៍ធ្ងន់ធ្ងរ

### គំនូសបំព្រួញទី២៖ ការធ្វើរោគវិនិច្ឆ័យនៃជំងឺរបេង លើអ្នកជំងឺអេដស៍ធ្ងន់ធ្ងរ




សំគាល់៖

a. សញ្ញាគ្រោះថ្នាក់រួមមាន លេចចេញរោគសញ្ញាណាមួយក្នុងចំណោមរោគសញ្ញាទាំងនេះ៖ ចង្វាក់ដង្ហើម>៣០ដង/នាទី, គ្រុនក្តៅ> ៣៩ អង្សាសេ, សង្វាក់ជីពចរ> ១២០ដង/នាទី, មិនអាចដើរបានដោយខ្លួនឯង។

b. ប្រើឱសថ Amoxicilin, Amoxiciline + Clavulanic Acid, ឬ Cefuroxime + Erythromycine ឬ Doxycicline ដើម្បីព្យាបាល ទាំងពពួកបាក់តេរី typical និង atypical ។ ដើម្បីបង្ការភាពស៊ាំជាមួយឱសថប្រឆាំងមេរោគរបេង មិនត្រូវ *ប្រើ Fluoroquinolones ទេ ។*

c. AFB វិជ្ជមានត្រូវកំណត់ដោយ យ៉ាងតិចមានតេស្តពិនិត្យមួយ វិជ្ជមាន ចំណែកឯ AFB អវិជ្ជមាន ត្រូវកំណត់ដោយ តេស្តពិនិត្យកំហាក អវិជ្ជមាន ២ ឬ ៣ឡើងទៅ ។

រូបភាពទី៤៦-៣ គំនូសបំព្រួញទី៣៖ ការគ្រប់គ្រងគ្លីនិកនៃការហើមប៉ោងកូនកណ្តុរលើអ្នកជំងឺអេដស៍
គំនូសបំព្រួញទី៣៖ ការគ្រប់គ្រងគ្លីនិកនៃការហើមប៉ោងកូនកណ្តុរលើអ្នកជំងឺអេដស៍




## សំគាល់៖

a.អ្នកជំងឺដែលព្យាបាលដោយART អាចឡើងកូនកណ្តុរក្នុងករណីមានការស្តារប្រព័ន្ធភាពស៊ាំឡើងវិញ(IRIS) ជាពិសេស កើតឡើងជំងឺរបេង និងជំងឺ MAC ហើយក៏អាចលេចឡើងជំងឺ Penicilliosis, ជំងឺ Cryptococcosis និង ជំងឺមហារីក ។ ត្រូវចាប់ផ្តើមព្យាបាលជំងឺឱកាសនិយម បើមិនទាន់ព្យាបាល ។ ត្រូវបន្តព្យាបាលដោយ ART ការប្រើ Steroids (Prednisone ១mg/kg/ថ្ងៃ) អាចជួយសម្រាល ក្នុងករណី IRIS ធ្ងន់ធ្ងរ និងអាចប្រើកម្រិតដូសពេញលេញ ១-២សប្តាហ៍ បន្ទាប់មក taper លើសពី ១-២ សប្តាហ៍ ។

b. បូមទឹកកូនកណ្តុរដោយប្រើម្ជុលធំ(ម្ជុលលេខ១៨ G) និងបញ្ជូលសំណាកទៅពិនិត្យ AFB, ពិនិត្យ Gram Stains និងKOH។

c. បើលទ្ធផលនៃការពិនិត្យAFB ទឹកបូមពីកូនកណ្តុរ អវិជ្ជមាន ត្រូវច្រិបយកកូនកណ្តុរ (បើអាចធ្វើបាន) ទៅវិភាគជាលិកា (histology) វិភាគកោសិកា(cytology) និង ពិនិត្យ AFB លើកំហាក ។

រូបភាពទី៤៦-៤ គំនូសបំព្រួញទី៤៖ ការគ្រប់គ្រងការហើមប៉ោងកូនកណ្តុរនៅពោះ

គំនូសបំព្រួញទី៤៖ ការគ្រប់គ្រងការហើមប៉ោងកូនកណ្តុរនៅពោះ




សំគាល់៖

* ជម្រើសនៃព្យាបាលដោយ Antibiotics សំដៅទៅការព្យាបាលប្រឆាំងពពួកបាក់តេរីដែលអាចជាមូលហេតុនៃ ការឡើងកូនកណ្តុរនៅពោះ ដូចជា Salmonella, Campylobacter, E.Coli ។ល។ ចៀសវាងប្រើ Antibiotics ប្រឆាំងជំងឺរបេង ។

## រូបភាពទី៤៦-៥ គំនូសបំព្រួញទី៥៖ ការគ្រប់គ្រងព្យាបាលទឹកក្នុងស្រោមសួត ចំពោះអ្នកជំងឺអេដស៍

## គំនូសបំព្រួញទី៥៖ ការគ្រប់គ្រងព្យាបាលទឹកក្នុងស្រោមសួតចំពោះអ្នកជំងឺអេដស៍

ថតសួត៖ ទឹកក្នុងស្រោមសួត (pleural effusion)

→ ពិនិត្យ AFB លើកំហាក បើមានក្អក (សូមមើលគំនូសបំព្រួញពីមុន)

- ទឹកក្នុងស្រោមសួតតែម្ខាង
- ទឹកស្រោមសួតមានលក្ខណៈ៖
  - ថ្លា ពណ៌ straw និង
  - កំណកឈាមក្នុងបំពង់ទីប ដែលបូម ករណីមិនប្រើ anticoagulants
- ស្រកទម្ងន់ បែកញើសពេលយប់ គ្រុនក្តៅ
- ហេតុផល ប្រវត្តិជំងឺរបេង។

→ ចាប់ផ្តើមព្យាបាល របេង

- ទឹកស្រោមសួតសងខាង (អាចខ្សោយបេះដូង ឬ ជំងឺរលាកសួត (pneumonia)
- មហារីក
- ទឹកស្រោមសួត មានលក្ខណៈ៖
  - ដូចពពក/ខ្ទុះ(empyema)→ Chest tube, បង្ហូរខ្ទុះដោយលាយ antibiotics។
  - បរាជ័យមិនបង្កជាកំណកឈាម (មិនអាចដាត់ចេញពីជំងឺរបេងទេ ត្រូវបញ្ជូនទឹកស្រោមសួតទៅពិនិត្យប្រូតេអ៊ីន និងរាប់ចំនួនកោសិកាផ្សេងៗ និងពិចារណាអំពី ជំងឺខ្សោយបេះដូង

→

- បញ្ជូនទឹកបូមពីស្រោមសួតទៅពិនិត្យរាប់ចំនួនកោសិកាផ្សេងៗ ប្រូតេអ៊ីន តេស្តAFB ប្រសិនជាអាចធ្វើបាន តេស្តcytology: ≥ ៥0% lymphocytes និង protein > ៣0ក្រ/ល នាំឱ្យគិតដល់ ជំងឺរបេង
- ព្យាបាលជំងឺរបេងដោយមិនគិតពីកំណកឈាមពេលបូមទឹកស្រោមសួត ឬ ធ្វើរោគវិនិច្ឆ័យជំងឺផ្សេងក្នុងកំឡុងពេល៧ថ្ងៃ ។

## រូបភាពទី៤៦-៦ គំនូសបំព្រួញទី៦៖ ការគ្រប់គ្រងព្យាបាលទឹកក្នុងស្រោមបេះដូងលើអ្នកជំងឺអេដស៍

## គំនូសបំព្រួញទី៦៖ ការគ្រប់គ្រងព្យាបាលទឹកក្នុងស្រោមបេះដូងចំពោះអ្នកជំងឺអេដស៍

- ស្រកទម្ងន់ បែកញើសពេលយប់ គ្រុនក្តៅ
- ឈឺចាប់ក្រោយឆ្អឹងសន្ទះទ្រូង ដកដង្ហើមខ្លី លឺស្វរកកិតគ្នា (friction rub)។

↓

ថតសួត
ធ្វើ ECG និង Echocardiogram បើអាចធ្វើបាន

→ ពិនិត្យ AFB លើកំហាក បើមានក្អក

↓

- ថតសួត៖ បេះដូងមាន globular ធំ, សួតថ្លា ឬ ទឹកក្នុងស្រោមសួត
-ធ្វើ ECG៖ បេះដូងដើរលឿន ប្រែប្រួលរលក ST និងT, low voltage QRS ។
-Echocardiogram៖ ទឹកក្នុងស្រោមបេះដូង

↓

- ចាប់ផ្តើមព្យាបាលជំងឺរបេង និង steroid[a]
- បញ្ជូលទៅសង្គ្រោះបន្ទាន់ pericardiocenthesis ប្រសិនបើអ្នកជំងឺបាត់ដង្ហើម/មិនស្រួលក្នុងខ្លួន ជាមួយរោគសញ្ញា hemodynamic ។

↓

- Streaky shadowing of lung fields និង/ឬ heart shape not symmetrical (ប្រហែលជាខ្សោយបេះដូង)
- សម្ពាធឈាមឡើងខ្ពស់
